រឿង

# ផ្កាយរង្វៃងមេឃ

និពន្ធ គូរគំនូរ និងរចនាក្របដោយ
អ្នកស្រី កែវ ចន្ទ័បូរណ៍

P.O.Box 600279
Saint Paul, MN 55119
USA
khmervissal@yahoo.com
www.angkorwat.com

CHANBOKEO.COM

បោះពុម្ពលើកទី៤
ខែកញ្ញា ២០០៦
រក្សាសិទ្ធិគ្រប់យ៉ាង

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៌

| | |
|---|---|
| ១- រឿង សំនៀងស្នេហ៍កវី | ២- រឿង និស្ស័យស្នេហ៍ |
| ៣- រឿង ផ្កាយវង្វេងមេឃ | ៤- រឿង ស្នាមញញឹម |
| ៥- រឿង កុលាបស្មឹងខៀវ | ៦- រឿង ក្លិនផ្កាមាលតី |
| ៧- រឿង លិខិតមរតកសម្ងាត់ | ៨- រឿង បំណុលជីវិត |
| ៩- រឿង ចរណៃដួងទ័យា | ១០- រឿង អំបែងអណ្តែត |
| ១១- រឿង ស្នែ្ហកចាកផុតទៅ | ១២- រឿង តន្ត្រីបេះដូង |
| ១៣- រឿង សារាណីយមាតា | ១៤- រឿង ទារុណដួងចិត្ត |
| ១៥- រឿង បើសិននៅមានថ្ងៃស្នែ្ហក | ១៦- រឿង លំអងផ្កាស្នេហ៍ |
| ១៧- រឿង ត្រៃមិត្ររតននារី | ១៨- រឿង ខ្មើយវាសនា |
| ១៩- រឿង បើសិនអាចបង្វិលផែនដី | ២០- រឿង សីវបុរេកាល |
| ២១- រឿង មេឃដ៏សក្តិសិទ្ធិ | ២២- រឿង មួយពាន់ទំព័រ |
| ២៣- រឿង អាមេរិកដែនដីមាស | ២៤- រឿង អាធ្រាតថ្ងៃរះ |
| ២៥- រឿង បក្សីសួនសុបិន | ២៦- រឿង ម្លប់អសោក |
| ២៧- រឿង ពិជេដ្ឋភានុមា | ២៨- រឿង ផ្ការីកក្រៅសួន |
| ២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ | ៣០- រឿង អនង្គលាភា |
| ៣១- រឿង ពណ្ណរាយពេជ្រ | ៣២- រឿង សារិកា |
| ៣៣- រឿង ផ្ការាជបឹងរាំង | ៣៤- រឿង នភាមណី |
| ៣៥- រឿង ស្រីនាថភ្លួងមាលា | ៣៦- រឿង វាយោដួងចិត្ត |

ISBN: 99950-79-03-8

9 789995 079031

CHANBOKEO.COM

## សូមឧទ្ទិសចំពោះ

- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី **សុវណ្ណធី ធម្មិកា បារមីបុណ្យ** ជាបុត្រីទោល
- លោកឪពុក ប៊ុនថង និង អ្នកម្តាយ កែវយឿង
- លោកឪពុកក្មេក មេង សួង និងអ្នកម្តាយក្មេក កូវសារ៉ាន់
- សាស្ត្រាចារ្យ លីតាយហុង សាស្ត្រាចារ្យមៀច សុខារី អ្នកគ្រូទូចសារៀង
  សាស្ត្រាចារ្យរេន រស់ អ្នកគ្រូកែវ សុផុន
- លោក ខូតារាឫទ្ធិ នាយកកម្មវិធីអក្សរសិល្បិ៍នូហាច
- អ្នកស្រីពេជ្រសង្វាររ៉ាន វិទ្យុបារាំងអន្តរជាតិ
- អ្នកស្រីនៅសារិម វិទ្យុសម្លេងសហរដ្ឋអាមេរិក វីអូអេ
- បណ្ឌិត ឃូ គិមទូយ
- លោកជាសយនា លោកអ៊ិមសុនាថ លោកជិនសាវិន កាសែតកោះសន្តិភាព





អ្នកស្រី កែវ ច័ន្ទបូរណ៍

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

khmervissal@yahoo.com

www.angkorwat.com

# វាចាអ្នកនិពន្ធ

នាងខ្ញុំអ្នកនិពន្ធបានបោះពុម្ពរឿង ផ្កាយវង្វេងមេឃ  នេះជាលើកដំបូង បង្អស់ នៅកម្ពុជា នាខែកញ្ញា ឆ្នាំ២០០៥ ហើយបានដាក់លក់ដុំនិងលក់រាយទូទាំង ប្រទេសខ្មែរផង នៅផ្សារឥន្ទ្រីណិត internet របស់ www.angkorwat.com និង www.khmerbusiness.com ផង និងនៅតាមផ្សារមួយចំនួននៅសហរដ្ឋអាមេរិក ផង ។ ដោយគាំទ្រយ៉ាងពេញទំហឹងពីមជ្ឈដ្ឋានអ្នកអាន ទាំងនៅកម្ពុជា ទាំងនៅ បរទេស រឿងផ្កាយវង្វេងមេឃនេះបានត្រូវបោះពុម្ពចេញផ្សាយជាច្រើនដងច្រើន សា ក្នុងរវាង១២ខែកន្លងមក ហើយអ្នកនិពន្ធខ្ញុំក៏សំរេចចិត្តគួរគំនូរនិងរចនាក្រប សំរាប់រឿងនេះផ្សេងៗគ្នាដែរ នៅរៀងរាល់លើកដែល នាងខ្ញុំត្រូវបោះពុម្ពសៀវភៅ នេះបន្ថែមទៀត ។

នាងខ្ញុំអ្នកនិពន្ធមានមោទនភាពខ្ពង់ខ្ពស់ក្រៃលែងដែលប្រិយមិត្តអ្នកអានទាំង ឡាយបានជួយគាំទ្រជ្រោមជ្រែងស្នាដៃរបស់នាងខ្ញុំយ៉ាងពេញទំហឹង ហើយសូម ថ្លែងអំណរគុណជាអតិបរមា ចំពោះប្រិយមិត្តអ្នកអានដែលឆ្លៀតពេលដ៏មានតម្លៃ ដើម្បីសរសេរសំបុត្រឬទាំងទូរសព្ទ័មកលើកកម្លាំងចិត្តដល់នាងខ្ញុំផ្ទាល់ មកពីស្រុក ខ្មែរ ឬមកពីប្រទេសនានា រួមទាំងបងប្អូនដែលនៅសហរដ្ឋផង ។

នាងខ្ញុំសូមប្រសិទ្ធិពរជ័យដល់ប្រិយមិត្តអ្នកអានទាំងអស់ សូមអោយបាន ជួបតែវឌ្ឍនសុខ និងសុវត្ថិភាពរាល់ទិវារាត្រី ជានិរន្តន៍ ។

អ្នកនិពន្ធ

អ្នកស្រី កែវ ចន្ទ័បូរណ៍

រដ្ឋមិនីសូតាសហរដ្ឋអាមេរិក

ខែកញ្ញា ២០០៦

CHANBOKEO . COM

# តារាងនាមចំរៀង កំណាព្យ និងកំរងកែវ
# នៅក្នុងរឿងផ្កាយវង្វេងមេឃ


| | | |
|---|---|---|
| ១. | ចិត្តស្នេហ៍ផ្ញើចន្ទ័ | ទំព័រ១២ |
| ២. | មន្តស្នេហ៍កែវនេត្រា | ទំព័រ៣២ |
| ៣. | បេះដូងមានសង្ឃឹម | ទំព័រ៤៤ |
| ៤. | សង្វេគ | ទំព័រ៥២ |
| ៥. | មហោរីខេមរា | ទំព័រ៦៤ |
| ៦. | អនុភាពផ្កាយព្រះចន្ទ័ | ទំព័រ៦៤ |
| ៧. | សូមអភ័យ | ទំព័រ ៧៥ |
| ៨. | ជូតទឹកភ្នែកជូនស្រី | ទំព័រ៩១ |
| ៩. | ផ្ញើជីវិតក្នុងដៃអូន | ទំព័រ៩៦ |
| ១០. | ផ្កាដុះវាលស្រែ | ទំព័រ១០៧ |
| ១១. | រាត្រីស្នេហ៍ | ទំព័រ១១៦ |
| ១២. | ចំរៀងគ្រួសារយើង | ទំព័រ១១៧ |
| ១៣. | ដើម្បីថ្ងៃស្អែក | ទំព័រ១២៥ |
| ១៤. | ឃ្លោកលិចអំបែងអណ្តែត | ទំព័រ១២៩ |
| ១៥. | ម្តេចគ្មានពាក្យថាលា | ទំព័រ១៣៤ |
| ១៦. | នាវាលាច្រាំង | ទំព័រ១៣៥ |
| ១៧. | ពិភពអន្ធការ | ទំព័រ១៤០ |
| ១៨. | មេអំបៅ | ទំព័រ១៤៦ |
| ១៩. | ម៉ែអើយ | ទំព័រ១៥១ |
| ២០. | ម្តេចដាច់មេត្តា | ទំព័រ១៥៧ |
| ២១. | ផ្កាយវង្វេងមេឃ | ទំព័រ១៦៨ |
| ២២. | បើសិនលោកនេះគ្មានរូបអូន | ទំព័រ១៧២ |
| ២៣. | ផ្កាយអម្រិតផ្តិតមេឃស្នេហ៍ | ទំព័រ១៩៩ |


CHANBOKEO . COM

# សង្ខេបរឿង

នៅក្នុងការសម្ភាសន៍តារាឯកបីដួងប្រចាំឆ្នាំ ខាងផ្នែកបទភ្លេង ផ្នែកចំរៀង និងផ្នែករាំ សិចស៊ី មានព្រឹត្តការណ៍គួរអោយចាប់អារម្មណ៍បានឧប្បត្តិកឡើងនៅក្នុងសាលសម្ភាសន៍ដែល មានទស្សនិកជនកុះករចូលមករង់ចាំស្តាប់ ។ តារាឯកបុរសផ្នែកបទភ្លេងឈ្មោះសុជាតិបាន ងើប ប្រកាសរកម្ចាស់បេះដូងរបស់គេ តាមរយៈការសម្ភាសន៍ជាមួយកម្មវិធីនារាត្រីនោះ ស្រាប់តែនារីសោភាមួយរូបឈ្មោះឈូក លេចខ្លួនផ្លោឡើងមកលើវេទិកាប្រកាសខ្លួនថាជាគូ ស្នេហ៍របស់តារានោះ ។ ដោយចៃដន្យ លោកឧត្តមសេនិយសម្បត្តិនិងភរិយាក៏ចេញមុខមក ដែរ ហើយប្រកាសថាលោកត្រូវជាឪពុកម្តាយបង្កើតរបស់ឈូក ក្នុងឱកាសដែលឈូកកំពុង ក្រាបសំពះស្រ្តីពិការភ្នែកមកពីជនបទម្នាក់ហៅគាត់ថាម៉ែៗពេញមាត់ ។ ព្រមជាមួយគ្នានេះ ដែរ កុមារីសុធាដែលនារីឈ្មោះឈូកទាមទារថាជាកូនស្រីបង្កើតរបស់នាង តែបែរជាត្រូវ លោកសម្បត្តិចោទថាជាកូនស្រីរបស់តារាពោះម៉ាយឈ្មោះសុជាតិទៅវិញ ។ នៅពេលនោះ ឈូកក៏ជាប្រកាសថា បុរសដែលជាឪពុកបង្កើតរបស់សុធាជាមនុស្សផ្សេងទៀត ។ ចៃដន្យ លោកវិសាលដែលត្រូវជាពិធីករប្រចាំរាត្រីនោះ ក៏ធ្លាប់ជាគូស្នេហ៍និងជាគូដណ្តឹងរបស់ឈូក ដែរហើយសព្វថ្ងៃលោកក៏កំពុងតែរលាកបេះដូង ដោយសារភ្លើងស្នេហាបីមុំជាមួយធិតាដ៏ ស្រស់ប្រិមប្រិយមួយរូបផ្សេងទៀត ធ្វើអោយសាច់រឿងជីវិតរិតតែសាំញ៉ាំឡើង ។  ទោះបីជា យ៉ាងណាក៏ដោយ ក៏គូស្នេហ៍ទាំងទ្វេ សុជាតិនិងឈូក នៅតែចាប់ដៃគ្នាឥតរបេះប្តូរពុះពារ ប្រឆាំងនូវពាក្យចោទប្រកាន់ទាំងឡាយនោះ ហើយក៏ងើបមកបំភ្លឺសាច់រឿងជីវិតរបស់គេ ទាំងពីរនាក់អោយទស្សនិកជនបានជ្រាប ដើម្បីនឹងជួយកាត់ក្តីផ្តល់យុត្តិធមិដល់ពួកគេដែល ត្រូវឧបសគ្គរារាំងបំបែកឱ្យឃ្លាតគ្នាអស់ជាច្រើនឆ្នាំ....

សូមប្រិយមិត្តអ្នកអានអញ្ជើញតាមដានសាច់រឿងជាមួយអ្នកនិពន្ធយើងដូចតទៅ...

CHANBOKEO.COM

# វគ្គទីមួយ
# បេះដូងវង្វេងម្ចាស់

ជិតដល់ម៉ោង៧កន្លះហើយ លោកវិសាលដែលជាពិធីករ និងជាប្រធាននៃគណៈកម្មការចាត់ចែងការសម្ភាសន៍នារាត្រីនេះ នៅតែមិនទាន់អញ្ជើញមកដល់សាល សម្ភាសន៍នៅឡើយ ម្យ៉ាងទៀត លោកក៏មិនឆ្លើយទូរសព្ទ័ដៃរបស់លោកដែរ មិន ដឹងថាមានរឿងអ្វីទេ។ ប្រិយមិត្តទស្សនិកជនជាច្រើនបានមកដល់អង្គុយពេញរោង ត្រៀបត្រារង់ចាំមើលការសម្ភាសន៍ផ្សាយបន្តផ្ទាល់តាមទូរទស្សន៍ របស់តារាទាំងបីដួង។ ម្នាក់ៗដែលជាការីរួមនៅក្នុងកម្មវិធីសម្ភាសន៍មានចិត្តកន្ទុះរាណាស់ ត្បិត មិនដឹងថាត្រូវធ្វើយ៉ាងម៉េចតទៅទៀត។ រំពេចនោះ អ្នកស្រីនិសាដែលជានាយករង ក្នុងកម្មវិធីក៏ត្រូវគណៈកម្មការសំរេចជ្រើសរើសមកជំនួសលោកវិសាល ។ រីឯតារា សំខាន់ៗទាំងបីរូបក៏បានមកដល់ ហើយត្រៀមខ្លួនរួចជាស្រេច  ដើម្បីទទួលវេន បង្ហាញខ្លួននៅចំពោះមុខកញ្ចក់ទូរទស្សន៍ជូនប្រិយមិត្តទាំងឡាយ ។

កម្មវិធីចាប់ផ្តើមហើយ....

លោកវិសាលនៅតែមិនទាន់មកដល់ដដែល ដូច្នេះអ្នកស្រីនិសាក៏ចេញបង្ហាញ ខ្លួនចាប់បើកកម្មវិធី ដោយមានបង្ហាញវត្តមានបុរសមួយរូបនិងនារីសោភាពីររូប ទៀតដែលអង្គុយទន្ទឹមគ្នា នៅក្នុងកៅអីសាលុងដ៏ស្អាតទាំងបីនាក់។ ភ្លាមនោះ អ្នកស្រីនិសាផ្តើមប្រសាសន៍ថា :

- សួស្តីប្រិយមិត្តទាំងឡាយ! ជំរាបសួរតារាកត្តិយសទាំងបី! សូមតារាអញ្ជើញ ណែនាំខ្លួនផ្ទាល់និង ទេពកោសល្យអាជីពជូនប្រិយមិត្តជាទីសណ្តាប់ផងចាស!

ភ្លាមនោះនារីដ៏សោភាមួយរូបស្លៀកពាក់របៀបសិចស៊ីស៊ីវិល័យបែបថ្មី ក៏វាចា ឡើងមុនគេបង្អស់ថា :

- ចាស! នាងខ្ញុំឈ្មោះម្លិះរួត ជាតារាសិចស៊ីប្រចាំផលិតកម្មការាអូខេ ហើយក៏ ធ្លាប់បានសំដែងនៅលើវេទិកាចំពោះមុខទស្សនិកជនផ្ទាល់ជាច្រើនរួចមកហើយ ។

នារីទីពីរមានសំលៀកទំនងរបៀបប្រពៃណីបូកពាសុភាព មិនសូវឆើតឆាយ តែបើគន់មើលយូរទៅ គឺមានរូបសោភណ័គួរចាប់អារម្មណ៏បំផុត ។ មាណវីក៏ លំអោនកាយគោរពភ្ញៀវហើយក៏បន្លឺវាចាថា :

- នាងខ្ញុំវិញឈ្មោះសុខា ជាអ្នកចំរៀងជំនាន់ថ្មី ថតតែសំលេងច្រៀងសំរាប់ខ្សែ ភាពយន្តនិងចំរៀងការាអូខេ តែមិនដែលបានបង្ហាញខ្លួនផ្ទាល់ជូនប្រិយមិត្តទាំង ឡាយនៅឡើយទេ ។ ថ្ងៃនេះគឺជាលើកទីមួយហើយ ដែលនាងខ្ញុំបានមកជួបផ្ទាល់ ជាមួយមិត្តទស្សនិកជនយើង។

ឮដូច្នោះអ្នកស្រីនិសាក៏មានប្រសាសន៍សួរបន្ថែមថា :

- មើលទៅរូបសម្បតិរបស់អ្នកនាងក៏មានសោភណ័សម្ផស្សយ៉ាងស្រស់បំព្រង ប៉ុន្តែ

CHANBOKEO.COM

តើហេតុអ្វីទៅ ដែលអ្នកនាងមិនចូលចិត្តបង្ហាញខ្លួននៅលើវេទិកា ជួបនឹងភ្ញៀវ ទស្សនិកជនទៅវិញ?

- ចាស! ត្បិតនាងខ្ញុំពិការជើង មិនអាចសំដែងនៅលើឆាកបាន ទើបបានជាលោក ចាងហ្វាងផលិតកម្មជ្រើសរើសយកកញ្ញាម្លិះរួតមកសំដែងបទដែលនាងខ្ញុំច្រៀងជា ជំនួសវិញ ឃើញថាយើងទាំងពីរមានថ្វីដៃស៊ីខ្សែចង្វាក់គ្នាណាស់ ។

អ្នកស្រីនិសាក៏បែរទៅសម្ភាសតារាទីបីដែលអង្គុយស្ងៀមស្ងាត់យូរហើយ :

- សូមអញ្ជើញតារាផ្នែកបុរសម្តង តើលោកអាចណែនាំជូនប្រិយមិត្តរបស់យើង អំពីនាមរបស់លោកនិងប្រវត្តិខ្លះៗដែលបណ្តាលអោយលោកក្លាយជាតារាល្បីទាំង នៅវ័យក្មេងយ៉ាងនេះបានទេ ចាស?

- បាទ! ខ្ញុំបាទមានឈ្មោះ សុជាតិ ជាបងប្រុសបង្កើតរបស់កញ្ញាសុខា មាន ស្រុកកំណើតនៅបាត់ដំបង ចូលចិត្តលេងឧបករណ៍ភ្លេងប្រពៃណីដូចជាខ្លុយនិងទ្រ ជាដើម ។ ការពិតខ្ញុំចូលចិត្តផ្លុំស្លឹកជាជាង ត្បិតមានខ្លឹមសារបែបលក្ខណៈធម្មជាតិ ។ រីឯការនិពន្ធបទភ្លេងនោះនិងទេពកោសល្យសំលេងច្រៀង គឺខ្ញុំមាននិស្ស័យតាំងពី កំណើតម្លេះព្រោះអីឪពុករបស់ខ្ញុំជាអ្នកភ្លេងបុរាណ ។ ក្រោយពីលោកអនិច្ចកម្ម ទៅ ខ្ញុំនៅតែលេងភ្លេងហើយច្រៀងលេងបន្ទាល់ថ្ងៃមិនសូវខាន មានកាលខ្លះនិពន្ធ បទថ្មីៗ ដើម្បីរំលឹកដល់គុណឪពុក ។ ក្រោយមកខ្ញុំក៏មានសំណាងខ្ពស់ដែលបានជួប លោកសមបុណ្យ ម្ចាស់ផលិតកម្មចំរៀងនិងភាពយន្តខ្មែរ ។ លោកក៏បានផ្តល់ឱកាសអោយខ្ញុំហ្វឹកហ្វឺនបញ្ចេញស្នាដៃយ៉ាងពេញទំហឹង រហូតដល់បានទទួលជោគជ័យ យ៉ាងខ្លាំងក្លានៅពេលនេះតែម្តង ។

អ្នកស្រីនិសាក៏សួរទៅតារាទាំងបីបន្តថា :

- ឥលូវនេះ តើតារាអាចជំរាបប្រិយមិត្តទស្សនិកជនបានទេថា តើអ្នកទាំងបីមានគូ គាប់ប្រចាំដួងចិត្តហើយឬនៅ?

ម្លិះរួត នារីសិចស៊ីគ្រវីក្បាលមុនគេ :

- នាងខ្ញុំស្រលាញ់អាជីពជាតារាសិចស៊ីណាស់ មិនទាន់មានគំរោងថានឹងមានគូគាប់ នៅពេលនេះឡើយទេ ។

- ចំណែកខ្ញុំវិញមានវ័យក្មេង ក្រោមអាណាព្យាបាលរបស់ចាស់ទុំនៅឡើយ មិន ទាន់អាចគិតគូរអំពីគូស្រករឬម្ចាស់ចិត្តបានដែរ ! (សុខាតារាចំរៀង ឆ្លើយបន្ត)

ប្លែកតែតារាបុរសទេដែលនៅស្ងាត់ស្ងៀមដូចជាមិនចង់ឆ្លើយ ។ ឃើញដូច្នោះ អ្នកស្រីនិសាក៏សួរបន្ថែមថា :

- ចុះលោកសុជាតិវិញ ដំណើរជីវិតផ្នែកបេះដូង យ៉ាងណាដែរ?

សុជាតិដកដង្ហើមយូ រួចទើបឆ្លើយវិញថា :

- ការពិតបេះដូងរបស់ខ្ញុំកំពុងតែវង្វេងតាមរកម្ចាស់របស់គេ ដែលបានបាត់ខ្លួនទៅ ចំនួនជិតពីរឆ្នាំហើយ មិនដឹងថាគេនៅទីណា សុខទុក្ខយ៉ាងណាទេ...

- រួចចុះម្ចាស់បេះដូងរបស់លោកជាអ្នកណាដែរតើលោកអាចជំរាបប្រិយមិត្តយើង ទាំងអស់បានទេ?

- បាទ! នាងគឺជាដួងចន្ទ័ដ៏ពណ្ណរាយនៃមេឃាភ្នំពេញដ៏សែនធំ សែនខ្ពស់ល្វឹងល្វើយ ដែលកូនទន្សាយតូចទាបដូចជារូបខ្ញុំនេះបានត្រឹមតែលួចគយគន់សម្លឹងពីដីទៅ ហើយរំពឹងបន់ស្រន់សុំក្តីមេត្តាពីមេឃាតែម្យ៉ាងប៉ុណ្ណោះ ។

ស្រាប់តែកំលោះសុជាតិរលីងរលោងទឹកភ្នែកឡើង ។ ដើម្បីបន្ធូរបរិយាកាស អ្នកស្រីនិសាក៏មានប្រសាសន៍បន្តថា :

- មានន័យថាបេះដូងរបស់លោកកំពុងដង្ហោយហៅរកម្ចាស់ស្នេហ៍ មែនទេហ៎? បើដូច្នេះមែន តើលោកមានបទចំរៀងអនុស្សាវរីយ៍អ្វីមួយទេហ៎ សំរាប់ផ្តាំទៅផ្កាយ ដែលជាម្ចាស់ដួងចិត្តរបស់លោក ថាលោកកំពុងតែរង់ចាំការវិលត្រលប់របស់នាង?

CHANBOKEO.COM

ឮដូច្នោះ សុជាតិក៏នឹកថា នោះជាឱកាសដ៏ល្អរបស់នាយហើយដែលនាយអាច ផ្ញើសំនៀងមួយបទនេះទៅដួងចន្ទ័ម្ចាស់ស្នេហ៍របស់គេ សង្ឃឹមថានារីកំពូលជីវិតនឹង បានដឹងបានឮអំពីជំរៅចិត្តស្នេហាដ៏ស្មោះស្មគ្រ័របស់មាណពចំពោះនាង ។ សុជាតិក៏ ងើបឈរឡើងចាប់ម៉ៃក្រូហ្វូន ហើយក៏វាចាដូចតទៅ :

- ខ្ញុំបាទសុជាតិ សូមជូនចំរៀងមួយបទនេះចំពោះនារីមួយរូប ដែលខ្ញុំគេងគិតគេង ស្រម៉ៃយរាល់យប់ថ្ងៃ គ្មានលោះមួយវេលាណា ។ សូមអោយម្ចាស់បេះដូងបានស្តាប់

ឮហើយ ទទួលដឹងផងថា សុជាតិស្នេហ៍រូបអូនតែម្នាក់គត់នៅក្នុងជាតិនេះ ។

ចិត្តស្នេហ៍ផ្ញើដួងចន្ទ័

ហូ! ហូ! ហូ!...................

១. ចន្ទ័រះបវរឮដ៏នភា មានហ្វូងតារាភ្លឺថ្លាពណ្ណរាយ តែចន្ទ័រះខ្ពស់ឆ្ងាយ
សែនស្តាយ ហត្ថាមិនដល់ ។

២. រាត្រី១០កើតខែអើតលីម១ ចិត្តលួចញញឹមស្នេហ៍ចន្ទ័និមល
ស្តាយដៃឈោងមិនដល់ ខ្វាយខ្វល់ម្នាក់ឯងសោកា ។

បន្ទរ. ជាតិជាទន្សាយ បានត្រឹមគេងឡើយណាយ ស្តាយដួងចន្ទ័ភ្លឺថ្លា
តើធ្វើម្តេចទៅនឹងបានចន្ទ័រួមវាសនា ជាគូទ្វេហានៃបរិត្យជិតកាយ ។

៣. បានត្រឹមសម្លឹងលួចស្នេហ៍ក្នុងចិត្ត បេតីវរមិត្រដួងចន្ទ័រណៃ
ទោះជីវិតរេមក្ស័យ ហឫទ័យផ្ញើចន្ទ័រួចហើយ ។

ស្នូរទះដៃក៏បានលាន់ឮរំពងឡើងពេញសាលសម្ភាសន៍ ។ រំពេចនោះស្រាប់តែ លោកវិសាលបានមកដល់ភ្លាមដែរ ដោយមានសុភាពនារីម្នាក់យ៉ាងសោភាដើរ តាមពីក្រោយមកដល់ផង ។ កាលបើក្រលេកឃើញ វត្តមានរបស់លោកវិសាល ការីការងារទាំងឡាយក៏នាំគ្នាស៊ីញ៉ូទៅអ្នកស្រីនិសា ដើម្បីរកវិធីសំរាកដូរវេនគ្នាវិញ តែអ្នកស្រីមិនបានចាប់ភ្លឹកឡើយ គិតតែមានប្រសាសន៍បន្តកម្មវិធីតាមតែ ដំណើរ រហូតទៅទៀត :

- ពិរោះហើយមានខ្លឹមសារណាស់ លោកសុជាតិ ។ នាងខ្ញុំព្រមទាំងប្រិយមិត្ត យើងទាំងអស់ជឿថា បទចំរៀងមួយបទនេះ នឹងបានផ្សព្វផ្សាយទៅដល់នារីម្ចាស់ បេះដូងរបស់លាកសុជាតិនៅពេលនេះជាក់ជាមិនខាន ហើយ យើងទាំងអស់គ្នាសូម បន់ស្រន់អោយ លោកសុជាតិឆាប់រកឃើញកំពូលដួងចិត្តរបស់លោកឆាប់ៗនេះ !!

ស្រាប់តែ...

- បងជាតិ.....! បងជាតិ... !

នារីសោភាដែលដើរចូលមកដល់ព្រមគ្នាជាមួយលោកវិសាល បានក្រឡេក ឃើញតារាយើង ដែលនៅលើវេទិកាសម្ភាសន៍នោះភ្លាម ក៏ស្ទុះរត់ចូលទៅរកបុរស យើងយ៉ាងរហ័ស រួចឧទានហៅនាយយ៉ាងខ្លាំងៗធ្វើអោយទស្សនិកជននិងវាគ្មិនក្នុង កម្មវិធីមានការភ្ញាក់ផ្អើលក្រៃលែង ។ តែសុភាពនារីសោភារបស់យើងហាក់ដូចជា មិនបានចាប់អារម្មណ៍ទេថាពេលនេះគេកំពុងតែថតកម្មវិធីផ្សាយទូរទស្សន៍បន្តផ្ទាល់ នោះឡើយ ។

CHANBOKEO.COM

ធិតាគិតតែពីរត់ទៅស្រវាអោបចង្កេះរបស់សុជាតិយ៉ាងណែន ធ្វើ អោយបុរសយើងភ្ញាក់ក្រញាងដូចគេចាប់គ្រវែង ។ តែលុះឈ្មោកឃើញភក្ត្ររបស់ មាណវីភ្លាម ស្រាប់តែនាយយើងបើកភ្នែកធំៗហើយឧទានថា :

- ទេវតាលោកអើយ! នេះគឺជាឈូករបស់បងមែនទេហ៎អូន ? បងពិតជាមិនមែន កំពុងយល់សប្តិទេ មែនទេហ៎ ? ឈូក... បងនឹកអូនអ្វីម្ល៉េះទេហ៎!! ឈូកអើយ!!

- បងជាតិ! ឈូកក៏នឹកបងដូចគ្នាដែរ... បងជាតិ! ម្ចាស់ជីវិតអូន! អូនស្រលាញ់ បងណាស់! អូននឹកបងណាស់! កំពូលដួងចិត្តរបស់អូន...!!

គូស្នេហ៍ទ្វេហាក៏ស្រវាអោបគ្នាយ៉ាងណែនពេញរង្វង់ដៃរបស់គេ ដោយដួងចិត្ត រំភើបញាប់ញ័រដើម្បីសំដែងនូវសេចក្តីស្នេហានិងការនឹករលឹករបស់គេ ចំពោះគ្នាទៅ វិញទៅមកយ៉ាងធំធេង នៅចំពោះមុខកញ្ចក់កាមេរ៉ាទូរទស្សន៍ដែលកំពុងថត ផ្សាយបន្តផ្ទាល់ចេញទៅក្រៅ ។ ទោះជាយ៉ាងណាក៏ដោយ ក៏គេទាំងពីរនាក់មិនបាន នឹកខ្វល់ដល់ការអៀនខ្មាសអ្វីឡើយ ក្រៅពីស្រវាអោបគ្នាញញឹមផងសើចផង ស្រក់ទឹកភ្នែកផង ខ្សឹកខ្សួលអួលអាក់ទាំងពីរកាយ នឹងរកពាក្យអ្វីមកនិយាយក៏មិន រួច ក្រៅពីបណ្តោយអោយចង្វាក់បេះដូងរណ្តំញាប់ញ័រឆ្លើយឆ្លងគ្នា ជាជំនួសពាក្យ នឹករលឹកនិងសេចក្តីស្នេហាដ៏ធំធេងរបស់គេតែម្យ៉ាងប៉ុណ្ណោះ ។ ទាំងអ្នកស្រីនិសា ទាំងលោកវិសាលដែលមកជាមួយមាណវីយើង ទាំងបុគ្គលិកប្រចាំការទាំងឡាយ ដែលនៅទីនោះ មានការភ្ញាក់ផ្អើលក្រៃណា ចំពោះវត្តមានរបស់មាណវីសោភា មួយរូបដែលផុសឆ្លោឡើងដោយឥតព្រាងទុក ធ្វើអោយដំណើរកម្មវិធីពិសេស នារាត្រីនោះក្លាយជាច្របូកច្របល់ពន្យល់មិនកើត ។ ផ្ទុយទៅវិញ ទស្សនិកជនយើង បែរជាគិតថា នោះគឺជាកម្មវិធីពិសេសរបស់គណៈកម្មការដែលចាត់ចែងអោយមាន ចំណើចក្នុងការម្ហូបដ៏ប្លែក សំរាប់ជាគ្រឿងពញ្ញាក់ស្មារតីភ្ញៀវអោយរំភើបសប្បាយតែ ប៉ុណ្ណោះ ហើយគ្មាននរណាម្នាក់ចាប់ភ្លឹកទេថា ការជួបគ្នារវាងតារាពានរង្វាន់ ផ្នែកនិពន្ធបទភ្លេងឈ្មោះសុជាតិ និងនារីសោភាឈ្មោះឈូកដែលជាគូស្នេហ៍របស់គេ នោះជាកម្មវិធីថៃដន្យមិនបានព្រាងទុកមុននោះឡើយ ត្បិតអី បើយើងមើលពីក្រៅ ទៅ គឺមិនខុសពីការសំដែងឆាកល្ខោនមនោសញ្ចេតនាមួយ យ៉ាងសមឥតខ្ចោះនោះ ឡើយ ។ ដើម្បីសំរួលបរិយាកាស អ្នកស្រីនិសាក៏ប្រកាសសំរាកកម្មវិធីថា :

- ប្រិយមិត្តទូរទស្សនិកជនជាទីមេត្រី! ថ្ងៃនេះកម្មវិធីរបស់យើងសូមបញ្ចប់ដោយ ភាពរីករាយមួយដែលគូស្នេហ៍មួយគូបានវិលមកជួបគ្នាវិញ...

- មិនទាន់អាចចប់បានទេហ៎!!! នៅមានរឿងដែលត្រូវដោះស្រាយច្រើនទៀត!!

សំលេងស្ត្រីមួយរូបនិយាយកាត់ប្រសាសន៍របស់អ្នកស្រីនិសាដែលកំពុងមាន វាចាទៅកាន់ទស្សនិកជន ។ អ្នកស្រីនិសាភ្ញាក់ក្រញាង លាន់មាត់ថា :

- ពុទ្ធោ! ថ្ងៃនេះមានកម្មវិធីចំលែកច្រើនណាសហ្ន៎? សូម្បីតែនាងខ្ញុំដែលជាពិធីករ ក៏មិនបានដឹងមុនផង ថាមានបាតុភាពអ្វីខ្លះនឹងកើតឡើងនៅក្នុងកម្មវិធីរាត្រីរបស់ យើងនៅវេលានេះខ្លះនោះទេ!

ទស្សនិកជនក៏សើចគិលឡើង ប៉ុន្តែស្ត្រីសោភាដែលមានប្រសាសន៍អំបាញមិញ មិនបានសំដែងការរីករាយជាមួយទេ។ អ្នកស្រីមួយរូបនោះហក់ចេញមកពីខាង ណាមិនដឹង ស្រាប់តែមកដល់លើឆាកវេទិកាដើរតាំងៗទៅចាប់បំបែកគូស្នេហ៍ទាំង ទ្វេអោយរបេះចេញពីគ្នាយ៉ាងរហ័ស ធ្វើអោយគេទាំងពីរភ្ញាក់ផ្អើលដូចត្រូវខ្សែ ភ្លើងឆក់។ អ្នកស្រីរូបស្អាតក៏ឧទានខ្លាំងៗទៅសុជាតិថា :

- នែ៎អ្នកតារាកម្លោះ! នាងមានគូប្រចាំជីវិតរបស់នាងរួចហើយ... ចូរអ្នកចៀសផ្លូវ អោយនាងដើរតាមផ្លូវជីវិតរបស់នាងផងបានទេ? ជាតារាដូចជារូបអ្នក មិនខ្វះទេ នារីដែលស្ម័គ្ររង់ចាំធ្វើជាគូគ្រងរបស់អ្នកនោះ!

ស្រាប់តែនារីសោភាឈ្មោះឈូកនោះ រលាស់ដៃបំរះពីដៃស្ត្រីចំណាស់ ហើយ ឆ្លើយឡើងថា :

- នោះមិនមែនជាការពិតទេ! ម៉ាក់កុំមានប្រសាសន៍យ៉ាងនេះ! គូប្រចាំជីវិតរបស់ កូនគឺជាបងជាតិនេះតែម្នាក់គត់ !

CHANBOKEO.COM

- នែ៎! ក្រពុំចិត្តកូន! បើគូជីវិតរបស់កូនជាតារាកម្លោះមួយរូបនេះ ចុះលោក វិសាលវិញ តើកូននឹងយកគេទៅទុកនៅត្រង់ណា?

ឈូកមិនទាន់ឆ្លើយថាយ៉ាងណាផង ស្រាប់តែតារាចំរៀងឈ្មោះសុខា ដឹកដៃ ស្រីចាស់ខ្ទះភ្នែកមួយរូបស្លៀកពាក់របៀបជាអ្នកភូមិជនបទ ដើរឡើងមកលើឆាក ទាំងពពីមពពើម ។ នៅដៃម្ខាងទៀតរបស់ស្ត្រីចំណាស់នោះ គាត់មានដឹកដៃកុមារី តូចដ៏ស្រស់ស្អាតមួយរូបក្នុងអាយុប្រមាណបួនឆ្នាំមកជាមួយផង ។ ភ្លាមនោះ សុខា ក៏ឧទានហៅនារីយើងថា :

- បងឈូក! មានគេចង់ជួបបងនែ៎ក!!

កាលបើក្រលេកឃើញស្រីចំណាស់នោះភ្លាម ឈូកបើកភ្នែកធំៗ :

- សុខា! ម៉ែ! កូនធា!

រួចហើយឈូកក៏ស្ទុះមកក្រាបសំពះស្ត្រីចំណាស់នោះ ក្បាលដល់កំរាលភ្លាម ព្រមទាំងវាចា ថា :

- ម៉ែ! ម៉ែជាទីស្រលាញ់របស់កូន! កូនក៏នឹកម៉ែខ្លាំងអនេគ មិនដែលភ្លេចម៉ែមួយ ថ្ងៃណាមួយឡើយ !!

ស្រីចំណាស់បន្ទាបខ្លួនអោនស្រវាអោបឈូកដោយសេចក្តីរន្ធត់ត្រេកអរ :

- ពីរឆ្នាំហើយដែលម៉ែមិនដែលដឹងដំណឹងពីកូន ម៉ែនឹកកូនណាស់ ទាំងអស់គ្នានៅ ក្នុងផ្ទះរបស់យើង នឹកកូនគ្រប់ៗគ្នា ។ ឈូក! តើសុខទុក្ខយ៉ាងម៉េចដែរ កូន?

ទាំងពីរនាក់ក៏ស្រវាអោបគ្នាយំសសឹកគួរអាណិតក្រៃលែង ស្រាប់តែ អ្នកស្រី រូបស្អាតស្ទុះមកចាប់បំបែកអ្នកទាំងពីរសាជាថ្មី ព្រមទាំងមានប្រសាសន៍ថា :

- នែ៎! កូនស្រីម្តាយ! នេះអ្នកស្រីជានីម្តាយបង្កើតរបស់កូននៅខាងនេះ! ហេតុដូច ម្តេចឡើយកូនបែរជាផ្តល់កត្តិយសអោនវន្ទាគោរពយ៉ាងខ្ពង់ខ្ពស់ ចំពោះអ្នកដទៃ ដែលជាអ្នកស្រែជនបទ ជាជាងម្តាយរបស់ខ្លួនទៅវិញ?

តែឈូកបែរជាធ្វើមិនដឹង រួចក៏បែរសំរុតខ្លួនរកនាងតូចកុមារីដែលឈរក្បែរ នោះហើយស្រវាអោបនាងយ៉ាងណែនពេញដៃ បន្ទាប់មកក៏យំខ្សឹកខ្សួលមិនស្តីអ្វី មួយម៉ាត់ឡើយ ។ ទាំងការីកាម៉ារ៉ា ទាំងគណកម្មការប្រចាំកម្មវិធី ទាំងទស្សនិកជន ដែលកំពុងអង្គុយមើលកុះករ ក៏នាំគ្នាស្ញៀមស្ងើងបើកភ្នែកធំៗ សម្លឹងស្ថានការណ៍ ទាំងចំលែកចិត្តផង ក្តុកក្តួលក្នុងអារម្មណ៍ផង ។ ម្នាក់ៗនាំគ្នាចំហមាត់ តាមដាន ស្ថានការណ៍ដោយឥតមានពព្រិចភ្នែកឡើយ ត្បិតគេមិនយល់សាច់រឿងអ្វីទាំង អស់ ។ សុជាតិដើរមកជិតឈូកដែលកំពុងយំខ្សឹកខ្សួលអោបកុមារីតូច ហើយក៏ មានវាចាឡើងថា :

- ឈូកអូន! សុធាគេបានរង់ចាំជួបម៉ាក់របស់គេជាយូរមកហើយ... គេនឹកអូន ណាស់ អូនដឹងទេហ៎?

ឈូកងើបសម្លឹងមុខកុមារីតូច ដែលសំលឹងមើលនាងវិញដោយសេចក្តីនឹក រលឹកនិងស្រលាញ់ :

- សុធាកូនស្រីម្តាយ! ម្តាយស្រលាញ់កូនស្មើជីវិត! អោយម្តាយសូមទោសកូនផង ដែលពីរឆ្នាំកន្លងមក ម្តាយគ្មានសមត្ថភាពវិលត្រឡប់មករកកូនបាន...

ពោលមកដល់ត្រង់នេះ ឈូកក៏ស្រក់ទឹកភ្នែកអួលដើមកហើយស្រវាអោបកូន ខ្សឹកខ្សួលសាជាថ្មី ។ ស្រាប់តែ មានដៃមួយមកបេះយកកុមារីចេញពីម្តាយភ្លាម :

- ថ្លើមធំណាស់! ហ៊ានចេញមុខចេញមាត់រត់មករកបុរស នៅទីប្រជុំមនុស្សបែប នេះ ហាក់ដូចជាមិនទុកកត្តិយសដល់យើងជាឪពុកសោះ! ដឹងទេថា កាលបើនាងធ្វើ យ៉ាងនេះ តើនឹងធ្វើអោយយើងជាឪពុកម្តាយរបស់នាងបាក់មុខបាក់មាត់ប៉ុណ្ណា?

ទាំងអស់គ្នាភ្ញាក់ក្រញ្ញាង នាំគ្នាក្រលេកមើលទៅម្ចាស់សំដី ក៏ប្រទះនឹងបុរស

CHANBOKEO.COM

ចំណាស់រូបរាងសង្ហារមួយរូប ក្នុងសំលៀកជាទាហានឧត្តមសេនិយយ៉ាងហំហួនមាន

អំណាច ដើរឡើងមកលើវេទិកាសំដៅមករកឈូកនិងកូន ។ គ្រាន់តែក្រលេក ឃើញលោកភ្លាម

ឈូកសំដែងអាការៈភ័យរញ៉េរញ៉ៃហាក់ខ្លាចសំបើមណាស់ តែលុះ ដល់ក្រលេកឃើញមុខកុមារីសុធាមកវិញ ស្រាប់តែនាងមានកំលាំងចិត្តប្រឹសមក

វិញ ហើយក៏តបទៅលោកវិញយ៉ាងក្លាហាន :

- មែនហើយ! លោកប៉ាពិតជាស្រលាញ់កត្តិយសមុខមាត់របស់លោកប៉ាណាស់ ស្រលាញ់រហូតដល់សុខចិត្តបំផ្លាញជីវិតកូនស្រីរបស់លោកប៉ា

អោយស្លាប់ទាំងរស់ បែបនេះ ក៏គឺដើម្បីកត្តិយសលោកប៉ាដែរ! ការពិត លោកប៉ាមានកត្តិយសត្រឹមតែ សំបក! មើលចុះ!

លោកឧត្តមសេនិយសម្បត្តិមានបុណ្យសក្តិកត្តិយសយ៉ាងធំធេង មានទ្រព្យយ៉ាងស្តុកស្តម្ភ តែខ្វះ...ខ្វះ....ខ្វះ... សូម្បីតែសេចក្តីស្រលាញ់ចំពោះកូន

និងចំពោះចៅរបស់ខ្លួនឯង!! ពិតជាគួរអោយសង្វេគណាស់....!!

ផាំង! លោកសម្បត្តិយារដៃទះកំភ្លៀងមាណវីរបស់យើងមួយដៃ ដួលខ្ទោក

ចំពោះមុខក្រសែភ្នែកមនុស្សទាំងឡាយដែលកំពុងតាមដានស្ថានការណ៍ ។ លោក សម្បត្តិលើកដៃចង្អុលមុខកូនស្រី :

- យើងបានប្រាប់ហើយថា នាងគ្មានសិទ្ធិជួបក្មេងនេះបានទេ ដរាបណានាងរកឪពុក

អោយកូននាងមិនឃើញ! បើនាងនៅតែបិទមាត់មិនព្រមឆ្លើយថា នរណាជាឪពុក របស់ក្មេងមួយនេះទេ នោះយើងនឹងគិតថានាងកុហកយើង

ដើម្បីរកលេសទៅជួប បុរសពោះម៉ាយដែលជាតារាមួយរូបនេះ ។

លោកមានប្រសាសន៍ផង ចង្អុលមុខទៅសុជាតិផង ធ្វើអោយបុរសយើងភ្ញាក់ ស្រលាំងកាំង ។ ស្រាប់តែឈូកក្រោកឈរឡើងយ៉ាងរហ័ស

ហើយបែរទៅប្រឈម មុខនឹងលោកឧត្តមសេនិយវិញ ដោយយកខ្លួនទៅពាំងពីមុខសុជាតិហើយតបថា :

- លោកប៉ា! ម្តេចក៏លោកប៉ាមានប្រសាសន៍បំផ្លើសការពិតយ៉ាងនេះ? សុធាជាសាច់

ឈាមរបស់ខ្ញុំពិតមែន តែបងសុជាតិគ្រាន់តែជាឪពុកធម៌របស់នាងតូចប៉ុណ្ណោះ ។ ការពិត គេមិនមែនជាឪពុកបង្កើតរបស់សុធាទេ ។

សូមលោកប៉ាកុំដាក់ទោសគេ ដោយសារតែគេមានចិត្តធម៌ចំពោះខ្ញុំនិងកូន បានទេ?

- បើនាយមិនមែនជាឪពុករបស់កុមារីមួយនេះមែន ហេតុអ្វីក៏គេប្តូរផ្តាច់បីបាច់ ថែរក្សាក្មេងតូចនេះជំនួសឯងម្លេះ? ម្យ៉ាងទៀត បើនាងថា

គេមិនមែនជាឪពុក អញ្ចឹងនាង និយាយប្រាប់យើងមក៏ ថានរណាជាឪពុករបស់ក្មេងនេះ? ( លោក សម្បត្តិសួរសង្កើញ)

អ្នកស្រីដានីម្តាយរបស់ឈូកដែលឈរក្បែរនោះយូរហើយ ក៏មានប្រសាសន៍ ទៅកាន់ឈូកដែរថា :

- មែនហើយ! បើប្រសិនជាមិនមែនជាបុរសខាងនេះ អញ្ចឹងតើជានរណាទៅវិញ?

ឬក៏ជាលោកវិសាល? បើដូច្នោះប្រសើរណាស់ ម៉ាក់នឹងរៀបចំឱ្យកូនបានរៀបការ នឹងគ្នាគ្រាឥឡូវនេះ ដោយមិនបាច់រង់ចាំអ្វីតទៅទៀត!

- អត់ទេ! ខ្ញុំដឹងច្បាស់ណាស់ថាមិនមែនជាបងវិសាលទេ!

នារីឆើតឆាយម្នាក់ក៏ផុសឆ្លោឡើងស្រែកតបនឹងវាចារបស់អ្នកស្រីដានី ។ ទាំង អស់គ្នាងាកផាំងយ៉ាងលឿន ។

អ្នកស្រីដានីងាកឃើញនាងហើយក៏លាន់មាត់ :

- ដារិយ៉ា! កូនដឹងរឿងអ្វីរបស់ប្អូនស្រីដែរមែនទេហ៎?

- កូនមិនដឹងទេម៉ាក់ គ្រាន់តែដឹងថា បងវិសាលមិនមែនជាឪពុកនាងតូចមួយរូប នេះតែប៉ុណ្ណោះ ។

- ថាម៉េច? ហើយចុះហេតុអ្វីក៏កូនមានការជឿជាក់ក្នុងចិត្តដល់ម្លឹង? ( អ្នកស្រីដានី លាន់មាត់)

ពុទ្ធោអើយ! មិនថាជានរណាទេ ដែលស្ថិតនៅរួមស្ថានការណ៍ទីនោះ ម្នាក់ណា ក៏នឹកចំឡែកចិត្តដែរថារឿងរ៉ាវពេលនេះ

វាកាន់តែវែងឆ្ងាយហើយ ។ រីឯកម្មវិធី ទូរទស្សន៍វិញក៏រកបញ្ឈប់មិនបានសោះ ត្បិតទស្សនិកជនកំពុងតែជក់អារម្មណ៍នឹង

CHANBOKEO.COM

សាច់រឿងដ៏ចំលែកនៅលើឆាកវិសេស ដែលមានអាថិកំបាំងគួរអោយចង់តាមដាន ក្រៃលែង។

សុជាតិលើកនាងតូចសុធាពឡើងហុចអោយទៅឈ្យូកជាម្តាយ ហើយ ឱ្យបដាក់ត្រចៀកប្រាប់ធិតាថា :

- ឈ្យូកអូន! មិនថាស្ថានការណ៍ជុំវិញខ្លួនរបស់អូននេះ បំបាក់ទឹកចិត្ត ឬក៏បំផ្លាញ កត្តិយសរបស់អូនក៏វិតណាក៏ដោយ ចូរអូនចងចាំទុកក្នុងចិត្តរបស់អូនចុះថា បង ស្រលាញ់អូននិងកូនសុធាពេញបេះដូងរបស់បង គ្មានថ្ងៃប្រែប្រួលទេ ។ ចំពោះបង អូននិងកូន ជាដួងតារាដែលរះបំភ្លឺអោយជីវិតរបស់បង ឱ្យមានន័យ មានខ្លឹមសារ ជានិច្ច ។ ពង្រឹងស្មារតីឡើងណាំអូនណាំ! យើងកាន់ដែតស៊ូនឹងឧបសគ្គជាមួយគ្នា ។ ពេលនេះ បងមិនបណ្តោយអោយគេប្រអូសប្រទាញយកអូនពីបងបានសាជាថ្មី ដូច ពេលមុនបានទៀតឡើយ... ទុកចិត្តបងចុះ!!

ឈ្យូកទទួលយកកូនស្រីមកថើប ហើយងើយមើលមុខសុជាតិទាំងទឹកភ្នែករលីង រលោង :

- អូនជានារីដែលមានទឹកចិត្តទន់ខ្សោយយូរមកហើយ ពេលនេះក៏ល្មមដល់ពេល ហើយ  ដែលអូនត្រូវតែតាំងចិត្តរឹងប៉ឹងក្លាហានជាថ្មី ដើម្បីប្រឈមមុខនឹងឧបសគ្គ ស្វែងរកជីវិតដែលជារបស់ខ្លួនឯងមកវិញ  គឺជីវិតដែលគ្មានគេត្រួតត្រាតទៅទៀត!

វិពេចនេះ ស្រាប់តែនារីស្រស់ឆើតឆាយឈ្មោះដារិយ៉ាដែលត្រូវជាបងស្រី របស់ឈ្យូកក៏ប្រអូសប្រទាញបុរសម្នាក់ដែលនៅឈរក្បែរនាង ហើយឧទានឡើង ទៅនាយថា :

- ឆ្លើយមកប៉េងឡុង! តើឯងបានប្រព្រឹត្តអ្វីមិនគប្បីចំពោះប្អូនស្រីយើងដែរទេហ៎?

បុរសឈ្មោះប៉េងឡុងធ្វើមុខស្លេក :

- អត់ទេ! ដារិយ៉ា! កុំលេងចោទគ្នាឯងយ៉ាងនេះ? ពិតមែនតែប៉េងឡុងខ្ញុំដើរលេង រប៉ាត់រប៉ាយបន្តិច តែក៏មិនដែលនឹកគិតលួកថ្លើមនារីណាដែរ... លែងខ្ញុំមើស៍!

ទាំងអស់គ្នាមើលមុខគ្នាទៅវិញទៅមក តែគ្មាននរណាម្នាក់ដឹងទេ ថាចំលើយ វាយ៉ាងម៉េច ។ គឺមានតែឈ្យូកប៉ុណ្ណោះដែលជាម្ចាស់រឿងសំងាត់ ប៉ុន្តែហេតុអ្វីបាន ជានាងលាក់រឿងយ៉ាងស្ងាត់រហូតដល់ថ្ងៃនេះ? ដើម្បីជំរះចំងល់ជូនទស្សនិកជន អ្នកស្រីនិសាក៏បន្តកម្មវិធីសម្ភាសន៍ជាមួយនឹងតារាសុជាតិបន្តទៀតថា  :

- ថ្ងៃនេះ នាងខ្ញុំគិតថា កម្មវិធីរបស់យើងពិតជាមានខ្លឹមសារចំលែកក្រៃ តែដើម្បី បណ្តោះចំងល់ តើនាងខ្ញុំអាចសួរលោកសុជាតិនិងអ្នកនាងឈ្យូកបានទេហ៎ថា តើ ហេតុការណ៍ពីមុនៗមកយ៉ាងណាខ្លះ បានជាសាច់រឿងជំពាក់ជំពិនដូចអំបោះជំពាក់ មុខយ៉ាងនេះ? ឥឡូវនេះ បើស្ថានការណ៍ធ្លាក់ដល់ថ្នាក់ធ្លាយការសំងាត់ក្នុងបេះដូង និងការសំងាត់ក្នុងក្រុមគ្រួសារ នៅលើឆាកវេទិកាចំពោះមុខសាធារណជនដូច្នេះ ទៅហើយ គួរតែលោកឆ្លៀតឱកាសនេះស្រាយមុខជំពាក់អោយជ្រះស្រឡះតែម្តង តើលោកគិតយ៉ាងណាដែរ? ជាពិសេស ទាន់នៅពេលនេះ មានប្រិយមិត្តរាប់ពាន់ រាប់ម៉ឺនជាសាក្សី ចំពោះសាច់រឿងជីវិតរបស់លោកស្រាប់ៗ ក្រែងជីវិតស្នេហារបស់ លោកអាចបានទទួលយុត្តិធម៌ខ្លះៗមកវិញ ។

សុជាតិបែរសម្លឹងទៅឈ្យូកមួយស្របក់ ហើយក៏បែរមកអ្នកស្រីនិសា រួចក៏ មានវាចាឡើងថា :

- ឈ្យូកជានារីដែលខ្ញុំស្រលាញ់បំផុតក្នុងជីវិត! ម្យ៉ាងទៀត ខ្ញុំមិនដែលគិតថា តើនរណាជាឪពុករបស់នាងតូចសុធាទេ ត្បិតនៅគ្រប់វិនាទី ក្នុងបេះដូងរបស់ខ្ញុំ សុធាគឺជាកូនស្រីដែលខ្ញុំស្រលាញ់ស្មើជីវិត ហើយមិនអាចបោះបង់នាងចោលបាន ឡើយ ។ ម្យ៉ាងទៀត

CHANBOKEO.COM

ខ្ញុំក៏បានបីបាច់ថែរក្សានាងតាំងពីក្រហមបាតជើងរហូតមក ។ សូម្បីតែនៅគ្រាមួយនោះ ជីដូនជីតារបស់គេមកចាប់ពង្រាត់យកម្តាយគេត្រឡប់ទៅវិញបាត់ក៏ដោយ ក៏ខ្ញុំនៅតែចិញ្ចឹមថ្នាក់ថ្នមថែរក្សានាងតូចហាក់បីនាងជាសាច់ ជាឈាមរបស់ខ្ញុំដោយឥតមាននឿយណាយឡើយ ។ គេជាក្មេងតូចណាស់! មិនបាន ដឹងរឿងរ៉ាវរបស់មនុស្សចាស់ទេ ប៉ុន្តែ ខ្ញុំមិនយល់សោះថា ហេតុអ្វីបានជាចាស់ៗ បែរជានាំគ្នាដាក់ទោសនាងតូចអោយនាងព្រាត់ម្តាយជាទីស្រលាញ់នោះកើត? ហើយតើលោកចង់យកចាញ់ឈ្នះដើម្បីអ្វីទៅ កាលបើកូនចៅរបស់លោកត្រូវរស់រងទុក្ខវេទនាផ្លូវចិត្តយ៉ាងរីងរៃដោយការព្រាត់ប្រាសគ្នាបែបនេះ?

សុជាតិនិយាយផង រលីងរលោងទឹកភ្នែកផង សម្លឹងទៅលោកសម្បត្តិ និង អ្នកស្រីដានីផង ។ នៅដៃម្ខាង នាយពសុធា ដៃម្ខាងទៀតត្រកងចង្កេះរបស់ឈ្យូក មកផ្អិបនឹងខ្លួនរបស់នាយយ៉ាងណែន ហើយក៏និយាយបន្តថា :

- ទាំងបីនាក់យើងស្រលាញ់គ្នា ជាក្រុមគ្រួសារតែមួយ ! សូមលោកមេត្តាកុំបំបែក យើងតទៅទៀតធ្វើអ្វី ! ខ្ញុំបាទសូមទទួចអង្វរចិត្តមេត្តាពីលោកទាំងពីរ សូមអោយ យើងបានរស់នៅជួបជុំគ្នា មានសុភមង្គលដូចគ្រួសារដទៃៗផងបានទេហ៎?

អ្នកស្រីដានីឮដូច្នោះ ក៏ពោលឡើងថា :

- មិនបាន! នាងមានគូដណ្តឹងរួចហើយ ហើយក៏ជិតរៀបការជាមួយគ្នាដែរ នោះគឺ លោកវិសាលដែលនៅឈរខាងនេះ ។ តាមការពិតគឺអ្នកទេ ដែលត្រូវដើរចេញពី ជីវិតរបស់កូនស្រីយើង ដើម្បីអោយនាងមានឱកាសសាងសុភមង្គល យ៉ាងសុខសាន្តដោយគ្មានរូបអ្នកមករំខានជីវិតរបស់នាងតទៅទៀត ។

- ម៉ាក់! ម៉ាក់អោយប្អូនរៀបការនឹងលោកវិសាលមិនបានទេ (ដារិយ៉ាឆ្លើយកាត់)

- ហេតុអ្វីរៀបការមិនបាន?

- គឺ.... គឺ.... (ដារិយាឆ្លើយតតាក់តតុប) ព្រោះ លោកវិសាលមិនមែនជាឳពុក របស់កុមារីមួយនេះ !!

- នោះល្អហើយ! (លោកសម្បត្តិឆ្លើយកាត់) បើក្មេងស្រីនេះជាកូនបុរសខាងណោះ (លោកចង្អុលទៅសុជាតិ) ទុកអោយគេថែរក្សាកូនរបស់គេទៅ នោះវាចប់ការណ៏!

- លោកប៉ា! (ឈ្យូកឆ្លើយកាត់) ម៉េចក៏លោកប៉ានៅតែមានះ ចោទបងជាតិ ដោយ បំផ្លើសការពិតយ៉ាងនេះ ? ថ្ងៃនេះ កូនរបស់លោកប៉ាលែងនៅស្ងៀមទៀតបាន ហើយ ដែលបងជាតិត្រូវ លោកប៉ាលាបមុខអោយគាត់ទាំងងងឹតងងល់....!

- យើ! កូនស្រីល្អ! ឥលូវនេះហ៊ានសំដីថ្លោសដាក់យើងផងហ្ន៎ស? ដឹងទេថា គេ នេះហើយជាអ្នកបំផ្លាញជីវិតនិងអនាគតរបស់កូន?

រំពេចនោះ ស្រាប់តែឈ្យូកស្រក់ទឹកភ្នែកច្រោក:

- ចាំស ខុសទេលោកប៉ា ! អ្នកដែលបំផ្លាញជីវិតរបស់កូនមិនមែនជារូបគេទេ! ការពិត... អ្នកដែលបំផ្លាញជីវិតរបស់កូនអោយស្លាប់ទាំងរស់នោះ គ្មាននរណា... ក្រៅពីលោកប៉ានិងម៉ាក់ទេ! លោកប៉ាជ្រាបទេហ៎ថា គឺរូបគេនេះ សុជាតិនេះ ជាអ្នកស្រោចស្រង់ជីវិតរបស់កូនអោយផុតមរណកម្ម អោយកូនមានទឹកចិត្តចង់ រស់នៅលើលោកសាជាថ្មីតទៅទៀត.... នៅក្នុងបេះដូងរបស់កូន គេគឺជាព្រះ ជា ទេវតា ដែលមកប្រោសជីវិតអោយឈ្យូកមានចិត្តចង់រស់សាជាថ្មីម្តងទៀត...

- តែផ្តាស! (លោកសម្បត្តិគំហក) យើងមិនគួរមានកូនដូចជារូបនាងដែលយក អ្នកដទៃទុកដាក់ស្មើព្រះ ហើយប្រមាថឳពុកម្តាយរបស់ខ្លួនយ៉ាងឧត្បាតដូច្នោះទេ! ព្រះលោកច្បាស់ជាមិនប្រោសប្រណីនាងឡើយ ។

ឈ្យូកឈរសំលឹងមុខលោកឧត្តមសេនីយ៍មិនព្រិចទេ ហើយក៏ឈប់តបតថា យ៉ាងណាតទៅទៀតដែរ ។ រួចហើយនាងក៏បែរសម្លឹងនាងតូចសុធាដែលជាកូន ស្រីរបស់នាងដែលមិនទាន់ដឹងក្តីសព្វគ្រប់នៅឡើយ រួចមើលសុជាតិ សុខា ស្ត្រី

CHANBOKEO.COM

ចំណាស់ដែលខ្វាក់ភ្នែក អ្នកស្រីដានីជាម្ដាយ ដារីយ៉ាជាបងស្រី ប៉េងឡុង លោក វិសាល
រួចហើយក៏ទាញដៃកូននិងសុជាតិដើរសំដៅទៅអ្នកស្រីនិសាដែលកំពុងឈរ ភាំងដូចគេសណ្ដំ
ដោយការភ្ញាក់ផ្អើលនឹងស្ថានការណ៍កម្មវិធីដែលមិនបានព្រាងទុក នោះខ្លាំងពេក ។ មាណវីយើងក៏ឱនគោរពអ្នកស្រីនិសាហើយស្រដីថា :
- នាងខ្ញុំសូមអភ័យទោសដែលធ្វើអោយកម្មវិធីថ្ងៃនេះមានភាពច្របូកច្របល់ ប៉ុន្តែ មានតែពេលនេះមួយគ្រាប៉ុណ្ណោះទេ ដែលខ្ញុំអាចរើខ្លួន
រកពន្លឺក្នុងជីវិតសាជាថ្មីបាន ហើយក៏មានតែអស់លោកអ្នកនៅទីនេះប៉ុណ្ណោះ ដែលអាចជួយធ្វើជាចៅក្រម និង
ជាសាក្សីចំពោះរឿងជីវិតអតិតកាលដ៏សែនសៅហ្មងរបស់នារីខ្ញុំនេះ ។ បំណាច់រឿង រ៉ាវធ្លាយមុខយ៉ាងធំបែបនេះទៅហើយ
នាងខ្ញុំក៏មិនគួរលាក់ការពិតតទៅទៀតដែរ ថ្វីត្បិតតែរឿងនោះទាក់ទិនទៅនឹងកត្តិយស កេរ្តិ៍ឈ្មោះអាស្រូវរបស់នាងខ្ញុំក៏ដោយ ចុះ ក៏នាងខ្ញុំជឿថា
កាលបើការពិតបានទំលាយរួចហើយ ព្រះលោកនឹងយាងចុះមក ប្រោសកូនសត្វទទឹកស្លាបដូចនាងខ្ញុំនេះ
អោយផុតបាបគ្រោះទាំងអំបាលម៉ានជា
មិនខានឡើយ ។ សូមអ្នកស្រីមេត្តាទុកឱកាសអោយនាងខ្ញុំផង!

អ្នកស្រីនិសាឈរភាំងមួយស្របក់ទើបមានប្រសាសន៏ថា :

- មែនហើយ! ទាំងនាងខ្ញុំ ទាំងគណកម្មការក្នុងពិធី ទាំងទស្សនិកជនទាំងឡាយ ពិតជាចង់ដឹងការពិតណាស់
ថាតើទំនាក់ទំនងរវាងអ្នកនាងនិងលោកសុជាតិ មាន ជំរៅបែបណា មានឧបសគ្គដូចម្ដេចខ្លះ ហើយអ្វីដែលជាកត្តាដែលជំរុញអោយ
អ្នកទាំងពីរមានកំលាំងចិត្តពុះពារតាមរកគ្នា ដោយមិនលះបង់ក្ដីសង្ឃឹមយ៉ាងនេះ?

សុជាតិដែលឈរស្ងៀមយូរហើយ ក៏ស្រាប់តែបន្លឺវាចាបន្ថែមថា :

- ណ្ហើយចុះ! បំណាច់នឹងក្លាយជាដួងតារារបស់ទស្សនិកជន នៅថ្ងៃនេះ ខ្ញុំបាទ សុជាតិក៏មានមោទនភាពយ៉ាងឧត្តុង្គឧត្ដម
នឹងមកជំរាបជូនដែរនូវប្រវត្តិទាំងឡាយ ដែលទាក់ទងនឹងជីវិតរបស់ខ្ញុំបាទផ្ទាល់ ជាមួយនឹងគូប្រចាំជីវិតរបស់ខ្ញុំបាទ ថាតើ
ខ្ញុំបាទសក្តិសមនឹងទទួលកត្តិយសជាតារាឯកគំរូ ដល់ប្អូនៗជំនាន់ក្រោយដែរឬក៏ យ៉ាងណា ។
សូមមេត្តាប្រិយមិត្តទស្សនិកជនជួយកាត់សេចក្ដីចំពោះដំណើរសាច់ រឿងជីវិតរបស់ខ្ញុំបាទនិងអូនឈូកដូចតទៅ....

ទស្សនិកជនក្រោកឈរព្រោងព្រាតឡើងទះដៃលាន់ប្រាវៗដូចលាជផ្ទុះ ហាក់
បីដូចជាកំលាំងចិត្តដ៏ខ្លាំងក្លា ជំរុញអោយគូស្នេហ៍ទេ្វហារីងរិតតែមានទឹកចិត្តពុះពារ
រនាំងជីវិតដ៏សែនធំមួយដែលបានធ្វើអោយគេទាំងពីរព្រាត់គ្នាមកជាយូរមកហើយ..
ទោះបីជាពេលនោះ នរណាចង់តវ៉ាអ្វី ជជែកអ្វី ប្រកែកអ្វីក៏លែងឮ លែងមាន ប្រសិទ្ធភាពទៀតហើយ
ក្រៅតែពីបណ្ដោយអោយកម្មវិធីបន្តដំណើរតទៅមុខ ទៀតតែម្យ៉ាងប៉ុណ្ណោះ...

00 00

00

CHANBOKEO.COM

# វគ្គទី២
# ចែងនៀជាន់ដៃ

នៅភូមិត្រាង  អូរតាគី....

ជិតភ្លឺហើយ... ភ្លៀងធ្លាក់ស្រិច១ ហាក់ដូចជាកំពុងបញ្ជូនភាពត្រជាក់ត្រជុំមក លើពសុធាដែលកំពុងតែក្រៀមក្រោះអស់ជាច្រើនខែកន្លងមក ។ ថ្ងៃនេះ នាយ សុជាតិភ្ញាក់ពីព្រហាមជាងរាល់ដង រៀបចំខ្លួនចេញទៅយកឡានពីថៅកែដែលមាន ផ្ទះនៅអូរតាគី ។ ការពិតនាយគឺជាអ្នករកស៊ីរត់ឡានឈ្នួល ជួលឡានគេប្រចាំថ្ងៃ សំរាប់រត់យកកំរៃលៀងជីវិត។ បន្ទាប់ពីទទួលយកឡានបានហើយ  នាយក៏បរចេញសំដៅទៅផ្សារណាត់បាត់ដំបង ត្បិតអីមានម៉ូយណាត់អោយទៅដឹកឥវ៉ាន់យក ទៅក្រុងភ្នំពេញនៅម៉ោង៥ភ្លឺនេះ ។

គ្រាន់តែបរឡានចេញមកដល់ជិតក្បាលស្ពានអូរតាគី ស្រាប់តែរថយន្តក្លាយ ជារត់ឃ្លេងឃ្លោងខុសធម្មតា ។ សុជាតិក៏អែបឡានចតហើយចុះដើរកាត់សរសៃ ភ្លៀងដោយមានយកពិលទៅឈ្លួលមើលកង់ទាំងបួនផង ស្រាប់តែប្រទះឃើញកង់ មួយបែកសំប៉ែតដល់ដី ។ នាយគ្រវីក្បាលហួសចិត្ត ក៏ស្ទុះស្ទារផ្លាស់កង់យ៉ាងរហ័ស ត្បិតខ្លាចមិនទាន់ដំណើរណាត់ ។ លុះដូរកង់ឡានរួចហើយ នាយយើងក៏ដើរអែបព្រៃខាងស្តាំដៃរថយន្តដើម្បីយកកង់ឡានបែកទៅទុក ស្រាប់តែមានអារម្មណ៏ថា នាយកំពុងតែដើរជាន់អ្វីមួយទន់១ ហាក់ដូចជាដៃមនុស្ស ។ នាយយើងភ្ញាក់ដូចគេ ចាប់គ្រវែង ក៏ស្ទុះយកពិលទៅឈ្លួលមើល ស្រាប់តែប្រទះនារីមួយរូបក្នុងសំលៀក មានតម្លៃតែរហែករយ៉ៃពាសពេញខ្លួន ព្រមទាំងមានប្រលាក់ឈាមពាសពេញ កំពុងដេកស្តូកស្តឹងមិនដឹងខ្លួន។ សុជាតិភ្ញាក់ផ្អើលណាស់ ហើយក៏មិនដឹងថានារីដែល នាយប្រទះនោះនៅមានជីវិតឬយ៉ាងណាទេ ត្បិតមិនឃើញនាងកំរើកអ្វីសោះ ។ តែលុះដល់នាយស្ទាបខ្លួនរបស់នាងទៅឃើញនៅក្តៅឧណ្ហ១ ទើបដឹងថានាងនៅមានជីវិតនៅឡើយទេ។ មាណពក៏យកពិលបំភ្លឺរេចុះរេឡើងនៅម្តុំនោះ  ក៏ប្រទះ ឃើញស្នាមកង់ឡានក្រឡៅ១អូសតាំងពីថ្នល់កៅស៊ូកាត់ព្រៃគុម្ពោតសំដៅចុះទៅ ក្នុងអូរ។ នាយងាកចុះងាកឡើង ក្នុងចិត្តគិតមិនដឹងថាត្រូវធ្វើដូចម្តេចទៀត ណា មួយ ពេលនោះទើបតែម៉ោងបួនជាងជិតភ្លឺត្រូវនឹងមេឃភ្លៀងទៀត ទើបមិនទាន់មានចរាចរមនុស្សម្នាអ្វីនៅឡើយ នឹងហៅរកគេអោយជួយក៏ពិបាក.. បើនឹងដឹក នាងទៅពេទ្យឯបាត់ដំបងទៅ ខ្លាចគេច្រលំចោទនាយថាជាអ្នកដែលបានរំលោភ យាយីឬបើកឡានបុកស្រីក្មេងម្នាក់នោះអោយមានរបួស។ ម្យ៉ាងនាយក៏មិនមានសោហ៊ុយសំរាប់ថ្លៃព្យាបាលនាងទៀតផង ។ បើថានឹងអោយដើរចេញទៅនោះ ហាក់ដូចជាខ្លួននាយនេះជាមនុស្សមានចិត្តដាច់មេត្តាក្រៃណាដែលឃើញស្រីភេទ រងគ្រោះហើយ នៅបញ្ឈរភ្នែកមើលមិនព្រមជួយយកអាសារជីវិត។ តែបើ អាល័យយកពេលមកជួយនាងទៅនោះនាយច្បាស់ជា ត្រូវខកការណាត់ដឹកជញ្ជូន អីវ៉ាន់នៅព្រឹកនេះមិនខាន ម្ល៉ោះហើយនឹងត្រូវដាច់ស្បៀងប្រចាំថ្ងៃរបស់ខ្លួន ជាពិសេសពេលនេះនាយមានមនុស្សក្នុងបន្ទុកដល់ទៅពីរនាក់ទៀតនៅឯផ្ទះដែល ត្រូវចិញ្ចឹមទំនុកបំរុងថែមទៀត។ តើនាយត្រូវធ្វើយ៉ាងណាទៅវិញទើបសមរម្យ? គិតចុះគិតឡើង នាយសំលឹងទៅនារីនោះសាជាថ្មីមួយស្របក់ ទើបនាយក៏ដាច់ចិត្ត

CHANBOKEO.COM

បង្អោនកាយស្រវាត្រកងលើកកាយនារីមួយរូបនោះ បីឡើងយកទៅដាក់ឡាន ឈ្នួលរបស់នាយ ។
ពេលនោះស្រាប់តែសុជាតិឃើញនាងអោបថង់ខ្មៅតូចមួយ ជាប់នឹងដៃឆ្វេងយ៉ាងណែន ។ ទោះបីជាពេលនោះ មាណវីបានបាត់ស្មារតីទៅហើយ ក្តី ក៏ដៃនាងនៅតែក្តាប់វាជាប់ មិនរបូតឡើយ ។ សុជាតិក៏ផ្តេករូបនាងទៅលើ
កៅអីពូកឡានហើយក៏ឡើងបរត្រលប់ថយក្រោយចេញទៅ ។ លុះមកដល់ផ្លូវ បំបែកពីផ្លូវជាតិលេខប្រាំសំដៅចូលភូមិត្រាង
នាយក៏បត់រឹងចូលទៅ។ ឱ! តើគេនាំ នាងទៅណាហ្ន៎? មែនហើយ! ការពិត ពេលនេះមាណពកំពុងនាំនាងមកលំនៅ របស់ខ្លួនទេតើ!
បន្ទាប់ពីមកដល់ផ្ទះភ្លាម នាយក៏លើកនាងយកទៅលើផ្ទះហើយ ផ្តេកនាងដាក់លើខ្នើយនិងកន្ទេលចាស់ៗរបស់ខ្លួន ។ ភ្លាមនោះ
ក្មេងស្រីមួយរូបមាន វ័យប្រមាណ១២ឆ្នាំ លូនចេញពីមុងរបស់នាងមកឃើញ ហើយក៏សួរថា :

- បងជាតិ! នាំអ្នកណាគេមកហ្នឹង? ហេតុអ្វីរបួសឈាមពាសពេញខ្លួនដូច្នេះ?

សុជាតិងាកមកនាងហើយស្រែកហៅនាងអោយមកជួយ :

- សុខា! មកជួយជូតសំអាតរបួសអោយនាងផង!
- ចាស!

សុខាស្ទុះចេញមកជួយយ៉ាងរហ័ស ។ បន្តិចក្រោយមក សុជាតិក៏ចេញទៅ ក្រៅរែកទឹកយកមកលាងឈាមដែលស្រក់ប្រលាក់លើឡាន ។
សុខាឃើញហើយ ក៏សួរទៅនាយថា :

- បងមិនចេញទៅរត់ឡានវិញទេថ្ងៃនេះ?
- មើលទៅ ប្រហែលត្រូវខកមួយថ្ងៃហើយ ព្រោះហួសម៉ោងណាត់ជិតមួយម៉ោង ទៅហើយ ។
បងគិតថាលាងឡានហើយយកវាទៅសងម្ចាស់គេវិញ ។
- អញ្ចឹង អ្នកដែលណាត់បងនោះ គេមិនខឹងនឹងបងស្លាប់ហើយទេហ៎?
- តើអោយបងធ្វើម៉េចទៅ បើបងអាល័យតែយកអាសារគេ...? ឃើញមនុស្សរង
គ្រោះហើយមិនសង្គ្រោះ វាមិនកើត... ដល់ជួយគេទៅ វាទាល់ច្រកខ្លួនឯង.... ហ៊ឹ!

ឃើញបងប្រុសដកដង្ហើមធំ សុខានៅស្ងៀម ឈប់សួរហើយក៏ប្រញាប់ទៅដាំ ទឹកយកមកស្អំស្អាមជាំពាសពេញខ្លួនមាណវីចំលែកភ្លាម ។
ភ្លាមនោះមាន ស្ត្រី ចំណាស់ពាក់កណ្តាលអាយុម្នាក់ ប្រវេប្រវាចេញពីមុងមក ទំនងដូចជាងងិតភ្នែក
ផង។ លុះឮអ្នកទាំងពីរជជែកគ្នាគាត់ក៏សួរឡើងថា :

- សុខា... សុជាតិវាទៅសង្គ្រោះពីណាគេមកហ្នឹង ហ្ន៎សកូន?
- ចាសម៉ែ! ជាស្រីម្នាក់ដ៏ស្រស់ស្អាតណាស់ មើលរាងដូចជាអ្នកទីក្រុងហើយទំនង ជាអ្នកមានផង...
- តិចលោវាជិះរត់កូនក្រមុំគេហើយជួបគ្រោះថ្នាក់ទេដឹងនេះ ?

សុជាតិកំពុងតែឈានជាន់កាំជណ្តើរឡើងទៅលើផ្ទះ កាលបើឮម្តាយសួរ ដូច្នោះ ក៏ឆ្លើយទៅគាត់វិញថា :

- មិនមែនទេម៉ែ ! នាងជាអ្នករងគ្រោះដែលកូនជួបតាមផ្លូវដោយចៃដន្យទេ....
- អ៊ើ... អោយតែវាអញ្ចឹងទៅចុះ... កុំតែកូនប្រព្រឹត្តអ្វីមិនគប្បីទៅបានហើយ ។

សុជាតិញញឹមឡើងហើយពោលថា :

- បាទម៉ែ!

CHANBOKEO.COM

ថាហើយ មាណពក៏ស្រវាយកសោរហើយបរឡានចេញទៅ ។ ដល់ផ្ទះថៅកែ នាយក៏យកសោរឡានឈ្នួនទៅប្រគល់អោយភរិយារបស់គាត់ ត្បិតថៅកែមិននៅ ស្រាប់តែគាត់ភ្ញាក់ព្រើតសួរនាយថា :

- អានាងឯងមិនរត់ឡានទេ ថ្ងៃនេះ បានជាយកសោរមកអោយមីងទាំងព្រហាម អញ្ចឹង?

- បាទ! ជាប់មានធុរៈប្រញាប់បន្តិចណា៎មីង ចាំស្អែកខ្ញុំមកទទួលយកឡានសាថ្មី ។

ថាហើយនាយក៏សំពះលារួចស្រវាកង់កញ្ចាស់របស់នាយ ដែលចតចោលនៅ ក្រោមដើមទឹកដោះគោក្រោយផ្ទះថៅកែឡើងជិះត្រលប់ក្រោយមកផ្ទះវិញ ។ មក ដល់កូនផ្ទះឈើកញ្ចាស់ដ៏តូចមួយខ្នងរបស់នាយ ដែលសង់ខ្ពស់ពីដីជាងមួយ ម៉ែត្រហើយមានជញ្ជាំងពុកធ្លុះប្រហោងដោយអន្លើ នាយក៏ប្រទះឃើញសុខារត់ មកចាំនៅមុខផ្ទះជាស្រេច ។ កាលបើក្រលេកឃើញនាយភ្លាម នាងក៏ខ្សិបប្រាប់ ទៅមាណពថានារីចំលែកនោះដឹងខ្លួនវិញហើយ ។ ប៉ុន្តែនាយយើងមិនហ៊ានឡើង ទៅបង្ហាញខ្លួនអោយនាងបានឃើញទេ ត្បិតគិតថានាយជាមនុស្សប្រុស ខ្លាចនាង ខ្មាស់អៀនចំពោះរូបនាយ ដោយនាងមានសំលៀកបំពាក់រដាច់ដោច រហែករយ៉ៃ យ៉ាប់ភ្នែកខ្លាំងពេក ។ នាយក៏លួចខ្សិបប្រាប់ប្អូនថា :

- សុខា! ម៉េចក៏អូនឯងមិនយកសំលៀកណាសមរម្យអោយនាងផ្លាស់សិនទៅ... ទុក អោយនាងស្លៀកខោអាវរហែកយ៉ាងនេះ ដូចជាមិនសមរម្យសោះ!

តែសុខាបែរជាបើកភ្នែកម៉ក់ៗ ហើយឆ្លើយវិញថា :

- តើយើងមានខោអាវអីអោយបងស្រីហ្នឹងគាត់ស្លៀកទៅ បងជាតិ? មានតែ សារុងចាស់ៗបំណះរុំ របស់ម៉ែតែប៉ុណ្ណោះ ។ ចំណែកខោអាវខ្ញុំក៏វាតូចៗជ្រុល គាត់ ច្បាស់ជាពាក់មិនត្រូវទេ ។

មាណពយកដៃអេះក្បាលគិតមិនចេញ :

- មើលទៅ ទាល់តែខ្ចីខោអាវម៉ែសិនទេដឹង?

រំពេចនោះ នារីចំលែកក៏ស្រែកថ្ងូរតិចៗ ហៅរកសុខា ថា :

- អ៊ុយ... ឈឺណាស់... អោយខ្ញុំសុំថ្នាំលេបបំបាត់ការឈឺចាប់បានទេ ប្អូនស្រី?

សុខាធ្វើមុខឡើងឡង់. ហើយស្ទុះចូលទៅជិត :

- មានតែថ្នាំឫសឈើ.. បងស្រីពិសាទេ ខ្ញុំទៅដណ្តាំយកមកអោយបងណា៎...

- បងមិនដែលបរិភោគថ្នាំឫសឈើទេ... សុំថ្នាំបារាំងបានទេ...?

- ថ្នាំបារាំង! ពុទ្ធោ! ខ្ញុំអត់មានទេបង....

រំពេចនោះ ស្រាប់តែស្ត្រីចំណាស់លូកដៃហុចមកព្រមទាំងមានប្រសាសន៍ថា:

- ម៉ែនៅសល់អាស្ពីរីនពីរគ្រាប់ដែរ កូនស្រីលេបសំរន់សិនទៅ ក្រែងជួយបំបាត់ការ ឈឺចាប់បានខ្លះៗណា៎កូន ! សុខាជួយយកទឹកមកអោយបងស្រីឯងផង កូន!

- ចាំសម៉ែ!

សុខាក៏ជួយលើកនារីយើងឡើង ហើយបញ្ចុកថ្នាំអោយនាង ។ សុជាតិនៅ អង្គុយខាងក្រៅ លួចមើលនារីចំលែកនោះតាមប្រលោះប្រហោងជញ្ជាំង គិតតែក្នុង ចិត្តតែម្នាក់ឯងថា :

CHANBOKEO.COM

- មើលទៅមុខមាត់រូបរាងនាងស្រស់ស្អាតសោភាណាស់.. តែហេតុអ្វីបែរជាមក មានគ្រោះភ័យយ៉ាងនេះ? គួរអោយអាណិតអាសូរនាងដល់ហើយ!

សុជាតិក៏ស្ទុះទៅរែកទឹកដាក់ពាង ហើយពុះអុសដាំទឹកក្តៅ រួចហើយក៏ទៅ ហៅម្តាយ :

- ម៉ែ! កូនដាំទឹករួចហើយ សូមម៉ែចុះមកងូតទឹកបាទ!!

ឮហើយ ស្ត្រីចាស់ក៏ប្រវេប្រវាដើរស្ទាប១ចេញមក ។ សុជាតិក៏ស្ទុះទៅកាន់ដៃ ម្តាយនាំផ្លូវ ។ ភ្លាមនោះ មីងសោមជាម្តាយក៏សួរនាយថា :

- ជាតិកូន! ឯងទៅសង្គ្រោះគេមកនេះ គិតថាត្រឹមត្រូវហើយហ្អែស?

- បាទ ! ចុះម៉ែគិតយ៉ាងណាវិញ?

- កូនដឹងទេ.. យើងក្រណាស់ ឯងរត់ឡានយកកំរៃទប់ទល់ស្បៀងប្រចាំថ្ងៃសំរាប់ យើងទាំងបីនាក់ស្ទើរមិនចង់គ្រប់មាត់ចុះដល់ទៅថែមម្នាក់ទៀត... តើនឹងពិបាក យ៉ាងណាទៀតទៅហ្អាសកូន?

- គឺ... ចេះតែរស់តាមហ្នឹងទៅណាំម៉ែ តែមួយរយៈខ្លីប៉ុណ្ណោះ ធ្វើម៉េចបើគ្មានរង គ្រោះថ្នាក់ទៅហើយ ។ ពេលណាខ្ញុំជួយនាងស៊ើបសួរដឹងផ្លូវទៅផ្ទះរបស់នាងបាន ហើយ នោះខ្ញុំនឹងជូននាងត្រលប់ទៅវិញហើយ ។

សុជាតិស្រដីផង លាយទឹកក្តៅជូនម្តាយងូតផង ស្រាប់តែសុខាកូកហៅ :

- បងជាតិមកនេះម៉ាភ្លែត ។

សុជាតិស្ទុះឡើងទៅលើផ្ទះ ឃើញនារីនោះមានទឹកមុខស្លេកស្លាំង ហើយកំពុង តែប្រវេប្រវាក្រោកអង្គុយ ។ នាយក៏សួរទៅមាណវីយើងថា :

- អ្នកនាង... អ្នកនាង... មានការអ្វីអោយខ្ញុំជួយមែនទេ?

- ចាស! គឺថា... តើ... លោកមានឃើញថង់ខ្មៅរបស់ខ្ញុំមួយទេហ៏?

- ឃើញ! គឺខ្ញុំបានយកទុកជូនអ្នកនាងហើយ ។

- អញ្ចឹងអោយខ្ញុំស៊ីវិញមក....

- បាទ !

សុជាតិក៏ស្ទុះទៅយកថង់ខ្មៅដែលព្យួរនៅជញ្ជាំងមកហុចអោយ រួចក៏សួរទៅ នាងបន្ថែមថា :

- អ្នកនាង តើផ្ទះអ្នកនាងនៅឯណាដែរ? ប្រាប់ខ្ញុំបានទេហ៏ ? ខ្ញុំនឹងជូនអ្នកនាង ទៅវិញ... (សុជាតិពោលសួរ)

ស្រាប់តែមាណវីបើកភ្នែកធំ១.... ហើយគ្រវីក្បាលតតាត់ :

- អត់ទេ... ខ្ញុំមិនអាចទៅផ្ទះវិញបានទេ... កុំយកខ្ញុំទៅផ្ទះវិញអី... ខ្ញុំសូមអង្វរ.... ខ្ញុំពិតជាមិនអាចត្រលប់ទៅផ្ទះវិញបានទេ....

រួចហើយ នារីចំលែកក៏ក្តោបមុខស្រែកទ្រហោរយំហ៊ូតែម្តង ។ សុជាតិឮនាង តបដូច្នោះ ក៏ស្រងាកចិត្តតែម្តងត្បិតនាយមិននឹកគិតសោះដែលនារីដ៏សោភាមួយ រូបដូចនាង បែរជាខ្លាចមិនហ៊ានចូលផ្ទះ ។ នាយនឹកពិភាល់ក្នុងចិត្តតែម្នាក់ឯងថា :

- ឬក៏នាងបានប្រព្រឹត្តអ្វីឆ្គាំឆ្គងហើយខ្លាចចាស់ទុំដាក់ទោសទេដឹង បានជាខ្លាច មិនហ៊ានត្រឡប់ចូលផ្ទះវិញយ៉ាងដូច្នោះ ?

រំពេចនោះ ស្រាប់តែនាយឃើញនារីចម្លែកនោះញ័រខ្លួនចំប្រប់ ទំនងហាក់ដូចជាកំពុងភិតភ័យខ្លាំងណាស់ ។ មាណពក៏សួរទៅនាងថា :

- អ្នកនាង! យ៉ាងម៉េចហ្នឹង....?

- អត់ទេ.. ខ្ញុំពិតជាមិនអាចត្រលប់ទៅផ្ទះបានទេ.. មិនអាចទេ... សូមមេត្តាកុំយក

CHANBOKEO.COM

ខ្ញុំត្រលប់ទៅផ្ទះវិញអី.... អោយខ្ញុំសូមអង្វរណា៎... ខ្ញុំមិនទៅវិញទេ.. មិនទៅទេ...

ថាផង នាងលើកដៃប្រណម្យសំពះផង រួចក៏ស្ទុះប្រវេប្រវាងើបឡើងរត់ចុះ តាមជណ្តើរបំរុងចេញទៅណាមិនដឹង.... ។ សុជាតិឃើញហើយក៏ស្ទុះរត់តាម :

- អ្នកនាងចង់ទៅណាហ្នឹង? អ្នកនាង...

តែនាងមិនបានឮមាណពហៅឡើយ ។ នាងចេះតែប្រឹងរត់ទៅមុខ ហើយចេះ តែស្រែកដដែលៗ ថា :

- អត់ទេ... អត់ទេ... ខ្ញុំមិនទៅផ្ទះវិញទេ... មិនទៅទេ... ឈប់ធ្វើបាបខ្ញុំទៅ.. ខ្ញុំ ខ្លាចហើយ....

សុជាតិងាកក្រោយស្រែកប្រាប់សុខា :

- ប្អូនចុះទៅមើលម៉ែផង ! បងរត់ទៅតាមនាងម៉ាភ្លែត...

ថាផង សុជាតិស្ទុះរត់រឹងទៅតាមនាងជិតដល់មាត់របងផ្ទះ ទើបប្រវាអោប ចង្កេះរបស់នាងជាប់យ៉ាងណែន តែនាងបែរជារើបំរះប្រទាញប្រទង់នឹងសុជាតិ យ៉ាងពេញទំហឹងទៅវិញ ។ ទ្រាំមិនបាន នាយយើងក៏ស្រែកឡើងថា :

- ពុទ្ធោអើយអ្នកនាង!! កុំរត់ឆ្វេឆ្វាក្នុងសំលៀកបំពាក់បែបនេះមើល៍! ប្រយត្ន័អ្នក ផងគេផ្អើលរត់មកចោមមើលនាង ហើយសើចពេញភូមិទៅថាអ្នកនាងជាមនុស្ស ឡប់សតិពេញតួ.....!!!

ព្ធមាណពស្តីដូច្នោះ ស្រាប់តែនាងឈប់បំរះភ្លាមមួយរំពេច ហើយក៏ឈ្ងោក មុខសម្លឹងរូបកាយរបស់នាងរួចឈរទ្រឹងតែម្តង ។ សុជាតិឃើញដូច្នោះក៏ចាប់ទាញ ដៃនាងអូសត្រឡប់ក្រោយមកផ្ទះវិញយ៉ាងលឿន ។ មាណពក៏យកសំលៀកបំពាក់របស់នាយដែលសមរម្យជាងគេមួយបន្លាស់មកហុចអោយស្រីស្រស់ :

- អ្នកនាងផ្លាស់ខោអាវសិនទៅ... ចាំយើងនិយាយគ្នាទៀត ។

មាណវីងើយមុខឡើង សំលឹងមុខបុរសយើង តាមប្រលោះសរសៃសក់ដែលធ្លាក់ចុះមកបាំងផ្ទៃមុខដ៏សោភារបស់នាង ទំនងប្រហែលចង់ស្ទង់ចិត្តនាយថា គួរទទួលយកខោអាវរបស់នាយនោះឬក៏យ៉ាងណា ។ ភ្លាមនោះ នាងក៏យកដៃច្បូត សក់សៀតត្រចៀកហើយសម្លឹងមុខមាណពយើងសាជាថ្មី ។ អូហ៍មែនហើយ! កែវ ភ្នែករបស់នាងខ្មៅថ្លាយង់ស្រទន់ថ្លាស្អាតគួរអោយគយគន់ណាស់ ។ កាលបើបានប្រទះនឹងក្រសែភ្នែករបស់មាណវីយើងភ្លាម... សុជាតិហាក់ដូចជាមានអារម្មណ៍ រំភើបប្លែកនៅក្នុងជំរៅចិត្តយ៉ាងណាមិនដឹង រកពាក្យថ្លែងមិនត្រូវសោះឡើយ ។

មន្តស្នេហ៍កែវនេត្រា

១. វាសនាថៃដន្យឱ្យបងបានយល់ នេត្រានិមល ស្រទន់ផ្អែមល្ហែមឥតបី
កែវភ្នែកល្អឯកល្ងួចគន់រំពៃ ហាក់ថ្លែងពាក្យពេចន៍មានន័យ
ជំនួសសំដីចចារ ។

២. នេត្រាខ្មៅយង់ក្បង់យកដួងចិត្ត បេះដូងបងពិត
លង់ក្នុងទេពមន្តស្នេហា ចុះចាញ់ឥទ្ធិពលទឹកដមនេត្រា
រំជើបរំជួលចិន្តា គ្មានពាក្យណាថ្លែងស្មើបានឡើយ ។

បន្ទរ. ឱ!កែវនេត្រាភ្លឺថ្លាពណ្ណរាយ ភ្លឺផ្លេកដូចផ្កាយ រះឆ្វាយឯនភាល័យ
ស្រោចស្រពសណ្តំអារម្មណ៍ភិសម័យ ជំពើបនេត្រាចរណៃ

CHANBOKEO.COM

ហឫទ័យលង់ក្តីស្នេហា ។

៣. បើសិនជាតិនេះវៀមមាននិស្ស័យ បន់រតនត្រ័យ
សូមអូនជាគូវាសនា នៃបនិត្យស្មគ្រ័ស្មោះចំពោះស្នេហា
ក្បែរម្ចាស់ដួងកែវនេត្រា លុះសង្ខារបងសូន្យទៅអើយ ។

កាលបើសង្កេតឃើញថា សុជាតិមានកិរិយាជាមនុស្សគ្មានពិលពុល ហើយ មើលទៅគេក៏ហាក់ដូចជាមានទឹកចិត្តព្រួយបារម្ភពីនាងពិតមែន នារីចំលែកយើងក៏ លើកដៃទទួលយកខោអាវពីសុជាតិទំនងខ្លាច។។ គ្រាន់តែហុចខោអាវដល់ដៃនាង ហើយ សុជាតិក៏ថយចុះចេញទៅក្រៅបាត់ទៅ ។

នារីយើងផ្លាស់សំលៀកហើយក៏ប្រាសខ្លួនទៅលើកន្ទេលវិញ ក្នុងអាការៈយ៉ាប់ យ៉ឺន ។ នាងលើកយកដៃច្បូតសក់ ហើយស្ទាបថ្ងាស សំដែងកិរិយាហាក់ដូចជាកំពុង មានកង្វល់យ៉ាងធំដែលមិនអាចស្រាយបាន ។ រំពេចនោះនាងបើកភ្នែកមើលជុំវិញ ខ្លួន ឃើញកូនផ្ទះដ៏តូចចង្អៀតមួយ គ្មានបន្ទប់ទេ មានតែវាំងននពីរផ្ទាំងចងបាំង ចែកទីសំរាប់នាំគ្នាចងមុងគេងតែប៉ុណ្ណោះ ។ ក្រៅពីនោះដូចជាគ្មានអ្វីសោះ ក្រៅពី ហិបឈើដាក់ខោអាវមួយនិងភួយមុងកន្ទេលចាស់។។ រំពេចនោះ ស្រាប់តែនាងឮ សំលេងខ្លុយយ៉ាងពិរោះរងំលាន់រវើយ។មកពីខាងក្រោយផ្ទះ ស្តាប់ឮហើយធ្វើឱ្យ មាណវីរបស់យើង រឹងរិតតែមានចិត្តស្រងេះស្រងោចខ្លោចផ្សាក្នុងចិត្តជាខ្លាំង រហូត ស្រក់ទឹកភ្នែកច្រោក។យំខ្សឹកខ្សួលតែម្នាក់ឯង.... នឹកស្រម័យដល់ជីវិតអតិតកាល របស់នាងដ៏សែនឈឺចាប់រកពាក្យបរិយាយមិនបាន។

មួយស្របក់ក្រោយមក សុខាក៏លើកថាសបបរដើរចូលមកដល់ ។ លុះនារី ក្រលេកឃើញសុខាដើរបុំងពៀច។ ផ្ទៀងផ្ទងខ្លួនកាន់ថាសបបរ មាណវីក៏ប្រឹង ក្រោកងើបឡើងមកទទួលថាសពីនាងតូច ហើយស្តីសួរថា :

- នាងតូចកើតអីបានជាមានដំណើរយ៉ាងនេះ?

សុខាលាត់ជើងអោយមើល ហើយនិយាយថា :

- ខ្ញុំមានជំងឺគ្រុនក្តៅកាលនៅពីតូច ហើយម៉ែគាត់ក្រពេក គ្មានប្រាក់ទិញថ្នាំ ព្យាបាល លុះខ្ញុំជាពីគ្រុនមកវិញ ក៏ស្វិតជើងមួយនេះរហូតអញ្ចឹងម៉ោហ៎

- ហ៊ឺ! គួរអាណិតនាងតូចណាស់ !!

ថាផង មាណវីក៏យកដៃទៅស្ទាបជើងនាងតូចផង សំដែងអាការៈហាក់ដូចជា អាណិតអាសូរសុខាក្រៃលែង ។ លុះសុខាឃើញនាងក្រោកអង្គុយបាន ហើយហាក់ ដូចជាមិនសំដែងការចុកចាប់ដូចពេលមុនទៀត ក៏នឹកឆ្ងល់ ហើយសួរឡើងថា :

- បងស្រី! បានគ្រាន់បើខ្លះហើយមែនទេហ៎?

- នៅទេ... នៅឈឺពេញអស់ទាំងខ្លួន... តែបងអាណិតប្អូនដែលប្រឹងដើរកាន់ថាស បបរមកអោយបង បានជាងើបមកជួយនោះអី ។

- អញ្ចឹង បងអង្គុយផ្អែកនឹងជញ្ជាំងសិនទៅ ចាំសុខាបញ្ចុកជូនបងណា៎ !

មាណវីឮដូច្នោះ ក៏សម្លឹងមុខនាងតូច ហើយនឹកអាណិតនាងព្រួចក្នុងពោះ :

- យើងមិនដែលស្គាល់គ្នាសោះ ប៉ុន្តែ ហេតុអ្វីក៏នាងតូចមានសន្តានចិត្តល្អជា មួយយើងម្ល៉េះ? សូម្បីតែម្តាយនិងបងប្រុសរបស់គេ សុទ្ធតែមានសទ្ធាក្នុងចិត្តគ្រប់។ គ្នា គួរអោយគោរពរាប់អានណាស់ ។

រំពេចនោះសុខាក៏សួរឡើងថា :

CHANBOKEO.COM

- បងស្រីឈ្មោះអី ជាអ្នកស្រុកអ្នកភូមិខាងណាដែរ...? ខ្ញុំចង់ស្គាល់....

មាណវីសំលឹងមុខនាងតូចមួយស្របក់ទើបឆ្លើយថា :

- បងឈ្មោះឈូក មកពីស្រុកឆ្ងាយ ប្អូនប្រហែលមិនស្គាល់ទេ ។ ចុះនាងតូចវិញ?

- ចាំស ខ្ញុំឈ្មោះសុខា !

- ឈ្មោះពិរោះណាស់... ចុះនាងតូចដែលទៅរៀននៅសាលានឹងគេទេ?

- ចាំស ធ្លាប់ទៅរៀនបានបីបួនឆ្នាំដែរ តែឥឡូវខានទៅរៀនយូរហើយ

- ហេតុអីបានជាប្អូនមិនទៅរៀនបន្តទៀត?

- មកពីសាលាឆ្ងាយ ហើយជើងខ្ញុំក៏ពិការ មិនអាចដើរទៅមកស្រួលបួលដូចគេ ដទៃ។ ណាមួយត្រូវនៅផ្ទះជួយមើលម៉ែព្រោះគាត់ងងឹតភ្នែកផង រីឯបងជាតិវិញ ចេញទៅរត់ឡានពីព្រលឹមទល់ព្រលប់ មិនមានពេលឌុបកង់នាំខ្ញុំទៅរៀនសោះ ឡើយ អញ្ចឹងហើយ បានជាខ្ញុំឈប់រៀនបណ្តោយទៅ ។

- ចុះប្អូនមានចង់ទៅរៀនវិញទេ?

- ចង់ណាស់ តែ..... តើអោយខ្ញុំទៅយ៉ាងណា បើ...

- បើបងស្មគ្រ័បង្រៀនប្អូននៅផ្ទះ តើប្អូនចង់រៀនទេហ៎?

- ជយោ! មើលទៅបងឈូកប្រហែលចេះអក្សរជ្រៅជ្រះហើយ!

- ចេះតិចតួចទេ តែល្មមចែកទៅប្អូនបានខ្លះណាំ

សុខាឮដូច្នោះក៏សើចកក្អឹកឡើង :

- មែនហើយ! ខ្ញុំចង់ចេះអក្សរណាស់ នឹងអាលបានមើលសៀវភៅរឿងប្រលោម លោកនិងសៀវភៅចំរៀង ។ បងដឹងទេ? ខ្ញុំចូលចិត្តច្រៀងណាស់ណាំ។

ឈូកអង្គុយញញឹមភ្លេចការឈឺចាប់អស់រលីង កាលបើឮនាងតូចស្រដីរួសរាយ ដាក់នាងយ៉ាងសប្បាយដូច្នោះ ។ មាណវី ក៏សួរទៀតថា :

- ហើយចុះនរណាគេផ្លុំខ្លុយអំបាញ់មិញ ពិរោះដល់ហើយ! ជាបងប្រុសរបស់ប្អូន មែនទេហ៎?

- ចាំស! មែនហើយ! បងជាតិពូកែផ្លុំខ្លុយនិងផ្លុំស្លឹកណាស់ អោយតែមានពេល ទំនេរ គាត់តែងផ្លុំលេងអោយម៉ែស្តាប់ជានិច្ច ជាពិសេសកំដរកុំអោយម៉ែគាត់អផ្សុក ពេក។ ម្យ៉ាងទៀត ខ្ញុំធ្លាប់ឮបងជាតិធ្លាប់និយាយប្រាប់ថាកាលពុកនៅរស់ គាត់ តែងតែផ្លុំស្លឹកឱ្យម៉ែស្តាប់រាល់ថ្ងៃ។ លុះពុកគាត់អនិច្ចកម្មទៅ ម៉ែក្រៀមក្រំពិបាក ចិត្តពេកហើយយំទាល់តែងងឹតភ្នែក។ ម្ល៉ោះហើយ ទើបរាល់ពេលទំនេរ បងជាតិ បេះស្លឹកមកផ្លុំ ជួនកាលផ្លុំខ្លុយលួងលោមចិត្តម៉ែ រាល់ថ្ងៃជាទំលាប់រហូតមក ។

ឮនាងតូចរៀបរាប់ដូច្នោះ មាណវីយើងរឹងរិតតែអាណិតនាងតូចឡើង ដែល កំព្រាឪពុកតាំងពីតូចក្រួចឆ្មារ ។ រីសុខាក៏មានសំដីរួសរាយ គួរអោយស្រលាញ់ ណាស់។ ទាំងពីរនាក់ជជែកគ្នាយ៉ាងសប្បាយហើយស្និទ្ធស្នាលបំផុត ធ្វើអោយ មាណវីយើងមានអារម្មណ៍ហាក់ដូចជាកក់ក្តៅជាងមុនច្រើន ហើយភ្លេចអស់ទុវការ ឈឺចាប់ផ្លូវកាយទាំងឡាយ។ បន្តិចមក សុជាតិក៏នាំម្តាយឡើងទៅលើផ្ទះវិញ។ លុះឃើញធិតាក្រោកអង្គុយជជែកគ្នាជាមួយសុខា ហើយឃើញស្លៀកខោអាវរបស់ នាយទៀត មាណពធ្វើញញឹម១ទឹកក្នុងចិត្ត ថា :

CHANBOKEO.COM

- ថ្វីបើគេស្ថិតនៅក្នុងសំល្បៀករបៀបនេះទៅហើយ តែគេនៅមានសោភ័ណគួរ អោយសរសើរ
បើសិនណាបានស្លៀកពាក់របៀបអ្នកទីក្រុងដ៏ល្អៗត្រឹមត្រូវទៀត មិនដឹងជាស្រស់ស្អាតយ៉ាងណា ហ្ន៎? ប្រហែលជាមិនចាញ់តារាភាពយន្តខ្មែរទេ។

ភ្លាមនោះ សុខាបន្លឺវាចាប្រាប់បងប្រុសថា :

- បងជាតិ! បងស្រីខាងនេះឈ្មោះបងឈ្យូក ចេះអក្សរច្រើនណាស់ ហើយគាត់ថា នឹងបង្រៀនខ្ញុំថែមទៀតផង ។

ពុទ្ធោអើយ ! នាងតូចរាយការណ៍យ៉ាងអស់រលីងធ្វើអោយនារីយើងនឹកអៀន ឡើងរីងខ្លួនតែម្តង ។ សុជាតិព្វបួនស្រដីដូច្នោះ ក៏ងាកទៅមាណវី ហើយស្រដីថា :

- សូមអ្នកនាងថែខ្លួនផងណា៎... ហើយអោយខ្ញុំសូមទោសជំនួសប្អូនស្រីដែលប៉ប៉ាច់ ប៉ប៉ោចរំខានអ្នកនាង ។

ឈ្យូកញញឹម ហើយតបវិញថា :

- ប្អូនមិនបានរំខានខ្ញុំទេ... ការពិតនាងជាមនុស្សគួរអោយស្រលាញ់ណាស់!

សុខាឮហើយ ក៏ញញឹមខ្មិបដាក់បងប្រុសខ្លួនភ្លាម ។ សុជាតិយកដៃអង្អែល ក្បាលប្អូនហើយពោលបន្តទៅទៀតថា :

- សុខា! បងទៅក្រៅម៉ាភ្លែត... អូននៅមើលជួយបំរើម៉ែនិងបងស្រីផងណា៎!

- ចាំស!

ថាហើយ សុជាតិក៏ចេញទៅ ។

បន្តិចក្រោយមក ឈ្យូកក៏ឮសូរសម្លេងត្បាល់បុក ក៏សួរទៅសុខាថា :

- បងប្រុសរបស់ប្អូនកំពុងធ្វើអ្វីហ្នឹង?

- មិនដឹងដែរ បង! ប្រហែលជាបុកថ្នាំទេដឹង?

មួយភ្លែតក្រោយមក មាណពក៏ចូលមកដល់ ហើយក៏ពោលទៅកាន់នាងថា :

- ខ្ញុំបុកថ្នាំបិទខ្មែរបិតរបួសជូនអ្នកនាង បើទុកអោយរបួសចំហមុខយូរ ខ្លាចវាដរ ក្លាយជាដំបៅកាន់តែធ្ងន់ នាំតែពិបាកព្យាបាល ។

ឈ្យូកឃើញហើយធ្វើមុខហាក់ដូចជាខ្ពើមពំនូតថ្នាំបុកនោះណាស់ ក៏ឆ្លើយថា :

- គឺ.... ខ្ញុំបានគ្រាន់បើហើយ មិនបាច់បិទថ្នាំបុកក៏បានដែរ....

តែសុជាតិបែរជាទទូច :

- ពាក្យចាស់លោកថា ការក្រកុំគិតងាយ បើសិនជាមានថ្នាំហើយ គួរតែព្យាបាល!

ប្រកែកមិនបាន មាណវីក៏ឈប់មាត់ ហើយបណ្តោយអោយបុរសយើងយកថ្នាំ បុកមកបំពកបិទរបួសអោយនាង ដោយមានសុខាជាអ្នកជួយជាដៃជាជើង ។ នៅ គ្រានោះ បុរសយើងហាក់ដូចជារំភើបរំជួលក្នុងចិត្តអ្វីម៉្លេះដែលមានមកកាន់ប៉ះដៃ ប៉ះជើងនារីរូបស្អាតម្នាក់ តែធ្វើម៉េចទៅ... បើគេស្ថិតក្នុងភាពទាល់ច្រកទៅហើយ ។ ហ៊ឺ ! មើលចុះ!សាច់នាងសត្រសូលគួរអោយបេតីម៉្លេះលោកអើយ! សុជាតិបំពកថ្នាំ លើរបួសរបស់តរុណីបណ្តើរ ញាប់ញ័របេះដូងបណ្តើរ ហើយលួចគយគន់សំរស់នាង កោតសរសើរតែក្នុងចិត្តម្នាក់ឯងបណ្តើរ ។

រីឯឈ្យូកវិញក៏ដូចគ្នា។ នាងនឹកព្រឺព្រួចរន្ធត់នៅក្នុងចិត្តយ៉ាងណាមិនដឹងទេ ដែលបណ្តោយអោយបុរសមិនស្គាល់គ្នាសោះមកប៉ះសាច់មុខក្រោយ គួរអោយតឹង ចិត្តណាស់!

CHANBOKEO.COM

ទាំងពីរនាក់គិតក្នុងចិត្តនឹកខ្មាសក្នុងចិត្តតែរៀង១ខ្លួន ។ តែក៏គ្រាន់បើ ដែរដែលនារីយើងអាល័យតែនឹកខ្មាស់សុជាតិ
ក៏ហាក់ដូចជាភ្លេចការឈឺផ្សាចំពោះ ស្នាមរបួសទាំងឡាយនោះអស់រលីងតែម្ដង ។

រសៀលបន្តិចនាថ្ងៃដដែល....

ឈូកកំពុងតែធ្មេចសំងំគេងរំងាប់ការឈឺចាប់ ស្រាប់តែសម្លេងមនុស្សស្រី
កួកហៅ :

- សុខា! នៅផ្ទះទេអូន? សុខា...

ឈូកប្រែខ្លួនលួចមើលតាមប្រហោងជញ្ជាំង ឃើញនារីម្នាក់ក្នុងវ័យប្រហែល
២០ឆ្នាំ ជិះម៉ូតូចូលមកដល់ថែមទាំងមានយួរចានស្រាក់មួយមកផង ។ សុខាក៏រត់ចុះ
ទៅទទួលទាំងត្រេកអរកខិបកខុប :

- បងនីម! មានអីផ្ញើខ្ញុំហ្នឹង? ធំឈ្ងុយដល់ហើយ ធ្វើឱ្យសុខាស្រក់ទឹកមាត់តែម្ដង!

នីមសើចហើយក្រឡេកទៅឃើញមីងសោមអង្គុយក្បែរមាត់ជណ្ដើរផ្ទះក៏លើក ដៃសំពះសួរភ្លាម :

- ជំរាបសួរមីង ! ខ្ញុំមានសម្លប្រហើរទំពាំងយកមកផ្ញើ!!

មីងសោមឮហើយក៏មានប្រសាសន៍តបវិញ :

- អរគុណណាស់នីមអើយ! ឯងយកសម្លមកអោយមីងញឹកញាប់យ៉ាងនេះ មីងមិន ដឹងមានអ្វីសងក្មួយវិញទេ...

- ជាសន្តានចិត្តបន្តិចបន្តួចរបស់ខ្ញុំទេ មីងកុំបារម្ភអី... ហើយចុះបងជាតិនៅទេមីង?

- នៅ... តែទៅឯក្រោយផ្ទះរែកទឹកស្រោចចំការថ្នាំជក់ឯណោះ ។

នីមក៏ហុចចានស្រាក់អាហារអោយទៅសុខាយកទៅទុកដាក់ហើយ ក៏ដើរ សំដៅចំការថ្នាំជក់ឯក្រោយផ្ទះ ។ ទទួលពេលនោះ
សុជាតិក៏រែកទឹកមកដល់ល្មម ។ នីមក៏ពោលឡើងទាំងញញឹមទៅមាណពយើងថា :

- បងជាតិ! ថ្ងៃនេះឆាប់មកដល់ផ្ទះម្ល៉េះ?

សុជាតិឃើញមាណវីហើយក៏ញញឹមរួចតបវិញថា :

- បងមានការបន្តិចបន្តួច... ហើយចុះនីមវិញ? ថ្ងៃនេះហេតុអីក៏អូនមកដល់ នេះដែរ ?
ឮថានៅរោងម៉ាស៊ីនកិនស្រូវរបស់នីមឥឡូវរវល់ណាស់មែនទេ?

នីមសើចខឹក១ :

- គ្រាន់តែនីមនឹកបងហើយមកលេងផងមិនបានទេហ៍? នេះ ! ខ្ញុំយកសម្លប្រហើរ មកផ្ញើបងនិងមីងផងណា៎!!

- មែនហ្អែស? ស្រេចហើយ! នីមមកលេងកាលណា មានអាហារផ្ញើកាលហ្នឹង ។ អោយតែយ៉ាងនេះចុះ
បងចង់អោយនីមមកលេងបងរាល់ថ្ងៃតែម្ដង !

នីមសើចខឹក១ រិតតែខ្លាំងថែមទៀតដោយឃើញសុជាតិលលេង ។ ឈូកលួច
គន់មើលអ្នកទាំងពីរយ៉ាងស្ងៀមស្ងាត់ពីលើផ្ទះ ឃើញគេទាំងពីរសើចរអឹកនិយាយ លលេងដាក់គ្នាយ៉ាងស្និទ្ធស្នាល ។
ឈូកឃើញគេទាំងពីរដើរបណ្ដើរកាន់ដៃគ្នាបណ្ដើរ ច្រៀងផ្ដោះផ្ដងបណ្ដើរ ក៏នឹកក្នុងចិត្តតែម្នាក់ឯងថា :

- សង្ស័យតែគេជាសង្សារនឹងគ្នាហើយ...

រំពេចនោះ នាងក៏បានឮនីមនិយាយទៅកាន់សុជាតិថែមទៀតថា :

CHANBOKEO.COM

- ព្រឹកមិញ ខ្ញុំឮដំណឹងថា នៅចុងស្ពានអូរតាគី មានឡានក្រឡាប់ធ្លាក់ទឹកមួយ នីម ភ័យអើយភ័យ ខ្លាចតែបងជាតិមានគ្រោះថ្នាក់ តែដល់អ្នកស្រុកស្រង់សពចេញពី ក្នុងទឹកនោះមកទើបដឹងថាជាបុរសម្នាក់ផ្សេង ខ្ញុំក៏ធូរទ្រូងខ្សាក ។

- អូហ៎ ហើយចុះមាននរណាស្គាល់ទេ ថាបុរសនោះជានរណា?

- មិនស្គាល់ទេ គ្រាន់តែដឹងថា ប្រហែលជាអ្នករត់ឡានឈ្នួលដូចបងអញ្ចឹងដែរ ។

ឈូកឃើញសុជាតិលួចមើលមកឈូកឯលើផ្ទះជាញឹកញាប់ ហើយមានកាល ក៏ប្រទាក់នឹងកែវភ្នែករបស់នាងដែរ ប៉ុន្តែមាណវីមិនបានឮសុជាតិនិយាយអ្វីអំពី វត្តមានរបស់នាងក្នុងគ្រួសាររបស់គេចំពោះនីមសោះ សូម្បីតែហៅនាងក្រមុំនោះឡើងអង្គុយលេងនៅលើផ្ទះក៏មិនមានផង ឃើញតែនៅអង្គុយជជែកគ្នា ឯលើគ្រែ ឫស្សីក្រោមម្លប់ដើមត្របែកខាងចំហៀងផ្ទះរហូត ។ មួយស្របក់ក្រោយមក នីមក៏លាត្រឡប់ទៅផ្ទះវិញ ។

ព្រលប់នោះ ឈូកខំត្រដររក្រោកអង្គុយចូលរួមបរិភោគបាយជាមួយគ្រួសាររបស់សុជាតិ ទោះបីជានាងនៅមានការចុកចាប់នឹងរបួសដ៏ធ្ងន់ធ្ងរក៏ដោយ ត្បិតនាង មានអារម្មណ៍ថាគេហាក់ដូចជាបារម្ភចំពោះរូបនាងគ្រប់ៗគ្នា ។ ធិតាមិនចង់អោយ គេត្រូវអំពល់ទុក្ខច្រើនចំពោះនាង ។ រីឯអាហារបរិភោគក៏មានរសជាតិខុសប្លែក យ៉ាងណាមិនដឹង ទំនងដូចជាខ្សត់អត្តខាត់ណាស់ ។ យ៉ាងណាក៏នាងមិនហ៊ានរអ៊ូអ្វី ដែរ គ្រាន់តែបរិភោគមិនសូវចូលប៉ុណ្ណោះ ។ ប៉ុន្តែដើម្បីអោយមានកំលាំងហើយឆាប់ជាសះស្បើយឡើងវិញ ឈូកក៏ប្រឹងលេបទាំងត្រដរ...

ក្រោយពេលបរិភោគបាយល្ងាច...

មីងសោមអង្គុយរៀបចងកញ្ចប់ថ្នាំជក់ទាំងពពឹមពពើម ។ ឈូកឃើញហើយ នឹកឆ្ងល់ក៏សួរថា :

- អត់ទោស!  មីងពិសារថ្នាំជក់ដែរ?

- អូហ៎ អត់ទេកូនស្រីអើយ... គឺមូរទុកអោយសុខាយកទៅបោះដុំអោយគេ

នាងសម្លឹងមុខមីងសោម ហើយសំលឹងមុខសុជាតិដែលនៅអង្គុយមូរស្លឹកថ្នាំ ញាត់ដាក់ក្នុងអីហាន់ថ្នាំ ។ នាងក៏នៅតែនឹកឆ្ងល់ដដែល :

- នៅសម័យឥឡូវ អ្នកស្រុកគេនាំគ្នាទិញបារីកញ្ចប់ផលិតពីបរទេសអស់ហើយ.. បើមីងលក់ថ្នាំដាំហាន់ដៃ យ៉ាងនេះ តើមានគេទិញដែរឬទេមីង...?

- មានខ្លះដែរណាក្មួយ ជាពិសេស អ្នកស្រែក្រីក្ររកលុយទិញបារីមិនបាន ក៏ចេះតែ នាំគ្នាទិញរបស់ដែលដាំក្នុងស្រុករបស់យើងទៅ... វាថោកហើយបានច្រើនផង ។

ឈូកឃើញជីវភាពអ្នកទាំងបីអត្តខាត់ណាស់ តែគេហាក់ដូចជាស្រឡាញ់ គ្នាហើយយកចិត្តទុកដាក់ចំពោះគ្នាក្រៃលែង ។ មើលចុះ! សូម្បីតែរូបនាងដែលជា អ្នកក្រៅសោះ ក៏គេនៅតែបែងចែកនូវភាពកក់ក្តៅនៅក្នុងគ្រួសាររបស់គេមកឱ្យ នាងដោយឥតកំណាញ់សោះឡើយ មានអ្វីបរិភោគហ្នឹងដូចគ្នា ។ ម្យ៉ាងទៀត នាងក៏ លួចសង្កេតមើលសុជាតិមួយថ្ងៃហើយ ឃើញតែរត់ធ្វើនេះធ្វើនោះ មិនឈប់ដៃទេ ប៉ុន្តែនាយនៅតែអើតមើលសុខទុក្ខនាងជាច្រើនដងមិនដាច់សោះ ។ មិនត្រឹមតែ ប៉ុណ្ណោះថែមទាំងរំលឹកសុខាអោយមកកំដរនាងទៀតផង ។

សុខាជួយរៀបកញ្ចប់ថ្នាំជក់ហើយ ហើយស្ទុះទៅចងមុងរួចក៏ចូលគេងជាមួយ មីងសោមបាត់ទៅ ។ មើលទៅនាងហាក់ដូចជាអស់កំលាំងដែរ ដែលនៅអង្គុយបំរើ ឈូកពេញមួយថ្ងៃកន្លងមក ។ លុះឃើញសុខាភ្លេចចងមុងអោយឈូក សុជាតិមិន ហ៊ានដាស់ប្អូនមកវិញ ក៏ងើបទៅចងមុងជំនួស ។ ឈូកលួចគយគន់មើលកិរិយា របស់នាយមិនដាក់ភ្នែកទេ ធ្វើអោយសុជាតិចាប់ភ្លឹកតែម្តង :

- អ្នកនាងមានការចង់ប្រាប់ខ្ញុំអំពីរឿងអ្វីមែនទេ បាទ?

ឈូកឮហើយ ក៏លើកដៃប្រណម្យសំពះសុជាតិ :

CHANBOKEO.COM

- គឺ ខ្ញុំ... សូមអរគុណបងប្រុស និងក្រុមគ្រួសារដែលមានទឹកចិត្តជួយយកអាសារ ឈូកនៅពេលនេះ !

សុជាតិភ្ញាក់ព្រើត លូកដៃចាប់ដៃឈូកទំលាក់មិនអោយនាងសំពះ :

- អូហ៎ គឺ... មិន... ជាគុណស្រ័យអ្វីទេ អ្នកនាង.... កុំសំពះខ្ញុំអី...

គ្រាន់តែដៃអ្នកទាំងពីរប៉ះគ្នាភ្លាម សុជាតិក៏ដូចឈូកដែរ មានអារម្មណ៏ហាក់ ដូចជាត្រូវរន្ទះភ្លើងអគ្គិសនីឆក់យ៉ាងដូច្នោះឯង ធ្វើអោយបេះដូងរបស់គេរំភើប ញាប់ញ័រទាំងពីរនាក់ដោយស្វ័យប្រវត្តិ រកពាក្យណាមកបរិយាយអោយសមស្មើ មិនបានឡើយ ។ ឈូកភ្ញាក់ព្រើតដកដៃមកវិញយ៉ាងរហ័ស ធ្វើអោយសុជាតិនឹក រអៀសខ្លួនយ៉ាងខ្លាំង ហើយក៏ស្ទុះគេចខ្លួនទៅម្ខាង ធ្វើកិរិយាអេះអុញៗ.. ក្ដៅមុខ ក្ដៅមាត់ភាយៗ ដូចគេអាំងភ្លើងខែចំរូតដូច្នោះឯង.... ក្នុងឱកាសដដែល ឈូកបែរ មុខទៅម្ខាងយកសក់បាំងមុខ មិនហ៊ានសម្លឹងប៉ះក្រសែភ្នែករបស់សុជាតិជាថ្មី ។

នៅពាក់កណ្ដាលអាធ្រាត....

ធិតាយើងភ្ញាក់ស្មារតីឡើងវិញ ដោយការឈឺចាប់ចំពោះមុខរបួសទាំង អំបានម៉ាន ។ នាងមិនហ៊ានស្រែកថ្ងូរទេព្រោះខ្លាចធ្វើឱ្យអ្នកក្នុងផ្ទះគេភ្ញាក់ពីដំណេក ក៏ទ្រាំខាំមាត់សង្កៀតធ្មេញទាំងបែកញើសស្រាក់ ។ រំពេចនោះនាងប្រែខ្លួនទៅម្ខាង ស្រាប់តែដាក់ភ្នែកទៅឃើញសុជាតិគេងដណ្ដប់ក្រមាកញ្ចាស់មួយនៅក្បែរមាត់ទ្វារតែម្នាក់ឯង ។ ក្រោមពន្លឺព្រះចន្ទ័ដ៏ស្រទន់ ចាំងជះចូលមកក្នុងគេហដ្ឋានដ៏កំសត់ តាមបង្អួចមួយ ដែលសុជាតិបើកចំហទុកចោលដើម្បីអោយមានអាកាសចេញចូល ឈូកឃើញ សុជាតិគេងអោបដៃស្ងៀមស្ងាត់ តែគ្មានមុងចងការពារមូសទេ ។ យូរៗម្ដង នាង ឃើញគេលើកដៃទះមូសហើយប្រែខ្លួន រួចក៏បន្តដំណេកទៅទៀត ។ ស្រាប់តែ នារីយើងមានអារម្មណ៏ថា នាងឈឺពោះត្រូវការចូលបន្ទប់ទឹក ក៏ងើបក្រោកឡើង ដើរលបៗរំលងសុជាតិហើយបើកទ្វារចុះចេញទៅក្រៅ ហើយ ទំលាក់ខ្លួនឈានចុះតាមកាំជណ្ដើរបំពង់ឬស្សីយឺតៗ ។ ភ្លាមនោះស្រាប់តែមានដៃ មកប្រវាអោបចង្កេះរបស់នាងពីក្រោយជាប់ ព្រមទាំងមានសំដីឃាត់នាងផង :

- អ្នកនាងចង់ចេញទៅណាទាំងយប់យ៉ាងនេះ? កុំទៅអី ក្រែងមិនសុខសប្បាយ...

ឈូកបែរក្រោយក្រលេកមើលទៅ ឃើញសុជាតិប្រវាប្រទាញកាយនាង អោយត្រឡប់ចូលមកខាងលើផ្ទះ វិញ ។ នាងក៏ឆ្លើយតបវិញ :

- លែងខ្ញុំសិនទៅ! ខ្ញុំមិនទៅណាទេ គ្រាន់តែ... ត្រូវការបន្ទប់អនាម័យ ។

សុជាតិឮដូច្នោះក៏ព្រលែងដៃវិញ :

- អូហ៎! អោយខ្ញុំសូមទោសផងណា៎ ! អំបាញមិញ ខ្ញុំបានគិតច្រឡំស្មានថាអ្នកនាង បំរុងរត់ចេញទៅ...

- អត់ទេ គឺ... មកពីខ្ញុំមិនហ៊ានដាស់បងប្រុសអោយជូនផ្លូវទេតើហ៎...

សុជាតិសម្លឹងមើលទៅនាង ឃើញមានដំណើរចឹងចោង ក៏ស្ទុះទៅជួយគ្រាហ៎ ឡើង នាំនាងទៅបន្ទប់ទឹកនៅខាងក្រោយផ្ទះ ។ កាលបើមានបុរសមកប៉ះរូបកាយ របស់នាងជាច្រើនដង ឈូកហាក់មានអារម្មណ៏ប្លែកយ៉ាងណាមិនដឹងទេ ពិបាកនឹង រៀបរាប់ណាស់ ប៉ុន្ដែដោយខ្វះមធ្យោបាយជួយខ្លួនឯង នាងត្រូវតែស៊ូទ្រាំទទួលនូវ ជំនួយរបស់គេ ។ រីឯការប្រកាន់ខ្លួនត្រូវតែទុកនៅមួយកន្លែងសិន ។ មួយស្របក់ ក្រោយមក សុជាតិក៏នាំឈូកត្រឡប់មកដល់មុងរបស់នាងវិញ ហើយក៏នៅអង្គុយ កំដរនាងនៅចុងជើងខាងក្រៅមុង រង់ចាំរហូតដល់នាងប្រាសគេងដណ្ដប់ភួយស្រួល បួលហើយទើបនាយវិលទៅកាន់ដំណេករបស់ខ្លួន ។

ព្រឹកស្អែកឡើង...

CHANBOKEO.COM

សុជាតិក្រោកពីព្រហាមស្រាង១ចេញទៅរត់ឡានឈ្នួលដូចរាល់ដង។ តែមុន នឹងចេញដំណើរ នាយបានដាស់សុខាមកផ្តាំថា :

- សុខា... ថ្ងៃនេះមិនបាច់ទៅលក់ថ្នាំទេ ចូរប្អូននៅផ្ទះជួយមើលម៉ែនិងបងស្រី ផងណាំ ។ បងស្រីកំពុងឈឺមិនស្រួលខ្លួន ប្អូនកុំដើរចោលអោយសោះ ឮហើយនៅ? រសៀលបន្តិចបងមកវិញហើយចាំបងទិញអាហារមក ប្អូនដាំតែបាយចាំបងចុះ។

- ចាំសបង! ហើយចុះថ្ងៃរណាបងវិលមកផ្ទះវិញ?

- បងគិតថា ថ្ងៃនេះបងនឹងឆាប់មកវិញ ព្រោះខ្លាចប្អូនត្រូវនឿយ មើលម៉ែផង មើលបងស្រីបងតែម្នាក់ឯង។ បងទៅសិនហើយណាំ!

- ចាំសបង!

ពេលនោះឈ្យូកបានឮសំដីរបស់សុជាតិគ្រប់ម៉ាត់ទាំងអស់ សូម្បីនាយប្រឹង និយាយខ្សិបតិច១ក៏ដោយ ។ ឃើញទឹកចិត្តដ៏ទូលំទូលាយរបស់នាយ ឈ្យូកហាក់ ដូចជាមានអារម្មណ៏រំភើបប្លែកខុសធម្មតាតែម្តង ។ ទោះបីពេលនេះ នាងឈឺចាប់សព្វរាងកាយក៏ដោយ ក៏នាងភ្លេចការចុកចាប់អស់រលីង ហើយប្រែជាមានចិត្ត រីក រាយកក់ក្តៅយ៉ាងចំលែក...

## បេះដូងមានសង្ឃឹម

(កំរងកែវ)

១. កក់ក្តៅក្នុងចិត្តណាស់ កាលបើបានយល់ភក្ត្រាអ្នកញញឹម
បេះដូងក៏មានក្តីសង្ឃឹម ព្រោះតែអ្នកមានចិត្តប្រណីមេត្តា
ជីវិតដ៏ក្រៀមស្រពោន ប្រែជាមានភាពស្រស់ភ្លឺថ្លា
នេះព្រោះតែភាពករុណា ដែលជីវ៉ាប្រគល់ចំពោះស្រី ។

២. ខ្ទមកំសត់តូចមួយព្រួយ ខ្ទះដំបូលប្រក់ ជញ្ជាំងបាំងបិទ
តែបែរក្លាយជាវិមានអម្រិត ជាម្លប់យ៉ាងប្រណិតដល់អ្នករងទុក្ខភ័យ
កន្ទេលកក់រហែក ក្លាយជាគ្រែទែនយ៉ាងស្អាតក្នុងប្រាង្គស្ពឹមស្ពៃ
នេះក៏ព្រោះតែហឫទ័យរបស់អ្នកដែលប្រកបដោយគុណធមិជ្រះថ្លា ។

៣. សូមអរគុណ! អរគុណចំពោះទឹកចិត្តដ៏សែនទូលំទូលាយ
ពិតជាគ្មានពាក្យណាបរិយាយអោយសមស្មើនឹងចិន្តា
លោកពិតជាអ្នកមានបុណ្យ ជាព្រះ ជាឥន្ទទេវតា
ចំពោះនារីកំពុងលង់ទុក្ខសោកា ស្ទើរមរណាក្ស័យលាលោកទៅ!

CHANBOKEO.COM

# វគ្គទី៣
# បក្សីស្លាបមាស

ក្នុងវីឡាមួយដ៏ស្កុកស្កម្ភ នាក្រុងភ្នំពេញ...

ឆវីស្រស់ឆើតឆាយមួយរូបតែងខ្លួនយ៉ាងមានសោភ័ណក្រៃលែង ពាក់វ៉ែនតា ខ្មៅ ដើរចេញពីបន្ទប់ចុះតាមកាំជណ្តើរដ៏ប្រណិត ថែមទាំងស្រែកថា :

- នាងធឿន... ទៅយកស្បែកជើងកែងចោទអោយខ្ញុំម៉ាគួម៉ោហ៏!
- ចាស! អ្នកនាង!

ស្រីបំរើម្នាក់ស្ទុះរត់ទៅយកមកអោយ ស្រាប់តែឆវីរូបស្រស់ស្រវាបោះចោល ទាំងកំហឹង វិះតែត្រូវក្បាលអ្នកបំរើ :

- មិនមែនអាមួយហ្នឹងទេ! យីស! វាហួសសម័យនឹងពាក់ហើយ! ឆាប់ទៅយកអា ម៉ាគូដែលខ្ញុំទិញពីផ្សារសុរិយា កាលម្សិលមិញនោះម៉ោហ៏ !
- ចាស១!

ភ្លាមនោះ នារីសោភាម្នាក់ក៏ចូលមកដល់ ។ លុះក្រឡេកឃើញឆវីរូបស្រស់ កំពុងពាក់ស្បែកជើង មាណវីក៏សួរឡើងថា :

- បងដាវីយ៉ា! ថ្ងៃនេះចេញទៅណាទៀតហើយហ្នឹង ?
- នែ៎កុំចេះ! នាងក្រពុំចិត្ត... បងធ្វើអ្វីស្រេចតែបង ចង់ទៅណាក៏ទៅទៅ កុំរំខាន

មើសឹ! បើអត់លុយចាយ នុ៎ះហ្ន៎! ប៉ានៅលើផ្ទះ មិនទាន់ចេញទៅធ្វើការទេ ឆាប់ ទៅសុំទៅ!

តិចប្រយត្ន័គាត់យកលុយទៅចែកកន្លែងពិសេសផ្សេងៗអស់ ។

ដាវីយ៉ាថាហើយស្ទុះដើរកុបៗចូលរថយន្ត ហើយបរចេញទៅលាន់ឮងយ៉ាងខ្ទ័រ ទុកអោយក្រពុំចិត្តឈរមើលចំហមាត់ពីក្រោយ ។វំពេចនោះ ស្ត្រីមួយរូបក្នុងវ័យ សាមប្លាយ មានរូបរាងស្រស់ស្អាតស្បែកពាក់យ៉ាងហ៊ឺហាដើរចុះមកដល់ដែរ ។តែគួរចម្លែកណាស់ នៅដើមដៃឆ្វេងនិងនៅថ្ពាល់ឆ្វេងរបស់ស្ត្រីរូបនោះ មានស្នាម ជាំកន្ទួលគួរឱ្យកត់សំគាល់ ទំនងដូចជាបានទទួលការវាយដំជាខ្លាំងផង។ កាលបើ ក្រឡេកឃើញនារីយើង ភ្លាម អ្នកស្រីក៏មានប្រសាសន៏ឡើង :

- ក្រពុំចិត្ត! ថ្ងៃនេះ ម៉ាក់ចេញទៅក្រៅ មិនបានមកបាយផ្ទះជាមួយកូនវិញទេ ។

ថាហើយ អ្នកស្រីក៏បក់ដៃហៅស្ហ៊ូវឡាន បរនាំអ្នកស្រីចេញទៅរកតែកូន ស្រីស្រដីសួរអ្វីមិនទាន់ឡើយ ។ នាងធឿន ស្រីបំរើគ្រវីក្បាល :

- ថ្ងៃនេះសង្ស័យតែអត់មានអ្នកណាពិសាបាយផ្ទះទៀតហើយ អ្នកនាងក្រពុំចិត្ត!
- តែ.... ក្រែងនៅមានលោកប៉ាដែរតើហ៏ណាំធឿន !!

វំពេចនោះ ស្រាប់តែបុរសចំណាស់ម្នាក់វ័យហាសិបប្លាយឆ្នាំ ស្លៀកពាក់ថ្លៃថ្នូរ ចុះជណ្តើរមកដល់ ហើយ និយាយទៅកាន់នារីសោភាយើងថា :

CHANBOKEO.COM

- ក្រពុំចិត្ត! ថ្ងៃនេះមិនទៅរៀនទេហ៎ ?

- ចាំសប៉ា ! ទៅនៅម៉ោង២ ឯណោះ !

- អឺ! ខំរៀនទៅ! ណេះ យកប្អូនរយដុល្លារទៅចាយលេងទៅណាំ ។ ថ្ងៃនេះ ប៉ាមិន មកផ្ទះទេ  អាល័យមានការបន្តិច....

ថាហើយ លោកក៏អោយស្វហ្វ័រឡានជូនចេញទៅដែរ ។ ក្រពុំចិត្តឈរមើល ភាំង ទំនងហាក់ដូចជាខកចិត្តណាស់ ។ គ្រួសារនាងមានគ្នាដល់ទៅប្អូននាក់ មាន ទ្រព្យសម្បត្តិចាយវាយមិនអស់ តែបែរជាគ្មានពេលជួបជុំគ្រួសារបរិភោគបាយជា មួយគ្នាសោះ ។ មើលចុះ! រាប់ឆ្នាំមកហើយ ថ្ងៃណាក៏ដូចថ្ងៃណាដែរ នាងមិនដែល បានឃើញមុខសមាជិកគ្រួសាររបស់នាងអោយបានលើសពីកន្លះម៉ោងទេ ។ ធិតា

ឈរទ្រឹង កាន់ប្រាក់ប្អូនរយដុល្លារនៅក្នុងដៃ ធ្វើមុខស្ងួត ។ ភ្លាមនោះ នាងធឿន ស្រីបំរើក៏ស្រដីកំប្លែងឡើង :

- បើអត់គ្នាដើរផ្សារទេ ខ្ញុំអាចជូនអ្នកនាងបានណាំ!!

តែតរុណីមិនឆ្លើយតបចំពោះនាងធឿនវិញទេ បែរជាក្តាប់លុយនោះក្នុងដៃ ឈរយំរលីងរលោងទឹកភ្នែកទៅវិញ ។ នាងធឿនឃើញដូច្នោះ នឹកភ័យខ្លួនក៏គេច ទៅបាត់ស្រមោល ។

រសៀលបន្តិច ក្រពុំចិត្តក៏ស្លៀកពាក់ក្រងសក់យ៉ាងស្អាតបើករថយន្តចេញ ទៅ។ ប៉ុន្តែ នាងមិនបានទៅរៀនសាលា ដូចដែលនាងបានជំរាបលោកប៉ានាងទេ ។នាងអផ្សុកធុញថប់ក្នុងចិត្តណាស់ ។ ឆ្នាំនេះជាឆ្នាំទីបីហើយ ដែលនាងរៀននៅ មហាវិទ្យាល័យ តែពិន្ទុប្រចាំមុខវិជ្ជានិមួយៗ ចេះតែស្រកស្រុតទៅរៀងរាល់ ឆមាស។ បើកុំតែសាលានោះជាសាលាឈ្នួល ហើយនាងក៏មានប្រាក់បង់ថ្លៃសាលា គ្រប់គ្រាន់នោះ ប្រហែលជាគេដេញនាងចោលពីសាលាយូរហើយ ។ បើតាមសន្ទុះ ល្បឿននៃការសិក្សារបស់នាង ក្រពុំចិត្តដឹងណាស់ថា នាងច្បាស់ជាប្រលងធ្លាក់ឆ្នាំ នេះទៀតហើយ ។ តើអោយនាងធ្វើយ៉ាងណា បើពេលខ្លះដែលនាងត្រូវការ ពិគ្រោះជាមួយឪពុកម្តាយ ប៉ុន្តែលោកមិនដែលមានពេលសំរាប់កូនសោះ ក្រៅពីខំ ប្រឹងបោះលុយអោយនាងនិងបងស្រីចាយពាលវាលពាសកាលតែប៉ុណ្ណោះ។

មកដល់មាត់ទន្លេ មាណវីចតឡានអង្គុយសំកុកមួយស្របក់ ក៏នឹកតុញតុះក្នុង ចិត្តទៀតហើយ ។ ក្រពុំចិត្តក៏ចុះចេញពីឡាន ចុះសំដៅភោជនីយដ្ឋានទំនើបមួយ ដែលមានភ្ញៀវបរទេសអង្គុយបរិភោគយ៉ាងអ៊ូអរ ។ ដំបូងអ្នកបំរើដាក់នាងអោយ អង្គុយនៅតុមួយក្បែរផ្លូវចេញចូល នាងហាក់ដូចជាមិនចូលចិត្ត ក៏សុំដូរទៅជាន់ទីពីរ វិញ ម្យ៉ាងចង់ទទួលខ្យល់អាកាសពីទន្លេផង ។ មកដល់តុមួយដែលមានរៀបចំ យ៉ាងស្អាត ក្រពុំចិត្តក៏ដាក់ខ្លួនចុះ ហើយក៏ចាប់កុម្មង់យកអាហារបរទេសភ្លាម ។ រំពេចនោះ នាងដាក់ភ្នែកទៅជ្រុងម្ខាងទៀតនៃភោជនីយដ្ឋានស្រាប់តែឃើញម្តាយ របស់នាងកំពុងអង្គុយប្រកៀកប្រកើយគ្នានឹងបុរសក្មេងម្នាក់ បញ្ចុកអាហារអោយ គ្នាទៅវិញទៅមកផង។ នាងក៏កត់សំគាល់ដែរថា បុរសនោះ ពិតជាមិនមែនឪពុក របស់នាងឡើយ។ ធិតាក៏លាន់មាត់ឡើង :

- ម៉ាក់?... ហេតុអ្វីក៏ម៉ាក់ធ្វើយ៉ាងនេះ?

តរុណីនឹកពិភាល់ក្នុងចិត្តផង ខឹងច្រលោតផង ក៏ស្ទុះងើបដើរសំដៅទៅរក ម្តាយភ្លាមឥតបង្អង់ ។ លុះទៅដល់ចំពោះមុខហើយ នាងក៏ពោលហៅ :

- ម៉ាក់!

អ្នកស្រីភ្ញាក់ព្រើត កាលបើបែរភ្នែកក្រឡេកឃើញកូនស្រីកាលណា។ រំពេច នោះ បុរសក្មេងដែលអង្គុយក្បែរអ្នកស្រី ក៏មានវាចាឡើងថា :

- តើនាងជាអ្នកណាអ្នកស្រីដានី? ជាកូនស្រីរបស់អ្នកស្រីមែនទេហ៎?

CHANBOKEO.COM

បុរសម្នាក់នោះមានវ័យក្មេងជាងអ្នកស្រីដានីឆ្ងាយណាស់ អាយុមិនដល់៣០ ឆ្នាំផង ។ កាលបើក្រឡេកឃើញក្រពុំចិត្តភ្លាម បុរសនោះសម្លឹងនាងឥតព្រិច ទំនង ដូចជាកំពុងពេញចិត្តនឹងរូបសោភ័ណរបស់ឆវីយើង ។ ចំណែក អ្នកស្រីដានីវិញមិន បានឆ្លើយទៅបុរសកំណាន់ចិត្តម្នាក់នោះទេ ត្បិតអាល័យតែភ្ញាក់ផ្អើលចំពោះ វត្តមានកូនស្រីនៅចំពោះមុខខ្លាំងពេក ។ អ្នកស្រីក៏ឧទានថា :

- នរណាប្រើកូនអោយមកតាមម៉ាក់ដល់នេះ...? ប៉ារបស់កូនមែនទេហ៏ (អ្នកស្រី ដានីសួរ)

ក្រពុំចិត្តសម្លឹងមុខម្តាយហើយយកដៃជូតទឹកភ្នែកដែលកំពុងស្រក់លើផ្ទៃមុខ របស់នាងរួចក៏ស្រដីតបវិញថា :

- កូនមកដោយខ្លួនឯង... លោកប៉ាមិនបានប្រើកូនមកទេ...

ដោយរន្ធត់ចិត្តខ្លាំងទ្រាំមិនបាន ធិតាក៏ខ្ទប់មុខយំ រត់ចេញទៅ ទោះម្តាយនាង ហៅអោយត្រឡប់ទៅរកគាត់វិញក៏ដោយក៏នាងមិនទុចដំណើរដែរ ។ មាណវីយើង ក៏បញ្ឆេះឡានលាន់វូ បើកល្បឿនស្ទេវចេញទៅ ដោយគ្មានយកចិត្តទុកដាក់នឹង ចរាចរទាំងឡាយលើផ្លូវនោះឡើយ ។ មកដល់វាលវង់ចុងស្ពានជ្រោយចង្វារ ស្រាប់ តែនាងមានអារម្មណ៍ថា បេះដូងរបស់នាងរណ្តំឱបឌាក់កាន់តែខ្លាំងឡើងៗធ្វើអោយ នាងងងិតមុខឈឺងហើយក៏ជ្រុលចង្កូតរថយន្តទៅបុកម៉ូតូដែលកំពុងបើកបរតាមដង ផ្លូវអស់មួយជួរយ៉ាងវែង ។ អ្នកបើកបរទាំងឡាយនោះក៏ដួលគ្រេងៗជាន់លើគ្នា ពាសពេញផ្លូវ.....

នៅក្នុងមន្ទីរពេទ្យ....

- ពុទ្ធោអើយ... ក្រពុំចិត្ត!! កូនឯងមានរឿងអី បានជាបើកឡានបុកគេអស់ម៉ាទី ក្រុងយ៉ាងនេះ? ដឹងទេ ថាប៉ាត្រូវខ្មាស់គេប៉ុណ្ណា ពេលគេផ្សាយវិទ្យុថាកូនស្រីរបស់ ប៉ាផឹកស្រាស្រវឹងបុកគេ? អោយទៅរៀនមិនទៅទេ បែរជាទៅដើរលេងប៉ៅឡែ... កូនរបៀបហ្នឹងសមតែយកទៅលក់អោយគេ យកធ្វើជាស្រីបំរើតាមសណ្ឋាគារវិញ ទើបវាសម.... នៅមិននៅ បុកអ្នកស្រុករបួសធ្ងន់ធ្ងរអស់ទាំងហ្វូង ហើយឡានម៉ូតូ អីក៏ខ្ទេចខ្ទីរជាច្រើនគ្រឿង ។ តើឯងនឹងបានប្រាក់ពីណាមកសងជំងឺ ចិត្តរបស់គេ? ពុទ្ធោអើយ! ឯងនេះនាំអំពល់ទុក្ខមែនតែហ្មងហើយ ធ្វើអោយប៉ាខកខានការងារ អស់ខ្ទេចខ្ទីរ ហើយត្រូវតាមសងជំងឺចិត្តគេជំនួសកូនទៀត ។

ពេលនោះក្រពុំចិត្តដឹងខ្លួនវិញហើយ ដឹងថា នាងមានរបួសស្រាំឆ្អឹងស្មានិង រលាត់ស្បែកដាច់ដៃដាច់ជើងជាច្រើនកន្លែងដោយសារមុតនឹងអំបែងកញ្ចក់ តែនាង មានអារម្មណ៍ថានាងមិនឈឺអ្វីទាំងអស់ ក្រៅពីឈឺចិត្តតែម្យ៉ាង ។ មើលចុះ! សូម្បី លោកសម្បត្តិប៉ារបស់នាង ដែលខិតខំរត់ទាំងស្លន់ស្លោមករកមើលនាងដល់មន្ទីរ ពេទ្យ ប៉ុន្តែតាមការពិត លោកមិនមែនមកសួរសុខទុក្ខរូបនាងឯណា គឺគាត់មករក ស្តីបន្ទោសនាងទៅវិញតើហ៏ ដែលនាងបានធ្វើអោយគាត់បាត់បង់ទ្រព្យនិងមុខមាត់ របស់លោកនោះអី! តាំងពីនាងដឹងខ្លួនមកវិញ នាងនៅសំងំមិននិយាយទេគឺនៅ គេងបន់ក្នុងចិត្តអោយលោកប៉ារបស់នាងសួរនាងថា នាងមានសុខទុក្ខយ៉ាងណា ហើយ នោះនាងនឹងអាលនិយាយជំរាបប្រាប់លោក អំពីហេតុការណ៍ទាំងឡាយ ដែលកើតឡើងថ្ងៃនេះ ។ អនិច្ចា! អ្វីៗក៏ប្រែរជាខុសពីការគិតទុករបស់នាងនោះ ស្រលះ ។ លោកសម្បត្តិដើរទៅ ដើរមក សំដែងអាការៈអន្ទះសាផង តប់ប្រមល់ផង ខឹងផង ស្តីបន្ទោសអោយកូនស្រីមិនឈប់មាត់ផង ។ មួយភ្លែតក្រោយមក លោកក៏ លើកនាឡិកាមើលម៉ោងហើយមានប្រសាសន៏ថា :

- ក្រពុំចិត្ត ! ប៉ាដល់ម៉ោងទៅធ្វើការវិញហើយ បើកូនត្រូវការអី ទូរស័ព្ទទៅផ្ទះ អោយនាងធឿនយកមកអោយទៅណ៎ា ។

មានប្រសាសន៏ចប់ លោកក៏ដើរចេញទៅ សូម្បីតែយកដៃអង្អែលក្បាល ថ្នម ចិត្តកូនស្រីបន្តិចក៏គ្មានផង ។

ថ្ងៃបន្ទាប់ៗមក មាណវីនៅគេងមន្ទីរពេទ្យម្នាក់ឯងយ៉ាងស្ងាត់ឯកា មិនឃើញ ម្តាយឬបងស្រីលេចមុខមកសួរសុខទុក្ខម្នាក់សោះ ។ ហ៊ឺ!! តើគេរវល់តែទៅឯណា? ក្រពុំចិត្តគិតទៅគិតមកនៅតែមិនយល់ដដែល... ធិតាគេងគិតតែម្នាក់ឯង នឹកដល់ សំដីរបស់មិត្តក្នុងថ្នាក់ខ្លះដែលធ្លាប់សរសើរនាង ថានាងមានសំណាងខ្ពស់ដែលបាន កើតមកក្នុងត្រកូលគ្រួសារអ្នកមាន មានទ្រព្យចាយមិនអស់

CHANBOKEO.COM

មិនដូចគេជាច្រើន ដែលត្រូវទៅរៀនផង ទៅធ្វើការផង ដើម្បីរកប្រាក់ទប់ទល់ការខ្វះខាតក្នុង គ្រួសារ ។ តែគេទាំងនោះមិនយល់ទេថា ក្រុមគ្រួសាររបស់នាង ល្អមើលបានត្រឹម តែពីសំបកក្រៅប៉ុណ្ណោះ ។ តាំងពីនាងដឹងក្តីពេលណាមក នាងមិនដែលឃើញ ក្រុមគ្រួសារនាងមានការរីករាយ ហើយស្និទ្ធស្នាលដូចគ្រួសារផងទាំងពួងនោះទេ ។ ឪពុកនាងតែងមានជម្លោះជាមួយម្តាយនាងជាញឹកញាប់ ជួនមានជ្រុលដល់ប្រើ ដៃជើងទៀតផង ជាពិសេសបើនៅឃើញមុខគ្នាលើសពីមួយម៉ោងឡើងទៅ ។ ម្យ៉ាងទៀតនាងក៏មានការសង្ស័យដែរថា មិនដឹងជាម៉ាក់របស់នាងជាស្រ្តីទីប៉ុន្មាន របស់លោកប៉ានាងទេ ព្រោះអោយតែលោកខឹងនឹងម្តាយនាងម្តងៗ លោកតែងតែ ស្តីប្រមាថកាតទានម្តាយនាងហាក់ដូចជានារីដែលលោករើសបានមកពីកន្លែងសំរាម អីចឹង ។ បើនិយាយពីបងស្រីនាងវិញ សាលាមិនដែលចូលសោះឡើយ មួយថ្ងៃៗ ឃើញតែតែងខ្លួន ដើរចាយលុយតែម្យ៉ាង ។ បើនាងចង់សួរ ចង់ជួបបង ឬសូមដើរ លេងជាមួយនាងតាមរបៀបជាបងប្អូនស្និទ្ធស្នាល  ដារិយ៉ាតែងតែឆ្លើយទៅនាងថា ក្រពុំចិត្តជាកូនក្មេងតូច មិនអាចដើរចូលហ្វូងជាមួយនាងបានឡើយ ។ ម្លោះហើយ ក្រពុំចិត្តក៏ក្លាយជាក្មេងស្រីដែលមានចិត្តកណ្តោចកណ្តែង អង្គុយនៅតែមុខកញ្ចក់ និយាយរកខ្លួនឯង ដើរតួជាក្រពុំចិត្តផង ជាតួកូនខ្មោចផង និយាយតបទៅតបមក នៅក្នុងបន្ទប់គេងតែម្នាក់ឯង មិនដែលដឹង មិនដែលស្គាល់ថា ពិភពខាងក្រៅមាន ជីវិតយ៉ាងណាយ៉ាងណើសោះឡើយ ។ លោកប៉ានាងក្តី ម៉ាក់នាងក្តី បងស្រីរបស់នាង ក្តី តែងតែនិយាយដដែលៗប្រាប់នាងថា អោយខំរៀនៗ ខំរៀនទៅកុំខ្ជិលឱ្យសោះ តែគ្មាននរណាម្នាក់យកចិត្តទុកដាក់ថា នាងត្រូវរៀនអ្វី រៀនយ៉ាងណា រៀនខ្សោយ អ្វី ពូកែអ្វី រៀនដល់ឆ្នាំណា ចប់ឆ្នាំណា គឺមិនដែលមាន នរណានឹកចាប់ភ្លឹកចង់មើល បញ្ជីស្រង់ពិន្ទុប្រចាំឆមាសឬប្រចាំឆ្នាំរបស់នាងសោះឡើយ ។ បើសិនជានាងកាន់ ក្រដាសពិន្ទុទៅបង្ហាញវិញ គេទាំងអស់គ្នាតែងគិតថា ក្រពុំចិត្តប្រាថ្នាទៅសុំប្រាក់ រង្វាន់ចំពោះការខំរៀនតែប៉ុណ្ណោះ ម្លោះហើយម្នាក់ៗ ប្រឹងតែហុចលុយអោយនាង តែម្យ៉ាង  មិនបាននឹកចង់មើលកិច្ចការសាលារបស់នាងឡើយ ហើយចេះតែពោល ថា" គ្មានពេលទេ.. រវល់ណាស់" ។

ក្រពុំចិត្តគិតទៅគិតមក   ក៏យំសសឹកតែម្នាក់ឯង នៅក្នុងបន្ទប់ព្យាបាល   នឹក អាណិតស្រណោះខ្លួន   ដែលនៅដេកឈឺឯកា មិនដឹងជា ពេលណា ថ្ងៃណាទេ ដែល សមាជិកក្រុមគ្រួសារគេនឹងនឹកដល់នាងហើយមកសួរសុខទុក្ខនាងសោះឡើយ ។

សង្វេគ

១. អាណិតខ្លួនណាស់រស់សែនឯកា    មានដែរគ្រួសារតែខ្វះទឹកចិត្ត
ភោគទ្រព្យសំបូរមិនពិបាកគិត    បែរអោបវិបត្តិក្នុងទ្រូងសែនត្អេរ ។
២. មានដែរម៉ាក់ប៉ាខ្វះក្តីថ្នាក់ថ្នម    ប្រលែងបីបមដូចបុត្រផងគេ
រស់មានរូបកាយបែរឆ្ងាយក្តីស្នេហ៍    ក្លិនដៃជូនថៃអ្នកម៉ែផងកូន ។
៣. អនិច្ចា! ដួងចិត្តវិបរិតលែងយល់    អោបតែអំពល់ទុក្ខាស្រពោន
ដូចមេឃងងឹតបាត់សុរិយ៍សូន្យ    រែងអាណិតខ្លួនសោកាតែឯង ។
៤. តើថ្ងៃណាទៅពៅយល់ក្តីសុខ    ចាកផុតនូវទុក្ខសោកសៅចំបែង
សង្ឃឹមស្អែកថ្មីក្រែងព្រះសូរ្យសែង    យាងប្រោសចំបែងអោយស្រីផុតកម្ម ។

ជាងពីរអាទិត្យកន្លងទៅហើយ...

មាណវីយើងនៅតែមិនឃើញម្តាយនិងបងស្រីរបស់នាង អើតមកមើលសួរ សុខទុក្ខនាងនៅមន្ទីរពេទ្យដដែល ។ នាងខំទូរសព្ទ័ទៅផ្ទះជាច្រើនដង ក៏មិនបានជួប ជួបតែនាងចឿនអ្នកសំអាតផ្ទះតែប៉ុណ្ណោះដែលចេះតែឆ្លើយប្រាប់បានតែ ម្យ៉ាងថា

CHANBOKEO.COM

លោកប្រុសមិននៅ! លោកស្រីមិននៅ! អ្នកនាងធំមិននៅ! មិនឃើញមាន ប្រយោគអ្វីល្អគ្រាន់ជាងហ្នឹងទៀតឡើយ ធ្វើអោយនារីយើងនឹកសោកាអាណិត ខ្លួនកាន់តែខ្លាំងហើយក៏មានអារម្មណ៍កាន់តែធុញថប់ឡើងក្នុងចិត្តជាលំដាប់ រហូតទ្រាំគេងនៅក្នុងពេទ្យព្យាបាលបន្តទៅទៀតស្ទើរមិនបាន។

ព្រឹកនេះ ក្រពុំចិត្តមានអារម្មណ៍ថាក្នុងកាយរបស់នាងហាក់ដូចជាបានគ្រាន់បើ បន្តិចហើយ។ នាងក៏ដាច់ចិត្តសូមលោកគ្រូពេទ្យចេញមកផ្ទះ តែលោកមិនព្រម អនុញ្ញាតិសោះ ដោយសំអាងថាទូរស័ព្ទរកលោកសម្បត្តិមិនជួប មិនហ៊ានអោយ នាងចេញទៅផ្ទះដោយគ្មានអ្នកមកទទួល។ ម្យ៉ាងទៀតលោកមានប្រសាសន៍ថា ក្រពុំចិត្តមិនទាន់មានសតិប្រក្រតីនៅឡើយ ម្ល៉ោះហើយលោកមិនហ៊ានអោយចេញទៅផ្ទះដោយខ្លួនឯងម្នាក់ឯង ខ្លាចក្រែងមានគ្រោះឧប្បត្តិហេតុកើតឡើងសាជាថ្មី ទៀត។ ក្រពុំចិត្តព្ញដូច្នោះនឹកខកចិត្តណាស់ ហើយក៏មានអារម្មណ៍ដូចក្មេងដែល ត្រូវគេបំបរបង់ចោលនៅមន្ទីរពេទ្យអីចឹង។ កាលបើមិនបានទទួលការអនុញ្ញាតិ ធិតាក៏លួចគេងស្រក់ទឹកភ្នែកតែម្នាក់ឯងសាជាថ្មី....

គិតយូរៗទៅ ក្រពុំចិត្តក៏ទ្រាំលែងបានតែម្តង។ ឆវីក៏បែកគំនិត ហ៊ានចូលទៅ លួចខោអាវរបស់ស្ត្រីគិលានុបដ្ឋាកម្នាក់ ដែលដាក់មកតាមខ្លួនសំរាប់ប្រើប្រាស់។ បន្ទាប់ពីផ្លាស់សំលៀករួចហើយ មាណវីយើងក៏លួចដើរចេញពីមន្ទីរពេទ្យតាមទ្វារក្រោយរួចទើបហៅម៉ូតូឌុបជិះបន្តចេញទៅ។ តាមផ្លូវធិតាភ័យបែកញើសសស្រាក់ នឹកអាណិតខ្លួន ដែលក្លាយមកជាមនុស្សដែលមានទោសពិរុទ្ធជាចោរដែលលួច របស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិ ។ នាគ្រាមួយនោះ នាងជាបុត្រីត្រកូលអភិជន មានប្រាក់ចាយមិនអស់ តែលុះមកដល់គ្រានេះនាងក្លាយជាចោរលួចរបស់គេ លួចចេញពីមន្ទីរពេទ្យដោយគ្មានការអនុញ្ញាតិ ថែមទាំងធ្លាប់ជាប់ពិរុទ្ធក្នុងរឿងបង្កគ្រោះថ្នាក់ចរាចរអោយមានរបួសមនុស្សនៅលើវិថីនៃទីក្រុងភ្នំពេញទៀត... តើ ហេតុអ្វីទៅហ្ន៎ បានជាជោគជតារាសីរបស់នាងធ្លាក់ដុនដាបដល់ថ្នាក់នេះ?

មកដល់មាត់ទ្វាររបងដ៏ប្រណិត មុខវិឡារបស់លោកសម្បត្តិ ក្រពុំចិត្តក៏ចុះពី ម៉ូតូ ដើរទៅចុចកណ្តឹងទ្វារ ស្រាប់តែអ្នករត់ម៉ូតូឌុបនោះក៏ពោលឡើង :

- អោយខ្ញុំសុំប្រាក់ថ្លៃឈ្នួលឌុបរបស់ខ្ញុំសិនបានទេ អ្នកនាង?

ក្រពុំចិត្តធ្វើភ្នែកឡិកឡក់ យកដៃស្ទាបហោប៉ៅហើយឆ្លើយថា :

- ពូចាំម៉ាភ្លែតបានទេហី ? ចាំខ្ញុំចូលទៅក្នុងផ្ទះរួចសិន ខ្ញុំនឹងយកមកជូន។

អ្នកម៉ូតូឌុបធ្វើមុខហាក់ដូចជាមិនទុកចិត្តនារីយើងទេ ។ ក្រពុំចិត្តមិនព្ញនរណា ឆ្លើយកណ្តឹងទ្វារសោះ ក៏កួកហៅ :

- ចឿន ! នៅផ្ទះទេ? ឆាប់មកបើកទ្វារអោយខ្ញុំបន្តិចមក៍ ! ចឿន!!

ស្ងាត់ជ្រៀប! គ្មាននរណាឆ្លើយម្នាក់ឡើយ ។ អ្នកម៉ូតូឌុបក៏លាន់មាត់និយាយ ទៅនាងថា :

- ប្រហែលជាគ្មាននរណានៅផ្ទះទេ អ្នកនាង !

ឆវីយើងងាកមកអ្នករត់ម៉ូតូ ហើយតបវិញថា :

- អញ្ចឹងពូចាំសិនណា៎! ខ្ញុំផ្លោះរបងចូលក្នុងផ្ទះសិន បន្តិចខ្ញុំយកលុយមកសងពូវិញ។

ថាហើយនាងក៏ស្រវាតោងរបងឡើងទៅ តែពូម៉ូតូឌុបស្រែកឃាត់ :

- នាង! កុំផ្លោះរបងចូលផ្ទះគេ ប្រយត្ន័ប៉ូលីសចាប់ តិចគេថានាងជាចោរណា៎!

ស្រាប់តែ ស្នូរកញ្ចែ លាន់ច្រេចៗ ថែមទាំងមានមនុស្សស្រែកយ៉ាងរហ័ស :

CHANBOKEO.COM

- នែ៎!! ឈប់សិន! ក្មេងខូច... ម៉េចបានមកធ្វើចោរផ្លោះរបងចូលលួចតវ៉ាន់គេ យ៉ាងនេះ?

ក្រពុំចិត្តមានអារម្មណ៍ថាមានគេមកចាប់ជើងនាងជាប់ ។ លុះនាងបែរងាក ក្រោយ ស្រាប់តែឃើញប៉ូលីសមួយរូប ដែលធ្វើមុខយ៉ាងមាំមករកនាង ថែម ទាំងស្រដីថា :

- ចុះមកក្រោមភ្លាម ក្មេងស្រីកំហូច!!

មាណវីក៏ចុះវិញភ្លាមដែរ ហើយញញឹមដាក់នាយតំរួតប៉ូលិស :

- លោកពូ! ផ្ទះនេះជាផ្ទះរបស់ខ្ញុំតើហ៎ ! ខ្ញុំមិនមែនជាចោរទេ...

ព្រះអើយ! មើលចុះ! សំលៀកក្រពុំចិត្តមើលមិនយល់ទេ គឺសំលៀកមនុស្ស ចាស់ដែលនាងលួចយកមកស្លៀកបន្លំខ្លួនលួចចេញពីមន្ទីរពេទ្យមកនោះ វាធំហួស មាឌរបស់នាង ធ្វើអោយសំបកក្រៅរបស់នាងមិនសមជាអ្នកដែលរស់នៅក្នុងវិឡា ដ៏សែនឧត្តមមហាសាលនេះសោះតែម្តង ។ នាយប៉ូលិសនោះឃើញហើយជ្រួញ ចិញ្ចើម ព្រមទាំងនិយាយខ្លាំងៗដាក់នាងវិញ :

- នែ៎ក្មេងខូច! កុំរៀនភរមើស៎! មុខនាងនេះឯណាសមជាសមាជិកកូនចៅផ្ទះនេះ? លោកអើយ! បើនាងជាអ្នកក្នុងផ្ទះនេះមែន ម៉េចបានជាផ្លោះរបងចូលផ្ទះរបស់ខ្លួន ឯងទៅវិញ? ដូចជាមិនសមហេតុផលទេរ៉ឺយ...

ថាផង នាយប៉ូលីសក៏ស្រវាចាប់ដៃមាណវីក្រពាត់ទៅក្រោយរួចយកខ្នោះមក ថ្ពក់ដាក់ជាប់ដៃរបស់នាង ។ ក្រពុំចិត្តនឹកឆ្ងល់ហើយសួរថា :

- លោកពូចាប់ខ្ញុំធ្វើអីហ្នឹង?

- ទៅមន្ទីរស្នងការសិន ចាំនិយាយគ្នា... (នាយប៉ូលីសឆ្លើយ)

- ខ្ញុំជំរាបលោកពូហើយតើ ថាខ្ញុំជាអ្នករស់នៅផ្ទះនេះតើហ៎!

- នែ៎ កុំប្រកែកច្រើន.. តិចយកកន្សែងញ៉ុកមាត់អីលូវ !

នាយប៉ូលីសមិនស្តាប់នាងទេ គិតតែពីអូសនាងបណ្តើរដាក់ឡាន ធ្វើអោយ ពូម៉ូតូឌុបឈរមើលធ្វើមាត់ចំហធ្លុង មិនដឹងថាត្រូវឃាត់ ឬត្រូវបណ្តោយអោយ ប៉ូលិសអូសនាងយកទៅស្នងការដ្ឋាន ត្បិតគាត់ក៏មិនស្គាល់ក្រពុំចិត្តដូចគ្នា។ ប្រសិន បើហើបមាត់និយាយទៅ ខ្លាចនាយប៉ូលីសចោទគាត់ថាឃុបឃិតដៃជើងជាមួយ ក្មេងស្រីនោះ ម្ល៉ោះហើយគាត់ក៏សុខចិត្តនៅស្ងៀមមើលស្ថានការណ៍វិញ។ ពេល នោះក៏មានមនុស្សមកចោមរោមមើលបួនដប់នាក់ កេះគ្នានិយាយខ្សិបៗ តែក៏ គ្មាននរណាចេញមុខជួយធានាថា តរុណីយើងជាអ្នករស់នៅម្តុំនោះឡើយ ។ មាណវី យើងនឹកហួសចិត្តណាស់ ដែលនាងត្រូវនាយប៉ូលីសចោទហើយថែមទាំងមិនព្រម ស្តាប់ការពន្យល់របស់នាងបន្តិចណាសោះ ។

រំពេចនោះស្នូរស៊ីផ្លេឡានមួយលាន់ឡើង ទីន! ទីន! នារីស្រស់សោភាមួយរូប ដើរចុះពីរថយន្តសំដៅមកម្តុំដែលមានមនុស្សឈរចោមរោមមើល ហើយឧទានថា:

- តើមានហេតុការណ៍អ្វីហ្នឹង បានជានាំគ្នាមកឈរអ៊ូអរពាសពេញមុខផ្ទះរបស់ខ្ញុំ បែបនេះ? សូមមេត្តាចៀសផ្លូវអោយខ្ញុំបន្តិចបានទេហ៎ ?

ថាហើយនាងក៏ហក់ចូលឡានវិញ គិតបំរុងនឹងបរកាត់ហ្វូងមនុស្សចូលទៅក្នុង វីឡាដ៏ស្កុកស្កម្ភនោះ ។ ចៃដន្យ ក្រពុំចិត្តក្រលេកឃើញនាង ក៏ឧទានទាំងត្រេកអរ កខិបកខុបថា :

CHANBOKEO . COM

- បងដារីយ៉ា!!

ដារិយ៉ាឮសូរគេហៅឈ្មោះនាងដូច្នោះ ក៏ដាក់ក្បាលអើតតាមបង្អួចរថយន្ត ស្រាប់តែប្រទះ នឹងក្រពុំចិត្តដែលកំពុងជាប់ខ្នោះ អង្គុយក្នុងឡានប៉ូលីស...

- នាងចិត្តទេហ៎? ពុទ្ធោ! ហើយចុះឯងទៅធ្វើស្អីហ្នឹងបានជាប៉ូលីសចាប់?

នាយប៉ូលីសក្រលេកមកឃើញអ្នកទាំងពីរស្គាល់គ្នាក៏ធ្វើភ្នែកឡឹងឡង់ ....

នៅក្នុងផ្ទះ....

- បាក់មុខបាក់មាត់បងអស់រលីង ពុទ្ធោអើយ! (ដារិយ៉ានិយាយឡើងទាំងអន់ចិត្ត) នាងចិត្ត! ដើរទៅឯណាបាត់ប្អូនដប់ម្ភៃថ្ងៃ មិនដែលឃើញមុខសោះ ដល់ពេល មកបង្ហាញខ្លួន ស្រាប់តែបែរជាប់ខ្នោះប៉ូលីសយ៉ាងនេះ ខ្មាសគេម្លេះខ្ញុំ?

ដារិយ៉ានិយាយផង គ្រវែងកាបូបដៃទៅលើតុផង ហើយដាក់ខ្លួនអង្គុយចុះក្នុង សាលុង រួចស្រវាដោះស្បែកជើងចេញពីជើង ។ ក្រពុំចិត្តដើរចូលមកក្នុងផ្ទះ តាមក្រោយបងស្រីរបស់នាង ដោយស្ងៀមស្ងាត់ ។ កាលបើឮដារិយ៉ាសួរនាងដូច្នោះ មាណវីគិតក្នុងចិត្តថា :

- តើបងដារិយ៉ាគាត់អាល័យទៅណា បានជាមិនដឹងថា ខ្ញុំមានគ្រោះថ្នាក់ឡាន ឬក៏លោកប៉ាមិនទាន់មានប្រសាសន៍អ្វីប្រាប់ក្រុមគ្រួសារខ្ញុំអោយបានដឹងទេ? ចុះ ម៉ាក់វិញ គាត់យ៉ាងម៉េចទៅហើយ? ហើយចំណែកនាងចឿន តើគេទៅណាដែរ បានជាមិនឃើញនៅចាំផ្ទះសោះ?

ឃើញក្រពុំចិត្តមិនឆ្លើយ ដារិយ៉ាក្រលេកបែរមកប្អូន ហើយបើកភ្នែកធំៗ :

- ទេវតាអើយ! មើលឯងស្លេកពាក់ចុះ ដូចចោរហារយ មិនសមជាកូនអភិជនទេ! មុខដូចឆ្មាអោងបែបនេះ តើឯងទៅណា? បានធ្វើអ្វីខ្លះ ? បងថា បើលោកប៉ានិង ម៉ាក់បានជ្រាបថាឯងបានទៅប្រព្រឹត្តអ្វីផ្តេសផ្តាសនៅខាងក្រៅផ្ទះ នោះឯងមុខជា មិនសល់ឆ្អឹងទេ ពេលនេះ ។

ក្រពុំចិត្តសំលឹងមុខបងស្រី តែមិនដឹងថាត្រូវឆ្លើយយ៉ាងណា ព្រោះថាបើតាម សំដីរបស់ដារិយ៉ាអំបាញមិញ គឺក្នុងចិត្តរបស់បងស្រីនាង គេបានសន្មតរួចទៅហើយ ថាក្រពុំចិត្តប្រាកដជាធ្វើអ្វីមិនគប្បីមិនខានឡើយ ។ នោះមិនមានខុសអ្វីអំពីនាយ ប៉ូលិសនិងលោកប៉ារបស់នាងទេ ដែលចេះតែនាំគ្នាសន្មតសាច់រឿងថានាងប្រព្រឹត្ត ខុសយ៉ាងនេះឬយ៉ាងនោះ ប៉ុន្តែគ្មាននរណាម្នាក់បាច្នាស្តាប់រឿងពិតរបស់នាងចេញ ពីមាត់នាងផ្ទាល់ទេថាការពិតវាយ៉ាងម៉េចខ្លះ ក្រៅតែនាំគ្នាគិតសន្មតសរុបជាមុន ថាអ្វីដែលគេបានគិតសន្មតនោះពិតជាត្រឹមត្រូវដូចការពិតជានិច្ច!! ហ៊ឹ! តើមាន នរណាមួយទៅដែលចេះគិតល្អៗពីអ្នកដទៃខ្លះទៅ? អោយតែឃើញអ្វីៗចំលែកៗ ខុសទំលាប់របស់ខ្លួនបន្តិច គេក៏នាំគ្នាគិតឃើញតែខាងផ្លូវខុស ផ្លូវអាក្រក់ រហូតទៅ ឬក៏យ៉ាងណាហ្ន៎?

បន្តិចមក មាណវីក៏ពោលទៅកាន់បងស្រីដ៏ស្រស់ឆើតឆាយរបស់នាងថា :

- បើប្អូនមានរឿងរ៉ាវខ្លះៗ ចង់ជំរាបបង តើបងស្តាប់ខ្ញុំទេ?

ដារិយ៉ាមើលមុខនាងហើយឆ្លើយវិញថា :

- តើឯងរកទីកវិធីដោះសារអោយបានសមរម្យហើយនៅ? បើរកទឹកឃើញហើយ ប្អូនទុករឿងហ្នឹងទៅជំរាបលោកប៉ានិងម៉ាក់ទៅ ព្រោះបងគ្មានពេលមកអង្គុយ ស្តាប់រឿងដោះសារបស់ក្មេងខូចដូចឯងនេះទេ ។

ថាចប់ ដារិយ៉ាក៏ស្ទុះឡើងទៅខាងលើ ចូលបន្ទប់របស់នាងបាត់ ។ ក្រពុំចិត្ត សំលឹងមើលតាមបងស្រីនាង ហើយនឹកហួសចិត្តតែម្នាក់ឯង :

CHANBOKEO.COM

- បើខ្ញុំជាក្មេងខូច.... ចុះបងដារិយ៉ា ដែលគេចសាលា ដើរលេងរាល់ថ្ងៃដែរនោះ
តើគួរហៅថាយ៉ាងណាវិញទើបសម?

ភ្លាមនោះ ស្រាប់តែនាងចឿនដើរចូលមកដល់ ។ លុះឃើញក្រពុំចិត្តហើយ នាងចឿនក៏បើកភ្នែកធំៗ ហើយលាន់មាត់ថា :

- អ្នកនាងចិត្ត... ចេញពីពេទ្យហើយ?

មាណវីងក់ក្បាលហើយសួរទៅចឿនវិញ :

- ហេតុអ្វីនៅក្នុងផ្ទះនេះ គ្មាននរណាម្នាក់ដឹងសោះថា ខ្ញុំមានគ្រោះថ្នាក់ត្រូវគេដឹងនៅ មន្ទីរពេទ្យអញ្ចឹង?

ចឿនក្រលេកនាយអាយរួចអោនខ្សិបដាក់ត្រចៀកក្រពុំចិត្តវិញ :

- លោកប្រុសលោកស្រីទាស់មាត់ទាស់កនឹងគ្នា មិននិយាយរកគ្នាតាំងពីថ្ងៃដែល អ្នកនាងមានគ្រោះថ្នាក់ឡានមកម្ល៉េះ
ហើយម៉ាក់អ្នកនាងក៏ប្រហែលមិនទាន់ដឹងទេ ថាអ្នកនាងសំរាន្តពេទ្យត្បិតអីលោកទាំងពីរមិននិយាយរកគ្នាសោះ ។ ចំណែកឯ អ្នកនាងដារិយ៉ា
ឮថាទៅខេត្តក្រៅមិនទាន់មកទេ ។

- ខុសហើយ ចឿនអើយ ! បងដារិយ៉ាមកដល់ហើយ នៅក្នុងបន្ទប់របស់គាត់ ខាងលើឯណោះ ហើយឯងទៅណាបានជាមិនដឹង ?

- គឺ... គឺ.... ខ្ញុំអាល័យមើលកុនភាគក្នុងទូរទស្សន៍ ហើយច្រលំគេងលក់ម៉ាសាលែត ទៅ... សូមទោសអ្នកនាង

- មិនអីទេ... ចឿន.. អោយខ្ញុំសុំអាហារម៉ាចានបានទេហ៎ ? ខ្ញុំឃ្លានណាស់ !

- ចាំសអ្នកនាង!

នៅបន្ទប់អាហារ ក្រពុំចិត្តកំពុងតែអង្គុយបរិភោគបាយម្នាក់ឯង ស្រាប់តែឮ ស្នូរសម្លេងឡានមកចតនៅមុខផ្ទះរបស់នាង ។
ឆវីក៏ស្ទុះចេញទៅរកមើល ស្រាប់
តែប្រទះឃើញម្តាយនាងចុះពីរថយន្តមកដោយមាន នាំកំលោះរូបសង្ហារមួយរូប
មកជាមួយផង ។ ក្រពុំចិត្តនឹកក្នុងចិត្តតែម្នាក់ឯងថា :

- ម៉ាក់? ម៉ាក់កំពុងនាំអ្នកណា មកធ្វើអីនៅផ្ទះរបស់យើងហ្នឹង? ឬបុរសមួយរូប នេះជាកំណាន់ចិត្តថ្មីរបស់ម៉ាក់?
ហេតុដូចម្តេចម៉ាក់ហ៊ាននាំគេចូលផ្ទះរបស់យើង? ឬ...ក៏...ម៉ាក់កំពុងផ្តើនចិត្តលោកប៉ា ដែលតែងតែធ្វើបាបទឹកចិត្តរបស់ម៉ាក់?

គ្រាន់តែឃើញក្រពុំចិត្តភ្លាម អ្នកស្រីដានីក៏បោយដៃហៅកូនអោយមកជិត :

- ក្រពុំចិត្ត ! មកណេះ ជំរាបសួរបងទៅហ៎ក! គេឈ្មោះ វិសាល ជាពិធីករ ប្រចាំវិទ្យុទូរទស្សន៍នៅភ្នំពេញយើងនេះណ៎ាកូន ។

ក្រពុំចិត្តលើកដៃសំពះជាការសមគួរ ។ វីបុរសនោះសំពះតបវិញយ៉ាងទន់ភ្លន់ តែមើលនាងមិនដាក់ភ្នែកដែរ ។ បន្តិចក្រោយមក អ្នកស្រីដានី
ក៏គេចទៅបន្ទប់ បាត់ទៅ ទុកអោយកូនស្រីពៅនិងកំលោះពិធីករនៅសំណេះសំណាលតែពីរនាក់ ។
ថ្វីត្បិតតែក្រពុំចិត្តមិនមែនជាមនុស្សរួសរាយសំដីជាមួយញាតិណា ប៉ុន្តែ លោក វិសាលពូកែនាំក្រពុំចិត្តជជែកពីនេះពីនោះយ៉ាងសប្បាយ ។
មាណវីយើងគិតក្នុង ចិត្តតែម្នាក់ឯងថា:

- ពេលនេះ យើងមានអារម្មណ៍ថា ហាក់ដូចត្រូវម៉ាក់ចាប់ផ្គូផ្គងរូបយើងអោយទៅ បុរសម្នាក់នេះអញ្ចឹង ។ ទោះជាយ៉ាងណា
មើលទំនងសំដីនិងចិត្តគំនិតរបស់គេ គឺគេមានការគោរពយ៉ាងខ្ពង់ខ្ពស់ដល់ម៉ាក់យើងណាស់ មិនដូចបុរសដែលយើងបាន
ប្រទះនៅភោជនីយដ្ឋានឯមាត់ទន្លេជាមួយម៉ាក់នោះឡើយ ។

CHANBOKEO.COM

បន្តិចក្រោយមក វិសាលក៏ជំរាបលាត្រលប់ទៅវិញ ។ លុះឃើញកំលោះ វិសាលវិលទៅវិញបាត់ អ្នកស្រីដានីក៏ចុះមកជួបកូន។ ក្រពុំចិត្តសំលឹងម្ដាយអត់ព្រិច ទេ តែក៏មិនដឹងសួរម្ដាយថាម៉េចដែរ ។ នាងកំពុងតែរង់ចាំអោយម្ដាយ នាងពន្យល់ឱ្យនាងបានយល់ជាជាង ។ ភ្លាមនោះ អ្នកស្រីដានីក៏បន្លឺវាចាថា :

- ឥលូវនេះ ម៉ាក់ណែនាំឯងឱ្យស្គាល់មិត្តប្រុសនឹងគេខ្លះហើយ ។ គេជាមនុស្ស ល្អហើយមានត្រកូលល្អ ការងារអាជីពក៏ល្អ បើកូនចេញទៅដើរលេងជាមួយគេ គឺ គេពិតជាដៃគូដ៏ល្អ គ្មានពិសពុលអ្វីទេ ហើយឯងកុំនឹកច្រណែននឹងម៉ាក់តទៅទៀត ដែរ ដែលម៉ាក់ចេញក្រៅមានមិត្តខ្លះៗ។ ឯងឃើញហើយតើ ប៉ារបស់ឯងមិនដែល មាន ពេលវេលាសំរាប់ម៉ាក់ទេ ។ គេចាប់អារម្មណ៍តែនារីក្មេងៗនៅកន្លែងពិសេសៗ តែម្យ៉ាងប៉ុណ្ណោះ....

អ្នកស្រីពោលដោយមានទឹកមុខស្រពោន។ ក្រពុំចិត្តនឹងភ្ញាក់ព្រើត ហើយ ឆ្ងល់ក្នុងចិត្តតែម្នាក់ឯងទៀតហើយ :

- ហេតុអ្វីម៉ាក់គិតថា ខ្ញុំច្រណែននឹងម៉ាក់ដូច្នេះ? ម៉ាក់មិនដឹងទេហ៎ថា អ្វីដែលម៉ាក់ កំពុងប្រព្រឹត្តគឺខុសនឹងសីលធម៌គ្រួសារខ្លាំងណាស់ ត្បិតម៉ាក់មានស្វាមី មានកូនរួច ទៅហើយ...ម៉ាក់ភ្លេចហើយហ្អែស? ម៉ាក់ចង់បានទទួលការថ្នាក់ថ្នមនិងពេលវេលា ពីលោកប៉ា ហើយខឹងនឹងលោកប៉ាដែលគ្មានពេលវេលាសំរាប៉ម៉ាក់... ចុះកូនវិញ?? កូនចង់បានពេលវេលានិងការកក់ក្ដៅពីម៉ាក់ដូចគ្នាដែរ ហេតុអ្វីក៏ម៉ាក់សំលឹងមើល កូនមិនឃើញ?

ឃើញនាងឈ្ងោកមុខមិនស្ដី អ្នកស្រីដានីក៏មានប្រសាសន៍បន្តទៅទៀតថា :

- បើកូនអផ្សុក កូនដើរលេងនៅក្រៅខ្លះទៅ... ហ៎កនេះ! យកប្រាំរយដុល្លារ ទៅចាយសិនទៅ បើអស់កាលណា ប្រាប់ម៉ាក់ ចាំម៉ាក់អោយថែមទៀត ។ ហើយ កុំសួរមករំខានម៉ាក់ទៀតដែរ ព្រោះសព្វថ្ងៃ ម៉ាក់ត្រូវការពេលវេលាទាក់ទងភ្ញៀវ រកស៊ីដើម្បីរកលុយមកអោយកូនចាយរស់នៅស្រណុកសុខស្រួល ឮហើយនៅ?

ក្រពុំចិត្តភ្ញាក់ព្រើត នឹកក្នុងចិត្តបន្តទៀតថា :

- ទៀតហើយ... ហេតុម្ដេចប៉ាម៉ាក់ គិតថាលុយទាំងរយៗនោះ អាចទិញសេចក្ដី សុខ និងការកក់ក្ដៅអោយកូនបានទៅវិញ? ខុសហើយម៉ាក់! ការពិត ខ្ញុំចង់បាន

ម៉ាក់ ចង់បានប៉ា នឹងភាពរីករាយក្នុងគ្រួសាររបស់យើង... មិនមែនលុយទេ !

ភ្លាមនោះ មាណវីយើងក៏សួរទៅម្ដាយថា :

- កូនមានរឿងនិយាយជាមួយម៉ាក់មួយភ្លែត តើម៉ាក់មានពេលសំរាប់កូនទេ?

- ពុទ្ធោអើយ ! ម៉ាក់មានជាប់ណាត់ហើយត្រូវចេញទៅវិញអីលូវនេះទៅហើយ ។ កូនចាំនិយាយថ្ងៃក្រោយបានទេ ពេលណាម៉ាក់ទំនេរ!

ក្រពុំចិត្តឈរធ្មឹង នឹកហួសចិត្តដែលម្ដាយនាងមិនបានអើពើសួរអ្វីអំពីសុខទុក្ខ របស់នាងមួយម៉ាត់សោះថាតើ ជាងពីរអាទិត្យកន្លងមក កូនស្រីរបស់គាត់ទៅ ណាខ្លះ? មានហេតុការណ៍អ្វីកើតឡើងខ្លះនៅក្នុងជីវិតរបស់នាងក្នុងរយៈកាលដែល គាត់មិននៅផ្ទះ? ដងណាក៏ឃើញតែគាត់រសាប់រសល់បំពេញសេចក្ដីត្រូវការរបស់ គាត់តែម្យ៉ាង.ប៉ុណ្ណោះ.....

ពីរបីថ្ងៃកន្លងទៅ...

ក្រពុំចិត្តមិនដែលបានឃើញឪពុកនាងត្រលប់មកផ្ទះសោះ ក៏សួរនាងធឿនថា:

- ធឿន ! លោកប៉ាមានប្រាប់ធឿនទេ ថាលោកមកផ្ទះថ្ងៃណាដែរ?

CHANBOKEO.COM

- អត់ទេ អ្នកនាង ! ជូនទៅបាត់ពីរបីថ្ងៃ ជូនមិនមកសោះតែម្តង... ហើយលោក ក៏ធ្វើទឹកមុខមាំៗរាល់តែដងពេក ទើបចឿនមិនហ៊ានសួរលោក ។

ក្រពុំចិត្តទំលាក់ទឹកមុខស្រពោនដកដង្ហើមធំតែម្នាក់ឯង ។ រំពេចនោះស្រាប់ តែនាងឮសូរស៊ីផ្លេឡាន ទីន!ទីន! នាងចឿនក៏ស្ទុះទៅបើកទ្វារ ឃើញលោកវិសាល ចូលមកដល់ថែមទាំងមានទិញផ្លែឈើមួយកញ្ច្រែងមកផ្ញើផង :

- អត់ទោស ! អ្នកនាងក្រពុំចិត្តនៅទេហ៎ នាង ?

- ចាស់នៅ ! សូមលោកអញ្ជើញចូលក្នុងសិនចាស!

ក្រពុំចិត្តក្រលេកឃើញភ្ញៀវបរឡានចូលមកដល់ ក៏ចេញទទួលតាមសមគួរ ទោះបីជាថ្ងៃនេះនាងមានអារម្មណ៍ដូចជាមិនសូវល្អប៉ុន្មានក៏ដោយ ។ ក្រលេកឃើញ ឆវីសោភាយើងកាលណា បុរសយើងញញឹមយ៉ាងស្រស់ហើយលើកដៃជំរាបសួរ :

- អ្នកនាងមិនចង្អៀតចង្អល់ក្នុងចិត្តទេ មែនទេហ៎ ដែលខ្ញុំមកលេងអ្នកនាងដោយ មិនបានណាត់ជាមុន ?

តរុណីក៏ឆ្លើយវិញថា :

- ចាស ! មិនទើសទាល់អ្វីទេ បានលោកនឹករលឹកហើយមកលេងខ្ញុំ ដល់ផ្ទះយ៉ាង នេះ ពិតជាកត្តិយសធំណាស់ ។ សូមអញ្ជើញចូលក្នុងអង្គុយលេងសិន ។

មាណវីសំដែងការគួរសមត្រលប់វិញ ។ លុះនាងចាក់ទឹកត្រជាក់ទទួលភ្ញៀវរួច ហើយ ក៏បន្លឺវាចាទៅលោកវិសាល ថា :

- ថ្ងៃនេះ លោកមិនធ្វើការទេ ទើបមានឱកាសមកលេងជាមួយខ្ញុំយ៉ាងដូច្នេះ?

លោកវិសាលញញឹមពព្រាយហើយឆ្លើយថា :

- ថ្ងៃនេះជាថ្ងៃអាទិត្យទេតើហ៎ ... ទើបខ្ញុំទំនេរ...

ភ្លាមនោះ នារីយើងនឹកខ្មាសតែក្នុងចិត្ត :

- យ៉ាប់មែនយើងនេះ ! តាំងពីចេញពីមន្ទីរពេទ្យមក ក៏ក្លាយជាមនុស្សមានសតិ ស្មារតីមិនគ្រប់គ្រាន់ហើយតើហ៎!

តែដើម្បីបន្លប់ការខ្មាសអៀន ក្រពុំចិត្តក៏តបទៅកាន់បុរសសង្ហារថា :

- អូហ៎ សូមទោស ខ្ញុំភ្លេចអោយឈឹងតែម្តង ។

លោកវិសាលក៏សើចខឹកៗឡើង តែមិនចាប់ភ្លឹកនឹងកិរិយារបស់នារីយើងទេ :

- ថ្ងៃនេះ ខ្ញុំគិតថាមកបបួលអ្នកនាងចេញទៅលំហែនៅក្រៅបន្តិច... តើអ្នកនាង ផ្តល់កត្តិយសអោយខ្ញុំបានដែរឬទេហ៎ ?

ក្រពុំចិត្តភ្ញាក់ព្រើត ។ នេះជាលើកទីមួយក្នុងជីវិតរបស់នាងហើយដែលមាន បុរសមកសុំណាត់ហៅដើរលេងនៅក្រៅតែពីរនាក់ ។ នាងនឹកឆ្ងល់ក៏សួរវិញថា :

- ហើយចុះ លោកមានបំណងចង់ទៅលេងខាងណាដែរទៅ ?

- គឺនៅអាហារដ្ឋានសែនមនោរម្យ ឯមាត់ទន្លេហួសព្រែកលាបបន្តិច ក្រោយវត្ត បាខែង មានលក់អាហារឆ្ងាញ់ណាស់ ថែមទាំងមានពោតស្ងោរដែលមានរសជាតិ រកគ្មានក្នុងលោកទៀតផង ។

និយាយពីរឿងចំណីភ្លាម ក្រពុំចិត្តហាក់ដូចជាស្រក់ទឹកមាត់តែម្តង ។ នាង ក៏ តបវិញថា :

- បើលោកមិនប្រកាន់ដូច្នេះ ខ្ញុំក៏មិនប្រកែកដែរ ។

CHANBOKEO.COM

ទាំងពីរនាក់ញញឹមដាក់គ្នាយ៉ាងស្រស់ស្រាយ ។

មួយស្របក់ក្រោយមក បុរសសង្ហារក៏បាននាំនារីសោភាមកដល់អាហារដ្ឋាន ប្រក់ស្បូវ សង់នៅក្រោមម្លប់ឈើដ៏ត្រឈឹងត្រឈៃមួយ នាមាត់ទន្លេមេគង្គ ។ នៅទីនោះ គេបរិភោគរបៀបខ្មែរបុរាណ ក្រាលកន្ទេលទទួលទានអាហារ ហើយ មានចងអង្រឹងទុកអោយភ្ញៀវអង្គុយយោលលេងកំសាន្តកាយទៀតផង ពិតជា សក្តិសមកន្លែងដ៏រមនា សំរាប់សំរាកកាយពីការនឿយហត់ និងទុក្ខលំបាកក្នុង ចិត្តក្នុងអារម្មណ៍នានា ។ លោកវិសាលបានហៅអាហារយ៉ាងឆ្ងាញ់ៗយកមក បរិភោគទាំងពីរនាក់ ។ តាមការពិតលោក មានសំដីទន់ភ្លន់ពិរោះណាស់ ហើយទោះ បីជាមើលទៅលោកមានវ័យប្រហែលសាមព្ទាយទៅហើយ ក៏ប៉ុន្តែនៅមានរូបរាង សង្ហារគួរអោយកត់សំគាល់ ។ ថ្ងៃនេះ ក្រពុំចិត្តមានអារម្មណ៍ ហាក់ដូចត្រជាក់ចិត្ត រសាយការតប់ប្រមល់ក្នុងចិត្តយ៉ាងច្រើន ដោយបានលោកវិសាលនិយាយលេង កំប្លែងជាមួយនាង ធ្វើអោយនាងរីករាយចិត្តខុសធម្មតា ។ បន្ទាប់ពីបរិភោគបាយ ហើយ លោកវិសាលបានយកហ្គីតាដៃមួយចេញពីកន្ទុយរថយន្តមក ។ តរុណីយើង ក្រលេកឃើញកាលណា ក៏សួរឡើងថា :

- អូហ៍! លោកចេះដេញហ្គីតាដែរ ?
- បាទ ! ចេះតិចតួចដែរ ។ ចុះអ្នកនាងវិញ ចេះច្រៀងខ្លះទេ ?

ក្រពុំចិត្តនៅអឹមអៀន មិនហ៊ាននិយាយថាយ៉ាងម៉េចទេ ។ ការពិតនាងក៏ចូល ចិត្តច្រៀងខ្លះៗដែរ តែមិនដែលច្រៀងឱ្យនរណាស្តាប់ក្រៅពីខ្លួនឯងតែប៉ុណ្ណោះ ។ រំពេចនោះលោកវិសាលក៏វាចាបន្តទៅទៀតថា :

- បើអ្នកនាងមិនចេះក៏មិនអីដែរ ចាំខ្ញុំច្រៀងអោយស្តាប់ណាំ ។

មាណវីញហើយក៏ញញឹមពព្រាយឡើង ។ លោកវិសាលក៏ចាប់ខ្ទង់ហ្គីតា ហើយ បន្លឺសៀងយ៉ាងក្រអួនក្រអៅគួរអោយចាប់ចិត្តចេតនាពេកក្រៃ :

មហោរីខេមរា

| | | |
|---|---|---|
| ១. | ឱ! សត្វមហោរី | យំស៊ីផ្លែជ្រៃ |
| | ស្រណោះទឹកដី | បវេណីអង្គរ ។ |
| ២. | ខ្មែរអើយសណ្តោស | មានប្រោសមានធមិ |
| | ដូចព្រហ្មអង្គរ | មេត្តាសព្វសត្វ ។ |
| ៣. | ឱ! សត្វមហោរី | ស៊ីហើយហើរបាត់ |
| | ជាតិខ្មែរយើងភ្លាត់ | ព្រោះបាត់មេត្តា ។ |
| ៤. | ធ្មេះសូមជ្រៃផ្លែ | សត្វបែរភោគ្គា |
| | ផ្អែតផ្ទៃលែងផ្សា | ចិន្តាមានសីល ។ |
| ៥. | លុះគ្រាជ្រៃផ្លែ | ចិត្តខ្មែរលែងធ្មិល (ទមិឡ) |
| | នោះជាតិយើងរិល | មានសីលក្សេមក្សាន្ត ។ |

សំលេងរបស់លោកវិសាលពិរោះណាស់ មិនចាញ់លោកឈឿនឧត្តម លោក សួសសងវាចា ឬលោកយន់សុភាព ប្រចាំក្រុមហ៊ុនផលិតឌីវីឌីការ៉ាអូខេ រៃមាស តោមាស និងផ្កាយព្រះចន្ទ័នោះឡើយ ។ សំលេងស្រទន់ត្រជាក់របស់បុរស ម្នាក់នេះ បានធ្វើអោយក្រពុំចិត្តរិតតែសប្បាយរំភើបចិត្តក្រៃលែង ។ នាងគិត ក្នុងចិត្តតែម្នាក់ឯងថា :

CHANBOKEO.COM

- តើជីវិតខ្ញុំ នឹងមានសេចក្តីសុខដូចនេះរហូតតទៅដែរឬយ៉ាងណា?

រំពេចនោះ លោកវិសាលក៏ប្តូរបទថ្មីមួយទៀត :

អនុភាពផ្កាយនិងព្រះចន្ទ

ប. ព្រះចន្ទរះហើយស្រស់ប្លែកធម្មតា សែនសោភា ចែងចាំងរស្មីពណ្ណរាយ
គូគាប់ទ្វេហា ចចារសំនៀងឆ្លងឆ្លើយ បានយល់ចន្ទហើយ ចិត្តស្បើយ
ណាយអស់កង្វល់ ។

ក្រពុំចិត្តឮសូរបទចំរៀងនេះភ្លាម ស្រាប់តែសប្បាយចិត្តតែម្តង ព្រោះនាងក៏ ចេះច្រៀងបទនេះដែរ ។
មាណវីក៏ទះដៃហើយច្រៀងតបវិញយ៉ាងរីករាយ :

ស. ផ្កាយរះត្រចះអមដួងចន្ទ្រា ឯនភាបញ្ចេញរស្មីនិមល ពន្លឺភ្លឺផ្លេក
ប្រស់ព្រំមង្គល ដល់គូនិមល អោយយល់នូវម្លប់សុខា ។

ប.ស. ឱ!ផ្កាយព្រះចន្ទដ៏ល្អពណ្ណរាយ ភ្លឺថ្លាឆើតឆាយ រះរាយ ពេញផ្ទៃមេឃា
អរគុណអ្នកណាស់ចំពោះរស្មីសោភា ចិន្តារងា ប្រែជាក្សេមក្សាន្តភិរម្យ ។

ប. សូមផ្កាយព្រះចន្ទរឿងរះគ្រប់កាល

ស. យើងត្រអាលរស្មីដ៏សែនមនោរម្យ

ប.ស. ពេលបានយល់អ្នកចិត្តយើងពិតសែនសុខុម
ស្រើបស្រាលអារម្មណ៍ ហាក់ស្ថិតនាស្ថានសួគ៌ា ។

CHANBOKEO.COM

ទាំងពីរនាក់ទះដៃព្រមគ្នាតែម្តងកាលបើច្រៀងបានចប់យ៉ាងពិរោះរណ្តំ។

ភ្លាមនោះ ស្រាប់តែទូរសព្ទមួយចូលមកដល់លោកវិសាល។ លោកក៏ងាកមក សុំទី ពីមាណវីរបស់យើង :

- សូមទោសអ្នកនាង ខ្ញុំសូមទៅទទួលទូរសព្ទពីចៅហ្វាយនាយមួយភ្លែតសិន។
បន្តិចទៀត ខ្ញុំមកវិញហើយ ។

ថាហើយ លោកវិសាលក៏ចូលទៅក្នុងរថយន្ត បិទកញ្ចក់និយាយកិច្ចការសំងាត់
ទុកអោយក្រពុំចិត្តនៅអង្គុយយោលទោងមើលខ្សែទឹកហូរក្នុងទន្លេតែម្នាក់ឯង ។ រំពេចនោះ
ស្រាប់តែមាណវីបានឮសំដីមួយនិយាយមករកនាងទំនងកាចៗផងថា :

- នាងចិត្ត ! មិនទៅសាលាទេហ៎? ហេតុអ្វីមកដើរលេងតែពីសតែពាសយ៉ាងនេះ?

ក្រពុំចិត្តភ្ញាក់ក្រញាងកាលបើឮសំដីនេះ។ នាងងាកក្រោយផាំង ឃើញដារិយ៉ា នាំមិត្តប្រុសមិត្តស្រីមួយហ្វូងដើរចូលមកដល់
ដោយនិយាយមកនាងបន្ថែមថា :

- គ្រាន់តែម៉ាក់ប៉ាមិនទៅពីរបីថ្ងៃហ៊ានថ្លើមធំលួចមកដើរលេងផងហ្អែស នាងចិត្ត? អីលូវហ្នឹង ដូចជាកាន់តែក្បាលខូចណាស់តើហ៎!
ឆាប់ទៅផ្ទះភ្លាម !!

ក្រពុំចិត្តជ្រួញចិញ្ចើមគិតក្នុងចិត្ត :

- បងដារិយ៉ា ! ពិតមែនតែបងខំតំលើងអំណាចជាបង ដេរស្តីប្អូននៅចំពោះពួក ម៉ាក ធ្វើឫកហាំយ៉ាងនេះក៏ដោយ ក៏បងមិនអាចជួយខ្លួនបងឱ្យខ្ពស់ជាងខ្ញុំប៉ុន្មានដែរ! មើលចុះ! បងក៏កំពុងដើរលេងជាមួយមិត្តភក្តិរហេតរហូតមកដល់ទីនេះដូចតែគ្នា មានដឹងខ្លួនទេ? ឬក៏បងកំពុងដេរស្តីដើម្បីអោយខ្ញុំអន់ចិត្តរួចដើរចេញ នឹងអាល លែងបានឃើញសកម្មភាពទាំងឡាយរបស់បងនិងមិត្តតទៅទៀត ?

ភ្លាមនោះ ដារិយ៉ាបែរទៅរកមិត្តប្រុសម្នាក់ ហើយនិយាយថា :

- នែ៎! ប៉េងឡុង ទំនេរទេហ៎ ? ជួយនាំប្អូនខ្ញុំទៅទំលាក់នៅផ្ទះវិញ បន្តិច !

កំលោះឈ្មោះប៉េងឡុង ក៏ងក់ក្បាល :

- មានអី! តែកុំភ្លេចចេញថ្លៃសាំងមក ហើយថែមបាយមួយពេលទៀតផង!

- យី! ស្អីក៏ស្អីទៅ អោយតែយកនាងចិត្តទៅដល់ផ្ទះវិញដោយសុខសប្បាយចុះ ។

ដារិយ៉ានិយាយចប់ក៏បែរមកនិយាយជាមួយក្រពុំចិត្តវិញ :

- ថ្ងៃក្រោយនៅផ្ទះ មើលការខុសត្រូវក្នុងផ្ទះផង កុំដើររហេតរហូតដូច្នេះទៀត ឮហើយនៅ?

ក្រពុំចិត្តនឹកថា ទោះប្រកែកជាមួយបងស្រីក៏ឥតបានការដែរ នាំតែអោយមិត្ត ភក្តិរបស់បងស្រីសើចចំអកនាងទាំងពីរនាក់តែប៉ុណ្ណោះ ម្ល៉ោះហើយក៏សុខចិត្តនៅ ស្ងៀម ចុះចាញ់បងស្រីហើយក៏ងើបដើរចូលទៅក្នុងរថយន្តរបស់ប៉េងឡុង ចេញទៅដោយមិនបានលាលោកវិសាលមួយម៉ាត់ឡើយ ។ ការពិតនាងមិនចង់ចូលទៅ លាលោកវិសាលដែរព្រោះមិនចង់អោយលោកបានឃើញចរិតដ៏យ៉ាប់យ៉ឺនរបស់បង ស្រី នាំឱ្យអាមាសឥតអំពើ ទើបសុខចិត្តទុកអោយលោកអន់ចិត្តនឹងនាងតែម្នាក់ ឯងទៅវិញ ។ នៅពេលក្រពុំចិត្តឈានដើរចូលឡានប៉េងឡុង មាណវីយើងបានឮ ដារីយ៉ានិយាយទៅកាន់មិត្តភក្តិរបស់នាងជាចុងក្រោយថា :

- ខ្ញុំត្រូវតែប្រយ័ត្នខ្លះទើបបាន ព្រោះអីប្អូនស្រីរបស់ខ្ញុំមួយនេះ ទក់មកទុយមុយ ឆោតល្ងង់ណាស់ មិនសូវមានប្រាជ្ញាទេ បើបណ្តោយអោយទៅដើរលេងផ្តេសផ្តាស ខ្លាចត្រូវគេបោកអស់ខ្លួនអស់ប្រាណ អញ្ចឹងហើយបានជាខ្ញុំចង់អោយនាងទៅផ្ទះវិញ ទើបមានសេចក្តីសុខ មានសុវត្ថិភាពជាជាង ។

ឮប្រយោគនេះ ក្រពុំចិត្តហាក់ដូចជាមានអារម្មណ៍មិនល្អអ្វីបន្តិចសោះ តែក៏ មិនតបមាត់អ្វីដាក់បងស្រីវិញដែរ គ្រាន់តែនឹកគិតក្នុងចិត្តថា :

- គ្រាន់តែខ្ញុំជាមនុស្ស ដែលមិនចូលចិត្តតមាត់ឬនិយាយឥតប្រយោជន៍ច្រើនប៉ុណ្ណឹង ម៉េចក៏បងហ៊ានសន្មតថាខ្ញុំជាមនុស្សល្ងង់កើត ? ការពិត ខ្ញុំមិនមែនជាអ្នកសន្សំ រឿងយកចាញ់យកឈ្នះតែប៉ុណ្ណោះ... ឬក៏បងយល់ថា មានតែបងម្នាក់ទេដែលជា មនុស្សឆ្លៀវឆ្លាតជាងគេក្នុងផ្ទះ?

ក្រពុំចិត្តគិតផង ដើរចូលឡានផង ទុកបណ្តោយអោយប៉េងឡុងជាអ្នកបើក បរជូននាងរហូតដល់ផ្ទះ ។ តាមផ្លូវ នាងធុញនឹងប៉េងឡុងទ្រាំសឹងមិនបាន ដែល នាយវាយឫកក្រលេមក្រឡឹម និយាយឌឺដងលែបខាយដាក់នាងមិនឈប់ឈរ ។ ទោះជាយ៉ាងណាក៏តរុណីយើងនៅស្ងៀមស្ងាត់មិនមាត់កអ្វីរហូតដល់លំនៅវិញ ។

រីឯលោកវិសាល កាលបើនិយាយទូរសព្ទចប់ ក៏វិលមកកន្លែងដើម ស្រាប់តែ បាត់រូបនារីយើងសូន្យពីកន្លែង។ លុះលោកក្រលេកមើលនាយអាយ រកមើលក្រពុំ ចិត្ត ក៏ស្រាប់តែប្រទះកញ្ញាឆើតឆាយដារិយ៉ាដើរចូលមកដាក់ខ្លួននៅទីមួយក្បែរ នោះព្រមជាមួយមិត្តប្រុសស្រីពីរបីនាក់ទៀត ។ ដារិយ៉ាក៏ទាញកញ្ចប់បារីចេញមក បំរុងនឹងយកបារីមកជក់។

CHANBOKEO.COM

លុះនាងដាក់ភ្នែកទៅម្ខាងក៏ប្រទាក់ក្រសែភ្នែករបស់ លោកវិសាលដ៏សង្ហាវិញដែរ ។ ឃើញដូច្នោះ លោកវិសាលក៏ញញឹមដាក់នាងធ្វើឫកពារធម្មតា ហើយក៏លើកហ្គីតាកាន់រចេញសំដៅទៅរថយន្ត ។ មិត្តស្រីរបស់ ដារិយ៉ាម្នាក់ យកដៃកេះដារិយ៉ា ហើយនិយាយថា :

- ហ្អក់ ! ឯងឃើញទេ? បុរសម្នាក់នោះពិតជាសង្ហាណាស់ ថែមទាំងញញឹមរកឯង ទៀតផង សង្ស័យតែគេជាប់ស្នេហ៍នឹងសម្ផស្សឆើតឆាយរបស់ឯងហើយ ។

ដារិយ៉ាញញឹមហើយញាក់ចិញ្ចើមធ្វើឫកយ៉ាងសឿង :

- នៅលើលោកនេះ តើបុរសណាមួយទៅដែលប្រកែកថា មិនចាប់ភ្លឹកនឹងសម្រស់ របស់ដារិយ៉ាយើងនោះ... ?

00 00

00

CHANBOKEO . COM

# វគ្គទី៨
# ហង្សក្នុងសំបុកក្អែក

ជាងពីរអាទិត្យកន្លងទៅហើយ ដែលឈូកបានមកស្នាក់នៅជាមួយគ្រួសារមីង សោម ។ ពិតមែនហើយ ! ជីវភាពគេអត្តខាត់បន្តិច តែគេមានទឹកចិត្តចំពោះនាង គ្រប់ៗគ្នា ។ ទោះបីឈូកគ្រាន់តែជាមនុស្សចំលែកក្នុងគ្រួសារ គេក៏នៅតែរាប់អាន ថែទាំជំងឺរបស់នាង មិនខុសពីសាច់ញាតិមួយរូបរបស់គេទេ ។ រាល់ព្រហាមស្រាង សុជាតិចេញទៅរត់ឡានឈ្នួលបាត់ ។ លុះរសៀលបន្តិច គេក៏ត្រលប់មកវិញហើយ ទៅរែកទឹកស្រោចចំការថ្នាំជក់ ព្រមទាំងរែកសំរាប់ការប្រើប្រាស់ក្នុងគ្រួសារទៀត ផង ។ រីឯសមាជិកគ្រួសារដែលនៅសល់ សុទ្ធតែជាស្រីមានពិការភាពគ្រប់ៗគ្នា ។ មីងសោមងងិតភ្នែក នាងតូចសុខាពិការជើង ហើយឈូកវិញក៏នៅមិនទាន់ជាស្រួល បួលពីជំងឺរកតែជួយអ្វីមិនកើត ។ ប៉ុន្តែគួរអោយសរសើរសុជាតិណាស់ ឃើញតែ ប្រឹងធ្វើការមិនដែលរអ៊ូត្អូញត្អែនឹងជីវិតរបស់ខ្លួនគេម្តងណាទេ ។ រាល់ពេលរសៀល ដែលគេត្រលប់មកពីរត់ឡានឈ្នួល គេតែងទិញចំណើមកផ្ញើអ្នកផ្ទះជានិច្ច ។ រីនាង តូចសុខាវិញ ថ្វីត្បិតតែពិការតែនាងជួយដៃជើងបងប្រុសរបស់នាងមិនទំនេរឡើយ មានកាលនាងរែកថ្នាំជក់ទៅអោយគេ នៅអូរតាគី ទាំងដំណើរបាំងពៀចៗយ៉ាប់ យ៉ឺន ។ មីងសោមមានមេត្តាចំពោះឈូកណាស់ ហាក់ដូចកូនដូចចៅរបស់គាត់មួយ រូប រួចគាត់តែងតែមានរឿងនិយាយសប្បាយរីករាយជាមួយកូនៗរបស់គាត់ជានិច្ច ពេលជួបមុខគ្នាម្តងៗ ។

ឥលូវនេះ សុខភាពរបស់ឈូកក៏បានគ្រាន់បើបន្តិចហើយ គ្រាន់តែនាងមិនទាន់ ទំលាប់ខ្លួនបានតាមរបៀបអ្នកក្រអត្តខាត់នៅឡើយ ។ ទោះជាយ៉ាងណាក៏មាណវី មិនបោះបង់ការព្យាយាមរបស់នាងចោលដែរ ។ ម្យ៉ាងទៀត បើនាងមិនប្រឹង សំរបសំរួលខ្លួនទេនោះ តើអោយគ្រួសារដ៏ក្រីក្រនេះតំរូវតាមទំលាប់ចាស់របស់នាង ដូចម្តេចបានទៅ បើគ្នាខ្វះមុខខ្វះក្រោយយ៉ាងដូច្នេះ?

ដោយនាងមានអារម្មណ៍ថាមានកំលាំងធម្មតាវិញហើយ ឈូកក៏ស្ម័គ្រសុំខ្លួន ជួយយកថ្នាំជក់ពីរនាក់សុខាទៅបោះដុំអោយម៉ូយនៅអូរតាគី ហើយមីងសោមក៏ អនុញ្ញាតអោយឈូកទៅជាមួយ គ្រាន់បានជាគ្នា ។ តាមពិតពីផ្ទះមីងសោមទៅ អូរតាគីមានចំងាយប្រហែលបីគីឡូម៉ែត្រងណោះហើយឈូកក៏មិនដែលមានទំលាប់ ធ្វើការអ្វីធ្ងន់ៗក្នុងជីវិតពីមុនមកដែរ ម្ល៉ោះហើយសូម្បីតែទូលថ្នាំជក់មួយទំនូលតូច សោះក៏ឈូកមានអារម្មណ៍ស្មើនឹងទូលអង្ករមួយបាវអញ្ចឹង ។ នាងខំប្រឹងទូលដើរ ឡើងបែកញើសសស្រាក់ ។ លុះឃើញបងស្រីខំប្រឹងទាំងត្រដរ សុខាក៏បបួលរំលែក ពីឈូកមកដាក់អម្រែករបស់នាងវិញដែរ តែឈូកអាណិតប្អូនស្រីពិការពេក មិន ហ៊ានតបអ្វីវិញទេ ក៏ខំប្រឹងតែពីទូលរហូតដល់ទីដៅ វិះតែនឹងដួលខ្យល់គ ម្តងៗ ។ មុននឹងត្រលប់មកផ្ទះវិញ ឈូកបានឃើញគេលក់នំសែសយ ក៏នឹកភ្នកដល់ មីងសោមដែលនៅឯផ្ទះ និងសុជាតិដែលខំធ្វើការនឿយហត់ ក៏ដាច់ចិត្តទិញពីរ កញ្ចប់មកផ្ញើ ។

តាមផ្លូវមកផ្ទះវិញ អ្នកទាំងពីរដើរបណ្តើរជជែកគ្នាបណ្តើរសើចកក្អឹក យ៉ាង សប្បាយ ។ ស្រាប់តែមានបុរសពីរនាក់ជិះកង់ឌុបគ្នាមកដល់ ។ កាលបើក្រលេក ឃើញអ្នកទាំងពីរ បុរសម្នាក់និយាយឡើងថា :

- អ៊ើ យាយបាក់! ឯងនាំក្រមុំចាមមកពីណា ដើរជាមួយគ្នាហ្នឹង?

សុខាឮហើយក៏អោនខ្សិបទៅឈូកថា :

- បងឈូកកុំនិយាយរកអោយសោះ ។ ពួកវាជាអ្នកលេងទេ !

CHANBOKEO.COM

ឈូកទាញក្រមាបាំងមុខហើយកាន់ដៃប្អូនដើរបន្តទៅទៀត ។ បុរសទី២ឃើញ ហើយក៏និយាយឡើងដែរ :

- នែ៎ អូន! បងកំពុងនិយាយរកអូនណា៎! ម៉េចមិនឆ្លើយបងវិញអញ្ចឹង?

- មែនហើយ! មើលទៅមុខប្លែកណាស់! អូនជាកូនចៅអ្នកណាដែរនៅម្ដុំនេះ? ម៉េចបានជាបងមិនដែលជួបមុខពីមុខមកសោះ? (បុរសទីមួយបន្ថែម)

តែឈូកនៅតែមិនមាត់ដដែល ចេះតែនាំប្អូនដើរលឿនឡើងៗ ។ បុរស ទាំងពីរហាក់ដូចមិនអស់ចិត្ត ដែលធិតាធ្វើឫកឆ្មើងឆ្មៃមិនព្រមឆ្លើយតបទៅគេវិញ ក៏នាំគ្នាចុះពីកង់  ដើរទទ្ទឹមឈូកនិងសុខាម្ខាងមួយហើយស្រដីថា :

- នែ៎អូនសំលាញ់! មុខមាត់ស្រស់ស្អាតណាស់! មានសង្សារហើយនៅ? បើមិនមាន ធ្វើសង្សារបងក៏បានដែរ ។ បងជាកំលោះនៅទំនេរ...

បុរសទីមួយនិយាយផង យកដៃភ្ជាក់លើស្មាឈូកផង តែនាងយកដៃគៀស ចេញភ្លាម ។ សុខាឃើញហើយក៏យកដងរែកវៃបុរសនោះយ៉ាងខ្លាំង :

- នែ៎ពូ ! កុំប៉ះពាល់បងស្រីខ្ញុំណា៎!

- យីអើ! គេស្រលាញ់បានគេប៉ះ! អីក៏ឆ្មាសម្លេះនាងល្អិត! កំបិកំបាក់យ៉ាងនេះ ចេះមកហៃហៃស៊ីដែរ?

ថាហើយ បុរសនោះយកដៃប្រច្រានសុខាដួលខ្ពោកទៅដី ។ ឃើញដូច្នោះ ឈូកក៏ស្ទុះទៅប្រវាចាប់ដៃបុរសនោះអូសចេញមិនអោយគេវាយប្អូន ក៏ត្រូវនាយ ទះប្រច្រានដួលប្រួសក្បែរសុខា ហើយជ្រុះនំសែសយពីដៃទៅដី ។  ស្រាប់តែ :

- ឈប់ភ្លាម!

បុរសម្នាក់បានមកដល់ហើយ ស្រវាទាត់បុរសទាំងពីរដួលខ្ពោកៗទៅដី ព្រម ទាំងចង្អុលមុខបុរសក្បាលខូចទាំងពីរ :

- ឆាប់ចេញពីទីនេះភ្លាម! ឯងគ្មានសិទ្ធប្រមាថគេទាំងពីរនេះទេ!

ឈូកងើបមុខឡើង ឃើញនាយភ្លាម ក៏សំដែងចិត្តត្រេកអរ :

- បងជាតិ!

បុរសទាំងពីរឃើញសុជាតិឈរសង្ហើញដាក់ខ្លួនក៏នាំគ្នាបន្ទន់សំលេង :

- អ៊ើណា៎ ! អាជាតិអើយ! អញលេងនឹងវាតើហ៏ា តែមីល្អិតនេះវាវៃអញមុន បាន អញប្រដៅវាខ្លះទៅ...

សុជាតិមិនមានអារម្មណ៏ធ្វើជាមិត្តរបស់គេទាំងពីរទេ ។ នាយក៏និយាយតប វិញថា :

- ទោះជាយ៉ាងណា ក៏ឯងជាបុរស ម្តេចទៅធ្វើបាបស្រីៗយ៉ាងនេះ?

- អញមិនមានចិត្តធ្វើបាបវាទេ អញគ្រាន់តែញ៉ៀវាលេងតើហ៏ា ហេតុអីក៏ឯងចាំវាយ ឫកធ្វើជាប្រចណ្ឌ័ផង? ឬក៏វាជាប្រពន្ធរបស់ឯងហ្អ៎ាស?

ទ្រាំមិនបាននឹងសំដីច្រលោងខាមរបស់បុរសទាំងពីរ សុជាតិក៏ស្រវាថៃមមួយ ដៃមួយជើង តបទៅតបមកជាមួយបុរសពាលទាំងពីរ រហូតដល់ពួកវាស្រវាទាញ កង់ឡើងជិះរត់បាត់ពីទីនោះទៅ ។ ឈូកក៏ងើបស្រវាសុខាជួយគ្រាហ៏ប្អូនអោយងើប ឡើង ហើយបែរញញឹមដាក់សុជាតិដោយក្តីត្រេកអរដែលនាយបានមកទាន់ជួយ ធ្វើអន្តរាគមន៏ ប៉ុន្តែសុជាតិបែរជាធ្វើមុខក្រញូវដាក់នាងទៅវិញ ។ លុះឃើញកិរិយា របស់នាយហាក់ដូចជាមិនសប្បាយចិត្ត ឈូកប្រែជាភ័យញ័រមិនហ៊ានហើបមាត់អ្វី និយាយជាមួយសុជាតិដែរ ។ នាងក៏ស្ទុះគ្រាហ៏សុខាយកទៅដាក់លើរានកង់របស់ សុជាតិពីក្រោយ ដើម្បីឱ្យនាយឌុបត្រលប់ទៅផ្ទះវិញ ។ រំពេចនោះ ឈូកឮសុជាតិស្តី អោយនាងដោយពាក្យខ្លាំងៗថា :

CHANBOKEO.COM

- ឥលូវនេះអីក៏ហ៊ីហាម្លេះហ្ន៎យើងហ្នឹង? មិនទាន់ជាពីឈឺស្រួលបួលផង ហ៊ានចេញ ដើររហេតរហូតទិញចំណីញ៉ាំសប្បាយ អួតបង្ហាញសម្ផស្សរូបកាយ តែពាសពេញ ភូមិ ដោយមិនខ្លាចចិត្តនរណាទៅហើយហ្អែស? ឬក៏សំបូរលុយចាយខ្ជះខ្ជាយណាស់ ទៅឬ បានជានាំប្អូនមកដើរស៊ីចាយដូច្នេះ? ដឹងទេហ៎ថាខ្ញុំមានការពិបាកប៉ុណ្ណាក្នុង ការរកប្រាក់មកទប់ទល់ការខ្វះខាតក្នុងផ្ទះរបស់យើង?

ឈូកឮហើយឈ្ងោកមុខចុះមិនហ៊ានពោលពន្យល់អ្វីវិញទេ ត្បិតមាណវីឃើញ នាយកំពុងមានអារម្មណ៍មិនល្អ ម្ល៉ោះហើយក៏គិតតែពីឈ្ងោកមុខដើរញ័រដៃញ័រជើង តាមពីក្រោយសុជាតិដែលអូសកង់ដឹកសុខាដើរត្រឹក១សំដៅទៅផ្ទះ ។ យូរ១ម្តង សុជាតិបែរក្រោយលួចមើលនាងម្តង១ដែរ ទំនងដូចជាមិនដាច់ចិត្តជិះកង់ទៅចោល អោយនាងនៅដើរតែម្នាក់ឯង ។ មកដល់ផ្ទះវិញ សុជាតិក៏យកថ្នាំទៅបិតកែងដៃនឹង ក្បាលជង្គង់អោយសុខាហើយបែរសំលឹងឈូក ដែលអង្គុយឈ្ងោកមុខ កេះម្រាម ដៃនៅកាំជណ្តើរផ្ទះ រួចស្រដីថែមថា :

- ថ្ងៃក្រោយ បើឈូកចង់ទៅដើរលេងឯណា ក៏ទៅចុះ តែកុំនាំសុខាអោយទៅដើរ ជាមួយនាងដូច្នេះទៀត ឃើញទេហ៎ រាសីមានគ្រោះរបស់នាងឆ្លងដល់សុខាហើយ!

ឮដូច្នោះ ឈូកក៏ឱនដើរចេញទៅ ទាំងទឹកភ្នែករលីងរលោង ទំនងដូចជាទឹក តូចចិត្តយ៉ាងណាមិនដឹង ។ កាលបើឮមាត់សុជាតិនិយាយខ្លាំង១ មីងសោមក៏សួរ :

- អាង៉ាអើយ! មានរឿងអីឬកូន?

តែសុជាតិមិនឆ្លើយទេ ។ សុខាឃើញដូច្នោះក៏ឆ្លើយជំនួសវិញ :

- បងជាតិគាត់ម៉ូម៉ៅ ព្រោះមានមនុស្សប្រុសពីរនាក់មកធ្វើបាបខ្ញុំនិងបងឈូក ។

- ហើយចុះឯងមានគ្រោះថ្នាក់អ្វីទេកូន?

- អត់អីទេម៉ែ! គ្រាន់តែដួលរលាត់ដៃជើងបន្តិចបន្តួច ។

- ហើយចុះឈូកវិញនោះ យ៉ាងណាទៅហើយកូន?

- គេមិនអីទេ! ថ្ងៃក្រោយ ម៉ែកុំបណ្តោយអោយគេដើរលេង ទិញទំពាំងរហេតរហូត ឆ្ងាយផ្ទះដូច្នោះទៀត ( សុជាតិឆ្លើយទំនងដូចជាអាក់អន់ចិត្ត)

- អត់ទេកូន! ឈូកវាមិនបានចេញទៅដើរលេង ទិញទំពាំងនោះទេ ។ ការពិត ម៉ែប្រើវាអោយជួយសុខាទូលថ្នាំជក់ទៅអោយគេនៅឯអូរតាគីឯណោះតើហ៎!

សុជាតិឮហើយភ្ញាក់ព្រើត បើកភ្នែកមូលខ្លំ :

- មែនឬម៉ែ?

- អឺ! សុខាថាវារែកយកមិនអស់ ទើបម៉ែប្រើនាងឈូកអោយវាជួយទូលមួយ ទំនួលដែរទៅ ។

ភ្លាមនោះសុជាតិមានអារម្មណ៍ហាក់ដូចជាធ្លាក់ពីចុងឈើ ត្បិតខ្លួនកំពុងចោទ ឈូកទាំងច្រលំទទឹងទទែង ។ នាយក៏ក្រលេករកមើលឈូកដែលនៅអង្គុយនៅមាត់ ជណ្តើរសាជាថ្មី ស្រាប់តែបាត់ស្រមោលរបស់នាងពីកន្លែងនោះទៅ ឃើញតែនំ សៃសយពីរកញ្ចប់ដែលនាងទុកចោលនៅក្បែរមាត់ទ្វារ ។ រំពេចនោះ សុខាក៏ពោល ទៅកាន់បងប្រុសខ្លួនថា :

- ការពិតបងឈូកថាគាត់អាណិតម៉ែមិនដែលបានពិសារអ្វីប្លែកមាត់ ហើយឃើញ បងជាតិក៏ធ្វើការហត់រាល់ថ្ងៃ ទើបគាត់ខំទិញនំផ្ញើ តែបងជាតិវិញគិតតែពីម៉ូម៉ៅស្តី គំហកដាក់គាត់ធ្ងន់១ បានជាគាត់មិនហ៊ានប្រាប់បងនោះអី!

CHANBOKEO.COM

សុជាតិឮដូច្នោះ ក៏នឹកស្តាយក្នុងចិត្ត អាណិតដល់ឈូកគ្រលួចតែម្តង មិនគួរ ណានាយឆាប់ច្រឡោតយល់ច្រលំចំពោះនាងឡើយ ។ បុរសយើងក៏ស្ទុះទៅស្រវាទំ ទាំងពីរកញ្ចប់នេះលើកឡើងឃើញប្រលាក់សុទ្ធតែដី ។ មែនហើយ សុជាតិបន្ទោស ខ្លួនឯងណាស់ដែលបានគំហកធ្ងន់ៗដាក់មាណវី ។ នាយក៏ដាក់នំទាំងពីរកញ្ចប់ចុះ ហើយក៏ស្ទុះចេញទៅរកឈូកភ្លាម ។ សុជាតិខំជិះកង់តាមរករហូតដល់មាត់ថ្នល់ជាតិ លេខ៥ នៅតែមិនឃើញស្រមោលរបស់ឈូកទាល់តែសោះ ។ គ្រានេះ នាយយើង មានចិត្តអន្ទះសាច្រាសច្រាល់យ៉ាងណាមិនដឹង កាលបើរកធិតាយើងមិនឃើញ ។ គេជិះកង់ទៅមកៗពីរបីសានៅតែមិនជួបឈូកដដែល ។ បន្តិចមក នាយក៏យកដៃ ឈ្លីសក់នឹកខឹងនឹងខ្លួនឯងជាខ្លាំងដែលឆេវឆាវគិតមែខុសទៅលើនាង ។ នាយយើង នឹកព្រួយចិត្តស្ងួតទឹកមាត់អស់ពីបំពង់ករលីងដោយការភ័យបារម្ភ មិនដឹងថានាង ចាកចេញទៅណា ហើយទៅយ៉ាងណា បើមានតែខោអាវមួយចង្កេះគត់ ។ រីឯមីង សោមនិងសុខាក៏ឆ្ងែឆ្ងាដូចគ្នា មិនដឹងថាត្រូវធ្វើយ៉ាងម៉េចដើម្បីតាមរកឈូកឃើញ ក៏នាំគ្នាអង្គុយសំកុកនៅមុខផ្ទះធ្វើមុខស្មើកទាំងពីរនាក់ ទុកបណ្តោយអោយសុជាតិ រត់ចុះរត់ឡើងតាមរកឈូកតែម្នាក់ឯង ។ អស់ចិត្តហើយ សុជាតិក៏បែរក្រោយ ត្រលប់ចូលផ្ទះវិញ ទាំងបេះដូងក្រៀមស្រពោនសោកសៅយ៉ាងចំលែក ។ ល្ងាចនោះ បុរសយើងលេបបាយមិនចូលទេ ។ អាហារអ្វីៗហាក់ក្លាយជាដុំថ្មដុំគ្រួសអស់រលីង ។ នៅក្នុងចិត្ត សុជាតិមានអារម្មណ៍តប់ប្រមល់ណាស់ ដៃជើងរបស់នាយក៏ក្លាយជា រសេះរសោះដោយឯកឯង ។ តើហេតុអ្វីទៅហ្ន៎? ហេតុអ្វីក៏ឈូកមានសារៈសំខាន់ ចំពោះដួងចិត្តរបស់នាយដល់ម្លឹង?

ព្រះសុរិយារៀបលិចឯនាយជើងមេឃបញ្ចេញឱភាសពណ៌មាសហើយ...

ឈូកនៅតែបាត់ស្រមោលមិនឃើញត្រលប់មកវិញដដែល ។ ក្នុងផ្ទះសុជាតិក៏ ហាក់ដូចជាស្ងៀមស្ងាត់ខុសធម្មតា មិនមានស្នូរសំណើចក្អាកក្អាយលាន់ឮដូចសព្វដង ទេ ។ មីងសោមសំរាន្តនៅស្ងៀម អោយសុខាអានសៀវភៅធមិអោយស្តាប់ ។ សុជាតិខ្វល់ចិត្តពេក ក៏ស្រវាយកខ្លុយរបស់នាយដើរសំដៅទៅត្រពាំងព្រលិតឯខាង ក្រោយផ្ទះ ដាក់ខ្លួនអង្គុយលើក្តារស្ពាន ហើយក៏ចាប់ផ្លុំនូវបទចំរៀងដួងចិត្ត មួយបទដ៏សែនសោកសៅ :

សូមអភ័យ

| | | |
|---|---|---|
| ១. | ស្តាយគ្មានឱកាសសូមទោសអូន | ស្តាយព្រោះខុសខ្លួនយល់ច្រឡំ |
| | ស្តាយចិត្តអាណិតកែវមាសមុំ | មិនដឹងអូនយំខឹងយ៉ាងណា... |
| ២. | ស្តាយត្រឹមតែគូមិនបានគិត | ឥលូវិបិតក្នុងឱរា |
| | បងនឹកពៅណាស់កែវជីវ៉ា | អូនបាត់ទៅណាអោយបងខ្វល់ ។ |
| ៣. | ព្រះសូរ្យយ៉ាងបាត់ស្ងាត់រូបស្រី | បេះដូងរីងរៃនឹកនិមល |
| | ក្នុងចិត្តបែបនេះសូមឱ្យយល់ | ភក្រ្តកែវនិមលថ្មីម្តងទៀត ។ |
| ៤. | បើសិនអូនពិតយល់ចិត្តបង | សូមស្រីទងវង់ស្រស់វរនាថ |
| | នាងឆាប់វិលវិញកុំឃ្លាឃ្លាត | ហត្ថាបងត្រៀមទទួលហើយ.... |

សុជាតិនៅអង្គុយសំកុកមួយស្របក់ ទើបងើបឡើងបំរុងនឹងដើរត្រលប់ទៅផ្ទះ វិញ ស្រាប់តែដាក់ភ្នែកទៅចំស្រមោលមនុស្សស្រីមួយរូប នៅអង្គុយផ្អែកនឹងដើម ក្រសាំង លើភ្លឺស្រែ មិនឆ្ងាយប៉ុន្មានពីត្រពាំងព្រលិតទេ ។ ឃើញនាងហើយ មាណព ញញឹមឡើងភ្លាមដោយក្តីត្រេកអររំភើបញាប់ញ័រហើយឧទានខ្សិបៗថា :

- ឈូក!....

CHANBOKEO.COM

នាយក៏ដើរតំរង់ទៅនាងភ្លាមដោយកិរិយាត្រេកអរកខិបកខុប ។ លុះមកដល់ ក្បែរនាង សុជាតិដាក់ខ្លួនចុះហើយវាចាយ៉ាងស្រទន់ទៅកាន់នាងថា :

- ឈ្មូក! ម៉េចមកសំងំស្ងាត់ៗទីនេះតែម្នាក់ឯងអញ្ចឹង? ដឹងទេហ៎ថាអ្នកផ្ទះរបស់ យើង គេកំពុងតាមរកឈ្មូកយ៉ាងខ្វាយខ្វល់បំផុត?

ឮភ្លាម ឈ្មូកងើបបែរមើលឃើញនាយយ៉ាងរហ័ស ស្រាប់តែសំដែងទឹកមុខ ស្វាយល្អក ភ័យញ៉័រដៃញ៉័រជើងតែម្តង ទំនងខ្លាចសុជាតិខ្លាំងណាស់ ។ ឃើញដូច្នោះ សុជាតិក៏លូកចាប់ដៃនាងក្តាប់យ៉ាងណែនអោយនាងបាត់ភ័យ ហើយក៏ស្រដីថា :

- ឈ្មូក! ខ្ញុំសុំទោសណាំដែលខ្ញុំម៉ូម៉ៅហើយនិយាយស្តីមិនសមរម្យដាក់ឈ្មូក កាល ពីរសៀលមិញ ត្បិតអីខ្ញុំខឹងនឹងបុរសពីរនាក់នោះជ្រុលពេក បានជាជះកំហឹងទៅ លើនាងដោយមិនបានគិត ។

ពេលនោះឈ្មូកងើបមុខឡើងស្រដីតបវិញដោយញ៉័រៗថា :

- ឈ្មូក... មិនបានខឹងនឹងបងទេ...

- បើមិនខឹង ហេតុអីក៏ឈ្មូកមិនត្រលប់ទៅផ្ទះរបស់យើងវិញ?

- ព្រោះ...ឈ្មូកខ្លាច... ខ្លាចឈ្មូកធ្វើឱ្យបងខឹងរិតតែខ្លាំង ព្រោះខ្លួនជាមនុស្សដែល មានរាសីនាំស៊យចូលផ្ទះ....

ឮដូច្នោះ សុជាតិនឹកអាណិតនារីយើងព្រួចក្នុងចិត្តតែម្តង ។ នាយ ក៏យកម្រាម ដៃទៅទប់បបូរមាត់មាណវីមិនអោយនិយាយដូច្នោះតទៅទៀត :

- គឺខុសមកពីខ្ញុំទេដែលនិយាយស្តីមិនពិរោះ...! ឈប់ភ័យចិត្តទៅណាំ! ម្យ៉ាងទៀត ទីនេះក៏ជាផ្ទះរបស់ឈ្មូកដែរ! កុំចាកចោលពួកយើងទៅណាទៀតអី... បានទេ?

ឮដូច្នោះ តរុណីយើងងើបមុខសំលឹងទៅសុជាតិវិញ ហើយតបខ្សិបៗវិញថា :

- ឈ្មូកក៏គ្មានផ្ទះឯណាដែរ... ក្រៅពីទីនេះ... ឈ្មូកគ្មានកន្លែងណានឹងទៅទេ...!

សុជាតិឮដូច្នោះ ហាក់ដូចជារន្ធត់ចិត្តនឹកអាណិតឈ្មូកតែម្តង :

- អញ្ចឹង...          ឈ្មូកត្រលប់ទៅផ្ទះយើងវិញណាំ!  ម៉ែនិងសុខាកំពុងមើលផ្លូវ !

សុជាតិងើបឈរឡើង  ហុចដៃអោយមាណវីតោងឈរ ។     ឈ្មូកក៏ងើយមុខ សំលឹងទៅសុជាតិហាក់ដូចជាចង់ស្ទង់ទឹកចិត្តថាតើនាយពិតជាមកទទួលនាងត្រលប់ ទៅផ្ទះវិញពិតមែនឬយ៉ាងណា  ។ លុះឃើញស្នាមញញឹមដ៏បំព្រងនៅលើផ្ទៃមុខ របស់នាយ ធិតាហាក់មានអារម្មណ៍កក់ក្តៅក្នុងចិត្តសាជាថ្មី ។ នាងក៏ស្រវាតោងដៃ សុជាតិងើបឈរឡើងដោយចិត្តត្រេកអរ ។ គ្រានេះ សុជាតិយើងក៏មានអារម្មណ៍ថា ពិភពលោកប្រែជាមានរស្មីស្រស់ភ្លឺថ្លាត្រចង់ឡើងវិញ លែងងងឹតសោកសៅតទៅ ទៀតហើយ ។ តាមផ្លូវត្រលប់មកផ្ទះវិញ នាយយើងកាន់ដៃឆវីរហូតឥតរបេះ ហាក់បីដូចជាខ្លាចនាងរត់បាត់ស្រមោលទៅវិញទៀតអីចឹង ។ យូរៗម្តង មាណពលួច សំលឹងទៅមុខឈ្មូកហើយលួចញញឹមលាក់គំនួចតែម្នាក់ឯង ។ ភ្លាមនោះ ស្រាប់តែ មាណពក្រលេកឃើញកែងដៃមាណវីមានឈាមហូរទាំងសងខាង ។ បុរសយើង ភ្ញាក់ព្រើត សួរថា :

- ឈ្មូក! ដៃរបស់ឈ្មូកកើតអីហ្នឹង?

- ចាំស អត់មានអីទេ! (ឈ្មូកទាញដៃយកលាក់នៅក្រោយខ្នង)

សុជាតិមិនអស់ចិត្តក៏ចាប់ដៃរបស់នាងមកមើលម្តងទៀត      ស្រាប់តែឃើញ ស្នាមដាច់រលាត់ យ៉ាងជ្រៅនៅកែងដៃទាំងសងខាង :

- ស្លាប់ហើយ! បុរសពីរនាក់នោះវាធ្វើបាបឈ្មូកដល់ម្លឹងផង?

CHANBOKEO.COM

- ឈូកមិនអីទេ! បងកុំគិតទៅរកសងសឹកគេវិញអីណា៎! ឈូកមិនចង់អោយបង
មានជំលោះត្រូវឈឺខ្លួនដោយសាររឿងអត់ប្រយោជន៍ទាំងអស់នោះឡើយ អោយ តែបងសុខសប្បាយនោះ ឈូកក៏បាត់ឈឺ លែងអីទៀតហើយ ។

សុជាតិញដូច្នេះកាន់តែនឹកអាណិតឈូកហើយនឹកក្នុងចិត្តថា :

- គិតទៅ នាងគិតពីសុខទុក្ខរបស់យើងណាស់ ប៉ុន្តែយើងបែរជាគិតមិនល្អពីនាងទៅវិញ ។ ហ៊ឺ! គួរអោយស្តាយណាស់!

មកដល់ផ្ទះវិញ សុជាតិក៏យកសំឡីនិងថ្នាំមកលាងរបួសអោយឈូកយ៉ាងស្អាត ហើយ ធ្វើជាសួរឈូកថា :

- សុខាប្រាប់ថា ថ្ងៃនេះឈូកបានទិញចំណីធ្វើខ្ញុំ មែនទេហ៎?

- ចាំស!

ឈូកក៏ងើបទៅផ្ទះបាយភ្លាម យកនំសែសយដែលសុខាបានយកទៅទុកនោះ មកលាតដាក់ចាន ហើយយកមកហុចអោយសុជាតិ :

- ថ្ងៃនេះ ឈូកមិនបានប្រយត្ន័ ធ្វើអោយជ្រុះនំប្រលាក់ដី តែក៏ប្រលាក់ត្រឹមតែស្លឹក
ខ្ចប់ប៉ុណ្ណោះ សាច់ក្នុងនៅល្អដដែល សង្ឃឹមថាបងមិនប្រកាន់នឹងពិសារទេ ។

សុជាតិញញឹមលូកដៃទទួលចាននំ តែបន្លំចាប់ដៃនាងជាប់ :

- ម៉ោះ! ញ៉ាំជាមួយគ្នាទេហ៎ ឈូក?

ឈូកភ្ញាក់ព្រើតដកដៃចេញមកវិញយ៉ាងរហ័សទំនងខ្មាស ហើយបែរមុខចេញ
មិនហ៊ានមើលមុខសុជាតិវិញទេ ថែមទាំងមិនហ៊ានឆ្លើយតបទៅវិញផង ។ មីងសោមឮកូនប្រុសនិយាយដូច្នោះ ក៏កេះកូន :

- សុខា! ជូនម៉ែទៅបង្គន់បន្តិចកូន!

ការពិតគាត់ឃើញកូនចៅត្រូវរ៉ូវគ្នាវិញ ក៏ចង់អោយគេនិយាយគ្នាតែពីរនាក់
ទើបធ្វើពើជាចង់ទៅបន្ទប់ទឹក ។ កាលបើសុខានាំមីងសោមចេញទៅបាត់ ឈូកនិង សុជាតិលួចដៀងភ្នែកសំលឹងគ្នាទៅវិញទៅមក
ហើយញញឹមធ្វើអេះអុញៗ សំដែង កិរិយាអៀនខ្មាស ក្តៅមុខ ក្តៅមាត់ ភាយៗ តែរៀងៗខ្លួន ។

ច្រើនថ្ងៃកន្លងផុតទៅ....

ឈូកចុះទៅជួយសុខានៅចង្ក្រានបាយ បង្កាត់ភ្លើងដាំបាយនិងរៀនធ្វើម្ហូប អាហារតាមបែបអ្នកស្រុកស្រែចំការ ។
អ្នកទាំងពីរដាំស្លបណ្តើរជជែកលេងបណ្តើរ ស្រាប់តែមានបុរសពីររូបជិះម៉ូតូឌុបគ្នាមកដល់មុខផ្ទះ ហើយកូកហៅឡើងថា :

- ជាតិអើយ.... អើយនាយជាតិ... នៅផ្ទះទេហ៎ ?

មីងសោមអង្គុយរៀបស្លឹកថ្នាំជក់ក្រោមដើមអំពិលទឹកនៅមុខផ្ទះ ។ កាលបើឮ សំលេងកូកហើយ មីងចំណាំសំលេងបាន
ក៏ឆ្លើយយ៉ាងរួសរាន់វិញថា :

- ជាតិមិនទាន់មកពីរត់ឡានវិញទេ ។ ក្មួយជ្រក់មានការអីដែរ?

- អូហ៎ អត់ទេហ៎មីង.... ខ្ញុំនឹកនាយជាតិពេកបានជានាំពេទ្យអេងមកលេងម្តង

- អញ្ជើង! ចូលអង្គុយលេងសិន! អឺសុខា! យកទឹកត្រជាក់មកជូនបងពិសា!

សុខាក៏ស្ទុះយកផ្តិលសមួយដួសទឹកមកធ្វើបុរសទាំងពីរ រួចហើយក៏ចេញទៅ
ចង្ក្រានដាំបាយវិញ ។ ពេលនោះ នាយជ្រក់ដាក់ភ្នែកមើលទៅផ្ទះបាយស្រាប់តែ ប្រទះឃើញឈូកពីក្រោយខ្នង
ហើយឃើញកេសាដ៏ខ្មៅអន្លាយរបស់នាងយ៉ាង រលោងរលើប ក៏សួរទៅមីងសោមថា :

- ខ្ញុំឮគេនិយាយរន្ទឺៗថា នាយជាតិគេមានប្រពន្ធហើយ មែនឬមិនមែន មីង?

CHANBOKEO.COM

- អូហ៍ អត់ទេក្មួយ ! ក្រដូចមីង មានខាន់ស្លាអីសំរាប់ដណ្ដឹងកូនក្រមុំគេទៅ? បើ រកម៉ាពេល រស់ម៉ាពេលយ៉ាងនេះ?

តែនាយជ្រក់មិនអស់ចិត្តទេ ក៏កេះពួកម៉ាកអោយសំលឹងមើលទៅមាណវី យើងដែលនៅក្នុងផ្ទះបាយ ។ ពេលនោះពេទ្យអេងជាមិត្តឃើញដែរ តែលួចកេះ អោយនាយជ្រក់នៅរៀបឫកធម្មតា១ កុំអោយខូះសុជីវធមិ ។ ប៉ុន្តែ... ទោះបីជា មីងសោមងងិតភ្នែកក៏ដោយ ក៏មីងហាក់ដូចជាស្ដាប់យល់នូវអ្វីដែលនាយជ្រក់ កំពុងសួរ ។ មីងក៏បន្លឺវាចាបន្តទៅទៀតថា :

- នៅផ្ទះនេះ មានតែកូនចៅរបស់មីងទេ ក្មួយឆ្ងល់អីហ្អែស?

- អូហ៍ បាទ! អត់ទេហ៍ ! គ្រាន់តែសួរ១ទៅ ព្រោះឃើញបាត់នាយជាតិយូរ ស្មានថា គេមានប្រពន្ធមានកូនហើយ ។

នាយជ្រក់មិនអស់ចិត្តទេ ក៏ធ្វើជាដើរទៅមើលសុខានៅក្នុងផ្ទះបាយ :

- ដាំស្លម្ហូបអីហ្នឹងនាងក្រមុំតូច?

មាត់និយាយតែភ្នែកនាយជ្រក់សំលឹងទៅតែឈ្មូកមិនព្រិចសោះ ។ មាណវីដឹង ខ្លួនក៏អង្គុយបែរខ្នងអោយដោយមិនងាកគួរសមអ្វីឡើយ ។ រីឯពេទ្យអេងហាក់ដូច ជាទឹកខ្មាស់ជំនួសមិត្តណាស់ ក៏ស្ទុះទៅអូសដៃនាយជ្រក់ចេញមកវិញ :

- នែ៎សំលាញ់! កន្លែងហ្នឹងជាទីបរិវេណរបស់ស្រី១ ថយអោយឆ្ងាយបន្តិចទៅ ។

ពិតមែនហើយ! មើលទៅ នាយជ្រក់ដូចជាមនុស្សចូលចិត្តចង់ដឹងចង់ឮរឿង រ៉ាវគេណាស់ ។ តើហេតុអ្វីទៅហ្ន៎ ? លុះមិនបានឃើញមុខស្រីក្រមុំក្នុងផ្ទះបាយ គេ ហាក់ដូចជានៅមិនសុខក្នុងខ្លួនសោះ ។ មើលហ្ន៎! គេអើតអើមដកកចំហមាត់ កវែងស្លឹតជិតដូចកុកទៅហើយព្រោះតែចង់ដឹងថាស្រីនោះជានរណា ។ មួយស្របក់ ក្រោយមក ពេទ្យអេងក៏អូសនាយជ្រក់ត្រលប់ទៅវិញ ព្រោះទ្រាំនឹងកិរិយារបស់
មិត្តខ្លួនមិនបានតទៅទៀត ។

រសៀលបន្តិច សុជាតិក៏ធាក់កង់មកដល់ផ្ទះវិញដូចធម្មតា ដោយមានយួរ កញ្ចប់អីវ៉ាន់រណិងរណោងមកជាមួយផង ។ បន្ទាប់ពីផ្អែកកង់នឹងសសរផ្ទះរួចហើយ នាយយើងក៏ស្ទុះទៅរែកទឹកស្រោចចំការថ្នាំជក់ភ្លាម រួចក៏រែកទឹកដាក់ពាងក្រោយ
ផ្ទះយ៉ាងពេញទើបលាងជំរះខ្លួនចូលបរិភោគបាយ ។ ពេលនោះថ្ងៃលិចទៅហើយ ។
សុខាក៏អុជចង្កៀងខ្លាញ់ត្រីបំភ្លឺឡើង ហើយនិយាយប្រាប់បងប្រុសថា :

- បងជាតិ ! ថ្ងៃនេះ បងជ្រក់និងបងអេងគាត់មកលេងបង ។

- អឺ ! ហើយចុះគេមករកបងមានការអីដែរ?

- អត់ឮថាម៉េចផង គ្រាន់តែនិយាយលេងជាមួយម៉ែពីរបីម៉ាត់ ហើយលាទៅវិញ ។

សុជាតិឮហើយញញឹម រួចក៏ដួសសម្លហុតគ្រូក ស្រាប់តែធ្វើមុខទ្រង់ឆ្ងល់ :

- សុខា ស្លម្ហូបអីប្លែកម្ល៉េះថ្ងៃនេះ?

- មិនមែនម្ហូបសុខាទេ គឺបងឈ្មូកជាអ្នកដណ្ដាំ ( សុខាតបវិញ)

ឈ្មូកឃើញសុជាតិជ្រួញចិញ្ចើមក៏នឹកភ័យ :

- អោយខ្ញុំសូមទោសផង ដែលដាំអាហារមិនត្រូវចិត្តបងប្រុស..

សុជាតិក៏ឆ្លើយយ៉ាងលឿនទៅវិញ :

- អូហ៍ មិនមែនទេបាទ! តាមពិត... សម្លនេះប្លែកមាត់ហើយឆ្ងាញ់ទៀតផង!

CHANBOKEO.COM

គ្រាន់តែឮដូច្នោះ សុខានិងឈ្យូកញញឹមដាក់យ៉ាងពព្រាយ ។ មីងសោមឮ ដូច្នោះ ក៏យកស្លាបព្រាវាវកចានសម្លដែរ :

- មើល៏ អោយម៉ែសូមភ្លក្សផង កូន !

ឈ្យូកក៏ស្រវាយកចានហុចជូនមីងសោមភ្លាម ។ មីងហុតហើយលាន់មាត់ :

- យី ប្លែកមាត់មែនណាំ... មិនដឹងសោះថាអ្នកទីក្រុងដូចឈ្យូក ចេះដាំស្លសម្លឆ្ងាញ់ អញ្ចឹងសោះ ។ ម៉ែធ្លាប់តែឮថាអ្នកទីក្រុងជាអ្នកមាន គេមិនដែលដាំស្លខ្លួនគេទេ

គឺគេមានមេផ្ទះធ្វើកិច្ចការទាំងនោះជំនួសសព្វទាំងអស់ ។

ឈ្យូកញញឹមមិនហ៊ានតបអ្វីទេ  គ្រាន់តែនៅស្ងៀមស្ងាត់ ហើយគិតតែក្នុងចិត្ត តែម្នាក់ឯងថា :

- មីងអើយ! អ្នកទីក្រុងដូចខ្ញុំនេះមានជីវិតរស់នៅ មិនខុសពីអ្នកបំរើក្នុងផ្ទះរបស់គេប៉ុន្មានទេ..

សុជាតិចេះតែលួចសំលឹងមុខឈ្យូកមិនដាក់ភ្នែកសោះមិនថាពេលណា។ សូម្បីតែថ្ងៃនេះ ក៏នាយលួចញញឹមសំលឹងមុខនាងជាញយៗដងដែរ ប៉ុន្តែគ្មាននរណាគេ ចាប់ភ្លឹកនូវកិរិយារបស់នាយទេក្រៅពីឈ្យូកតែម្នាក់។ ឃើញដូច្នោះមាណវីយើងវិញ ក៏ចេះតែឈ្ងោកមុខគេចក្រសែភ្នែករបស់នាយជានិច្ច ត្បិតឱ្យតែឃើញនាយសំលឹង មកចំមុខនាងដងណា ឈ្យូកភ័យញ័រដៃញ័រជើងបែកញើសស្រោក់ដងហ្នឹង។

ក្រោយពីបាយហើយ សុជាតិក៏ស្ទុះយកបង្វិចកញ្ចប់ដែលនាយស្ពាយពីថ្ងៃមក ស្រាយយកឥវ៉ាន់ហុចជូនម្តាយមុនគេ :

- ម៉ែ ! នេះ! កូនបាន ទិញអាវសជូនម៉ែមួយស្អាតណាស់ ។

មីងសោមសំដែងអាការៈត្រេកអរ :

- អឺៗ អរគុណណាស់ជាតិ ! មើល អោយម៉ែសូមលបន្តិចមើល !

សុជាតិក៏ហុចអាវជូនមីងសោម ។

- បងជាតិ ! ចុះឯណារបស់សុខា ប្អូនសំលាញ់របស់បង? (សុខាឈ្លេចសួរព្រោះ ឃើញនៅមានអីវ៉ាន់ក្នុងកញ្ចប់ទៀត)

- នេះ! សំពត់ចងហើយហ្នឹងអាវពណ៌ស៊ីជំពូមួយកំផ្លែសំរាប់ប្អូនស្រីសំលាញ់ចិត្ត!

គ្រាន់តែឮដូច្នោះ សុខាមុខរីកប៉ុនចង្អេរ :

- អរគុណណាស់បងជាតិ ។

ឈ្យូកអង្គុយក្បែរនោះ ធ្វើមុខញឹមៗ  សំដែងការរីករាយ   ដោយឃើញក្រុមគ្រួសាររបស់សុជាតិមានភាពសុខដុមរមនា ។ ភ្លាមនោះ សុជាតិសំលឹងមុខនាងឡើងហើយពោលថា :

- ចំណែកឈ្យូកវិញ... គឺ... ឱ្យខ្ញុំសុំដូរ....យកខោអាវចាស់របស់ខ្ញុំវិញបានទេហ៏ ?

ឈ្យូកឮដូច្នោះ អៀនផង សប្បាយចិត្តផង ថែមទាំងនឹកក្នុងចិត្តថា :

- ពុទ្ធោ! គេគិតឃើញដល់ខ្ញុំដែរតើហ៏?   ប្រហែលជាខ្ញុំយកអាវគេពាក់អស់ហើយទេដឹង  បានជាគេទៅទិញថ្មីយកមកជាថ្នូរដូរអាវចាស់ទៅវិញ ? ឬក៏មកពីគេគិតថា

CHANBOKEO.COM

ខ្ញុំស្លៀកពាក់ខោអាវបុរសនោះវាអាក្រក់ភ្នែកមើលពេក បានជាទិញខោអាវថ្មីមក អោយ? ពុទ្ធោអើយ !
គ្រួសាររបស់គេក្រីក្រខ្វះមុខក្រោយម្លឹង១ បើអាល័យតែ យកប្រាក់ទៅទិញរបស់អោយយើង នោះតើគេនឹងខើចវិកាក្នុងគ្រួសាររបស់គេ
យ៉ាងណា? គួរគោរពសន្តានចិត្តរបស់គេណាស់ដែលនឹកគិតដល់សុខទុក្ខរបស់យើង សូម្បីតែគេមិនដែលស្គាល់យើងពីមុនមកផង....

មាណវីលូកដៃទទួលយកសំលៀកពីសុជាតិទាំងខ្លាចចិត្ត ។

- កុំខ្លាចចិត្តអីណា៎ ឈូក! ឆាប់ទៅលសាកមើលទៅ! (សុជាតិនិយាយ)

ឈូកងើបចូលទៅពួនក្រោយវាំងននកញ្ចាស់ក្នុងផ្ទះ ផ្លាស់សំលៀកភ្លាមឥត ប្រកែក ណាមួយកំពុងតែចង់បានសំលៀកស្រីស្លៀកពាក់ផង ។
ចំណែកមីងសោម និងសុខាក៏កំពុងតែលសំលៀកចុះឡើងយ៉ាងសប្បាយចិត្តដូចគ្នាដែរ ។ បន្តិចមក ឈូកក៏ដើរចេញមកវិញក្នុងសំលៀកថ្មី ។
សុខាក្រលេកឃើញហើយក៏លាន់មាត់ :

- អូហ៎ូ! មើលហ្ន៎! បងឈូកស្លៀកសំលៀកមនុស្សស្រីអញ្ចឹងទៅ ស្រស់ស្អាត សោភាអស្ចារ្យតែម្តង !

សុជាតិបែរមើលឈូកយ៉ាងរហ័ស ស្រាប់តែភ្ញាក់ស្រលាំងកាំង សំលឹងមុខធិតា យ៉ាងភ្លឹកស្មារតីតែម្តង ។ មែនហើយ!
ឈូកពិតជាស្រស់ស្អាតដូចសុខាសរសើរ មិនខុស មិនមែនស្រមេកស្រម៉កដូចសព្វដងនោះទេ! ទោះបីជាសំលៀកដែល
នាងកំពុងស្លៀកនោះមានភាពសាមញ្ញធម្មតា១ក៏ដោយ ក៏សោភ័ណរបស់នាងលេច
ធ្លោរអណ្តែតមកយ៉ាងត្រកាលគួរអោយចាប់ចិត្តចេនាក្រៃលែង ។ កាលបើឃើញ សុជាតិសំលឹងមុខនាងមិនដាក់ភ្នែក
ឈូកនឹកអៀនរឹងខ្លួនយ៉ាងណាមិនដឹងទេ ស្រាប់ តែញាប់ញ័រក្នុងចិត្តរន្ធត់រហូតដល់ដើរទាក់ជើងដួលផ្ងោលទៅលើក្តារផ្ទះព្រូស!

- ឈូក! យ៉ាងម៉េចហ្នឹង?

សុជាតិឧទានឡើង ហើយក៏ស្ទុះស្ទារទៅជួយត្រកងលើកខ្លួនឈូកអោយងើប
អង្គុយ ។ សុខាក៏ស្ទុះមកដល់ដែរ ជួយលើកនាងនៅម្ខាងទៀត ។ រំពេចនោះ ស្រាប់តែមាន សំដីមនុស្សស្រីឧទានឡើងពីកាំជណ្តើរផ្ទះមកថា :

- បងជាតិ!.... ហេតុអ្វីក៏បងធ្វើយ៉ាងនេះចំពោះនីម?

សុជាតិកំពុងតែត្រកងលើកឈូកអោយងើបមកវិញ កាលបើឮសំដីនោះភ្លាម ក៏ងើយមុខឡើងបែររកម្ចាស់សំលេង ហើយក៏លាន់មាត់ដែរ :

- នីម ! មករកបងទាំងយប់ស្ងាត់... អូនមានការអ្វីសំខាន់ឬ ?

មែនហើយ ! នោះគឺជានីម សង្សាររបស់សុជាតិ ដែលតែងទៅមករកគ្នាជា រឿយ១នោះតើហ៎ ។ ការពិតនីមមិនដែលបានជួបឈូកទេ
ហើយសុជាតិវិញក៏មិន ដែលហើបមាត់អ្វីនិយាយអំពីឈូកប្រាប់នីមដែរ ត្បិតនាយយើងមិនចង់អោយឮ
ខ្វះខ្វាយថានាយលាក់មនុស្សស្រីចំលែកក្នុងផ្ទះ និងដើម្បីការពារសុវត្ថិភាពអោយ ឈូកផង ។ នីមយកដៃជូតទឹកភ្នែក ហើយឆ្លើយវិញថា :

- បើនីមមិនមកពេលនេះទេ ប្រហែលជានីមមិនដឹងការពិតរហូតតទៅ! បងជាតិ!! ហេតុអ្វីបងលួចមានប្រពន្ធដោយមិនស្តីប្រាប់នីមអ្វីមួយម៉ាត់?
តើនីមខុសអីបានជា
បងធ្វើយ៉ាងនេះចំពោះអូន...?

ថាហើយនាងក៏ខ្ទប់មុខរត់ចេញទៅ រកតែសុជាតិនិយាយអ្វីក៏មិនទាន់ ។ លុះ នាយលើកឈូកអោយអង្គុយស្រួលបួលហើយ
ក៏ស្ទុះរត់តាមពីក្រោយទៅស្រវ៉ា ចាប់នាងជាប់ហើយពោលថា :

- នីម! យើងនិយាយគ្នាសិនបានទេហ៎?

នីមស្រវ៉ាខ្ទេះដៃមាណពចេញ ហើយបែរតបទៅសុជាតិខ្លាំង១ថា :

- បងជ្រក់បានប្រាប់ខ្ញុំថា បងមានប្រពន្ធរស់នៅជាមួយគ្នារាល់ថ្ងៃ តែខ្ញុំមិនជឿទើប

CHANBOKEO.COM

មកតាមមើលឱ្យឃើញផ្ទាល់ភ្នែក អីលូវឃើញពិតដូចពាក្យបងជ្រក់ថាមែន... បង
ជាតិ! បងសាហាវណាស់ ហ៊ានសំលាប់ចិត្តនីមទាំងរស់! នីមស្អប់បងបំផុតនៅក្នុង
លោកនេះ... (ថាចប់ នីមក៏ស្ទុះរត់ចេញទៅ)
- នីម! តើអូនអាចស្តាប់ការពន្យល់របស់បងខ្លះទេហ៎? អោយបងមានឱកាស និយាយផងណាអូន... (សុជាតិរត់តាមឃាត់នាង)
- អត់ទេហ៎ មិនស្តាប់ទេ... នីមលែងជឿបងទៀតហើយ !

នីមចេះតែរត់លឿនទៅៗ ត្រលប់ទៅផ្ទះនាងវិញ ឯសុជាតិក៏ចេះតែដេញតាម
ពីក្រោយកិតៗ ស្រាប់តែនាយជ្រក់ចេញមុខមកឃាត់ផ្លូវ :
- នែ៎ នាយជាតិ! បើឯងមានប្រពន្ធហើយ នៅរញ៉ីរញ៉ៃស្អីនឹងអូននីមទៀត?
- ជ្រក់! ឯងកុំនិយាយផ្តាស! យើងគ្មានប្រពន្ធដូចឯងស្មាននោះទេ។
- កុំមកភូតភរឯងអញ្ចឹងអ៊ី... បើស្រីម្នាក់ដែលនៅក្នុងផ្ទះឯងនោះមិនមែនប្រពន្ធ តើជាស្អីទៅវិញ? សង្សារលួចលាក់របស់ឯងមែនទេ?

សុជាតិខឹងណាស់កាលបើនាយជ្រក់ប្រមាថទឹកចិត្តរបស់នាយ មិនតែប៉ុណ្ណោះ ថែមទាំងចំអកអោយឈូក ដែលមិនដឹងអ្វីសោះនោះទៀត :
- ជ្រក់ ! មិត្តសំលាញ់គេមិនបំបែកបំបាក់ស្នេហារបស់មិត្តទេ ។ ការដែលឯងញុះ
ញង់អោយនីមខឹងនិងយើង បានន័យថា ឯងកំពុងសំលាប់មិត្តភាពរបស់យើងហើយ រួចក៏សំលាប់ចិត្តស្នេហារបស់យើងចំពោះនីមដែរ។

ជ្រក់អោបដៃ ឈរខែងរែង :
- តែចំពោះមិត្តដែលធ្វើបាបចិត្តមនុស្សស្រី ដោយការក្បត់ចិត្ត មានពីរមានបីដូចជា
ឯងនេះ ក៏មិនសមធ្វើជាមិត្តរបស់ខ្ញុំដូចគ្នា! ខ្ញុំមិននឹកស្មានសោះថាឯងជាមនុស្សដើរ
ខ្សែកេងលើមនុស្សស្រីល្អៗដូចជានីមអញ្ចឹងសោះ។ ឯងធ្វើយ៉ាងនេះបណ្តាលអោយ
ខូចកេរ្តិ៍ឈ្មោះកំលោះភូមិត្រាងអស់រលីងគ្មានសល់ទេ ឯងដឹងទេហ៎ ?
- ឯងយល់ខុសហើយ ! គ្នាមិនដែលក្បត់ចិត្តអូននីមទេ !

សុជាតិពោលផង ឈានដើរទៅមុខផង តែជ្រក់លើកដៃរាំង :
- នែ៎ ថយក្រោយវិញទៅ ! ផ្លូវទៅផ្ទះរបស់ឯងនៅខាងក្រោយឯណោះ! កុំរត់ទៅ
មុខតាមនីមធ្វើអីទៀត... ឮហើយនៅ?

សុជាតិស្ទុះចង់តែទៅ ឯនាយជ្រក់ក៏ចេះតែខារខាំង ហើយនិយាយដៀមដាម ដោយពាក្យសំដីអសុរសជាច្រើន
ធ្វើអោយសុជាតិខឹងណាស់ក៏យារដៃដាល់នាយ ជ្រក់មួយដៃយ៉ាងធ្ងន់។ ទ្រាំមិនបាន ជ្រក់ក៏តដៃវិញមួយទំហឹងចំមុខសុជាតិផាំង។
សុជាតិក៏ដួលប្រូសទៅដីភ្លាម ។ រំពេចនោះមានសុខានិងឈូករត់មកដល់ហើយក៏
ប្រវាឃាត់បំបែកអ្នកទាំងពីរចេញពីគ្នា ។ សុខាក៏ស្រែកឡើងថា :
- បងទាំងពីរឈប់វាយគ្នាទៅ! បងជ្រក់! អោយខ្ញុំសូមសំពះអង្វរបងចុះ! បងកុំ វាយបងប្រុសខ្ញុំអី! បើគាត់យ៉ាងម៉េចៗទៅ
តើគ្រួសាររបស់ខ្ញុំមានអ្វីជាទីពឹងទៅ?

ឃើញមុខសុខាក្មេងស្រីពិការគួរអោយអាណិត ជ្រក់ក៏ក្តាប់ដៃថយទុកវិញ ហើយចង្អុលមុខសុជាតិ ហើយគំហកថា :
- ថ្ងៃក្រោយឈប់ទៅរវីរវល់ជាមួយនីម ប្អូនស្រីរបស់យើងទៀត ឮហើយនៅ ?

ថាហើយនាយក៏ដើរចេញទៅ។ ឈូកក៏ស្ទុះមកជិតសុជាតិ ឃើញនាយមាន

CHANBOKEO.COM

ឈាមហូររីមៗពីមាត់ ក៏យកដៃទៅជូតអោយ :

- បងជាតិ !

សុជាតិកំពុងតែខឹងជាមួយនាយជ្រក់ជាខ្លាំង ។ លុះឈូកនិងសុខា មកប្រទិស  ប្រទើសពីមុខពីក្រោយទៀត ក៏រឹតតែខកចិត្ត

ម៉្លោះហើយនាយយើងក៏ស្រវាទាញដៃ

របស់ឈូករលាស់ចេញយ៉ាងរហ័សធ្វើអោយនាងដួលប្រូសទៅម្ខាង   តែសុជាតិមិន

បានចាប់ភ្លឹកទេ ត្បិតអាល័យតែខឹងនឹងនាយជ្រក់ ។ នាយគំហកអោយឈូកថា :

- ថយចេញអោយបាត់ពីមុខខ្ញុំទៅបានទេ? ដឹងទេហ៎ថា  គឺព្រោះតែនាងម្នាក់ហ្នឹង

ហើយទើបជីវិតរបស់ខ្ញុំឥលូវវាក្លាយជាយ៉ាងដូច្នេះ?

សុខាឃើញដូច្នោះក៏ស្ទុះមកឃាត់ :

- បងជាតិ! កុំម៉ូម៉ៅអីបង ! មើលនែ៎ក!  បងធ្វើអោយបងឈូកដួលចំឈើខ្លួន ហើយណា៎ ! ម៉ោះ! ទៅផ្ទះយើងវិញណា៎បង!

តែសុជាតិមិនស្តាប់ទេ ។ នាយយកដៃគៀសសុខាចេញហើយក៏ស្ទុះរត់រឹងទៅ តាមរកនិមដល់មុខផ្ទះរបស់នាង ។ នៅទីនោះ

មាណពកម្លោះយើងប្រទះឃើញ ម្តាយរបស់និមឈរជាមួយនាយជ្រក់រង់ចាំនរ:ជាស្រេច ។ គ្រាន់តែឃើញមុខនាយ ភ្លាម

ម្តាយរបស់និមក៏មានប្រសាសន៍ថា :

- និមកូនស្រីខ្ញុំមិនត្រូវការចង់ជួបនិយាយជាមួយនរណាទេ ។ ឥលូវនេះ ក៏យប់ទៅ ហើយដែរ ។ បើមានការអ្វី ក្មួយចាំនិយាយពេលថ្ងៃស្អែកទៅ!

ពោលចប់គាត់ក៏នាំកូនប្រុសដើរឡើងទៅលើផ្ទះបាត់ ទុកអោយសុជាតិនៅ ឈរធ្មឹងតែម្នាក់ឯង មិនខុសពីរូបចំលាក់គតវិញ្ញាណឡើយ....

រាត្រីនោះ ឈូកគេងមិនលក់ឡើយ ។ នាងបន្ទោសខ្លួនឯងណាស់ ដែលក្លាយ ខ្លួនជាបុព្វហេតុធ្វើអោយសង្សារមួយគូយល់ច្រលំគ្នា ។

នាងក៏គេងនឹកដល់អតិត កាលចាស់ៗដ៏សែនអប្រិយមិនគួរនឹងរំលឹក ។ ពុទ្ធោអើយ! នាងបាន ទទួលការរីក រាយក្នុងចិត្តមិនបានប៉ុន្មានថ្ងៃផង

ស្រាប់តែមកប្រទះទុក្ខសោកគ្រាំចិត្តសាជាថ្មី ទៀតហើយ ។ តើហេតុអ្វីទៅហ្ន៎ ដែលជីវិតរបស់នាងប្រទះតែគ្រោះអភព្វ័ មិនចេះ អស់

មិនចេះហើយយ៉ាងនេះ? គិតយូរៗទៅ ធិតាយើងចេះតែឃើញពិភពលោក កាន់តែចង្អៀតទៅ ងងិតទៅ

គ្មានច្រកណាមួយដែលមានពន្លឺសំរាប់ជីវិតរបស់នាង

ឡើយ... ធ្វើអោយនាងលែងនឹកនាចង់រស់នៅជាមនុស្សតទៅទៀត...

ឯសុជាតិក៏ផ្តេចមិនលក់ដូចគ្នា ។ គេគេងគងថ្ងាស ដោយក្តីតប់ប្រមល់ធុញថប់ ក្នុងចិត្តបំផុត ។ ប្រហែលពាក់កណ្តាលអាធ្រាត

នាយយើងក៏ស្ទុះងើបចុះទៅដី បំរុង ដើរទៅអង្គុយលើរានឫស្សីក្រៅផ្ទះមើលមេឃមើលផ្កាយ រំសាយចិត្តខ្វល់តែម្នាក់ ឯង...

ស្រាប់តែនាយចាប់ភ្លឹកឃើញមានស្រមោលមនុស្សស្រីមួយរូបអង្គុយនៅ រានឫស្សីនោះជាស្រេចហើយថែមទាំងកំពុងអង្គុយខ្សឹកខ្សួលទៀតផង ។

មាណព យើងនឹកឆ្ងល់ចំលែកចិត្តក៏ហៅខ្សិបៗតិចៗ :

- និម ! តើជាអូនមែនទេហ៎?

ស្រាប់តែស្រមោលនោះក៏យកដៃជូតទឹកភ្នែករួចក៏ឈរទ្រើងស្ងៀមស្ងាត់ ។

- និម! （សុជាតិហៅខ្សិបៗម្តងទៀតទាំងភ័យអរៗ អរព្រោះនិមត្រលប់មករក នាយម្តងទៀត តែភ័យត្បិតមិនសមប្រពៃណី

ដែលមកជួបនាងកណ្តាលយប់ស្ងាត់）

ភ្លាមនោះ ធិតាក៏ងាកមកបុរសយើងហើយបន្លឺវាចាតបថា :

- ចា៎ស... នេះគឺ... ឈូកទេ... !

CHANBOKEO.COM

សុជាតិភ្ញាក់ក្រញាង ៖

- ឈូក? ព្រះអើយ ហេតុអីមកអង្គុយម្នាក់ឯងកណ្ដាលយប់ស្ងាត់យ៉ាងនេះ?

ឈូកនៅស្ងៀមមិនស្ដី ។ សុជាតិនឹកពិភាល់ក្នុងចិត្តក៏រំកិលខ្លួនមកជិតនាង ។ ក្រោមពន្លឺមេឃដ៏ងងិតដែលមានតែផ្កាយព្រោងព្រាតតដួងចន្ទ័ សុជាតិឃើញ ស្រមោលឈូកស្ងុង១ បង់ក្រមាហើយស្លៀកសំលៀកទីក្រុងរបស់នាង ដែលរហែក រយ៉ៃនោះវិញ ។ ម្ដងនេះសុជាតិរឹតតែពិភាល់ក្នុងចិត្តរិតតែខ្លាំង ៖

- ឈូក! បំរុងចេញទៅណាទាំងយប់ហ្នឹង?...

ឈូកនៅតែឈ្ងោកមុខមិនស្ដីដដែល ។ បុរសយើងហាក់ដូចជារន្ធត់ចិត្តយ៉ាង ណាមិនដឹង ក៏លូកដៃស្រវាឈូកហើយអូសទាញនាងអោយត្រលប់មកផ្ទះវិញ ស្រាប់តែ មាណវីរលាស់ដៃបំរះថយចេញ ហើយស្រដីទាំងអួលអាក់ថា ៖

- ឈូកបាននាំទុក្ខអំពល់ដល់គេផងគ្រប់គ្នា មិនថានៅទីណា មិនសមបើនឹងរស់នៅ នាំគ្រោះ នាំទុក្ខសៅហ្មងឱ្យគេឯងតទៅទៀតទេ....

ឮប្រយោគដែលពោរពេញដោយការអស់សង្ឃឹមក្នុងឆាកជីវិតរបស់ឈូកនោះ ភ្លាម សុជាតិទុចដំណើរង៉ក់ បែរក្រោយសំលឹងមកឈូក ៖

- ឈូកខឹងអន់ចិត្តនឹងសុជាតិទៀតហើយមែនទេហ៎? (សុជាតិសួរ)

ឈូកឈ្ងោកមុខជូតទឹកភ្នែក... មួយស្របក់ក៏តបវិញថា ៖

- ឈូកមិនហ៊ានខឹងនឹងបងទេ! ការពិត គឺឈូកតូចចិត្តនឹងជីវិតរបស់ខ្លួនឯងដ៏សែន អពមង្គលនោះវិញតើហ៎... មិនដឹងជាមានជីវិតរស់នៅតទៅទៀតដើម្បីអ្វី.....?

ឈូកនិយាយទាំងខ្សឹកខ្សួលហាក់ដូចជាកំពុងអាណិតខ្លួនក្រៃលែង ។ សុជាតិ ឮហើយភ្ញាក់ព្រើត ស្ទុះចាប់ដៃឈូកយ៉ាងរហ័សថា ៖

- ពុទ្ធោ!! នែះ.... ឈូកកំពុងតែមកលួចធ្វើអត្តឃាតតើហ៎...

ឈូកឈ្ងោកមុខនៅស្ងៀមមិនស្រដី ។ សុជាតិក៏វាចាបន្តថា៖

- ព្រះអើយ! ហេតុអ្វីក៏ឈូកខ្វះសេចក្ដីរឹងប៉ឹងយ៉ាងនេះ? ដឹងទេថា ជីវិតមនុស្ស យើងមានតម្លៃណាស់! ម៉េចក៏ឈូកចង់បំផ្លាញជីវិតខ្លួនឯងដូច្នេះ?

ឈូកនៅតែមិនតបដដែល គិតតែពីខ្សឹកខ្សួលតែម្យ៉ាងប៉ុណ្ណោះ ។ សុជាតិមិន អស់ចិត្តសោះក៏ពោលបន្តទៅនាងទៀតថា៖

- ឈូកដឹងទេ? នាគ្រាមួយនោះខ្ញុំសុខចិត្តលះបង់ការងារផ្ទាល់ខ្លួនមកសង្គ្រោះឈូក អោយផុតគ្រោះថ្នាក់ ត្បិតមិនចង់ឃើញឈូកស្លាប់បង់ជីវិតនៅកណ្ដាលព្រៃគុម្ពោត ដោយអាសារឥតការ ។ មើលចុះ! សូម្បីតែម្ដាយនិងប្អូនស្រីរបស់ខ្ញុំដែលសុទ្ធសឹងតែ ជាជនពិការហើយក្រីក្រអត្តខាត់ទៀត តែគេនៅតែមានចិត្តចង់រស់នៅហើយប្រវៃ ប្រវាប្រឹងជួយខ្លួនឯងទាំងត្រដេវត្រដរ មិនដែលត្អូញត្អែចំពោះឆាកជីវិតអភព្វ័របស់ ខ្លួនគេម្ដងណាឡើយ ។ មិនតែប៉ុណ្ណោះ គេថែមទាំងចែករំលែកនូវសេចក្ដីសុខក្នុង ជីវិតរបស់គេមកអោយឈូកដោយមិនបានគិតរកចំណេញតបស្នងមកវិញ ។ ប៉ុន្តែ កាលបើឈូកបានទទួលជីវិតត្រលប់មកវិញហើយ ម្ដេចបែរជាចង់បំផ្លាញវាចោល ដោយឥតសោកស្ដាយឥចឹង បើឈូកដាច់ចិត្តធ្វើដូច្នេះពិតមែន គឺមិនខុសពីបំផ្លាញ ទឹកចិត្តរបស់យើងទាំងបីនាក់នេះឡើយ ។

ឈូកឮដូច្នោះ ក៏យំខ្សឹកខ្សួលសាជាថ្មី ។ មែនហើយ! ប៉ុន្មាននាទីមុននេះ នាង

CHANBOKEO.COM

គិតបាថ្នាចង់ធ្វើអត្តឃាតដូចសុជាតិថាមែន ព្រោះនាងខ្វះសេចក្តីរឹងប៉ឹងនិងកំលាំង ចិត្ត ។ អ្វី១ក្នុងជីវិតរបស់នាងគឺប្រកបតែភាពអស់សង្ឃឹមនិងអពមង្គល ។ ប៉ុន្តែកាល បើបានស្តាប់វាចារបស់សុជាតិរួចហើយ នាងបែរជាមានអារម្មណ៍ថា គេនៅមាន ចិត្តខ្វល់ខ្វាយចំពោះរូបនាងនៅឡើយ ហើយនឹកស្តាយក្រោយណាស់ ដែលខ្លួនបាន គិតខ្លី ។ បើកុំតែសុជាតិចេញមកទាន់ កុំអី...

ឃើញឈ្មួកឈរស្ងៀមស្ងាត់ សុជាតិក៏បន្ថែមមួយឃ្លាចុងក្រោយថា :

- ឈ្មួកអើយ! ទោះបីជាថ្ងៃនេះ ជីវិតរបស់យើងត្រូវជួបប្រទះនឹងព្យុះភ្លៀងខ្លះ១ ក៏ដោយ តែក៏កុំឡើយបោះបង់ក្តីសង្ឃឹមរបស់យើងនោះចោលអោយសោះ ព្រោះ ត្បិតនៅថ្ងៃស្អែក ព្រះអាទិត្យកំពុងត្រៀមខ្លួនរង់ចាំរះបំភ្លឺផ្លូវជីវិតដល់យើងជានិច្ច ដើម្បីអោយយើងបានបន្តដំណើរតទៅមុខទៀត ទៅស្វែងរកសុភមង្គលនិងជោគជ័យសំរាប់ជីវិតថ្មីរបស់យើង....

សុជាតិនិយាយផង លើកដៃផ្តិតទឹកភ្នែកចេញពីផែនថ្ពាល់របស់ឆវីផង:

- ហើយសុជាតិក៏សូមទោសដែរ ដែលបាននិយាយស្តីគំរោះគំរើយមិនសមរម្យដាក់ ឈ្មួកកាលពីក្បាលព្រលប់ ។ ខ្ញុំនេះមិនល្អទាល់តែសោះ ឆេវឆាវមិនចេះទប់កំហឹង ប៉ុន្តែ... ខ្ញុំសន្យាថា ចាប់ពីថ្ងៃនេះតទៅមុខ សុជាតិលែងជះកំហឹងផ្តេសផ្តាសដូច្នេះ ទៀត ហើយ! ឈ្មួកឈប់យំទៅណា! ណា!

ឮដូច្នោះ ឈ្មួកក៏ជូតទឹកភ្នែកភ្លាមដែរ ទំនងហាក់ដូចជាមានអារម្មណ៍ត្រជាក់ មកវិញ ។ សុជាតិឃើញហើយក៏អូសដៃនាងត្រលប់ឡើងទៅលើផ្ទះ :

-ម៉ោះ! ចូលគេងទៅវិញទៅ យប់ជ្រៅហើយ !

មិនប្រកែកអ្វីទេ ពេលនេះឈ្មួកក៏បណ្តោយអោយសុជាតិកាន់ដៃនាងនាំឡើង ទៅលើផ្ទះ ចូលដំណេកវិញទាំងកិរិយាស្ងប់ស្ងៀម ។ តាមចន្លោះស្បៃមុងកញ្ចាស់ សុជាតិនៅអង្គុយសំលឹងមើលមុខធិតា ដែលសំងំបិទភ្នែកគេងរំងាប់អារម្មណ៍ទុក្ខ សោកយ៉ាងលំបាក រួចហើយនាយក៏ចាប់ច្រៀងរហ៊ឹម១ថ្នម១ហាក់ប្រាថ្នាលួងលោម បំពេរដួងចិត្តរបស់ឈ្មួកអោយមានអារម្មណ៍ស្ងប់ក្សេមក្សាន្ត នាកណ្តាលរាត្រីដែលមានតែពន្លឺផ្កាយជាមង្គល....

ជូតទឹកភ្នែកជូនស្រី

១. មានទុក្ខរឿងអ្វីពិសីទ្ធនល្អង ម្តេចស្រស់ទងវង់នាងលង់ទឹកភ្នែក
ឃើញអូនសោកាវៀមរ៉ាសង្វេគ ខ្លោចចិត្តអនេគអាណិតស្រីថ្លៃ ។

២. មានទុក្ខរឿងអ្វីស្រដីប្រាប់វៀម ពៅកុំនៅស្ងៀមបៀមចិត្តរឹងរៃ
សូមវាចាចេញក្រែងស្បើយហឫទ័យ បងនៅក្បែរស្រីជូតទឹកភ្នែកអោយ ។

បន្ទរ. ចំរៀងមួយបទបងច្រៀងជូនមុំ ប្រាថ្នាលួងលោមឱ្យទួននាងស្បើយ
យប់យន់រាត្រីបងក្បែរអូនហើយ ឱ!កែវត្រាណត្រើយឈប់យំទៅអូន!

៣. គេងទៅណាស្ងួនទួនមាសកន្និដ្ឋា សូមឱ្យចិន្តាអូនឈប់ស្រពោន
កង្វល់ក្នុងចិត្តរលាយសាបសូន្យ ថ្ងៃនេះទៅអូនញញឹមរៀងអើយ....

មីងសោមនិងសុខា បានភ្ញាក់ពីដំណេកលួចផ្ទៀងស្តាប់អ្នកទាំងពីរយូរហើយ ។ តែលុះសុជាតិត្រលប់មកដល់លើផ្ទះវិញ ចាប់ច្រៀងរហឹម១យ៉ាងពិរោះ អ្នកទាំងពីរ ក៏នាំគ្នាគេងស្តាប់ដោយអារម្មណ៍សុខសាន្តរហូតនិទ្រាលង់លក់ក្នុងដំណេកវិញដែរ....

00 00

00

CHANBOKEO.COM

# វគ្គទី៥
# មែកមួយត្រួយពីរ

នៅភ្នំពេញ....

ក្រពុំចិត្តខានបានទៅរៀនច្រើនអាទិត្យហើយ ម្យ៉ាងដោយសារនាងអាល័យ មានគ្រោះថ្នាក់ត្រូវគេងពេទ្យ ។ អីលូវនាងបានជាសះស្បើយវិញហើយដែរតែក៏នៅ មិនព្រមចូលសាលាដដែល ។ កាលដើមឡើយនាងចូលចិត្តការសិក្សាណាស់ ។ ពេល នេះគ្រាន់តែនឹកគិតពីសៀវភៅនិងមុខវិជ្ជាភ្លាម នាងបែរក្លាយជាអផ្សុកធុញថប់ ក្នុងចិត្តបំផុត ។ រីឯលោកប៉ារបស់នាងវិញ ក៏នាងមិនដែលបានឃើញមុខលោកតាំង ពីយូរហើយមិនដឹងថាលោកមានរវល់អីទេ ។ ចំណែកអ្នកស្រីជានីម្ដាយនាងវិញ បាត់ៗឃើញៗតាមតែទំលាប់ចាស់ៗចឹងទៅ ។ បើនិយាយពីដារិយ៉ាវិញ ក្រពុំចិត្ត ហើបមាត់សួរមិនបានមួយម៉ាត់ទេ ដារិយ៉ានឹងឆ្លើយវិញដូចលាជផ្ទុះឯណោះ ។ ទី បំផុត ក្រពុំចិត្តមានមនុស្សម្នាក់គត់ជាមិត្តគឺនាងចឿនអ្នកបំរើដែលម្ដាយនាងរើស មកពីស្រុកស្រែដើម្បីជួយដៃជើងក្នុងផ្ទះ ។ ចឿនជាមនុស្សរួសរាយ គ្រាន់តែមិន ចេះអក្សរ ម្ល៉ោះហើយរកពឹងជាមុខជាមាត់អ្វីមិនបានសោះឡើយ ។ យូរៗម្ដង ចឿនតែងសុំទៅលេងផ្ទះបាត់ពីរបីថ្ងៃ ។ ដូច្នោះតរុណីយើង ត្រូវគេងនៅក្នុងលំនៅ យ៉ាងធំស្កឹមស្កៃតែម្នាក់ឯងកណ្ដោចកណ្ដែងឯកា...

ព្រឹកនេះ មាណវីនៅផ្ទះម្នាក់ឯង... កំពុងតែរៀបចំខ្លួន គិតថាចង់ចេញទៅ ក្រៅរកដើរលេងលំហែអារម្មណ៍ ស្រាប់តែលោកវិសាលមកដល់ :

- ជំរាបសួរអ្នកនាងក្រពុំចិត្ត !
- ចាំស ! ជំរាបសួរ !

មាណវីតបដោយលើកដៃសំពះតបវិញ ថែមទាំងវាចាបន្ថែមថា :

- អោយខ្ញុំសូមទោសផង ដែលថ្ងៃមុន ខ្ញុំចាកចេញទាំងប្រថុចប្រញ៉ុចពេក មិនបាន ជំរាបលាលោកមួយម៉ាត់ ។
- អូហ៎ មិនអីទេ! ការពិតក៏ខុសពីខ្ញុំដែរ ដែលនៅនិយាយទូរសព្ទ័យូរពេក ធ្វើអោយ អ្នកនាងរង់ចាំទាំងធុញទ្រាន់ ។

ធិតាមិនឆ្លើយតបដាក់កំហុសលើបងស្រីទេ សុខចិត្តនៅស្ងៀមស្ងាត់ហើយប្តូរ បរិយាកាស និយាយលេងជាមួយលោកវិសាលពីរឿងផ្សេងៗដទៃទៀត ។ ការពិត លោកវិសាលជាមនុស្សចិត្តទូលាយ និយាយស្ដីពិរោះ ហើយមានអត្ថន័យគួរត្រង ត្រាប់ណាស់ ។ ពិតមែនតែលោកមានវ័យចាស់ជាងក្រពុំចិត្ត ប្រហែលដល់ទៅ ១០ ឆ្នាំ ប៉ុន្តែគេទាំងពីរមានចំណូលចិត្តដូចគ្នាច្រើន ដូចជាចូលចិត្តចំរៀង កំណាព្យ និង ការនិពន្ធទំនុកភ្លេង ។ ថ្ងៃនេះ អ្នកទាំងពីរ អង្គុយនិយាយលេងជាមួយគ្នាយ៉ាង សប្បាយ ។ ក្រពុំចិត្តក៏បានអញ្ជើញលោកអោយនៅពិសាអាហារដែលនាងបាន ដណ្ដាំដោយផ្ទាល់ដៃទៀតផង ។ តាំងពីថ្ងៃនោះមក ចំណងទាក់ទងរវាងលោក វិសាលនិងកញ្ញាក្រពុំចិត្ត ក៏កាន់តែមានភាពស្និទ្ធស្នាលខ្លាំងឡើងជាលំដាប់ទៅដែរ ធ្វើឱ្យធិតាយើងមានអារម្មណ៍ថា លោកនេះមិនសូវជាចង្អៀតចង្អល់ប៉ុន្មានដូចគ្រា មុនទៀត ។

ជាច្រើនខែកន្លងទៅ....

លោកវិសាលចេញពីធ្វើការភ្លាម ក៏មកលេងក្រពុំចិត្តទាំងព្រលប់ ។ មាណវី ឃើញវត្តមានរបស់គូប្រតិពទ្ធ័ភ្លាម ក៏ស្ទុះទៅទទួលទាំងចិត្តត្រេកអរ :

- បងវិសាល...

CHANBOKEO.COM

វិសាលឮហើយញញឹមយ៉ាងស្រស់ ហើយនិយាយដាក់នារីថា :

- ចិត្ត! អូនទាយទៅមើល៍ ថាបងមានអ្វីមកផ្ញើអូន?

- ឃើញហើយ.. គឺបាច់ផ្កាយ៉ាងស្រស់ស្អាតនោះអី...

- នៅមានទៀត... វិសេសជាងហ្នឹងឆ្ងាយណាស់ !

- មានអ្វីទៅ ? អោយអូនសុំមើលផងបានទេហ៎?

លោកវិសាលដាក់ខ្លួនចុះទៅក្នុងទោងយោលមួយនៅមុខផ្ទះ ក្នុងសួនច្បារ ហើយអូសដៃក្រពុំចិត្តអោយអង្គុយក្បែរខ្លួន រួចក៏ស្រដីថា :

- ចិត្ត ! អូនចាំបានទេហ៎ ថាយើងបានស្គាល់គ្នាយូរប៉ុណ្ណាហើយ?

- គឺ... ជិតមួយឆ្នាំហើយទេដឹង?

- តែបងថាយូរជាងហ្នឹងទៅទៀត...

ក្រពុំចិត្តសំលឹងមុខលោកវិសាល :

- បងស្រដីប្លែកម្ល៉េះថ្ងៃនេះ? មានការអ្វីឬបង?

ឮដូច្នោះ លោកវិសាលញញឹម :

- គឺបងយល់ថា យើងទាំងពីរយល់ចិត្តគ្នាជាក់ច្បាស់ហើយអាចចុះសំរុងគ្នាបាន ។

- ចាស មែនហើយ! តាំងពីយើងស្គាល់គ្នាមក យើងមិនដែលមានចិត្តរឱស្ពាននឹងគ្នា ម្តងណាឡើយ ។

- អញ្ចឹង បើបងសុំអូននូវរឿងសំខាន់មួយក្នុងជីវិត អូនទទួលយកទេហ៎?

- និយាយប្រាប់អូនសិនមក៏ ថាបងចង់សុំអូនរឿងអ្វី?

លោកវិសាលលូកហោប៉ៅ ទាញយកកូនប្រអប់មួយចេញមក :

- អូនបើកមើលទៅ!

ក្រពុំចិត្តទទួលយកកូនប្រអប់មកបើកទាំងចិត្តភ័យអរ ។ មែនហើយ នោះគឺ ជាកូនចិញ្ចៀនពេជ្រ ដ៏សែនសស្អាតភ្លឺចិញ្ចាចមួយវង់ ។ លោកវិសាលញញឹម រួច ហើយមានវាចាឡើងថា :

- ចិត្ត! បើបងសុំអូនរៀបការ តើអូនយល់យ៉ាងណាដែរ ?

មាណវីភ្ញាក់ក្រញេង :

- ពុទ្ធោ ! មិនរហ័សពេកទេហ្អី បងវិសាល?

- តែបងស្រលាញ់អូន រួចគិតថាយើងទាំងពីរអាចសាងគ្រួសារមួយប្រកបដោយ សុភមង្គលបាន ។

- តើបងគិតជាក់ច្បាស់ក្នុងចិត្តហើយឬនៅ?

-ច្បាស់ហើយ! អូនគឺជានារីដែលបងសំរេចចិត្តជ្រើសរើសយកជាគូស្រករតែម្នាក់ គត់ ។ នៅវេលាអាទិត្យក្រោយនេះ បងនឹងសូមអោយចាស់ទុំចូលស្តីអូនហើយ ។

ឮប្រយោគនេះកាលណា ក្រពុំចិត្តទំលាក់មុខចុះ ហើយពោលខ្សិបៗថា :

- តែលោកប៉ាមិននៅផ្ទះតាំងពីយូរខែមកហើយ ។ ចំណែកម៉ាក់វិញ មិនដឹងថាគាត់ មានពេល សំរាប់បងដែរឬក៏យ៉ាងណាទេ?

- ចំពោះអ្នកស្រីដានី បងអាចជំរាបលោកដោយផ្ទាល់បាន ព្រោះបងស្គាល់ អ្នកស្រីជិតដិត តែចំពោះលោកប៉ារបស់អូន....

- គឺ គាត់មិនដែលវិលមកផ្ទះជួបជុំប្រពន្ធកូនជិតមួយឆ្នាំហើយណ៎បង ។

CHANBOKEO.COM

ពេលនោះលោកវិសាលក៏ទំលាក់ទឹកមុខដែរ ។ មែនហើយ ការពិតក្រពុំចិត្តពិត មិនដឹងថា ម្តាយឪពុករបស់នាងមានទំនាស់នឹងគ្នាដំរៅណាទេ... ឃើញតែឈ្លោះ មិនចេះឈប់ឈរ ជួនកាលមានការធ្វើបាបរូបកាយ ធ្វើអោយម្តាយនាងមានរបួស មានស្នាមជាំពេញទាំងខ្លួនទៀតផង ឈ្លោះហើយ លោកសម្បត្តិក៏ចុះចេញទៅបាត់ រាប់ខែរាប់ឆ្នាំ ទើបនឹកឃើញអើតមុខមកម្តង ។ លុះឃើញក្រពុំចិត្តមានទឹកមុខ ស្រពោន លោកវិសាលក៏និយាយកម្សាចិត្តនាងថា :

- មិនអីទេអូន ! បើដូច្នេះយើងរក្សាជាកំណាន់ចិត្តនឹងគ្នាសិនក៏បានដែរ ហើយពេល ណាដែលចាស់ទុំចុះសំរុងនឹងគ្នា ចាំយើងរៀបការជាក្រោយក៏បាន ។

ក្រពុំចិត្តងើបមុខឡើងសំលឹងលោកវិសាលរួចក៏ទទួលយកចិញ្ចៀនដែលលោក កំពុងស៊កម្រាមដៃអោយនាងទាំងទឹកមុខញញឹមពព្រាយ ។ លោកវិសាលលើក ម្រាមដៃនាងឡើងថើបដោយក្តីស្រលាញ់ :

- សូមអោយសេចក្តីស្រលាញ់របស់យើងស្ថិតស្ថេរតរៀងទៅណាំអូន ។

ផ្ញើជីវិតក្នុងដៃអូន

១. ជំនោរនិរតីរាត្រីស្នេហា ញាប់ញ័រឱរាស្រើបស្រាលអារម្មណ៍
គូគាប់ទ្វេហា ចិន្តាភិរម្យ សៀងចម្រើតយំកំដរគូស្នេហ៍ ។

២. ចន្ទ័រះលើម។ញញឹមជូនពរ សិរីបវរដល់គូទាំងទ្វេ
ស្នេហាភក្តីគ្មានថ្ងៃបែរ ជាតិនេះគ្មានទេចិត្តក្បត់សារ៉ា ។

បន្ទរ. ញញឹមណាំអូន ញញឹមណាំស្ងួនទួនធិតា
បងពិតជាស្មោះលុះអស់សង្ខារ ជាតិនេះជាតិណាស្មគ្រ័តែផ្កាអូន ។

៣. បេះដូងបងមួយកាត់ជូនពិសី ថែផងណាំស្រីលុះថ្ងៃយើងសូន្យ
ជីវិតស្នេហាផ្ញើក្នុងដៃអូន ឱ!ពៅមាសស្ងួន អូនម្ចាស់ចិត្តបងហើយ ។

CHANBOKEO.COM

អ្នកទាំងពីរអង្គុយយោលទោងមួយ។ សន្ទនាភាសាដួងចិត្តចំពោះគ្នាទៅវិញ ទៅមកយ៉ាងផ្អែមល្ហែម ជាលើកដំបូងបង្អស់ក្នុងជីវិតរបស់គេ ។

រំពេចនោះ រថយន្តថ្មីស្រលាងមួយបានបោះពួយមកដល់ ។ នារីឆើតឆាយមួយ រូបក៏ឈានចុះចេញមក ។ ក្រពុំចិត្តក្រលេកឃើញភ្លាម ក៏លាន់មាត់ឡើង :

- បងវិសាល ! ថ្ងៃនេះបងមានសំណាងណាស់ ដែលបានជួបសមាជិកទីមួយក្នុង គ្រួសាររបស់អូន ។ នោះគឺ... បងដារីយ៉ា! បងទៅជួបគាត់មួយភ្លែតទេ?

លោកវិសាលមិនទាន់ឆ្លើយថាយ៉ាងណាផង ក្រពុំចិត្តក៏ស្ទុះទាញដៃលោកអូស រឹង តំរង់ទៅដារីយ៉ាតែម្តង ។ កាលបើឃើញប្អូនស្រីដឹកដៃបុរសសង្ហារមួយរូប ដារីយ៉ាឈរភាំងស្មារតី ហើយឧទានឡើងថា :

- នាងចិត្ត ! នរណាគេហ្នឹង?

មែនហើយ! ដារិយ៉ាចូលចិត្តដើរលេងមិនសូវនៅផ្ទះទេ ហើយក៏មិនដែលនឹក ចំណាយពេលជាមួយប្អូនស្រីក្នុងភាពស្និទ្ធស្នាលជាបងប្អូនដែរ ម្ល៉ោះហើយនាងមិន ដែលបានដឹងនូវអ្វី។ ដែលទាក់ទងពីជីវិតរបស់ប្អូនស្រីឡើយ ។ ពេលនោះ ក្រពុំចិត្ត ក៏ឆ្លើយឡើងថា :

- នេះគឺបងវិសាល... បងវិសាល ខាងនេះ គឺបងដារិយ៉ា

លោកវិសាលក៏ប្រណម្យដៃជំរាបសួរ :

- ជំរាបសួរអ្នកនាងដារិយ៉ា !

ពុទ្ធោអើយ! មើលចុះ! ដារិយ៉ាសំលឹងលោកវិសាលយ៉ាងភ្លឹកតែម្តង សំដែង កិរិយាហាក់បីដូចពេញចិត្តនឹងបុរសមួយរូបនេះខ្លាំងណាស់ ។ បន្ទាប់មក នារីរូប ស្រស់ក៏បែរមកដេញប្អូនថា :

- នាងចិត្ត! ម៉េចក៏មិនអញ្ជើញភ្ញៀវទៅក្នុងផ្ទះ? យ៉ាងម៉េចបានជានាំលោកមក ជដែកលេងនៅក្រៅផ្ទះអញ្ចឹង ?

ប្អូនដូចជាខ្វះសុជីវធម៌ដល់ហើយហ្ន៎!!

លោកវិសាលនិងក្រពុំចិត្តសំលឹងមុខគ្នា ។ ក្រពុំចិត្តនឹកគិតតែក្នុងចិត្តម្នាក់ឯង :

- បងវិសាលមិនមែនជាភ្ញៀវទេ តែជាគូកំណាន់ចិត្តរបស់ខ្ញុំ.... បងទេហ៎ដែលខ្វះ សុជីវធម៌នោះ

ព្រោះមកស្តីបន្ទោសប្អូននៅចំពោះមុខគេទាំងមិនដឹងរឿង!

- លោកវិសាល! សូមអញ្ជើញអង្គុយលេងក្នុងផ្ទះសិនចាស! (ដារិយ៉ាអញ្ជើញ)

ហើយដារិយ៉ាក៏បែរមកបញ្ជាប្អូន :

- ចិត្ត! ទៅលើកភេសជ្ជៈមួយថាសមក៍ !

- ចាំសបង!

លោកវិសាលបែរមើលទៅក្រពុំចិត្ត ហើយសំលឹងទៅដារិយ៉ា តែដោយទើស ទាល់

លោកក៏បោះជំហានតាមក្រោយក្រមុំឆើតឆាយចូលទៅក្នុងផ្ទះ ។ លុះ

មាណវីយើងលើកថាសភេសជ្ជៈមកដល់ ស្រាប់តែបងស្រីនាងពោលដេញ :

- ដាក់ចុះត្រង់ហ្នឹងហើយ ហើយថយទៅចុះ ទុកអោយចាស់ៗគេនិយាយគ្នា ។

ក្រពុំចិត្តងើបមុខសំលឹងបងស្រី រួចជ្រួញចិញ្ចើម ហើយក៏សំលឹងទៅលោក វិសាលទាំងកិរិយាចំលែកចិត្ត ។ ឃើញប្អូនស្រីនៅអេះអុញ ដារិយ៉ាក៏ពោលបន្ថែម:

- នែ៎ ! បើប្អូនចង់ចេញទៅក្រៅដើរលេងនៅមាត់ទន្លេ ក៏ទៅៗ ហើយហៅនាង ចឿនអោយជូនទៅផង កុំទៅតែម្នាក់ឯងពូហើយនៅ?

មាណវីពួហើយក៏ឆ្លើយថា :

- យប់ហើយបង! ចេញទៅដើរលេងយប់មិនសូវមានសន្តិសុខទេ ម្យ៉ាងទៀត នាង ចឿនក៏មិននៅដែរ ទៅលេងស្រុកចំនួនម៉ាអាទិត្យហើយ ។

- អឺៗ បើមិនទៅមាត់ទន្លេក៏បាន តែប្អូនចេញទៅក្រៅទិញចេកចៀនមកអោយបង បន្តិចបានទេ ?

- បងដារិយ៉ា? ថ្ងៃនេះ បងចង់ពិសាចេកចៀន? ចំលែកណាស់ (ឈូកនឹកក្នុងចិត្ត) បើចង់ពិសារចេកចៀនមែន គ្រាន់តែទូរសព្ទ័ក៏បានដែរ

មិនគួរដល់ថ្នាក់ដេញប្អូន អោយចេញទៅក្រៅរកទិញទាំងយប់នោះទេ ឬ ក៏ ប្រហែលគ្រាន់តែជាលេសដើម្បី

ដេញយើងអោយផុតពីមុខពីមាត់គាត់ប៉ុណ្ណឹងឯង ។

ក្រពុំចិត្តគិតដូច្នោះហើយក៏ថយចេញទៅ ដោយមិនប្រកែកប្រណាំងអ្វីនឹងបង ស្រីអ្វីឡើយ ។ នាងដើរចេញសំដៅរថយន្តរបស់នាងបណ្តើរ បែរក្រោយបណ្តើរ

ហើយនឹកពិភាល់ក្នុងចិត្តថា :

- តើបងវិសាលគាត់មានអារម្មណ៍យ៉ាងណាចំពោះបងដារិយ៉ា? តើគេទាំងពីរនឹង សន្ទនាពីអ្វីទៅ? ហេតុអ្វីក៏បងស្រីរបស់ខ្ញុំ

ហាក់ដូចជាចាប់អារម្មណ៍ចំពោះរូបបង វិសាលយ៉ាងនេះ?

តរុណីបរឡានចេញទៅក្រៅ ទាំងចិត្តកន្ទុះរា មិនដឹងថាត្រូវទៅណា ហើយក៏

CHANBOKEO.COM

មិនដាច់ចិត្តនឹងទៅទៀត ព្រោះពេលនេះ ម៉ោង៨យប់ទៅហើយ តើស្រីក្រមុំដូចជា នាងនឹងមានកន្លែងណាទៅដែលមានសុវត្ថិភាពសំរាប់នាង? ការពិត នាងក៏មានមិត្ត ភក្តិពីរនាក់ដែរ តែនាងខានទៅរៀនអស់ពេលជាយូរ មិនដែលបានជួបគេសោះ ។ ម្នាក់ជាអ្នកអរិយក្សត្រ ហើយម្នាក់ទៀតនៅឫស្សីកែវ ។ បើអោយទៅលេងគេ ទាំងយប់ដូច្នេះដូចមិនសម បើមិនទៅវិញ ក៏នាងមិនដឹងថាត្រូវទៅត្រង់ណាទៀត ។ ក្រោយមកនាងក៏បររថយន្តទៅចតនៅមុខផ្ទះរបស់មិត្តនៅឫស្សីកែវ រួចពន្លត់ភ្លើង តែមិនហ៊ានចូលទៅគោះទ្វារផ្ទះរកមិត្តរបស់ខ្លួនទេ ។ មួយស្របក់ក្រោយមក នាងក៏ ត្រលប់មកដល់ម្តុំវិទ្យារបស់នាងវិញ ។ នាងនៅឈប់ឡានរេរាមិនហ៊ានបរចូលទៅ ក្នុងផ្ទះ ត្បិតខ្លាចត្រូវមាត់បងស្រី ម្លោះហើយស៊ូនៅអង្គុយស្ងាបនៅក្នុងឡានដែល ចតនៅកាច់ជ្រុងវិថីក្បែរលំនៅ ។ លុះបញ្ចោះឡានបើកម៉ាស៊ីនត្រជាក់យូរពេក រថ យន្តក៏អស់សាំងរលីងធ្វើអោយម៉ាស៊ីនរលត់ឈឹង ។ មាណវីយើងក៏ចុះពីរថយន្តដើរ ត្រឹក១សំដៅទៅផ្ទះវិញ ស្រាប់តែមានម៉ូតូមួយផ្ទុកបុរសគ្នាពីរនាក់បរមកជិតហើយ ស្រវាចាប់ខ្ទប់មាត់នាងរួចអោបលើកដាក់ម៉ូតូបរចេញទៅយ៉ាងលឿន ។ ធិតាយើង ខំស្រែករើបំរះយ៉ាងខ្លាំង  តែធ្វើយ៉ាងណាក៏មិនរួចសោះ ថែមទាំងមានអារម្មណ៍ថា នាងកំពុងត្រូវថ្នាំសណ្តំធ្វើអោយងក់ងុយយ៉ាងខ្លាំងរួចក៏បាត់ស្មារតីទៅ ។

    រីឯលោកវិសាលវិញ  ដែលនៅអង្គុយសំណេះសំណាលជាមួយដារិយ៉ា មាន អារម្មណ៏ថា ខ្លួននៅជជែកយប់ជ្រៅពេក ក៏សុំខ្លួន :

- អត់ទោស! អ្នកនាង! យប់នេះ ខ្ញុំមានកម្មវិធីទូរទស្សន៏ពេលយប់ ត្រូវត្រលប់ ចូលទៅកន្លែងធ្វើការវិញឥលូវនេះហើយ ។

    តែដារិយ៉ាបែរជាឃាត់ :

- នៅលេងមួយស្របក់សិនទៅណាំ រួចទូរសព្ទ័ទៅក្រសួងថាមានការផ្ទាល់ខ្លួនត្រូវ អាក់ខានការងារមួយថ្ងៃ ។ កុំប្រញាប់ទៅណាអីត្បិតខ្ញុំមិនទាន់បានជជែកលេងជា មួយលោកអោយស្គាល់គ្នាជិតដិតផង ។   យ៉ាងម៉េចយ៉ាងម៉ា ក៏គួរតែនៅរងចាំលា ប្អូនស្រីរបស់ខ្ញុំសិន បន្តិចទៀត គេត្រលប់មកពីទិញចេកចៀនវិញហើយ ។

    លោកវិសាលមានអារម្មណ៏ហាក់ដូចជាទើសទាល់កាន់តែខ្លាំង ហើយនឹកឆ្ងល់ ក្នុងចិត្តម្នាក់ឯងថា :

- ហេតុអ្វីក៏បងប្អូនបង្កើតពីររូប មានចរិតមិនដូចគ្នាយ៉ាងនេះ? មើលចុះ ប្អូនស្រី ស្លូតបូតរមទម្យគួរអោយស្រលាញ់មានសោភណ័របៀបល្អគន់ មិនដូចបងស្រីទេ ដែលឆើតឆាយរួសរាយហើយសិចស៊ីដល់សួរតែម្តង នឹងទ្រាំមិនរំភើបចំពោះរូប សម្ផស្សរបស់នាងមិនបានទេ ។ តែហ៊ឺ.... យើងមិនមែនមកទទួលនាទីសំរាប់ជ្រើស រើសគូស្រកទេ ពេលនេះនារីដែលយើងពេញចិត្តគឺអូនក្រពុំចិត្ត មិនមែននារីដ៏ស្រស់ ឆើតឆាយមួយរូបនេះឡើយ ។

    ពេលនោះ ដារិយ៉ាដើរចូលទៅផ្ទះបាយ ចាក់ស្រាពីរកែវមកផង :

- ពិសាលាងមាត់សិនទៅ កុំអោយអផ្សុក..

    លោកវិសាលទទួលកែវស្រាពីដារិយ៉ាពិតមែន  តែអារម្មណ៏របស់លោកនៅឯ ក្រពុំចិត្តឯណោះ ។ គ្រាន់តែទទួលកែវស្រាដាក់មួយក្អឹកភ្លាម ស្រាប់តែលោកមាន អារម្មណ៏ថា ផែនដីវិលក្រលាប់តែម្តង ។

    ដារិយ៉ាលើកទូរសព្ទ័ចុចហៅ :

- ប៉េងឡុង ! ជួយមើលប្អូនស្រីរបស់ខ្ញុំផង... បើកឡានផ្ទាល់ខ្លួនរបស់នាង... ចេញ ទៅម៉ាស្របក់ហើយ... ទៅទិញចេកចៀន... មិនដឹងថានៅម្តុំណាទេ... ឯងទំនេរ តាមមើល៏ ផងណាំ ... អឺអឺ អរគុណ!!

    ដារិយ៉ាដាក់ទូរសព្ទ័ចុះ ហើយសំលឹងមុខលោកវិសាលដែលដួលផ្កាប់មុខនៅ លើកំរាលឥដ្ឋ ងើបមិនរួច....

00 00

CHANBOKEO.COM

# វគ្គទី៦
# ចំរៀងគ្រួសារយើង

ថ្ងៃនេះសុជាតិភ្ញាក់ពីព្រលឹម គិតថានឹងស្កាត់ទៅរកជួបនីមម្តងទៀត ។ ប៉ុន្តែ លុះពេលនាយទៅដល់ ម្តាយនីមបានប្រាប់មាណពថានីមទៅលេងជូនទាវជាមួយ ជ្រក់បងរបស់នាងបាត់ទៅហើយ ។ សុជាតិមានអារម្មណ៏ថាខកចិត្តណាស់ ក៏វិលមកផ្ទះវិញទាំងមិនអស់ចិត្ត ។ មកដល់ជិតផ្ទះ ស្រាប់តែនាយឃើញសុខាដើរមក រកនាយទាំងរហន់ :

- បងជាតិ! ទៅមើលបងឈូកផង! គាត់ដួលសន្លប់នៅក្បែរជណ្តើរផ្ទះមិនដឹងខ្លួន ទេ! ខ្ញុំខំជួយលើកដែរតែលើកមិនរួច..

សុជាតិឮដូច្នោះ ក៏ស្ទុះទៅយ៉ាងលឿន ឃើញឈូកដួលបាត់មាត់ឈឹង ហើយ មានទឹកមុខស្លេកស្លាំងបំផុត ។ នាយក៏ស្ទុះបីនាងយកទៅដាក់នៅលើផ្ទះយ៉ាង ប្រញាប់ ។ មីងសោមក៏ស្ទុះស្ទារប្រវេប្រវា មកជួយដែរ :

- នាងឈូកគេយ៉ាងម៉េចហ្នឹង អាង៉ាកូន?

- បាទ! មិនដឹងទេម៉ែ! នាងមានសាច់ឈាមស្លេកស្លាំងណាស់!

ឃើញឈូកមានអាការៈជំងឺចំលែកដូច្នោះ សុជាតិក៏នឹកមេថាប្រហែលជាឈូក លួចលេបថ្នាំបំពុលសម្លាប់ខ្លួនសាជាថ្មីក៏មិនដឹង ត្បិតអីនាងប៉ុនប៉ងព្យាយាមរកធ្វើ អត្តឃាតកាលពីយប់មិញ ម្តងរួចមកហើយ ។ ដោយនឹកបារម្ភក្នុងចិត្តខ្លាំងពេក សុជាតិក៏ស្ទុះទៅតាមពេទ្យអេងដែលជាមិត្តសំលាញ់របស់ខ្លួននៅឯអូតាគី ។ មួយ ស្របក់ក្រោយមក ឈូកក៏ដឹងខ្លួនមកវិញ ព្រមពេលដែលសុជាតិនាំពេទ្យអេងនោះ មកដល់ដែរ ។

- ឈូក! ឈូកកើតអីហ្នឹង? （សុជាតិសួរ ）

ឈូកបែរមើលគ្រប់គ្នាជុំវិញខ្លួនហើយឆ្លើយខ្សាវៗថា :

- ខ្ញុំមិនអីទេ... គ្រាន់តែធីងធោងវិលមុខបន្តិចបន្តួច

ពេទ្យអេងក៏រៀបពិនិត្យរោគរបស់នាងភ្លាម ។ មួយសន្ទុះធំក្រោយមក ពេទ្យ ក៏លាចេញទៅវិញ ហើយហៅសុជាតិទៅខ្សិបថា :

- អោយខ្ញុំជួយត្រេកអរសុជាតិឯងផងណា៎! ភរិយាឯងកំពុងមានផ្ទៃពោះហើយ!

ព្រះអើយ! ដំណឹងនេះធ្វើអោយសុជាតិភ្ញាក់ផ្អើលខ្លាំងណាស់ ហាក់ដូចត្រូវគេ ច្រានទំលាក់ជ្រោះអញ្ចឹង :

- ស្រេចហើយ! (សុជាតិលាន់មាត់តែម្នាក់ឯង) រឿងរ៉ាវកាន់តែវែងឆ្ងាយហើយ តើហ៏យើងនេះ! នាយជាតិអើយ តើគួរធ្វើយ៉ាងណាទៀតទៅ? តើយើងកំពុងតែ យកអន្ទាក់មក ល បំពង់ក របស់ខ្លួនឯងទេដឹងនេះ?

ពេទ្យអេងក៏លាឡើងម៉ូតូធ្វើដំណើរទៅវិញ សុជាតិក៏បកក្រោយឡើងទៅលើ ផ្ទះ តែនៅក្នុងចិត្តមិនដឹងថាត្រូវទំលាយរឿងនេះប្រាប់ទៅឈូកយ៉ាងម៉េច ហើយក៏ មិនដឹងដែរថា បើនាយប្រាប់នាងហើយ តើនាងនឹងត្រេកអរ ឬ តក់ស្លុតចំពោះ ដំណឹងនេះ ។ ម្យ៉ាងទៀត មើលទៅនាង ហាក់ដូចជានារីដែលមានជីវិតពោរពេញ ដោយក្តីវិបត្តិ មិនដឹងថាតើ

CHANBOKEO.COM

វត្តមានទារកតូចក្នុងផ្ទៃរបស់នាងជាកំលាំងចិត្ត ជំរុញអោយនាងប្រឹងត្រដររស់តទៅទៀត ឬ ក៏ជាសត្រូវសំលុតស្មារតីនាងអោយថមថយសេចក្តីក្លាហានចំពោះការពុះពារឧបសគ្គក្នុងជីវិត? ឃើញនាយយើងមាន តិរិយាអន្ទះសាច្រាសច្រាល់ដូចមាន់រកពង សុខាក៏សួរឡើង :

- បងជាតិ! ថ្ងៃនេះបងយ៉ាងម៉េចហ្នឹង? ឆ្លេឆ្លា១...
- បងមិនអីទេ... គ្រាន់តែបារម្ភពីសុខទុក្ខរបស់ឈូកប៉ុណ្ណោះ ។

កាលបើឮដូច្នោះ ឈូកក៏រាំចាឡើងថា :

- បងប្រុសកុំបារម្ភអី! ខ្ញុំជំរាបបងហើយតើហ៎ ថាខ្ញុំមិនអីទេ ។ ហើយចុះបងមិនទៅវត់ឡានទេហ៎ ថ្ងៃនេះ?
- ខ្ញុំគិតថាសំរាកមួយថ្ងៃ នៅបរិភោគបាយថ្ងៃត្រង់ជុំគ្នាម្តង (សុជាតិឆ្លើយ)
- អញ្ចឹង ចាំខ្ញុំនិងសុខាជាអ្នកដាំស្លជូនបងចុះ ! (ឈូកតបមកវិញ)
- អឺ! ធ្វើអោយច្រើនមក ! ម៉ែក៏ចង់ឆ្ងាញ់មាត់ដែរ កុំភ្លេចចំណែកម៉ែណាំកូន
- ចាំស! (ឈូកឆ្លើយទទួល)

ទាំងអស់គ្នាក៏ញញឹមឡើង ផ្លាស់ប្តូរបរិយាកាសអាប់អួរ ទៅជារីករាយស្រស់ បំព្រងតែម្តង ។ លុះបរិភោគបាយរួច សុជាតិក៏ចេញទៅធ្វើចំការក្រោយផ្ទះតែម្នាក់ ឯងបាត់ទៅ ។ ឈូកក៏នៅហាន់ស្លឹកថ្នាំជាមួយសុខាខាងក្រោមផ្ទះ ទុកអោយមឹងសោមសំរាន្តយកកំលាំង ។ មួយស្របក់ធំក្រោយមក ស្រាប់តែមានខ្យល់បក់នាំ ភ្លៀងធ្លាក់ខ្ទោក១យ៉ាងខ្លាំង ថែមទាំងមានទាំងរន្ទះធំ១ទៀតផង ។ ឈូកនឹកឃើញ ដល់សុជាតិដែលនៅឯចំការតែម្នាក់ឯង ក៏និយាយជាមួយសុខាថា :

- ភ្លៀងធំយ៉ាងនេះ បងជាតិច្បាស់ជាទទឹក រងាស្លាប់ហើយ!
- មិនអីទេបងឈូក! យើងជាអ្នកកំសត់ធ្វើការហាលភ្លៀងហាលខ្យល់ជាទំលាប់ ទៅហើយ ។ បងជាតិច្បាស់ជាមិនអីទេ ។

ឈូកអង្គុយសំលឹងទៅមេឃ ហើយនឹកពិភាល់យ៉ាងណាមិនដឹងក៏សួរទៀតៈ

- ប្អូនមានអាវភ្លៀងទេ? បងចង់យកទៅផ្ញើបងជាតិបន្តិច!

សុខាសើចខឹក១ ហើយគ្រវីក្បាលៈ

- មិនដែលមានទេបង មានតែមួកស្លឹក ឬ ស្លឹកចេកម៉ាធាងតែម្តង តែបងកុំអន្ទះសាអី ។ បងជាតិពិតជាសុខសប្បាយទេ ។ បន្តិចទៀត គាត់ច្បាស់ជាត្រលប់មក ផ្ទះវិញហើយ ។

តែឈូកនៅតែមានអារម្មណ៍មិនល្អដដែល ចេះតែនឹកពិភាល់បារម្ភពីសុជាតិមិនអស់មិនហើយ ។ ទ្រាំមិនបាននាងក៏ស្ទុះដើរចេញរឹងកាត់ភ្លៀងទៅតាមរកនាយនៅឯចំការទោះបីជាសុខាស្រែកឃាត់នាងយ៉ាងណាក៏មិនស្តាប់ឡើយ ។ នាងដើរ កូកហៅសុជាតិពាសពេញចំការចេក ចំការថ្នាំជក់ ដើររហូតដល់មាត់ត្រពាំងព្រលិត ក្បែរវាលស្រែ :

- បងជាតិ!.... បងជាតិ!

ប៉ុន្តែភ្លៀងធំណាស់ ។ នាងមិនបានឮសំលេងឆ្លើយតបវិញទេ ។ រីតំណក់គ្រាប់ ភ្លៀងដែលធ្លាក់ចុះមកនោះទៀតសោតក៏ត្រជាក់ក្រៃណា ធ្វើអោយចិតាយើងរងា ឡើងរណ្តំចង្កា ។ ប៉ុន្តែសុខទុក្ខរបស់សុជាតិមានន័យធំធេងសំរាប់ឈូកណាស់ ។ ក្តី បារម្ភរបស់នាងចំពោះសុជាតិ បាននាំអោយរូបនាងក្លាយជាបាត់រងាអស់រលីង ។ នៅក្នុងចិត្ត ក្នុងអារម្មណ៍របស់នាងពេលនេះ គឺមានតែការបន់ស្រន់អោយសុជាតិ

CHANBOKEO.COM

សុខសប្បាយតែម្យ៉ាងប៉ុណ្ណោះ ។ លុះមាណវីដើរមកដល់ដើមស្វាយជាយដីចំការ ស្រាប់តែប្រទះឃើញសុជាតិដួលដេកក្នុងថ្លុកឈាមតែម្នាក់ឯង ដោយត្រូវមែក ស្វាយបាក់សង្កត់លើ ។ នារីយើងឃើញហើយភិតភ័យឡើងស្វាយមាត់:

- បងជាតិ! បងដឹងខ្លួនទេ? បង...

វិពេចនោះ ស្រាប់តែសុជាតិប្រែខ្លួននិយាយខ្សាវៗថា :

- ឈូក....ជួយបងផង....

មាណវីក៏ខំប្រវេប្រវាជួយអូសមែកស្វាយបង្វើប អោយសុជាតិនទៀលចេញ មកទើបស្ទុះគ្រាហ៍សុជាតិចេញមកទាំងតតេះតតះ :

- បងជាតិ! បងដើររួចទេហ៎?

សំណាងល្អណាស់ដែលសុជាតិដឹងស្មារតីមកវិញពេលឈូកទៅដល់ ។ នាយក៏ខំ

ប្រឹងត្រដរងើបទប់ខ្លួននឹងឈូកដើរត្រលប់មកផ្ទះទាំងអាការៈយ៉ាប់យឺនក្រៃលែង ។ ទោះបីជាយ៉ាងណា ក៏មាណពហាក់ដូចជាមានអារម្មណ៍ថា បាត់ឈឺចាប់អស់រលីង

កាលបើឃើញឈូកមានចិត្តព្រួយបារម្ភចំពោះសុខទុក្ខរបស់នាយជាទីបំផុត ។

នៅក្នុងផ្ទះ...

សុជាតិត្រូវមែកស្វាយវាត់ត្រូវស្មៀតផ្កានិងស្មាខាងឆ្វេង ដាច់សាច់យ៉ាងជ្រៅ តែនាយមិនមានថ្ងូរមួយអ៊ឺះ អោយអ្នកផ្ទះបារម្ភទេ ថែមទាំងឃាត់ឈូកមិនអោយ ចេញទៅតាមពេទ្យទាំងកណ្តាលភ្លៀងផង ។ សុខានិងមីងសោមឃើញសុជាតិមាន របួសធ្ងន់ធ្ងរ ក៏មានការតក់ស្លុតក្នុងចិត្តពេកក្រៃ ។ ឈូកក៏យកទឹកក្តៅឧណ្ហៗមក

លាងសំអាតរបួសអោយសុជាតិដែលធ្មេចភ្នែកគេងសំងំបំបាត់ការឈឺចាប់ស្រាប់តែ សុជាតិលូកដៃស្រវាចាប់ដៃនាងជាប់

ទោះពេលនោះនាយនៅបិទភ្នែកនៅឡើយ ។ ឈូកក៏ទាញដៃចេញតែនាយក៏នៅមិនព្រមលែងសោះ ។ ឈូកនឹកខ្មាសយ៉ាងណា

មិនដឹងក៏លួចបែរមើលទៅសុខា ឃើញនាងកំពុងយកខោអាវប្រលាក់របស់សុជាតិ ទៅគក់មិនបានចាប់ភ្លឹកនឹងកិរិយារបស់អ្នកទាំងពីរទេ ។

ចំណែកមីងសោមនៅក្បែរ នោះក៏ងងិតភ្នែកមិនបានឃើញដែរ ។ ម្ល៉ោះហើយឈូកហាក់ធូរទ្រូងបន្តិច រួចក៏ លួចទាញដៃចេញម្តងទៀត

តែសុជាតិនៅតែកាន់ដៃនាងជាប់ដដែលមិនព្រមលែង សោះ ធ្វើអោយចិត្តរិតតែញាប់ញ័រក្នុងចិត្ត មិនដឹងថានាយកំពុងចង់ធ្វើអ្វី ។ បន្តិច មក

នាយយើងក៏បើកភ្នែកព្រឹមៗ មើលមកនាងហើយញញឹម ។ ទោះបីពេលនោះ

ផ្ទៃមុខរបស់នាយបានបង្ហាញនូវការឈឺចាប់ខ្លះៗដោយសាររបួសដ៏ធ្ងន់ធ្ងរក្តី ក៏កែវ ភ្នែកស្រទន់របស់មាណព

បានលួចខ្សិបបរិយាយនូវភាសាដួងចិត្តមួយឃ្លាដ៏មាន ន័យយ៉ាងធំធេងទៅកាន់មាណវីយើងថា :

- ក្នុងលោកនេះ... មានតែអូនទេ... ដែលជាកំពូលដួងចិត្តរបស់បង...!!

ឈូកប្រទះក្រសែភ្នែកនរៈកាលណា ក៏យល់អត្ថន័យភ្លាមដែរ ធ្វើឱ្យនាងមាន អារម្មណ៍ច្របូកច្របល់យ៉ាងណាមិនដឹង

ហើយក៏ឈ្ងោកងាកគេចមុខចេញដោយការ ខ្មាស់អៀន ស្រាប់តែ សុជាតិទាញដៃរបស់នារីសាជាថ្មី យកទៅដាក់លើដើមទ្រូង

របស់នាយហើយធ្វើមុខញញឹមរួចក៏ធ្មេចសំងំគេងទៅវិញ ។ ឃើញដូច្នោះឈូកក៏ អង្គុយស្ងៀម

ទុកបណ្តោយអោយសុជាតិកាន់ដៃនាងក្តាប់យ៉ាងណែន ។ គ្រានោះ មាណវីមានអារម្មណ៍ថាបេះដូងរបស់នាង

ក៏បានទទួលនូវភាពកក់ក្តៅយ៉ាងចំលែក មួយ ដែលនាងមិនធ្លាប់បានទទួលអារម្មណ៍បែបនេះពីមុនមកម្តងណាឡើយ ។

CHANBOKEO.COM

យប់នោះ ឈ្យូកមិនហ៊ានគេងទេ ស៊ូនៅអត់ងងុយអង្គុយងក់ផ្ងក់ៗ កំដរ សុជាតិមួយយប់ទល់ភ្លឺ ត្បិតនាយយើងគ្រុនក្ដៅជាខ្លាំង ដោយការបាត់បង់ឈាម ពីខ្លួនច្រើនពេក ។ នៅខាងក្រៅផ្ទះឯណោះ ភ្លៀងក៏នៅតែបង្អុរខ្ទោកខ្ទាក់ឥត ស្រាកស្រាន្ត រកតែឈ្យូករត់ទៅតាមពេទ្យអោយពិនិត្យសុជាតិក៏មិនបានឡើយ ។

ភ្លឺស្រាងៗ មាន់រងាវ សុជាតិក៏ភ្ញាក់ដឹងខ្លួនមកវិញ ឃើញឈ្យូកអង្គុយដណ្ដប់ ក្រមាផ្ទេចគេងផ្អែកនឹងជញ្ជាំងក្បែរជើងមុងរបស់នាយ ។ មាណពលួចគយគន់ឆវី យ៉ាងភ្លន់ភ្លឹកហើយ គិតតែក្នុងចិត្តតែម្នាក់ឯងថា :

- ឈ្យូក! អូនជាមនុស្សមានសន្ដានចិត្តល្អណាស់! ប៉ុន្តែហេតុអ្វីទៅហ្ន៎ដែលអូនត្រូវ រសាត់អណ្តែតជីវិតមកយ៉ាងកំសត់បែបនេះ? តើអូនជាអ្នកណា? ឬអូនជាធិតា ដែលទេវតាលោកប្រទានអោយមកជួបគ្នាជាគូជីវិតរបស់បង?

រំពេចនោះ ឈ្យូកក៏ភ្ញាភ្ញាក់ស្មារតីឡើង ឃើញសុជាតិក្រោកអង្គុយ ក៏សួរថា :

- បង! បានស្រួលគ្រាន់បើហើយមែនទេ?

- បាទ! មិនអីទេ! អរគុណឈ្យូកណាស់ដែលទៅសង្គ្រោះបងមក កុំអីច្បាស់ជា ត្រូវនៅហាលភ្លៀងម៉ាយប់ហើយ!

- បងធ្លាប់ជួយជីវិតឈ្យូកពីមុនមក រឿងអីដែលឈ្យូកជួយបងវិញមិនបាននោះ?

សុជាតិព្ញហើយញញឹមពព្រាយឡើង :

- បានន័យថា ឈ្យូកក៏បារម្ភពីសុខទុក្ខរបស់បងដែរមែនទេហ៎?

ឈ្យូកមិនហ៊ានឆ្លើយវិញទេ ព្រោះហាក់ដូចជានឹកអៀនចំពោះក្រសែភ្នែកភ្លឺថ្លា ផ្លេកៗរបស់សុជាតិដែលកំពុងសំលឹងមក ។ នាងក៏សួរបន្លប់ទៅវិញថា :

- ជិតភ្លឺហើយ បងពិសាបបរទេ? ឈ្យូកនឹងទៅដណ្ដាំយកមកជូន!

សុជាតិងក់ក្បាលហើយញញឹមដាក់នាង :

- បាទ! អោយតែជាស្នាដៃឈ្យូក បងញ៉ាំទាំងអស់ ។

ដោយនឹកខ្មាសចំពោះក្រសែភ្នែកសុជាតិ ដែលសំលឹងនាងពេក ឈ្យូកក៏ក្រោក គេចទៅផ្ទះបាយបង្កាត់ភ្លើងបាត់ទៅ ទុកអោយសុជាតិលួចមើលពីក្រោយ ញញឹម ទាំងដួងចិត្តរំភើបតែម្នាក់ឯង...

ព្រឹកឡើង ភ្លៀងរាំង ថ្ងៃរះពេញពន្លឺ....

ឈ្យូកដើរតាមសុខាទៅក្រោយផ្ទះកាត់ចំការចេក រហូតដល់មាត់ត្រពាំងមួយ ជិតវាលស្រែដែលមានសន្ទូងខៀវស្រងាត់ ។ ធិតាឃើញត្រពាំងមានទឹកថ្លាខ្យង ហើយមានផ្កាឈ្យូក ព្រលិត ផ្កាត្រកួនរីករហង់ គួរអោយចាប់ចិត្តចេតនាក្រៃលែង ។ ភ្លៀងធំកាលពីយប់មិញ បានធ្វើអោយដំណាំស្រូវស្រែ ធម្មជាតិទាំងឡាយ ក្លាយជា ស្រស់បំព្រងតែម្ដង ។ រំពេចនោះ នាងបាន ព្ញនាងតូចសុខាស្រែកច្រៀងឡើងយ៉ាង គ្រលួច :

ផ្កាដុះវាលស្រែ

១. ផ្កាត្រកួនស្វាយចាយពេញស្រែ ប្រណាំងហួរហែនឹងផ្កាស្នោ
ផ្កាក្រជីបស្រស់ក្រហមផូរ រីកតាមដងអូរស្រស់ប្រណិត ។
២. ផ្កាឈ្យូករហង់រំចង់ឆើត ផ្កាម្អមខំអើតក្បែរព្រលិត
ឃើញផ្ការីកស្រស់រំភើបចិត្ត នាសាផ្ដេកផ្ដិតពិដោរទេព ។
៣. ផ្កាស្រែឆ្លុះពណ៌នឹងវាលស្មៅ សន្ទូងស្រែស្រូវបណ្ដោយទ្វីប

CHANBOKEO.COM

យល់សោភណ៍ផ្កាចង់និត្យនៃប ត្រកងផ្កាក្រេបគន្ធាសាយ ។

៤. រដូវវស្សាផ្ការីកស្រស់ នាសាបបោសមិនជិនណាយ

ផ្កាក្រហមសឿងខៀវស្វាយ ផ្ការីកសប្បាយនឹងធម្មជាតិ ។

- ពិរោះមែនៗ ! សុខា! អូនច្រៀងពិរោះអស្ចារ្យតែម្តង ។

ឈូកនិយាយផងទះដៃផង ។ សុខាឮដូច្នោះក៏មានអំនួតភ្លាម :

- បទនេះពិសេសណាស់បង ! មិនដែលមានចាក់តាមវិទ្យុទេ ព្រោះអីជាបទដែល បងជាតិនិពន្ធអោយខ្ញុំច្រៀងលេងតែប៉ុណ្ណោះ ។

- អូហូហ៎ បងជាតិចេះនិពន្ធបទចំរៀងដែរហ៎?

- មិនត្រឹមតែចេះតែង ប៉ុណ្ណោះទេ គឺថែមទាំងចេះច្រៀងពិរោះទៀតផង ទាស់តែ បងជាតិជាអ្នកស្រុកជនបទ មិនមានទំនាក់ទំនងជាមួយអ្នកទីក្រុង ទើបបងជាតិ គ្មានឱកាសបញ្ចេញស្នាដៃរបស់គាត់នោះអី ។

អ្នកទាំងពីរនិយាយបណ្តើរបេះផ្កាព្រលិតបណ្តើរ ។ មួយសន្ទុះមក សុខាក៏ដើរ លើភ្លឺស្រែហើយហក់ប្រូងទៅក្នុងប្រឡាយតាមដងភ្លឺក្បែរនោះ :

- សុខា! អូនធ្វើអ្វីហ្នឹង?

- បេះម្អមណាំបង ! មើលនែក! ក្រអូបឈ្ងុយ បើបេះយកទៅស្លម្ជូរព្រលិតពិតជា ឆ្ងាញ់លេខមួយហើយ ។

ទាំងពីរនាក់បេះផ្កាព្រលិតផង បាចទឹកប្រលែងគ្នាផងយ៉ាងសប្បាយ ។ មួយ សន្ទុះក្រោយមក គេក៏ត្រលប់មកផ្ទះវិញស្រាប់តែឃើញសុជាតិអង្គុយវេញព្រាល ។ សុខានឹកឆ្ងល់ក៏សួរឡើង :

- បងជាតិ ធ្វើអីហ្នឹង?

- បងគិតថាក្រងអង្រឹងកូនងាមួយណាំអូន!( សុជាតិឆ្លើយ )

- ស្លាប់ហើយ! ផ្ទះយើងអត់មានកូនង៉ាផង បងក្រងធ្វើអ្វី?

សុជាតិឮដូច្នោះ ក៏ឆ្លើយបន្ទប់វិញ :

- សុខា! អូនប្រញាប់ទៅដាំបាយទៅ! បងឃ្លានហើយណាំ!

សុជាតិនិយាយផង លួចដៀងភ្នែកសំលឹងទៅឈូកផង ។ ឈូកក៏សំលឹងមក នាយវិញ ដោយក្រសែភ្នែកភ្ញាក់ផ្អើល ហើយនឹកក្នុងចិត្តថា :

- ហេតុអ្វីក៏បងសុជាតិដឹងថាខ្ញុំកំពុងមានគភ៌ ? ឬក៏គ្រូពេទ្យនិយាយប្រាប់គាត់?

ពេលឈូកកំពុងល្ងោកគិតស្លុងស្មារតី ស្រាប់តែសុជាតិដើរមកជិតហើយ ពោលទៅកាន់នាងដោយវាចាយ៉ាងស្រទន់ថា :

- ឈូកឈប់ព្រួយចិត្តអ្វីតទៅទៀតទៅណាំ! ចាប់ពីថ្ងៃនេះទៅ បងសន្យាថានឹង រក្សាអូនឱ្យមានសេចក្តីសុខក្នុងជីវិតជានិច្ច!

ឈូកងើបមុខសំលឹងសុជាតិដោយដួងចិត្តរំភើបយ៉ាងខ្លាំង :

- ឈូក... ពិតជាមិនដឹងបានអ្វីមកតបស្នងទឹកចិត្តដ៏ល្អរបស់បងវិញទេ...

សុជាតិយកដៃទប់មាត់នាងមិនអោយស្តីដូច្នោះ ហើយក៏ពោលបន្ទប់ថា :

- ថ្ងៃនេះមានសម្លអ្វីប្លែកអោយបងញុំាទេហ៏? បងចង់ភ្លក្សស្នាដៃរបស់ឈូកណាំ!

CHANBOKEO.COM

- ចាស១ ចាំខ្ញុំទៅដណ្ដាំជូនបងឥលូវនេះ ។

ថាហើយនាងក៏រត់ចូលចង្ក្រានបានភ្លាម ទុកអោយសុជាតិមើលតាមពីក្រោយ
ទាំងទឹកមុខព្រួយផង សប្បាយផង ច្របូកច្របល់គ្នា ។ រំពេចនោះមីងសោមហៅ សុជាតិអោយទៅជិតគាត់ ហើយក៏ឈ្ងោកខ្សិបសួរនាយថា :

- អាងាអើយ! នាងឈូកវាមានផ្ទៃពោះ មែនទេហ៎កូន?

- បាទ!... ហើយម៉េចក៏ម៉ែជ្រាប... ?

- គឺម៉ែធ្លាប់ពពោះដែរនោះអី ។ អ៊ើនែហ៏! ជាតិកូន! ឯងឆ្លើយប្រាប់ម៉ែអោយត្រង់ មកមើល៍ ថាតើនាងឈូកជាប្រពន្ធឯងពិតមែនឬក៏មិនមែន...?

- បាទម៉ែ..! គឺថា.... គឺ...

សុជាតិឆ្លើយតតាក់តតុបត្បិតមិនដឹងថាត្រូវឆ្លើយយ៉ាងណាឱ្យសម ។ ភ្លាម នោះ មីងសោមពោលបន្តថា :

- កូនអើយ! គ្នាជាស្រី មានតែការខូចខាតប៉ុណ្ណោះណាំកូន មើលចុះ! គ្នាមានពោះ មានពុងផង.... ឯងជួយមើល៍១ផងទៅណាំកូន! អាណិតគ្នា!!

សុជាតិឈ្ងោកមុខព្រោះមិនដឹងថាត្រូវជំរាបម្ដាយយ៉ាងម៉េចអោយគាត់ជឿ ។ នាយក៏ពោលទៅកាន់ម្ដាយវិញថា :

- កូនម៉ែជាមនុស្សល្អដូចដែលម៉ែធ្លាប់ប្រដៅ បើម៉ែយល់ថាផ្លូវជីវិតណាមួយប្រពៃ សំរាប់កូន កូននឹងគោរពតាមការណែនាំរបស់ម៉ែជានិច្ច ។

នាយក៏ក្រាបសំពះម្ដាយហើយក៏អង្គុយស្ងៀមស្ងាត់ទៅវិញ ។ មីងសោមឃើញ កូននៅស្ងៀម ក៏មានប្រសាសន៍បន្ត :

- ឬកូនឯងនៅអាលោះអាល័យស្រីនីម បានជាឯងមិនហ៊ានសំរេចចិត្តទទួលយក ឈូកជាប្រពន្ធពេញលក្ខណៈ? ទោះបីយ៉ាងណា កូនអើយ! ជួញជិតប្រសើរជាជាង ជួញឆ្ងាយដែរ ។ មើលទៅ ទូកជីវិតរបស់នីមកំពុងតែលាចាកកំពង់របស់ឯងហើយ! ឯងកុំទៅគេងគិតស្រម័យពីគេទៀតអី ណាមួយគេជាកូនថៅកែម៉ាស៊ីនស្រូវ មិនដឹង ថាតើឪពុកម្ដាយរបស់គេ នឹងព្រមទំលាក់ខ្លួន មកទទួលយកអ្នកក្រដូចឯងជាកូន ប្រសារដែរឬទេ? ជាពិសេស បើពេលនេះគេដឹងថា ឯងមានលាក់នារីម្នាក់នៅក្នុង ផ្ទះ ហើយកំពុងពផ្ទៃទៀតផងនោះ តើគេនឹងគិតយ៉ាងណាវិញទៅកូន?

សុជាតិមិននិយាយស្ដីអ្វីទៀតទេ ព្រោះម្នាក់១សុទ្ធតែមានហេតុផលក្នុងជីវិត រៀង១ខ្លួន ។ ម្យ៉ាងទៀត នាយក៏មិនគិតស្ដាយក្រោយដែរ ដែលបានជួយសង្គ្រោះ ឈូកអោយរួចជីវិតមកនេះ ត្បិតក្នុងក្រសែភ្នែករបស់នាយ ឈូកជានារីមួយរូប ដែលគួរអោយអាណិតអាសូរបំផុត ។ មីងសោមក៏ពោលបន្តទៅទៀតថា :

- មើលទៅនាងឈូកក៏ជាស្រីដែលគ្មានពិសពុលអីដែរ ។ តាំងពីនាងមកជ្រកនៅ ក្នុងផ្ទះយើងមក៏ម៉ែឃើញនាងខិតខំសំរបសំរួលតាមការរស់នៅរបស់យើងដោយ មិនរអ៊ូរទាំអីម៉ាម៉ាត់សោះ ជាពិសេសឈូកវាស្លូតបូតផង ហើយក៏ស្រលាញ់គ្នាជា មួយសុខាណាស់ មើលចុះ! គេត្រូវរ៉ាគ្នាចាក់ទឹកមិនលេចទេ ។ ចំពោះម៉ែវិញ បើកូន ព្រមទទួលយកនាងជាប្រពន្ធពេញមុខ ម៉ែក៏មិនថាអីដែរណាំកូន ។

សុជាតិរវើ្ភកសំលឹងទៅឈូក ដែលកំពុងលាងឆ្នាំងដណ្ដាំស្ល ។ មែនហើយ! ពិតមែនតែនាងធ្វើកិច្ចការអ្វី១ក្នុងផ្ទះរបស់នាយហាក់ដូចជាឆ្គង១បន្តិច តែនាងក៏ នៅតែប្រឹងធ្វើ មិនដែលរអ៊ូ មិនដែលត្អូញ ឬបញ្ចេញអាកប្បកិរិយាណាដែលថា នាងមិនពេញចិត្តនោះទេ ឃើញតែធ្វើអោយតគ្រុក ខុសផងត្រូវផងតែអញ្ចឹងទៅ ។ ការពិតនាយក៏លួចមានគំនួចចិត្តប្រតិពទ្ធ័ទៅលើឈូកតាំងពីថ្ងៃដំបូងដែលនាយបាន ប្រទាក់ខ្សែភ្នែកជាមួយនាងលើកទីមួយម្ល៉េះ ។ ម្យ៉ាងទៀត នៅគ្រាណាដែលនាយ បានឃើញមុខនាងម្ដង១ បេះដូងរបស់នាយរំភើបសប្បាយហើយញាប់ញ័រប្លែក ខុសធម្មតា ផ្ទុយពីពេលដែលនាយនៅជាមួយនីម ដែលនាយមានត្រឹមតែអារម្មណ៍ ជាមិត្តជិតដិតប៉ុណ្ណោះ

CHANBOKEO.COM

មិនរំភើបញាប់ញ័រដូចអារម្មណ៍ដែលនាយមានចំពោះមាណវី ចំលែកមួយរូបនេះឡើយ ខុសតែម្យ៉ាងទេដែលនាយមិនច្បាស់លាស់ក្នុងចិត្ត នោះគឺសុជាតិមិនដែលបានដឹងពីប្រវត្តិរបស់នាងអ្វីសោះ ថាតើនាងជាអ្នកណា?

ថ្ងៃខែចេះតែកន្លងទៅ...

ឈូកបានសុំសុជាតិចិញ្ចឹមមាន់ចិញ្ចឹមជ្រូកគ្រាន់ជាជំនួយថវិកាបន្ថែម ដោយ ហេតុថាមីងសោមមានចំការចេកស្រាប់គ្រាន់តែចំណាយប្រាក់ទិញកន្ទក់ប៉ុណ្ណោះ ។ រាល់ថ្ងៃ ឈូកនិងសុខាជួយគ្នាហាន់ដើមចេកបុកលាយកន្ទក់អោយបាយជ្រូក ហើយទទាក់ស្រូវទុកអោយមាន់រាល់ថ្ងៃ ។ ជីវភាពអ្នកផ្ទះរបស់សុជាតិក៏ផ្លាស់ប្តូរវិវត្តន៍ បន្តិចដែរ ដោយគេម្នាក់ៗខំប្រឹងធ្វើការរកស៊ីតតទំនេរ ។ យូរៗម្តងឈូកតែងបេះ ផ្លែឈើពីចំការយកទៅលក់គ្រាន់នឹងបានកំរៃជួយទប់សោហ៊ុយក្នុងផ្ទះខ្លះ ណាខ្លាចចិត្តម្ចាស់ផ្ទះដែលគេមានសន្តានចិត្តមកលើនាងយ៉ាងល្អប្រពៃ ណាចង់សន្សំដើម្បី ពេលសំរាលកូនខាងមុខនេះផង ។ ទោះជាយ៉ាងណាក៏ដោយ ក៏ឈូកមានអារម្មណ៍

ថាពេលនេះជីវិតរបស់នាងមានសេចក្តីសុខណាស់ ទោះបីជានឿយលំបាកបន្តិចក្តី ។

នៅរាត្រីមួយ....

ម្នាក់ៗចូលនិទ្រារអស់ហើយ ប្លែកអីតែឈូកមួយដែលនៅរសាប់រសល់ចំលែកខុសធម្មតា ។ នាងក៏ក្រោកលាត់មុងដើរចេញទៅក្រៅហើយដាក់ខ្លួនអង្គុយនៅមាត់ ជណ្តើរផ្ទះតែម្នាក់ឯង ។ ពូជអាកាសដ៏ខ្ពស់ល្វឹងល្វើយព្រះចន្ទមួយចំណិតខំប្រឹងអើត បញ្ចេញរង្សីមកលើពសុធា ហាក់ដូចជាប្រាថ្នាលួងលោមដួងចិត្តកង្វល់របស់ឈូកឱ្យ បានស្បើយរសាយទៅ ។ រំពេចនោះ នាងចាប់ភ្លឹកថាមានសំរឹបដើរចូលមកជិត ។ ធិតាងាកបែរក្រោយ ស្រាប់តែឃើញសុជាតិដើរមកដល់ហើយដាក់ខ្លួនអង្គុយចុះក្បែរនាងថែមទាំងពោលថា :

- ឈូក! អូនមានកង្វល់អ្វីហ្នឹស? តើអូនអាចនិយាយប្រាប់បងបានទេហ៎?

ឈូកឈ្ងោកមុខ មួយស្របក់ទើបឆ្លើយថា :

- គឺខ្ញុំខ្លាចរអារជីវិតទីក្រុងណាស់បង! ជីវិតច្របូកច្របល់នៅទីក្រុងបាននាំអោយ រូបខ្ញុំធ្លាក់រណ្តៅអប្បលក្ខណ៏... រហូតមកទល់ពេលនេះខ្ញុំនៅមិនទាន់សំរួល

ចិត្ត បាននៅឡើយទេ ។

- គិតទៅជីវិតនៅភ្នំពេញច្របូកច្របល់ពិតមែនហ្អែស ឈូក?

ឈូកបើកភ្នែកមូលក្រលង់សំលឹងមុខសុជាតិ :

- ម្តេចក៏បងដឹងថាអូនជាអ្នកភ្នំពេញ? បងដឹងពីណាមក៏?

សុជាតិសើចញញឹមតបថា :

-គ្រាន់តែឮសំដីរបស់អូននិយាយ បងក៏ដឹងស្រេចទៅហើយ! អ្នកភ្នំពេញគេនិយាយ

កាច់តុងឡូយណាស់ មិនដូចអ្នកបាត់ដំបងដែលនិយាយតាមតួអក្សរខ្មែរត្រង់ៗនោះ ទេ ។

ជួនកាលអូនមាននិយាយលាយភាសាបរទេសដាក់បងទៀតផង ធ្វើអោយ បងវង្វេងអោយញយ ត្បិតមិនដឹងថាមានន័យយ៉ាងម៉េចសោះ ។

ឈូកឮសុជាតិនិយាយកំប្លែងដូច្នោះ ក៏លាន់មាត់សើចតាមដែរ :

- ចេះតែថាហើយ... ខ្ញុំឯណាដែលនិយាយភាសាបរទេសដាក់បងនោះ?

CHANBOKEO.COM

- ម៉េចក៏ថាមិនដែល? ជួនកាលអូននិយាយដាក់សុខា រហូតដល់សុខាលួចមកសួរ អោយបងជួយបកប្រែអោយទៀតផង ។ ម្យ៉ាងទៀត បងក៏ធ្លាប់លួចសង្កេតមើល អូនបង្រៀនសុខា ឃើញអូនមានកិរិយានិងការចេះដឹងខ្ពង់ខ្ពស់ណាស់ ។

- ព្រះអើយ!បងធ្លាប់ធ្វើអ្នកស៊ើបអង្កេតតាំងពីអង្កាល់ហ្នឹង? (ធិតាសួរលេងបន្ទប់)

- តាំងពីឃើញមុខអូនថ្ងៃដំបូងមកម្ល៉េះ.... មិនដឹងខ្លួនទេហ៏?

ពូដូច្នោះ ឈូកក៏ញញឹម ហើយសួរវិញថា :

- ហើយចុះបងវិញ រៀនដល់ណាដែរ?

- ប្រលងឌីប្លូមធ្លាក់ ក៏ឈប់រៀនទៅ ។ កាលណោះបងស្នាក់នៅវត្តហើយទៅរៀន នៅសាលា មិនបានទៅមើលក្រុមគ្រួសារអោយជិតដល់ទេ ។ ក្រោយពីឪពុកបង អនិច្ចកម្មទៅ បងក៏សំរេចចិត្តវិលមកភូមិវិញ ត្បិតគ្មានអ្នកណានៅមើលថែរក្សាម៉ែ និងសុខា ។

- គ្រួសារបងពិតជាគួរអោយអាណិតណាស់!

- តែពេលនេះ គ្រួសាររបស់យើងឈប់ក្រទៀតហើយណា៎!

- ម៉េចអញ្ចឹង?

- ព្រោះបន្តិចទៀត អូនឈូកឡើងបុណ្យជាថៅកែជ្រូកថៅកែមាន់ នៅម្តុំភូមិត្រាង អូរតាគី អូរតាកែ ស្រែបារាំង ព្រៃទទឹង សោមនស្ស វត្តឯកភ្នំ នរណាមិនស្គាល់ ថៅកែសុជាតិ អូហ៏ច្រលំមាត់! មិនមែនទេ! សុំនិយាយម្តងទៀតថា នរណាមួយមិន ស្គាល់អ៊ីឈូកថៅកែជ្រូក...? អ៊ូយ! ឈ្មោះជូនគ្នាពិរោះណាស់...

សុជាតិសើចខឹកៗលលេងជាមួយឈូក ។ ធិតាពូហើយចង់សើចផង ខ្មាញ់ផង ដែលសុជាតិនិយាយចំអន់កំប្លែងដាក់នាង ក៏លួចក្តិចកំភួនដៃសុជាតិ:

- តែផ្តាស...! យ៉ាប់មែន បងជាតិនេះ!

- មិនយ៉ាប់ទេ! បងនិយាយតាមការពិតតើហ៏ ។

- អញ្ចឹង ឈូកសាធុទទួលយកទៅចុះណា៎!

ទោះជាយ៉ាងណា ឈូកក៏ទប់សំណើចមិនបានដែរ ។ នាងក៏សើចតាមសុជាតិ ព្រមគ្នាឡើងដែរ ធ្វើអោយនាងរសាយអស់នូវទុក្ខអំពល់ក្នុងចិត្តទាំងអំបាលម៉ាន ។ អ្នកទាំងពីរនៅអង្គុយសាសងគ្នាសើចរអឹក ក្រោមផ្ទៃមេឃដ៏រមនានៃរដូវវស្សា មើលទៅហាក់បីដូចជាបក្សីបក្សាមួយគូដែលកំពុងទទួលនូវសុភមង្គលមួយ យ៉ាង សែនសុខក្សេមក្សាន្ត ។ មួយស្របក់ក្រោយមក សុជាតិក៏មានវាចាទៅកាន់មាណវី យើងបន្តទៅទៀតថា :

- ឈូក! បើបងសួរអូនរឿងមួយ អូនឆ្លើយប្រាប់បងទេហ៏?

ឈូកពូដូច្នោះ នាងហាក់ដូចជារន្ធត់ញាប់ញ័រយ៉ាងណាមិនដឹងទេ ។ នាងក៏នៅ ស្ងៀមត្បិតមិនដឹងថាត្រូវឆ្លើយវិញយ៉ាងណា ក៏ស៊ូឈ្ងោកមុខចាំស្តាប់ ។ សុជាតិក៏ សួរបន្ថែមថា :

- អូនបានមករស់នៅជាមួយបងនិងក្រុមគ្រួសារយូរខែយូរថ្ងៃហើយ តើអូនគិតថា អូនអាចទុកចិត្តបងខ្លះហើយឬនៅ?

ឈូកងើបមើលមុខសុជាតិសំដែងការជឿជាក់ :

CHANBOKEO.COM

- ម៉ែចក៏បងសួរដូច្នោះ? បងនិងម៉ែជាមនុស្សដែលខ្ញុំទុកចិត្តបំផុតក្នុងជីវិត!

- បើដូច្នោះ... អូនអាចប្រាប់បងបានទេ ថាអូនមានក្រុមគ្រួសារនៅឯណាដែរ? តើ ហេតុដូចម្ដេចបានជាអូនមិនដែលរំលឹកពីគេសោះអញ្ចឹង?

ឈូកដកដង្ហើមធំឃ្ងូ ឈ្ងោកមុខហើយតបវិញដោយវាចាខ្សិបៗថា :

- អតីតកាលរបស់ឈូកគួរអោយស្អប់ខ្ពើមណាស់ ឈូកមិនចង់រំលឹកវាទេ.. ការពិត បើសិនជាបងបានដឹងនូវរឿងពិត ប្រហែលបងប្រែជាស្អប់អូនដែរក៏មិនដឹង...

សុជាតិឮនាងពោលដូច្នោះ ក៏លូកស្រវាចាប់ដៃឈូកក្ដាប់យ៉ាងណែន រួច សំលឹងមុខនាង ដោយក្រសែភ្នែកភ្លឺថ្លាស្រទន់ ប្រកបដោយក្ដីអាណិត :

- ខុសហើយអូន! មិនថាឈូកមានអតិតកាលយ៉ាងណាទេ តែបច្ចុប្បន្ននេះអូនគឺជា នារីដ៏ល្អម្នាក់ក្នុងក្រសែភ្នែករបស់បង ហើយបងក៏អាចទទួលស្គាល់នូវអតីតកាល របស់អូនជានិច្ច មិនថាអាក្រក់ឬល្អទេ អោយតែអូននិយាយប្រាប់នូវការពិត ចំពោះបងកុំលាក់លៀម....

- បងជាតិ... និយាយពិតមែនហ្អែស? ( ឈូកសួរ )

សុជាតិងក់ក្បាល :

- បាទ! ដោយមានព្រះពុទ្ធជាសាក្សីផង! តើអូនជឿចិត្តបងទេហ៏?

- ប៉ុន្តែ.... រឿងរបស់អូនវែងឆ្ងាយ ហើយកំសត់អណោចអធម្មណាស់  ពេលនេះ ឈូកកំពុងតែសប្បាយចិត្ត ចង់ស្ដាប់បងច្រៀងជាជាង ។

- បើអញ្ចឹង បើបងច្រៀងអោយអូនស្ដាប់ហើយ តើអូននិយាយរឿងអូនអោយ បងស្ដាប់វិញទេ?

- ចាស! អូនសន្យា... ថានឹងជំរាបការពិតទាំងឡាយដែលទាក់ទងនឹងរូបឈូកជូន បង អោយបានដឹងមុនគេបង្អស់....

សុជាតិឮដូច្នោះក៏ញញឹមយ៉ាងស្រស់បំព្រងឡើង រួចក៏ស្រវាឈូកអោយផ្អែក កេសាកើយលើស្មារបស់ខ្លួន ទើបចាប់ខ្លុយមកផ្លុំនូវសូរសៀងយ៉ាងគ្រលួចគួចដួង ចិត្តមួយ ក្រោមជំនោរវាតារសៀកៗគួរអោយភិសម័យក្រៃលែង ។  ពេលនេះ ឈូកយើងមានអារម្មណ៍ថា ជីវិតរបស់នាងនាបច្ចុប្បន្ននេះមានន័យគួរអោយចង់ រស់នៅណាស់ ជាពិសេស កាលបើនាងបានរស់នៅក្បែរបុរសមួយរូបដែលយល់ចិត្ត នាង ស្គាល់ទុក្ខធុរៈ ហើយតែងតែជួយរំលែកនូវវិបត្តិទាំងឡាយអោយនាងបានធូរ ស្រាលក្នុងចិត្តឡើងវិញរាល់ដងជានិច្ច ។

### រាត្រីស្នេហ៍

| | | | |
|---|---|---|---|
| ស. | រាត្រីនេះ | មេឃស្រឡះ | ចន្ទ័ភ្លឺថ្លា |
| | សៀងវាតា | ផ្ទមកាយា | សែនមនោរម្យ |
| | សូរចម្រៀង | ហាក់សៀងទិព្វ | លោមអារម្មណ៍ |
| | សែនរណ្ដំ | អោយចិត្តមុំ | រំភើបក្រៃ ។ |
| ប. | ឱ! មាសស្នេហ៍ | អូនឃើញទេ | ផ្កាយភ្លឺផ្លេក |
| | រះពេញមេឃ | គួរអោយត្រេក | សប្បាយចៃ |
| | រីដួងចន្ទ័ | មានឆពណ្ណ៍ | យ៉ាងប្រិមប្រិយ |
| | ហាក់ភក្ត្រ័ស្រី | កល្យាណី | ស្នេហាបង ។ |
| ស. | រាត្រីស្នេហ៍ | ច្រៀងបំពេរ | គូទ្វេហា |
| ប. | ក្នុងហត្ថា | ប្រុសរៀមរ៉ា | បីត្រកង |

CHANBOKEO.COM

| | | | |
|---|---|---|---|
| ប.ស. | ស្នេហាមួយ | លែងស្គាល់ព្រួយ | ទុក្ខសៅហ្មង |
| | អូននិងបង | ជាគូគ្រង | លុះក្ស័យអើយ។ |

ច្រើនខែកន្លងទៅ...

ផ្ទៃពោះរបស់ឈូកកាន់តែរីកចំរីនជាលំដាប់ ។ រាល់ថ្ងៃ ម្នាក់ៗក្នុងគ្រួសារ សុជាតិតែងតែនាំគ្នាភ្នាល់ថាជាកូនស្រី ឬជាកូនប្រុស ។ មកទល់ពេលអីលូវ ឈូក បានរស់នៅយ៉ាងមានសេចក្ដីសុខបំផុត ក្នុងរង្វង់គ្រួសារសុជាតិដែលមានជីវភាព ធម្មតាៗ មិនសំបូរទេ តែក៏សុជាតិផ្គត់ផ្គង់មិនអោយខ្វះអ្វីដែរ ។ ចំណែកមីងសោម វិញក៏ទទួលអោយឈូកហៅគាត់ថាម៉ែៗពេញមាត់ដោយឥតមានស្ទប់ខ្ពើម។

ថ្ងៃនេះ សុជាតិត្រលប់មកពីរត់ឡានឈ្នួល តាំងពីថ្ងៃត្រង់ ត្បិតនឹកថាចង់នាំឈូកទៅពេទ្យពិនិត្យផ្ទៃពោះ ព្រោះជិតដល់ថ្ងៃសំរាលហើយ ។ លុះនាយចាក់កង់ ត្រលប់ពីអូរតាគីមកដល់ផ្ទះវិញ ក៏ប្រទះឃើញឈូកកំពុងបង្រៀនអក្សរដល់សុខា ក៏ទុចង់ក់ នឹកដូរចិត្តចង់នៅអង្គុយមើលអ្នកគ្រូស្រស់ក្មេងបង្រៀនប្អូនវិញ។ តាមពិត រៀងរាល់ពេលដែលទំនេរ ឈូកតែងនាំសុខាអោយរៀនអាន រៀនសរសេរ និងរៀន គិតលេខ ជាពិសេស គឺរៀនសរសេរចងក្រងនូវចំរៀងទាំងឡាយដែលនាងចេះច្រៀងទាំងអស់នោះទុកជាសំណៅ ទីមួយជាប្រយោជន៍នៃការហ្វឹកហ្វឺនអក្សរ សាស្ត្រផង ទីពីរសុខាអាចរក្សានូវទំនុកចំរៀងទាំងឡាយនោះជានិច្ចតទៅផង ។ កាលបើឃើញបងប្រុសជិះកង់មកដល់ ហើយយកទៅចតនៅក្រោមដើមអំពិលទឹក សុខាក៏ស្រែកវ៉ាងឡើង :

- មើលនែ៎កបងជាតិ! បងឈូកតែងចំរៀងអោយសុខាច្រៀងយ៉ាងពិរោះតែម្ដង !

សុខាថាផង លើកយកសៀវភៅយកទៅបង្ហាញបងប្រុសរបស់ខ្លួនផង ។

- មើលឯណា? បងសុំមើលបន្តិច! (សុជាតិតបវិញ)

ឈូកនៅអង្គុយញញឹមស្ងៀមស្ងាត់មិនហ៊ានមាត់ទេ ព្រោះមិនដឹងថា សុជាតិ មានអារម្មណ៍យ៉ាងណាចំពោះចំរៀងមួយបទនោះ ។ សុជាតិចោលកន្ទុយភ្នែកទៅ មើលឈូក លួចញញឹមដាក់នាង ហើយក៏បែរមកទទួលយកសៀវភៅពីសុខាមកអាន :

ចំរៀងគ្រួសារយើង

| | | |
|---|---|---|
| ១. | ចំរៀងយើងច្រៀងដោយដួងចិត្ត | និមិត្តមង្គលក្នុងចិន្តា |
| | បន្ទរសំនៀងច្រៀងរួមគ្នា | រៀងរាល់សន្ធិយាសប្បាយក្រៃ ។ |
| ២. | មួយបទដំបូងច្រៀងជូនម៉ែ | គ្រួសារស្រុកស្រែរស់ក្រក្រី |
| | ប្រគំដោយសៀងកូនទាំងបី | សូមជូនពរជ័យអ្នកមានគុណ ។ |
| ៣. | ចំរៀងទីពីរជូនទៅបង | ដែលគ្រប់គ្រងប្អូនដោយចិត្តបុណ្យ |
| | មួយបទជូនបងខំ រែកពុន | គុណអ្នកសែនធ្ងន់វាស់មិនបាន ។ |
| ៤. | ចំរៀងយើងច្រៀងទាំងអស់គ្នា | រាល់ពេលសន្ធិយាទាំងប្អូនប្រាណ |
| | ចំរៀងមង្គលសុខក្សេមក្សាន្ត | លុះថ្ងៃអវសានគ្មានប្រែឡើយ.... |

ភ្លាមនោះ សូរសៀងគ្រហឹមតិចៗរងំៗ ចេញពីក្រអូបមាត់របស់សុជាតិ ។ សុខាឮហើយក៏បន្ទរឡើងយ៉ាងគ្រលួច។ ឮចំរៀងនោះកាលណា មីងសោមក៏ដើរ ចេញមកអង្គុយស្ដាប់នៅមាត់ជណ្ដើរផ្ទះ ធ្វើទឹកមុខញញឹមរីករាយហាក់ពេញចិត្តនឹង បទចំរៀងនេះណាស់ ។

CHANBOKEO.COM

លុះឃើញអ្នកទាំងពីរច្រៀងព្រមគ្នាយ៉ាងសប្បាយ ឈូកក៏ ទះដៃជាចង្វាក់បន្ទរឡើងដែរ ធ្វើឱ្យចំរៀងមួយបទនោះក៏ក្លាយជាទឹកអម្រឹតផ្តិតនូវសេចក្តីសុខសុភមង្គលដ៏ត្រចះត្រចង់មួយ ដល់ក្រុមគ្រួសារសុជាតិយ៉ាងរមនា។

កំពុងតែច្រៀងសប្បាយ ស្រាប់តែអ្នកទាំងបួនបានឮសូរសំលេងភ្លេងការលាន់ល្វើយៗ ឆ្លងឆ្លើយមកពីទិសខាងកើត។ មីងសោមក៏លាន់មាត់ឡើង :

- ថ្ងៃនេះ អ្នកណាគេរៀបការកូនចៅទៅហ្ន៎? សំលេងភ្លេងនេះ ហាក់ដូចជាឮមកពី ម្តុំក្បែរវត្តត្រាងហើយ ។

គ្រាន់តែឮម្តាយវាចាដូច្នោះ សុជាតិក៏ធ្លាក់ទឹកមុខហើយស្រវាចាប់កង់ឡើងជិះ ចេញទៅបាត់។ ឈូកនឹងសុខាមើលមុខគ្នាឡឹងឡង់។ តើសុជាតិគេទៅណាហ្ន៎? មួយស្របក់មក សុជាតិក៏មកដល់ផ្ទះវិញទាំងទឹកមុខក្រៀមស្រពោន។ នាយ មិននិយាយស្តីអ្វីទេ គ្រាន់តែបោះកង់ចោលហើយ ក៏ដើរចូលទៅចំការចេកខាង ក្រោយផ្ទះទៀតទៅ។ ទាំងបីនាក់ហាក់យល់ពីហេតុការណ៍ ក៏នាំគ្នាអង្គុយស្ងាត់មាត់ឈឹង។ បន្តិចក្រោយមក ឈូកក៏ងើបដើរទៅតាមលបមើល ឃើញសុជាតិនៅអង្គុយលើក្តារស្ពានសំយុងជើងក្នុងទឹកជត្រពាំងព្រលិតតែម្នាក់ឯង សំដៅងទឹកមុខ ស្រពាប់ស្រពោន។ ឈូកមិនហ៊ានទៅជិតទេព្រោះខ្លាចនាយត្រូវការនៅម្នាក់ឯង តែនាងក៏មិនហ៊ានដើរចោលមាណពដែរ ក៏សុខចិត្តនៅឈរស្ងៀម សំលឹងមើលនាយពីចំងាយ។ មួយសន្ទុះក្រោយមកនាងក៏ដាច់ចិត្តដើរទៅជិតសុជាតិហើយស្រដីថា:

- បងជាតិ!.... អោយឈូកសុំនៅអង្គុយជាមួយបងផងបានទេហ៏?

សុជាតិងាកមកឃើញមាណវីភ្លាម ក៏ប្តូរទឹកមុខ ហើយរំកិលងាកខ្លួនទុកកន្លែងឱ្យឈូកអង្គុយក្បែរ ។ លុះដាក់ខ្លួនអង្គុយចុះក្បែរសុជាតិហើយ ឈូកក៏សួរថា :

- ថ្ងៃនេះ នីមគេរៀបការមែនទេហ៏?

សុជាតិភ្ញាក់ក្រញាង :

- ម៉េចក៏អូនដឹង? មានគេប្រាប់អូនមែនទេហ៏?

- អត់ទេ! គឺទឹកមុខរបស់បងតើហ៏ ដែលនិយាយប្រាប់...

សុជាតិឈ្ងោកមុខវិញ។ ឈូកក៏ពោលបន្តថា :

- ឈូកមិនដឹងថាត្រូវសូមទោសបងយ៉ាងណាទេ ដែលធ្វើអោយជីវិតស្នេហារបស់ បងផ្លាស់ប្តូរ... ទៅជាបែបនេះ ....

សុជាតិឮដូច្នោះ ក៏ស្រវាដៃឈូកទៅកាន់ ហើយឆ្លើយថា:

- នេះមិនមែនជាកំហុសអូនទេ ឈូក! ការពិត បងគ្រាន់តែនឹកស្តាយដែលយើង ធ្លាប់ស្គាល់គ្នារាប់ឆ្នាំស្រាប់តែបែកគ្នាទៅដោយមិនបានលាគ្នាអីមួយម៉ាត់!

ឮដូច្នោះ ឈូកគិតតែក្នុងចិត្តម្នាក់ឯងថា :

- បងជាតិអើយ! ប្រហែលនីមគេលាបងនៅក្នុងដួងចិត្តរបស់គេរួចទៅហើយទេដឹង ទើបគេដាច់ចិត្តរៀបការចោលបងយ៉ាងនេះ?

ឈូកនៅស្ងៀមមួយស្របក់ ក៏បន្លឺវាចាតទៅទៀតថា :

- បងជាតិចាំបានទេហ៏ នូវពាក្យមួយឃ្លាដែលបងតែងតែរំលឹកប្រាប់ឈូក?

សុជាតិបែរមើលមកឈូកវិញ ធ្វើទឹកមុខងឿងឆ្ងល់ ហាក់ដូចជាកំពុងរង់ចាំស្តាប់ពាក្យនាងបរិយាយឱ្យនាយខ្លាំងណាស់ :

CHANBOKEO.COM

- តើបងបាននិយាយអ្វីប្រាប់ឈូកខ្លះទៅ?

- គឺបងធ្លាប់ប្រាប់ឈូកថា ទោះបីជាថ្ងៃនេះ ជីវិតរបស់យើងត្រូវជួបប្រទះនឹងព្យុះភ្លៀងខ្លះៗក៏ដោយ តែកុំឡើយបោះបង់ក្ដីសង្ឃឹមរបស់យើងនោះចោលអោយ សោះ ព្រោះត្បិតនៅថ្ងៃស្អែក ព្រះអាទិត្យកំពុងត្រៀមខ្លួនរង់ចាំរះបំភ្លឺផ្លូវជីវិតដល់ យើងជានិច្ច ដើម្បីអោយយើងបានបន្តដំណើរតទៅមុខទៀត ទៅស្វែងរកសុភមង្គលនិងជោគជ័យថ្មី សំរាប់ជីវិតថ្មីរបស់យើង....

គ្រាន់តែឮប្រយោគនេះកាលណា ស្រាប់តែសុជាតិក៏ញញឹមពព្រាយភ្លាម ឡើងតែម្ដង។ រីឯភាពស្មុគ្រស្មាញក្នុងចិត្តទាំងអំបាលម៉ានក៏រលាយបាត់អស់រលីង គ្មានសល់។ មាណពក៏វាចាតបទៅកាន់ឈូកវិញថា :

- ឈូក! អរគុណអូនណាស់ដែលមកជួយលើកទឹកចិត្តបងនៅពេលនេះ!

ថាហើយ សុជាតិលើកដៃអង្អែលកេសារបស់ធិតាថ្មមៗ ហាក់ដូចជាកំពុងសំដែងនូវគំនូចប្រតិពទ្ធ័ក្នុងដួងចិត្តរបស់នាយដ៏ធំធេងចំពោះមាណវីយើង។ ពេល នេះ មាណពយើងហាក់ដូចជាភ្លេចភ្លាំងអ្វីៗអស់ហើយ ក្រៅពីការរំភើបចិត្តយ៉ាង ជ្រាលជ្រៅដែលនាយមានឈូកនៅក្បែរខ្លួន ចាំយកចិត្តយកថ្លើមនាយជានិច្ច មិនថា ជាពេលណា វេលាណាទេ។ ក្រោមជំនោរត្រជាក់រំភើយៗនៃអាកាសស្រុកស្រែ និងពន្លឺសុរិយានាពេលរសៀល សុជាតិនិងឈូកអង្គុយញញឹមដាក់គ្នាទៅវិញទៅ មក សំដែងនូវអារម្មណ៍សំងាត់ក្នុងបេះដូង តាមរយៈក្រសែភ្នែកដែលប្រកបទៅ ដោយទឹកដមយ៉ាងផ្អែមល្ហែមបំផុត។ រីឯស្រមោលរបស់នីមវិញក៏ចាប់ផ្ដើម រលប់បាត់ពីដួងចិត្តរបស់សុជាតិបន្តិចម្ដងៗទៅដែរ។

ព្រលប់នៃថ្ងៃដដែល....

ឈូកអង្គុយរៀបស្លឹកថ្នាំហាន់តែម្នាក់ឯង ឯសុខាវិញកំពុងអានសៀវភៅធមិអោយមីងសោមស្ដាប់ ។ សុជាតិក៏ចុះទៅពុះអុសបង្ហើយឯក្រោយផ្ទះ ។ ស្រាប់តែនីមជិះម៉ូតូមកដល់ក្នុងសំល្បែកកូនក្រមុំចូលរោង។ គ្រាន់តែក្រលេកឃើញសុជាតិ នៅក្រោយផ្ទះ នីមក៏ដើរសំដៅទៅរកនាយភ្លាម :

- បងជាតិ!

សុជាតិងើបមុខឡើងឃើញនីមភ្លាម ក៏សំដែងទឹកមុខភ្ញាក់ផ្អើលហាក់ដូចត្រូវភ្លើងអគ្គីសនីឆក់ទាំងរស់ :

- នីម! ហេតុអីក៏អូនមកទីនេះ? ក្រែងថ្ងៃនេះ ជាថ្ងៃចូលរោងមង្គលការរបស់អូនមែនទេហ៎?

- គឺ...នីមមកសូមពាក្យឆ្លើយយ៉ាងស្មោះពីបងគ្រាចុងក្រោយ...

- ពុទ្ធោ! ចំលើយអ្វីទៅនីម?

- គឺ.... នីមចង់ដឹងថាតើបងគិតយ៉ាងណាដែរ ចំពោះនីមនៅពេលនេះ?

នីមសំលឹងមុខសុជាតិដោយដួងចិត្តអាលោះអាល័យ ប៉ុន្តែសុជាតិបែរជាឈរ ទ្រឹង ធ្មើភ្នែកស្ងឹង ហើយគិតក្នុងចិត្តថា :

- នីមអើយ! តើឱ្យបងឆ្លើយយ៉ាងណាវិញ បើថ្ងៃនេះ មេបារបស់អូនកំពុងរង់ចាំរូប អូនអោយទៅក្រាបសំពះលើខ្នើយជ័យទៅហើយនោះ...?

កំពុងតែលង់ក្នុងក្ដីគិត ស្រាប់តែសុខាប្រកួកហៅពីលើផ្ទះមកថា :

- បងជាតិ! បងឈូកឈឺពោះសំរាលកូនហើយ...ឆាប់មក! លឿនឡើង...

ឮដូច្នោះ សុជាតិក៏ស្ទុះរឹងទៅយ៉ាងរហ័សដោយមិនបានស្រដីលានីមមួយម៉ាត់

CHANBOKEO.COM

សោះឡើយ ទុកឱ្យនីមបែរមើលតាមនាយពីក្រោយ ទាំងទឹកភ្នែករលីងរលោង ។

យប់នោះ គ្រប់ៗគ្នាក្នុងគ្រួសារមីងសោម មានសេចក្ដីរីករាយណាស់ដែលគេ បានចូលរួមជាសាក្សីនៃកំណើតរបស់ទារិកាដ៏ស្រស់ស្អាតមួយ ជាពិសេសគឺឈូកតែ ម្ដង ដែលត្រេកអររហូតស្រក់ទឹកភ្នែក។ មីងសោមលូកដៃត្រកងបីចៅស្រីដោយ ក្ដីអាណិតស្រលាញ់ :

- មើល៍...! អោយយាយសុំបីចៅបន្តិចមក៏...

សុខាអង្គុយក្បែរនោះ យកដៃស្ទាបទារក :

- នាងតូចស្រស់ស្អាត គួរអោយស្រលាញ់ណាស់ម៉ែ !

សុជាតិសំលឹងមុខឈូក ហើយសំលឹងមុខទារិកាដោយចិត្តញាប់ញ័រ។ មីង សោមមិនឮកូននិយាយស្ដី ក៏ហៅនាយអោយមកជិតគាត់ :

- ជាតិ! ទៅណាំហើយកូន... ឆាប់មកបីនាងតូចបន្តិចមើល៍! មក់! កូនដំបូងយ៉ាង នេះ យើងត្រូវតែត្រកងបីជូនពររូបគេ នោះទារកតូចនឹងនាំមកនូវលាភដ៏ល្អបំផុត ដល់ជីវិតរបស់យើងណាំ !

- បាទម៉ែ!

សុជាតិក៏រំកិលខ្លួនទៅជិតម្ដាយ ហើយទទួលនាងតូចយកមកបីអោបផ្ទាប់នឹង ទ្រូងរបស់នាយដោយអារម្មណ៍ភ័យអរយ៉ាងណាមិនដឹង។ លុះសុជាតិសំលឹងនាង តូចដែលសំងំនៅក្នុងរង្វង់ដៃរបស់នាយស្ងៀមឈឹង ទំនងហាក់ដូចជានាងបានទទួល ការកក់ក្ដៅពីដើមទ្រូងមាណពយើងយ៉ាងក្សេមក្សាន្ត សុជាតិមានអារម្មណ៍ថាខ្លួន មិនអាចប្រកែកបានទេ ថាមិនទទួលនាងតូចជាកូនរបស់នាយ។

រំពេចនោះ មីងសោមសួរសុជាតិថា:

- អីនែ៎ អាង៉ា ! ឯងមានរកនឹកដាក់ឈ្មោះអោយកូនហើយឬនៅ?

- បាទ! គឺ... ខ្ញុំគិតថា គួរតែឈូកជាអ្នកដាក់អោយនាងទើបសមជាង.....

- ចុះឯងជាឪពុកដែរ ម៉េចក៏មិនគិតរើសយកឈ្មោះមួយមកដាក់ផងហ្នាស?

- ទុកអោយខ្ញុំជាអ្នកដាក់វិញក៏បានដែរ... (សុខាឆ្លើយកាត់) គួរដាក់ឈ្មោះថា ព្រលិត អោយវាសមនឹងម៉ែឈ្មោះឈូក... (សុខាសើចខឹកៗ)

ទាំងអស់គ្នាក៏សើចគិលឡើង កាត់បរិយាកាសដ៏ស្ងៀមស្ងាត់។

- ខ្ញុំគិតថា សុំឈ្មោះចៅស្រីពីម៉ែវិញ តើម៉ែគិតយ៉ាងណាដែរ? (ឈូកស្រដីឡើង)

មីងសោមឮដូច្នោះក៏ញញឹមឡើង :

- អឺ! ម៉ែដាក់អោយក៏បានដែរ... ឪពុកឈ្មោះសុជាតិ ម៉ែឈ្មោះឈូក.. អីយ៉ា! ដូច ពិបាករកឈ្មោះអោយជួនណាស់... អូហ៍មែនហើយ... បើដាក់ថាឈ្មោះសុធា អោយវាជួនទាំងឈ្មោះសុខាដែរនោះ តើកូនទាំងអស់គិតយ៉ាងណាដែរ?

- ពិរោះណាស់ម៉ែ (សុខាឆ្លើយមុនគេព្រមទាំងទះដៃផង)

ឈូកសំលឹងទៅសុជាតិ ទំនងដូចជាចង់ដឹងពីយោបល់របស់នាយ ។ សុជាតិ ឃើញដូច្នោះក៏ឆ្លើយឡើង :

- បាទ! ខ្ញុំយល់ស្របតាមម៉ែ! សុធា មានន័យថា ស្អាតបរិសុទ្ធ ដូចនេះ ពេលណា នាងធំពេញវ័យសុំឱ្យក្លាយជាក្មេងល្អប្រពៃ។

គ្រាន់តែឮពាក្យបរិយាយរបស់សុជាតិធ្វើអោយ ឈូកនឹករំជួលចិត្តអាណិតខ្លួន ឥតឧបមា។ មាណវីក៏លើកដៃសំពះមីងសោមនិងសុជាតិ :

CHANBOKEO.COM

- ឈូកអរគុណម៉ែនិងបងជាតិណាស់!! ជាតិនេះ ជីវិតរបស់ខ្ញុំនិងសុធា សូមផ្ញើជា មួយម៉ែនិងបងជាតិហើយ ។

មីងសោមញញឹមហើយក៏យកដៃរាវរអង្អែលក្បាលឈូក ដែលកំពុងគេងដណ្តប់ភួយ ស្អំទឹកក្តៅ ហើយមានប្រសាសន៍ថា :

- កុំបារម្ភអីកូន! ម៉ែក៏មិនអោយកូនទៅណាមកណាដែរ ។ យើងនឹងរស់នៅជួបជុំ គ្នាដូច្នេះរហូតតទៅ....

សុជាតិបីនាងតូចសុធាទៅដាក់ប្របក្បែរនឹងខ្លួនរបស់ឈូក ហើយឈ្ងោកមុខ បន្ទាបខ្លួនទៅជិតនាង រួចលូកដៃស្តាំទៅចាប់កាន់ដៃឈូកក្តាប់ជាប់យ៉ាងណែនព្រម ទាំងបន្លឺវាចាយ៉ាងស្រទន់ទៅនាងថា :

- ឈូក! បងគិតថា បងចង់បោះជំហានបន្តទៅមុខទៀត ដើម្បីស្វែងរកពន្លឺព្រះ អាទិត្យដែលបំរុងរះនៅពេលថ្ងៃស្អែកសំរាប់បំភ្លឺជីវិតរបស់យើងទាំងពីរនាក់ តើ ឈូកសុខចិត្តដើរទៅព្រមជាមួយគ្នានឹងបងដែរទេហ៎?

ឈូកភ្ញាក់ព្រើតចំពោះវាចារបស់សុជាតិនៅពេលនេះ ។ ការពិត ពាក្យពេចន៍ ទាំងនេះមានន័យធំធេងជាអតិបរមាសំរាប់រូបនាងដែលជាមនុស្សគ្មានបង្គោលជីវិត អ្វីបន្តិចសោះ ។ គ្រានោះ ឈូករំភើបក្នុងចិត្តរហូតរលីងរលោងទឹកភ្នែកសាជាថ្មី ។ ធិតាក៏ស្រវាក្តាប់ដៃរបស់សុជាតិវិញយ៉ាងណែន ហើយឆ្លើយទៅវិញទាំងដួងចិត្ត រំភើបញាប់ញ័ររកពាក្យអ្វីមកថ្លែងមិនត្រូវ :

- ដោយក្តីករុណាពីបង ឈូកសន្យាថានឹងដើរតាមបងជានិច្ច រៀងរហូតទៅ !

អ្នកទាំងពីរកាន់ដៃសំលឹងមុខគ្នាដោយដួងចិតស្នេហាយ៉ាងធំធេងបំផុត ។

មែនហើយ! វត្តមានរបស់ទារិកាតូច បានធ្វើអោយសុជាតិរិតតែអាណិតឈូក ថែមទ្វេឡើងមួយជាពីរមិនដឹងថាមកពីហេតុអ្វីទេ ។ ពេលនេះ មាណពយើងមាន អារម្មណ៍ថា បេះដូងរបស់នាយក្លាយជាទន់ជ្រាយបាក់លោងអស់រលីងតែម្តង នឹង រកប្រកែកថាមិនទទួលយកនាងមកក្នុងជីវិតរបស់នាយមិនបានឡើយ ។ លុះឃើញ គេទាំងពីរសំដែងមនោសញ្ចេតនាដាក់គ្នាយ៉ាងផ្អែមល្ហែម មីងសោមក៏ហៅកូនស្រី :

- សុខាអើយ! យកអំបោះសបីសរសៃមកអោយម៉ែបន្តិចម៉ោហ៎!

- ចា៎សម៉ែ!

សុខាក៏ស្ទុះងើបឡើង កាត់អំបោះនៅបីសរសៃជូនម្តាយភ្លាម ។ មីងសោមក៏ ហៅសុជាតិនិងឈូកអោយមកអង្គុយក្បែរគាត់ រួចក៏មានប្រសាសន៍ថា:

- ឈូកអើយ! ម៉ែក្រណាស់ គ្មានអ្វីចងដៃកូនទេ ក្រៅពីអំបោះសដែលម៉ែចងដៃកូន នៅពេលនេះ ។ សូមអោយព្រះលោកតាមថែរក្សាកូន អោយសុខសប្បាយរហូត តទៅ ។ ចំណែកសុជាតិវិញ ម៉ែក៏សូមអោយឯងថែទាំឈូកនិងកូនឱ្យបានល្អផង ។ ទោះបីជីវិតយើងក្រក្រីអត្តខាត់ខ្វះមុខខ្វះក្រោយក៏ដោយ តែកុំអោយខ្វះទឹកចិត្តណា៎ កូនណា៎ ។ ចូររក្សាសេចក្តីស្រលាញ់ចំពោះគ្នាអោយបានខ្ជាប់ខ្ជួន នោះអ្នកទាំងពីរនឹង អាចឆ្លងផុតឧបសគ្គអ្វីផងទាំងឡាយបានគ្រប់យ៉ាងទាំងអស់ក្នុងជីវិត ។

មីងសោមក៏យកអំបោះទៅចងអោយឈូកនិងសុជាតិ ព្រមទាំងទារិកាតូចផង

CHANBOKEO.COM

ដែរ ។ ឈ្មួកនិងសុជាតិសំលឹងមុខគ្នាញញឹមជាថ្មី ហើយក៏អោនវន្ទាកិរិយាក្រាបសំពះ មីងសោមក្បាលដល់កន្ទេល ។ សុជាតិសំលឹងឈ្មួក ដោយក្រសែភ្នែកយ៉ាងស្រទន់ ហាក់បីដូចជាកំពុងចង់ប្រាប់នាងថា នាយក៏កំពុងមានអារម្មណ៍រំភើបពេកក្រៃដែល ក្លាយជាកូនកំលោះរបស់ឈ្មួកនៅថ្ងៃនេះ ។

ដើម្បីថ្ងៃស្អែក

១. កាន់ដៃបងមកណាំត្រាណត្រើយ ក្រាបក្បាលដល់ខ្នើយទទួលពរ
ម្ដាយយើងប្រស់ព្រំជ័យបវរ ដល់គូស្រករទាំងទ្វេហា ។
២. កាន់ដៃបងជាប់កុំរបេះ ថ្ងៃនេះយើងចេញចរយាត្រា
ទាំងគូស្វែងរកពន្លឺថ្លា មង្គលសុខាក្នុងជីវិត ។
៣. យើងកាន់ដៃដើរទាំងអស់គ្នា ឆ្លងព្យុះព្យោមាទុក្ខវិបរិត
ឆ្លងភពអន្ធការយប់ងងឹត ទៅដែនប្រណិតមានរស្មី ។
៤. យើងកាន់ដៃគ្នាតរៀងទៅ ចាកសោកហ្មងសៅអស់ព្រួយភ័យ
ទាំងគូក្បែរគ្នាស្វែងជោគជ័យ ដើម្បីស្អែកថ្មីស្រីមង្គល ។

00 00
00

CHANBOKEO . COM

# វគ្គទី៧
# កុកសប្រែពណ៌

ក្រពុំចិត្តភ្ញាក់ស្មារតីឡើងឃើញខ្លួននាងស្ថិតនៅក្នុងបន្ទប់ងងឹតមួយ :

- តើខ្ញុំនៅកន្លែងណា?

នាងភិតភ័យណាស់ក៏ក្រោកឡើង គោះជញ្ជាំង :

- ជួយផង... ជួយខ្ញុំផង....

តែគ្មាននរណាឆ្លើយទេ ។ នាងរឹងរិតតែភ័យតក់ស្លុតឡើង ញាប់ញ័រអស់ពេញ ទាំងខ្លួន...
តើហេតុអ្វីបានជានាងមកនៅកន្លែងចំលែកបែបនោះ ។ រំពេចនោះ នាងឮសួរបុរសនិងស្ត្រីពីរនាក់ជជែកគ្នានៅខាងក្រៅ ។ បុរសម្នាក់ពោលថា:

- មេមាន់មួយនេះផ្លាងណាស់ មើលទៅប្រហែលមិនទាន់ផ្សាំងទេ ។ សូមថ្លៃពីររយ ដុល្លារបានទេ ចៃ?

សំលេងស្រីម្នាក់ឆ្លើយឡើង :

- ម៉េចក៏ឯងដឹងកើតថាវាជាមេមាន់ផ្លាង មិនទាន់ផ្សាំង?

- ពុទ្ធោអើយ! ខ្ញុំរកស៊ីចាប់មាន់លក់ម៉ាអាយ៉ូសទៅហើយ ម៉េចក៏ថាមិនដឹង? មួយ ថ្មីនេះ មិនមែនមេមាន់សាំងទេណា៎ចៃ
គឺមាន់ស្មាវហើយផ្លាងទៀត ។ ចៃឯងមិន ដឹងទេហ៏ ថៅកែគេទិញកូនមាន់ផ្លាងមួយដល់ទៅម៉ាពាន់ឯណោះ ហើយបើចៃ អោយខ្ញុំតែមួយរយអញ្ចឹង
ដូចជាមិនយុត្តិធម៌សោះ!

- អើ! បើថៅកែអោយអញដល់ម៉ាពាន់ពិតមែន ចាំអញអោយឯងថែមទៀត តែ
ពេលនេះ យកម៉ារយដុល្លារសិន ហើយឆាប់ថយទៅ ទុកអោយយើងចាត់ការ កុំមាត់ឡូឡាច្រើន! តិចពិបាកផ្ញើលមេមាន់អញរត់បាត់វ៉ើយ!

ភ្លាមនោះស្នូរជើងលាន់ឮខ្សោយទៅៗ ។ ភ្លាមនោះស្រាប់តែមានស្ត្រីមាឌ ធាត់ធំមួយរូប បើកទ្វារចូលមកដល់
ដោយមានអង្គរក្សបុរសមាឌធំបងមួយរូប
ឈរពីក្រោយគាត់ផង។ ស្ត្រីនោះក៏ហុចទឹកក្រូចមួយកែវ អោយនាង :

- ហ៎ាកនេះផឹកទៅ នឹងអាលតសាច់រឿង!

ដោយសារក្រពុំចិត្តស្ថិតនៅបន្ទប់ងងិតយូរហើយ កាលបើមានពន្លឺតាមទ្វារ ចូលមក
នាងក៏ស្រវាំងភ្នែកមើលមុខបុរសស្ត្រីពីរនាក់នោះមិនឃើញសោះ ។

- ខ្ញុំមិនស្រេកទេ ( ក្រពុំចិត្តប្រកែក) ហើយតើឥលូវនេះ ខ្ញុំនៅទីណាទៅមីង?

- សួរច្រើនម៉េះវ៉ឺ! ថាឱ្យផឹកទៅ ! យីស! តិចវ៉ៃងាប់អាលូវ !

ដោយខ្លាចឈឺខ្លួន តរុណីក៏ស្រវាទទួលកែវទឹកក្រូចមកអកហើយហុចកែវទៅ វិញ ។ ស្ត្រីនោះមិននិយាយអ្វីជាមួយនាងទៀតដែរ ។
ក្រោយពីបានទទួលកែវវិញ ហើយគាត់ក៏ទាញទ្វារបិទចេញទៅបាត់ ។ ទីនោះគឺជាបន្ទប់ងងិតមានតែពន្លឺចាំង

CHANBOKEO.COM

ព្រាល១តាមរន្ធបង្អួចដែលមានរនាំងខ្មៅបិទជិត មិនដឹងថាគន្លឹះភ្លើងនៅត្រង់ណា ទេ ។ ធិតាក៏យកដៃរាវ១ស្រវាតាមជញ្ជាំងរកគន្លឹះភ្លើង ស្រាប់តែងងឹតមុខឈឹង ដួលប្រួស ទៅលើកំរាលឥដ្ឋបាត់ស្មារតីសាជាថ្មីម្តងទៀត ។

មិនដឹងជាអស់ប៉ុន្មានម៉ោងទេហ៎ដែលនាងរលត់ស្មារតីទៅ ។ លុះដល់ដឹងស្មារតី ខ្លះ១មកវិញ ឆវីយើងមានអារម្មណ៍ថានាងកំពុងត្រូវមនុស្សប្រុសធ្វើបាបផ្លូវភេទ ឈឺចាប់អស់ពេញប្រាណស្ទើរទ្រាំមិនបាន ។ តែជាតិថ្នាំនៅក្នុងទឹកក្រូចបានធ្វើអោយ នាងរសេះរសោះដៃជើងអស់រលីង នឹងរើបំរះយ៉ាងណាក៏មិនរួចសោះឡើយ ។ ពេល នោះ ក្រពុំចិត្តមានអារម្មណ៍ហាក់ដូចជាធ្លាក់នរកទាំងរស់អញ្ចឹង! ហេតុម្តេចទៅហ្ន៎ បានជាជីវិតនាងមានបាបកម្មដល់ម្លឹង? ទោះបីជាយល់សប្តិក៏នាងមិនដែលគិតស្មាន ដែរ ថារូបនាងបែរជាធ្លាក់ក្លាយជាចំណីបុរសយ៉ាងថោកទាបបំផុតដូច្នោះឡើយ ។ ធិតានឹកសោកសង្រេងអាណិតខ្លួនណាស់ ដែលនាងត្រូវគេចាប់ខ្លួននាងយកមកលក់ សំរាប់បំរើផ្លូវភេទ ។ ពេលនេះ តើមាននរណាខ្លះទៅដែលអាចជួយនាងបាន? គឺមានតែខ្លួននាងជួយខ្លួនឯងតែប៉ុណ្ណោះ ប៉ុន្តែតើនាងត្រូវជួយខ្លួនឯងយ៉ាងណាទៅ? ហើយទីនេះជាកន្លែងណា? នៅឯណា?

មួយស្របក់ធំក្រោយមក បុរសនោះក៏ប្រាសខ្លួនប្រែទៅម្ខាងហើយដេកលក់ ស្រមុខលាន់ខុរ១ ប្រហែលជាស្រវឹងជោគដល់សួរហើយ ។ ធិតាយើងតាំងស្មារតី មកវិញ ហើយស្រវារាវរកសំលៀកបំពាក់មកពាក់ ។ ស្រាប់តែក្រពុំចិត្តស្រវាបាន ខោរបស់បុរសនោះដោយចៃដន្យ ។ នាងនឹកភ្នកដល់កាបូបលុយក្នុងហោប៉ៅរបស់ បុរសនោះក៏រាវយកវាចេញមក រួចយកស្បៀតហោប៉ៅខោរបស់នាង ។ បន្ទាប់មក នាងក៏ដើររាវរកមាត់ទ្វារ តែជាប់គន្លឹះជាប់មួលបើកមិនរួចសោះ ។ នាងក៏ត្រលប់ ដើរសំដៅបង្អួចវិញម្តង! មែនហើយ ពេលនោះបង្អួចអត់មានដាក់គន្លិះទេ ។ មាណវី ត្រេកអរណាស់ ក៏ស្ទុះបើកគន្លិះបំណងលោតចេញទៅ ប៉ុន្តែ លុះនាងសំលឹងទៅក្រៅ បង្អួច ទើបដឹងថាពេលនេះជាពេលជិតភ្លឺហើយ ហើយបន្ទប់មួយនេះស្ថិតនៅនា ជាន់ទីពីរក្នុងសណ្ឋាគារមួយ ម៉្លំណាក៏មិនដឹង ត្បិតនាងរកចំណាំទិសមិនបាន ។ រំពេច នោះ បុរសតិរច្ឆានក៏ភ្ញាក់ស្មារតីឡើងឃើញឆវីឈរតោងបង្អួច ក៏ឧទានឡើង :

- នែ៎នាង! បំរុងចុះទៅណាហ្នឹង... នៅបំរើយើងសិន ! យើងចាយលុយទិញខ្លួននាង ដល់ទៅជាងម៉ាពាន់ដុល្លារ ត្រូវបំរើយើងឱ្យអស់ថ្លៃសិនរ៉ឺយ កុំទាន់ទៅណា៎.....

បុរសនោះមានសំដីហាក់ដូចជានៅស្រវឹងសើងម៉ាម៉ើងនៅឡើយ ។ លុះឃើញ បុរសចិត្តខ្មៅស្រវាក្រោកដើម្បីមកឃាត់រូបនាង ក្រពុំចិត្តនឹកភ័យណាស់ក៏លោត ហក់ចេញតាមបង្អួចរឹង ធ្លាក់មកដីខ្ពោក ចំក្បែរមាត់ទ្វារចេញចូលរបស់សណ្ឋាគារ តែម្តង ។ ពេលនោះនាងមានអារម្មណ៍ថាឈឺចុកណែនអស់ពេញខ្លួនរកពាក្យថ្លែង ឱ្យសមស្មើមិនបានឡើយ តែក៏នៅមិនស្មើនឹងការឈឺចាប់ទាំងឡាយមួយយប់កន្លង មកនោះឡើយ ។ នៅក្នុងចិត្ត នាងប្រឹងស្រែកដង្ហោយហៅរកទេវតាអោយមក រំដោះយកវិញ្ញាណរបស់នាងចេញផុតពីរូបកាយនាគ្រានោះតែម្តងទៅ ដើម្បីកុំ អោយនាងមានការឈឺចាប់ទាំងផ្លូវចិត្តនិងផ្លូវកាយតទៅទៀត ។ មុននឹងបាត់ស្មារតី ទៅ មាណវីបានឮសំលេងរបស់បុរសស្ត្រីជាច្រើន ដែលនៅយាមទ្វារចេញចូលរបស់ សណ្ឋាគារកំពុងស្រែកឆោឡោឡើងថា :

- មានមនុស្សស្រីលោតសំលាប់ខ្លួនពីជាន់ទីពីរមក៏ ឆាប់ទៅមើល៍ផងមើល៍ តើជា នរណាគេ?

ឃ្លោកលិចអំបែងអណ្តែត

១. មេឃរាំងស្ងួតដី ត្រីភ័យមរណា ក្អែកឥតមេត្តា ចឹកជាចំណី
សត្វចាកសំបុកត្បិតខ្លាចត្រូវក្ស័យ ដោយសារព្រានព្រៃយាយីប្រហារ ។

២. ពពែស្លាប់ក្រោមចង្កូមខ្លាព្រៃ ចិត្តអន្សត្តិរ្ឋយ៍សាហាវឫស្យា

CHANBOKEO.COM

កុកសប្រៃពណ៌ ត្បិតប្រាក់ដុល្លារ សូម្បីទេវតា ក៏ធ្មេចព្រះនេត្រ ។
បន្ទរ. មេឃខ្មៅប្រែកល កង្វល់ព្យុះធំ កូនជ្រូកស្រែកយំក្រោមជើងស្តេចប្រេត
ឃ្លោកលិចក្នុងទឹក អំបែងអណ្តែត មេឃរាំងខុសហេតុប្រេតលុកលុយក្រុង ។
៣. នរកលោកិយ ស្តីមិនបានសោះ ហារស្លាក់ដូចពស់ រស់ក៏លិចលង់
មិនខុសកង្កែប យំឮងប៊ីង កំភ្លាញងាប់ឈឹង ព្រោះមាត់ជាងគេ ។
៤. ឱ! ព្រះជាម្ចាស់ លោកគង់ទីណា ឥន្ទ!ព្រហ្ម!ទេវតា! លោកទតឃើញទេ
សត្វតូចរងគ្រោះ ទុក្ខាកើនទ្វេ សូមព្រះយាងបែរប្រោសសត្វលោកផង!

ក្រពុំចិត្តបើកភ្នែកមកវិញ ឃើញខ្លួននៅក្នុងមន្ទីរពេទ្យមួយ ។ គិលានុបដ្ឋាក មួយរូបបានចូលមកដល់ :
- អ្នកនាងដឹងខ្លួនវិញហើយ? ដឹងទេហ៏ថាអ្នកនាងមានសំណាងណាស់ដែលមិនមាន គ្រោះថ្នាក់បាក់ឆ្អឹងបាក់ឆ្អែងទេ គ្រាន់តែគ្រាំគ្រាប៉ុណ្ណោះ ។
- លោកគ្រូពេទ្យ... ហេតុអ្វីក៏ខ្ញុំមកដល់ទីនេះ? ( ក្រពុំចិត្តសួរដោយសំលេងខ្សាវៗ)
- គឺមានគេឃើញអ្នកនាងលោតចេញពីបង្អួចជាន់ទីពីរនៃសណ្ឋាគារមួយ ធ្លាក់ដួល សន្លប់បាត់ស្មារតី ហើយក្រុមតម្រួតសន្តិសុខដែលនៅយាមម៉្តុំនោះក៏សង្គ្រោះនាង យកមកមន្ទីពេទ្យតែម្តងទៅ ។

ធិតាទឹកអាមាសហើយឈឺចាប់ក្នុងចិត្តរកពាក្យនិយាយមិនបាន ។ របួសផ្លូវ កាយមិនបានរំខាននាងបន្តិចឡើយ តែរបួសផ្លូវចិត្តវិញគឺគ្មានពាក្យណាបរិយាយ អោយសមស្មើនឹងការឈឺចាប់របស់នាងឡើយ ។ ទឹកភ្នែកនារីក៏ហូរធ្លាក់មកឯងៗ ។ បន្តិចមក លោកគ្រូពេទ្យក៏សួរថា :
- អ្នកនាងមានបងប្អូននៅឯណាទេ? មន្ទីរពេទ្យយើងអាចជួយនាំដំណឹងទៅអោយ បាន ។

មែនហើយ! តើបងប្អូនសាច់ឈាមរបស់នាងនៅឯណាខ្លះទៅ? តើនាងត្រូវ ប្រាប់គេដូចម្តេច? ប្រាប់ថានាងជាកូនអភិជនឈ្មោះសម្បត្តិត្រូវគេចាប់ខ្លួនលក់ អោយពួកឈ្លើងសង្គម ឬ ក៏ថានាងជាស្រីរយរាយរកស៊ីផ្លូវភេទ? ហើយបើឪពុកម្តាយរបស់នាងដឹងរឿងដែលនាងត្រូវគេរំលោភលើព្រហ្មចារិយ៍ ហើយលោត សំលាប់ខ្លួនពីសណ្ឋាគារចុះមក តើគាត់នឹងជឿពាក្យពិតរបស់នាងទេហ៏ កាលបើ ពីយប់មិញនាងបើកឡានចេញពីផ្ទះដោយខ្លួនឯង? ចំណែកលោកវិសាល តើលោកនឹងគិតយ៉ាងណាទៅដែលនាងបានក្លាយជានារីដែលប្រលាក់ប្រលូសទៅដោយក្អែល សង្គមអប្បលក្ខណ៍យ៉ាងនេះ? ចុះបងស្រីនាង? ហ៊ឺ!....

គិតទៅគិតមក នាងនៅតែសុញដែលមិនដឹងថា នឹងត្រូវរកពាក្យអ្វីមក និយាយអោយសមហេតុផល អោយគេឯងជឿនាងបានទេ ។ ទីបំផុត នាងក៏សុខ ចិត្តបិទនេត្រាសំរក់ទឹកភ្នែកតែម្នាក់ឯង ហើយឆ្លើយទៅលោកគ្រូពេទ្យវិញថា :
- ខ្ញុំកំព្រាគ្មានសាច់ញាតិទេ...

លោកគ្រូពេទ្យសំលឹងមុខនាង ហើយគ្រវីក្បាល :
- គួរអាសូរនាងណាស់! ណ្ហើយចុះ! ដល់នាងមានអាការៈធូរស្រាលបន្តិច នាង ចេញទៅផ្ទះវិញបានហើយ ហើយនេះគឺកញ្ចប់តវ៉ាន់ផ្ទាល់ខ្លួនរបស់នាង ដែលមន្ទីរ ពេទ្យខ្ចប់ទុកអោយ ។ នាងយកវិញចុះណា៎!

លោកគ្រូពេទ្យលើកថង់មួយដែលមានចងមាត់ ដាក់នៅលើតុមួយក្បែរគ្រែ អ្នកជំងឺ ។ លុះលោកដើរចេញទៅផុតទៅ ក្រពុំចិត្តក៏ស្ទុះផ្លាស់ខោអាវ រួច ដើរលបៗមើលផ្លូវ ក្រែងមានដៃជើងពពួកសណ្ឋាគារគេមកឆ្មក់យាមចាំស្ទាក់យក នាងត្រលប់ទៅកន្លែងគេវិញ ។ លុះនាងបើកទ្វារឡើង ស្រាប់តែវ៉ាក់អ៊ើ នឹងបុរស ចំណាស់ម្នាក់តែម្តង ។ ក្រពុំចិត្តឃើញហើយក៏លាន់មាត់ឡើង :
- លោកប៉ា?...

CHANBOKEO.COM

នោះគឺវត្តមានរបស់លោកសម្បត្តិនៅចំពោះមុខឆវីតែម្តង ។ តែពេលនោះធិតា នឹកឆ្ងល់ណាស់ថាហេតុអ្វីលោកប៉ារបស់នាងដឹងកើតថានាងគេងនៅមន្ទីរពេទ្យ ។ លោកសម្បត្តិមិននិយាយស្តីអីជាមួយនាងឡើយ គ្រាន់តែជ្រួញចិញ្ចើម ធ្វើទឹកមុខចំលែកហើយក៏អូសដៃកូនអោយទៅឡើងរថយន្តមួយ ដែលនៅចតចាំនៅមុខមន្ទីរ ពេទ្យជាស្រេច ។

បន្ទាប់មកលោកក៏ពោលផ្តាំទៅសូហ្វ៊ុរឡានថា :

- ជួយរក្សាសុវត្ថិភាពរបស់នាងអោយដល់ផ្ទះផង ឮហើយនៅ...?

- បាទ!

សូហ្វ៊ុរឡានទទួលពាក្យហើយ ក៏នាំក្រពុំចិត្តចេញទៅ ។ លោកសម្បត្តិឈរមើលពីក្រោយ យកដៃល្អីថ្ងាសហើយគ្រវីក្បាលព្រមទាំងដកដង្ហើមធំៗទៀតផង ។

លុះនារីយើងឈានជើងទៅដល់ក្នុងបរិវេណទីធ្លាមុខវីឡាដ៏ស្កុកស្តម្ភរបស់នាង ក្រពុំចិត្តហាក់មានពិភាល់ក្នុងចិត្តណាស់ ត្បិតតរុណីបានឃើញរថយន្តរបស់លោក វិសាល នៅចតចោលត្រង់កន្លែងដដែល តាំងពីម្សិលមកម្ល៉េះ ។

មាណវីដើរចូលទៅក្នុងផ្ទះ តែមិនឃើញមាននរណាសោះ  ក៏ដើរឡើងជណ្តើរបំរុងនឹងទៅរកបន្ទប់គេងផ្ទាល់ខ្លួនរបស់នាង ស្រាប់តែប្រទះស្បែកជើងបុរសមួយ ចំហៀងនៅកាំជណ្តើរ ហើយមួយចំហៀងទៀតនៅចំពីមុខបន្ទប់របស់បងស្រីរបស់ នាងតែម្តង ។ ឃើញដូច្នោះធិតារន្ធត់ចិត្តណាស់ ! នាងមិនចង់គិតទេថា ឥឡូវនេះលោកវិសាលកំពុងតែស្ថិតនៅក្នុងបន្ទប់គេងរបស់ដារិយ៉ា ។ ប៉ុន្តែអោយនាងទប់ចិត្ត ថាមិនសង្ស័យដូច្នោះមិនបានឡើយ ។ ក្រពុំចិត្តនៅឈប់ឈរទ្រឹងនៅពីមុខទ្វារ បន្ទប់របស់ដារិយ៉ា ហើយគិតនៅក្នុងចិត្តទាំងឈឺចាប់ថា :

- ហេតុអ្វី បងធ្វើយ៉ាងនេះ បងវិសាល? បងដឹងទេ ថាអូនកំពុងឈឺចិត្តយ៉ាងណា កាលបើដឹងថាបងកំពុងប្រែប្រួល? ប៉ុន្តែ... ក្រពុំចិត្តអើយ នាងក៏បានក្លាយជាផ្កា បាក់ទងទៅហើយ តើនាងគួរសង្ឃឹម ថាលោកវិសាលអាចទទួលនូវជីវិតដ៏ប្រលាក់ ប្រលូសរបស់នាងនោះដែរឬទេ?

ក្រពុំឈរខ្ទប់មុខយំហើយយំទៀត.... យំរហូតទឹកភ្នែករីងខះអស់លែងហូរ...

រំពេចនោះ ដារិយ៉ាក៏ដើរចេញពីបន្ទប់មក ក្នុងសំលៀកដំណេករាត្រី :

- នាងចិត្ត! ទើបមកពីណាហ្នឹង? ហេតុអីក៏ស្រមេកស្រមកម្ល៉េះ?

ធិតាយើងឈរទ្រឹងភាំង មិនដឹងជាត្រូវឆ្លើយយ៉ាងម៉េចទៀត កាលបើនៅពី ក្រោយខ្នងដារីយ៉ា គឺជារូបលោកវិសាលដែលគេងដោះអាវនៅខ្លួនទទេ លង់លក់ ស្មៀមឈឹងលើគ្រែបងស្រីរបស់ខ្លួន ។ ក្រពុំចិត្តនៅធ្មឹងមួយស្របក់ ខាំមាត់ហើយក៏ដើរចេញទៅ ដោយឥតមានស្តីរកបងស្រីមួយម៉ាត់ ឡើយ ។

ក្រពុំចិត្តរត់ចូលទៅក្នុងបន្ទប់ យំមិនដឹងអស់ប៉ុន្មានម៉ោងទេ...

រសៀលបន្តិចទើបនាងសំរេចចិត្តងើបឡើង រៀបចំស្លៀកពាក់ហើយក៏ចុះចេញ ពីបន្ទប់តម្រង់ទៅរថយន្តរបស់នាងដែលចតនៅខាងក្រៅកាលពីយប់មិញ ។ ទោះ បីពេលនោះ នាងមានរបួសគ្រាំគ្រាពាសពេញរូបកាយដោយការរំលោភក្តី ដោយការលោតចុះពីសណ្ឋាគារក្តី ក៏នាងមិនមានអារម្មណ៍ថា ឈឺចុកចាប់អ្វីបន្តិចណា សោះឡើយ ។ អ្វីដែលនាងឈឺទ្រាំមិនបានគឺការដាក់ទណ្ឌកម្មពីព្រហ្មលិខិតដែល ក៏រិតជីវិតនាងអោយមកជួបតែកម្មអកុសលមិនអស់មិនហើយ ។ ក្រពុំចិត្តមិនមានកាន់អ្វីតាមទេក្រៅពីថង់ខ្មៅដែលមន្ទីរពេទ្យដោះឥវ៉ាន់ទុកអោយនាងនោះឡើយ ។ នាងកាន់ថង់ផងឈ្លីផងសំដែងអាការៈហាក់ដូចជាចង់តែច្របាច់កថង់ខ្មៅនោះ អោយស្លាប់តាមអារម្មណ៏របស់នាងអញ្ចឹង ។ លុះនាងដើរមកដល់រថយន្តរបស់ នាងស្រាប់តែឆវីប្រទះលោកវិសាលឈរវងចាំទីនោះស្រេច ។ គ្រាន់តែក្រលេក ឃើញនាងភ្លាម លោកវិសាលក៏ស្ទុះមករកនាង :

CHANBOKEO.COM

- ចិត្ត... ! អោយបងសូមនិយាយពន្យល់អូនអ្វីបន្តិចបានទេហ៎

តែក្រពុំចិត្តមិនមានចិត្តចង់ស្តាប់រឿងអ្នកណាតទៀតឡើយ ។ ពេលនេះ នាង កំពុងតែមានអារម្មណ៍ថា " ឆ្កែត... សែនឆ្កែតនឹងកម្មលោកិយ!!!" ម្ល៉ោះហើយ ទោះបីជាលោកវិសាលទទូចចង់ពន្យល់ប្រាប់ពីហេតុការណ៍កាលពីយប់មិញ ក៏ឥត ប្រយោជន៍ដែរ ។ ក្រពុំចិត្តឈ្ងោកមុខសំលឹងទៅចិញ្ចៀនដែលលោកវិសាលបំពាក់ អោយនៅលើម្រាមដៃរបស់នាងកាលពីយប់ម្សិល ។ នាងនឹកស្តាយ... សែនស្តាយ... ស្តាយណាស់ តែនាងក៏មិនអាចបកក្រោយទៅកែកុនអ្វីបានទៀតដែរ មានតែការ បោះជំហានបន្តទៅមុខតែម្យ៉ាងប៉ុណ្ណោះ ។ ធិតាក៏លើកដៃឡើងដោះយកចិញ្ចៀនដ៏ ភ្លឺចិញ្ចាចនោះចេញមក ហើយហុចទៅអោយគូកំណាន់ចិត្តវិញ :

- បងវិសាល! សូមបងទទួលយកចិញ្ចៀនរបស់បងវិញទៅ!

- អត់ទេ! ចិត្ត! យើងនិយាយគ្នាបន្តិចសិនបានទេ?

តែក្រពុំចិត្តលែងមានចិត្តចង់ស្តាប់អ្វីទៀតហើយ ។ នាងហុចចិញ្ចៀនអោយ លោកវិសាលវិញហើយក៏ឈ្ងោកមុខដើរចូលឡានយ៉ាងលឿន រួចបិទទ្វារចាក់គន្លឹះ មិនព្រមស្តីរកលោកវិសាលតទៅទៀតឡើយ ។ តើអោយនាងធ្វើម្តេចទៅ? អោយនាងធ្វើបាបចិត្តបងស្រីដោយទទួលយកលោកវិសាលវិញ? ឬ អោយនាងធ្វើពើជាស្រីបរិសុទ្ធម្នាក់ភូតកុហកលោកវិសាលដើម្បីរក្សាស្នេហារបស់នាងតទៅទៀត? ឬក៏និយាយជំរាបការពិតអំពីរឿងរបស់នាងប្រាប់គេដឹងទាំងអស់? ចុះបើនាងប្រាប់ គេរួចហើយ តើគេនៅស្រលាញ់នាងដដែលដូចមុនឬក៏ប្តូរចិត្តយ៉ាងណាវិញ? ទេ! នាងបានគិតដាក់ច្បាស់ហើយ... គឺនាងទេដែលត្រូវលាចាកចេញពីជីវិតរបស់លោក វិសាលនិងបងស្រីរបស់នាង ត្បិតពេលនេះ រូបនាងគឺជាស្រីដែលប្រលាក់ប្រលូស ដោយភាពសៅហ្មងក្រៃលែង ។ លុះសំរេចចិត្តដូច្នោះហើយ ក្រពុំចិត្តក៏បរឡាន ចេញទៅយ៉ាងលឿន ទុកអោយលោកវិសាលស្រែកដង្ហោយហៅនាងពីក្រោយ យ៉ាងសោកសៅ...

ម្តេចគ្មានពាក្យថាលា?

១. យើងស្រលាញ់គ្នាឥតបីជិនណាយ គូគាប់ពីរកាយចងចិត្តមង្គល
លើកដៃសច្ចាស្នេហានិមល តែអកុសលផលបែរព្រាត់វិញ ។

២. ម្សិលមិញស្រីសើចជាមួយនឹងរៀម ថ្ងៃនេះចុកឈាម ឱរាទោម្នេញ
អូនព្រាត់ពីបងទាំងក្តីស្រលាញ់ ព្រោះតែចុះចាញ់ទណ្ឌកម្មព្រហ្មព្រះ ។

៣. អូនអើយ!ស្តាប់ផង! បងសូមអង្វរ ឱ!កែវកេសរម្តេចប្រែនិរាស
បងស្រលាញ់អូនលុះថ្ងៃបងប្រាស លោកសន្និវាសផុតកល្បជីវី ។

៤. អូនឃ្លាតទៅហើយគ្មានឡើយពាក្យលា អោយបងគ្រាំគ្រាអស់អង្គអញ្ចលី
បងកាត់បេះដូងផ្ញើស្រស់ឆវី សូមតរុណីវិលវិញណាអូន ។

ក្រពុំចិត្តបានមកដល់មុខផ្ទះមិត្តរបស់ខ្លួននៅសង្កាត់ឫស្សីកែវ ក៏ចុះចូលទៅសួរ រកតែសាច់ញាតិនៅទីនោះប្រាប់ថាមិត្តស្រីគេបានរៀបការទៅនៅឯខេត្តក្រោបាត់ ទៅហើយ ។ ឮដូច្នោះ មាណវីយើងខកចិត្តណាស់ ។ នាងក៏ជំរាបលាចេញមកវិញ ។ ស្រាប់តែនាងនឹកភ្នកទៅដល់ផល្លីនមិត្តរបស់នាងនៅអរិយក្សត្រ ក៏បររថយន្តសំដៅ ទៅកំពង់ចំលងភ្លាម ។

ស្នូរសំនៀងកប៉ាល់រោទិ៍ឡើង ជាសញ្ញាអោយអ្នកដំណើរបានដឹងថា កប៉ាល់ សាឡាងកំពុងចេញដំណើរពីផែសំដៅទៅត្រើយខាងកើត ដោយមានផ្ទុករថយន្ត ម៉ូតូ ទំនិញ និងមនុស្សម្នាជាច្រើនយ៉ាងខ្ទាន់ខ្ទាប់ ។ នៅលើកប៉ាល់ ក្រោមដំនោរ ខ្យល់ផាត់នាដើមរដូវវស្សា ក្រពុំចិត្តចុះពីរថយន្ត ឈរសំលឹងមើលទៅត្រើយខាង

CHANBOKEO.COM

លិច   ទំនងហាក់ដូចជាកំពុងតែផ្ញើពាក្យបណ្តាំទៅក្រុងភ្នំពេញទាំងមូល      ថា.....
" លាហើយភ្នំពេញអើយ! "

នាវាលាច្រាំង

១.      នាវាលាច្រាំងថ្ងៃចាំងក្តៅហែង ចិត្តអើយចំបែង ទឹកភ្នែកប្រលែងរង្វង់ភក្ត្រា
        ក្រុងភ្នំពេញធ្លាប់ថ្នមសុខា ឥលូវក្លាយវាលមរណា កំណប់សាវតារឧក្រិដ្ឋ ។
២.      នាវាលាទៅពៅយំទន្ទេញ ឱភាទោម្ទេញ គ្មានទេវិលវិញជួបស្នាមអតិត
        លាស្នេហាដែលធ្លាប់នែបនិត្យ លាហើយលាភពឧក្រិដ្ឋ សំលាប់ដួងចិត្ត
        ដែលស្មោះ ។
បន្ទរ.   លា! លាហើយ! លាហើយ! លាហើយ! លាគ្មានថ្ងៃវិលវិញឡើយ
        លាគ្មានសោកស្តាយស្រណោះ លាភពឬស្យាអសប្បុរស សូមនៅសុខចុះ
        លាចិត្តទុរយសអប្រិយ ។
៣.      នាវាលាចេញលែងអាល័យត្រើយ លាស្នេហ៍បងហើយ ជូតទឹកភ្នែកហើយ
        ញញឹមជាថ្មី សង្ឃឹមស្វែកទាំនូវរស្មី ស្នេហាស្មោះស្នេហ៍មេត្រី ផុតកម្មអវិចី
        រៀងអើយ....

កន្លះម៉ោងក្រោយមក ក្រពុំចិត្តបានមកដល់អរិយក្សត្រដោយសុវត្ថិភាព។ នាងបានឡើងទៅរកផល្លីនមិត្តរបស់នាងឃើញ ហើយក៏នៅស្នាក់លេងជាមួយក្រុម គ្រួសាររបស់គេដើម្បីលាងអារម្មណ៍ហ្មងហ្មួយកំលុងពេលសិន ត្បិតពេលនេះ នាងកំពុងមានអារម្មណ៍វិលវល់ណាស់ គិតអ្វីមិនចេញទេ ។ មួយវិញទៀត នាងក៏នឹក ម្តាយ មិនដឹងថាអ្នកស្រីជានីសព្វថ្ងៃសុខទុក្ខយ៉ាងណា នៅឯណា ។ នាងមិនដែល បានឃើញមុខម្តាយនាងច្រើនខែហើយ ចំណែកឪពុករបស់នាងក៏ដូចគ្នាដែរ ។ ជួន កាល នាងអង្គុយសួរទៅមេឃ សួរទៅផ្កាយ ថាហេតុអ្វីបានជាក្រុមគ្រួសាររបស់នាង មានលក្ខណៈមិនធម្មតាដូចក្រុមគ្រួសារដទៃសោះអញ្ចឹង? សូម្បីតែក្រុមគ្រួសារ របស់ផល្លីន ក៏គេម្នាក់ៗមានសេចក្តីស្រលាញ់ចំពោះគ្នាជានិច្ចជាពិសេស ស្គាល់ទុក្ខ ធុរៈហើយស្និទ្ធស្នាលនឹងគ្នាណាស់ ។ ផល្លីនឃើញក្រពុំចិត្តកំពុងមានទុក្ខ មិនហ៊ាន សាកសួរអីច្រើនទេ គ្រាន់តែនាំមាណវីបន្លប់អារម្មណ៍ធ្វើនេះធ្វើនោះមិនទំនេរ ដើម្បី កុំអោយនាងកើតទុក្ខព្រួយពេកប៉ុណ្ណោះ ។ សព្វថ្ងៃផល្លីនគេរៀនចប់ហើយ ហើយ បានធ្វើការនៅធនាគារមួយនៅឯភ្នំពេញ។ មានកាលខ្លះផល្លីនក៏បបួលក្រពុំចិត្ត អោយត្រលប់មកលេងភ្នំពេញវិញដែរ តែ មាណវីប្រកែកមិនព្រមមកឡើយ។

ពីរអាទិត្យក្រោយមក...

ផល្លីនឆ្លងសាឡាងត្រលប់មកផ្ទះវិញពីថ្ងៃខុសប្លែកធម្មតា ហើយមានកិរិយា ដូចជាត្រហេបត្រហបណាស់ :

- ចិត្តអើយ ! វីវរហើយ! បងស្រីជាវិរិយ៉ារបស់ឯងបានទូរសព្ទ័មកខ្ញុំដើម្បីរកឯង អោយទៅមើលម៉ាក់ឯងឥលូវនេះភ្លាម..
- ទៅមើលម៉ាក់? ម៉ាក់ខ្ញុំមានគ្រោះថ្នាក់អីហ្នឹស?

ទ្រាំមិនបាន   ក្រពុំចិត្តក៏ស្ទុះឡើងកប៉ាល់ត្រលប់ចេញមកភ្នំពេញវិញ ទាំងចិត្ត កន្ទុះរា។ តាមផ្លូវ នាងបែបន់ព្រះជាប់ជានិច្ច សុំអោយម្តាយនាងសុខសប្បាយ។ ជាងកន្លះម៉ោងក្រោយមក ឆរីក៏បានមកដល់លំនៅរបស់នាងវិញ ។ នាងធឿនក៏ស្ទុះ ចេញមកទទួល ។ ក្រពុំចិត្តក្រលេកឃើញធឿនហើយ ក៏សួរភ្លាមថា :

- ធឿន! ម៉ាក់នៅឯណា?
- ចាស! នៅសំរាន្តក្នុងបន្ទប់របស់គាត់ អ្នកនាងចិត្ត !

CHANBOKEO.COM

ធិតាស្ទុះរត់ឡើងជណ្តើររឹងយ៉ាងរហ័ស ។ នៅលើគ្រែដ៏ប្រណិតមួយ អ្នកស្រី ដានីកំពុងសំរាន្តយ៉ាងស្ងៀមស្ងាត់ ។ ក្រពុំចិត្តចូលទៅដល់ ឃើញម្តាយមានរបួសជាំ អស់ពាសពេញខ្លួន ។ ធិតាស្រក់ទឹកភ្នែកច្រោក រត់ទៅអោបម្តាយយំទ្រហោរ ដោយក្តីរំជួលក្នុងចិត្តក្រៃលែង :

- អ្នកណាគេធ្វើបាបម៉ាក់យ៉ាងនេះ? អ្នកណា? គឺលោកប៉ាមែនទេហ៎ ម៉ាក់?

អ្នកស្រីដានីមានរាងកាយទ្រុឌទ្រោមណាស់ ។ កាលបើឃើញកូនស្រីមកដល់ អ្នកស្រីក៏ហើបមាត់មានប្រសាសន៍ខ្សាវៗថា :

- មែនហើយកូន គឺប្រុសចង្រៃនោះឯង... វាធ្វើបាបម៉ាក់គ្មានប្រណីទេ....

- យើ! ហ៊ានហៅយើងសុទ្ធតែប្រុសចង្រៃផង! ម៉េចចង់ថែមទៀតមែនទេហ៎?

ក្រពុំចិត្តងាកយ៉ាងរហ័ស ឃើញលោកសម្បត្តិដើរចូលមកទាំងទឹកមុខប្រកប ដោយកំហឹងរោលរាល ហើយមានធំក្លិនស្រាពីមាត់ផង ។ ធិតាក៏ស្ទុះទៅឃាត់ ភ្លាម :

- លោកប៉ាចង់ធ្វើស្អីម៉ាក់ហ្នឹង.? លោកប៉ា..!. ឈប់..!.. ខ្ញុំមិនអោយប៉ាបំពារបំពាន ធ្វើបាបម៉ាក់តទៅទៀតទេ... លោកប៉ាធ្វើបែបនេះព្រៃផ្សៃណាស់!

នេះជាលើកទីមួយហើយដែលមាណវីយើងតមាត់នឹងឪពុកវិញ ។ លោក សម្បត្តិពើងទ្រូងដើរចូលទៅកាន់តែជិត យារដៃចង្អុលមុខអ្នកស្រីដានី :

- រឿងអីយើងដាក់ទោសវាមិនបាន បើវាមិនគោរពយើងជាប្តី លួចទៅមានប្រុស ឈ្មោលនៅខាងក្រៅ!

- តែលោកប៉ាបន្ទោសតែម៉ាក់ ( ក្រពុំចិត្តតបកាត់ប្រសាសន៍ឪពុក) ចុះលោកប៉ាវិញ ដែលទៅមានស្រីញីព្រោងព្រាតនៅខាងក្រៅដែរនោះ តើសក្តិសមជាកិរិយាថ្លៃថ្នូរ របស់បុរសដែលជាស្វាមីនិងជាឪពុករបស់គេដែរទេ?

- យើស! មីក្មេងតូច ! អីលូវឆ្អឹងធំ ហ៊ានតមាត់ឪវាហើយតើហ៎ ម៉េចចង់ស៊ីស្លាស៊ីម្លូ អោយក្រហមមាត់មួយទៀតដែរមែនទេហ៎ ?

លោកសម្បត្តិនិយាយផង យារដៃរកទះកំភ្លៀងកូនផង ។ ក្រពុំចិត្តមិនគេចទេ សុខចិត្តអោយឪពុកទះឡើងក្រហមថ្ពាល់ រួចហើយ នាងក៏ឆ្លើយទៅឪពកវិញថា :

- លោកប៉ាអាចធ្វើបាបរូបកូនបាន តែកូនមិនបណ្តោយអោយលោកប៉ាធ្វើបាបម៉ាក់ របៀបនេះទៀត បានទេ ។ យើងមិនមែនជាសត្វធាតុទេ យើងជាមនុស្សមាន សាច់មានឈាម ចេះឈឺចេះផ្សាចេះខឹងចេះអន់ចិត្តដូចតែលោកប៉ាដែរ ។ ប៉ុន្តែហេតុ អ្វីដែលគ្រាន់តែយើងកើតមកជាស្រីប៉ុណ្ណឹង ក៏ចាំបាច់ត្រូវតែទទួលកំហុស ទទួល ទណ្ឌកម្មធ្ងន់ពីបុរសដូច្នេះ កាលបើពេលជាមួយគ្នា បុរសដែលប្រព្រឹត្តមិនគប្បី ដូចលោកប៉ា បែរទទួលថា ខ្លួនជាមនុស្សល្អ មនុស្សត្រូវជានិច្ចទៅវិញ?

- នែ៎ នាងចិត្ត... យើងចិញ្ចឹមនាងជាកូន មិនមែនចិញ្ចឹមឆ្កែ ចិញ្ចឹមក្រពើសំរាប់ អោយមកខាំយើងទេ ។ នាងមាត់ធំណាស់ ទាល់តែប្រដៅខ្លះទើបបាន !

លោកសម្បត្តិក៏លើកដៃទះក្រពុំចិត្តលើកទីពីរ ។ អ្នកស្រីដានីឃើញដូច្នោះ ក៏ ទ្រាំលែងបាន ។ អ្នកស្រីក៏ស្ទុះងើបទៅការពារកូនស្រីភ្លាម តែក៏ត្រូវលោកសម្បត្តិទះ ដួលទៅលើកំរាលគ្លោលៗទាំងពីរនាក់ ។ ក្រពុំចិត្តរន្ធត់ចិត្តណាស់ គ្រាដែលឃើញ ម្តាយនាងត្រូវទំងន់ដៃយ៉ាងដំណំ ។ នាងក៏ងើបស្ទុះទៅប្រទាញប្រទង់ឪពុកអោយ ឈប់ តែលោកសម្បត្តិលែងមានសតិទៅហើយ ដោយសារកំរោលស្រាជ្រាបចូល ពេញខ្លួន ។ លោកគ្មានសតិនឹងគិតថាអ្វីដែលលោកកំពុងប្រព្រឹត្តនោះវាយង់ឃ្នង ប៉ុណ្ណាទេ ។ ដោយទប់កំហឹងមិនបាន លោកក៏ជ្រុលដៃវាយភរិយារិតតែខ្លាំង ។ ក្រពុំចិត្តទ្រាំវេទនាភ្នែកមើលម្តាយដែលត្រូវឪពុកធ្វើបាបមិនបាន ក៏រត់ទៅប្រច្រាន ឪពុកនាងពីក្រោយយ៉ាងអស់ទំហឹង ធ្វើអោយរូបកាយលោកច្រលោតទៅមុខ ជាន់ខុសកាំជណ្តើរ ហើយរមៀលធ្លាក់តាំងពីជាន់ទីពីររហូតដល់ដី បាត់ស្មារតីឈឹង ភ្លាមមួយរំពេច ។

CHANBOKEO.COM

កាលបើឃើញដូច្នោះ ក្រពុំចិត្តភិតភ័យជាខ្លាំងណាស់ គិតអ្វីមិន ចេញទេ។ ស្រាប់តែដារិយ៉ាបរឡានចូលមកដល់ ចំពេលដែលក្រពុំចិត្តច្រានលោក សម្បត្តិធ្លាក់ចុះតាមកាំជណ្តើរ ។ នារីក៏ស្រែករឹងឡើង :

- នាងចិត្ត! ហេតុអ្វីបានជានាងធ្វើចំពោះលោកប៉ាបែបនេះ?

ដារិយ៉ាក៏ស្ទុះទៅស្ទាបដង្ហើមលោកសម្បត្តិ ហើយក៏ងើបឡើងចង្អុលមុខប្អូន :

- កូនទុរយស! ហេតុអ្វីហ៊ានសំលាប់ឪពុកយ៉ាងនេះ ? ហេតុអ្វី? ឬ ឯងមានបំណង ប្រុងលេបយកទ្រព្យសម្បត្តិរបស់គាត់?

ក្រពុំចិត្តមិនឆ្លើយទេ ក្រៅពីឈរធ្វើរញ៉ីរញ៉ៃរភិតភ័យឡើងស្លេកស្លាំងតែ ប៉ុណ្ណោះ។ រំពេចនេះ ដារិយ៉ាក៏លើកទូរសព្ទ័ឡើងហៅរកជំនួយ ។ ក្រពុំចិត្តតក់ស្លុត ខ្លាំងណាស់ ភិតភ័យខ្លាចត្រូវគេចាប់នាងទៅដាក់ឃុំក្នុងពន្ធនាគារ ម្លោះហើយ នាងក៏ស្រវាចង់ខ្មៅរបស់នាងរត់រឹងចេញទៅក្រៅយ៉ាងលឿន។

- នាងចិត្ត! ទៅណាហ្នឹង? ឆាប់មកវិញ! កុំទៅណា នាងចិត្ត!!

នៅជាន់ខាងលើ អ្នកស្រីជានីលើកដៃដង្ហោយហៅកូនខ្សាវ់ៗពីចំងាយ តែ.... ក្រពុំចិត្តមិនបានឮសំលេងអ្នកស្រីឡើយ ។

ក្រពុំចិត្តជិះម៉ូតូឌុបទៅដល់ជួបផល្លីននៅកន្លែងធ្វើការ តែផល្លីនប្រកែកមិន ហ៊ានទទួលយកនាងទៅផ្ទះរបស់ខ្លួនវិញទេ ត្បិតខ្លាចដារិយ៉ាហៅតម្រួតឱ្យតាមរក ក្រពុំចិត្ត នាំតែមានរឿងដល់នាង ។ ទីបំផុត ធិតាយើងក៏ក្លាយជាមនុស្សទាល់ច្រក មិនដឹងថាត្រូវគេចទៅខាងណាទៀត។ ណាមួយបើសិនជាឪពុកនាងនៅរស់រានមាន ជីវិតមកវិញ នោះលោកច្បាស់ជាមិនប្រណីនាងឡើយចំពោះអ្វីដែលនាងធ្វើចំពោះ លោកអំបាញ់មិញនេះ។ តែបើសិនជាលោកផុតជីវិតទៅវិញ ក្រពុំចិត្តក៏ត្រូវក្លាយ ខ្លួនជាឃាតករដែលសំលាប់ឪពុករបស់ខ្លួនឯងដែរ។ ម្យ៉ាងទៀត នាងក៏មិនព្រម ចូលខ្លួនអោយប៉ូលិស ចាប់នាងទៅដាក់គុកវិញដែរ។ នាងស្អប់បន្ទប់ងងិតណាស់ បន្ទប់ដែលឃុំរូបនាងអោយធ្លាក់អវិចីទាំងរស់ដូចកាលគ្រាថ្មីៗកន្លងមក។ ប៉ុន្តែ បើនាងដើរចេញទៅ តើម្តាយរបស់នាងនឹងការពារខ្លួនយ៉ាងណាវិញ? រួចចុះដារីយ៉ា តើនាងយល់សុខទុក្ខរបស់អ្នកស្រីជានីដូចក្រពុំចិត្តដែរឬទេ? ឬក៏កាន់ដៃកាន់ជើង ជាមួយឪពុករបស់នាង ហើយប្រមាថមើលងាយម្តាយរបស់ខ្លួនឯងវិញ ?

ក្រពុំចិត្តដើរទៅដើរមកនៅម្តុំមាត់ទន្លេតែម្នាក់ឯង។ រសៀលក៏កាន់តែជ្រេរ ទៅហើយ។ នៅទីបំផុត ឆវីក៏ដាច់ចិត្តឡើងម៉ូតូឌុបទៅឫស្សីកែវរកក្រុមគ្រួសារ របស់មិត្តនាងដែលឈ្មោះផាន់ណា។ លុះទៅដល់ ម្តាយផាន់ណាប្រាប់ថា គេបាន ចេញទៅរស់នៅជាមួយប្តីរបស់គេឯសេរីសោភ័ណ ព្រមទាំងអោយអាស័យដ្ឋាន នឹងលេខទូរសព្ទ័ទៀតផង។ ចែដន្យផ្ទះគាត់តូចង្អៀត កូនក៏ច្រើន មានទាំងកូន ប្រសារ មានទាំងចៅនៅជុំគ្នាព្រោងព្រាត បើនឹងអោយក្រពុំចិត្តសុំស្នាក់នៅក៏ពុំ សមរម្យឡើយ ម្លោះហើយ មាណវីក៏ដាច់ចិត្តជំរាបលាចេញមកវិញ។

ដើរចុះដើរឡើងមួយស្របក់ ឆវីក៏ហៅម៉ូតូឌុបជិះសំដៅចំណតឡានឈ្នួល ដើម្បីរកឡានជិះទៅសេរីសោភណ័ទាំងយប់។ មួយជីវិតហើយដែលនាងមិនដែល ដើរឆ្ងាយផ្ទះម្នាក់ឯងសោះ ជាពិសេសគឺដំណើរពេលយប់តែម្តង ។ កាលបើឃើញ សំលៀកបំពាក់របស់នាង នរណាក៏គេសំលឹងមើលនាងគ្រប់គ្នាដែរព្រោះនាងមិន បានស្លៀកពាក់របៀបអ្នកស្រុកធម្មតាៗសំរាប់ធ្វើដំណើរទៅណាមកណាទេ បែរជាស្លៀកពាក់តាមរបៀបអ្នកក្រុងសំបូរលុយចាយដើរលេងតែប៉ុណ្ណោះ។ គ្រោះជា ពេលនោះ មានរថយន្តមួយកំពុងរៀបចេញដំណើរល្មម។ ធិតាចូលទៅបង់ប្រាក់ ហើយក៏ឡើងទៅក្នុងរថយន្ត ព្រមជាមួយអ្នកដំណើរជាច្រើនទៀត។ បន្ទាប់មក រថយន្តក៏បរចេញគ្រឿនៗតាមផ្លូវជាតិលេខ៥ ពុះជ្រែកស្បៃរាត្រីដែលកំពុងតែវាត ដណ្តប់អំណាចលើប្រថពី។ ផ្ទៃមេឃក៏ចាប់ងងឹតមើលមិនយល់ មិនខុសពីចិត្ត ពិ អារម្មណ៍របស់តរុណីយើងនៅគ្រានេះទេ។ ពេលនេះ នាងគិតអ្វីលែងចេញហើយ

CHANBOKEO.COM

ក្រៅពីឈានដើរទៅមុខដោយឥតទិសដៅតែម្យ៉ាងប៉ុណ្ណោះ ។

ពិភពអន្ធការ

១. ងងិតអ្វីម៉្លេះ ឱ!ព្រះឥន្ទព្រហ្ម បេះដូងទទួលយំសុំក្ដីមេត្តា
លោកីយ៍ងងិតសាហាវឫស្យា យាយីប្រហារកូនសត្វស្លាបទន់ ។
២. តើខ្ញុំខុសអ្វីទើបជួបកម្មពៀរ ទទួលវេរាដ៏សែនទារុណ
បើកភ្នែកពេលណាយល់ទុក្ខវែងធ្ងន់ ម្នាក់ឯងវេកេពុនស្មើរក្ស័យមរណា ។
៣. រីព្រះសុរិយ៍យាងបាត់ដំណឹង ខ្ញុំបាត់ព្រលឹងឈឹងដូចអន្ធការ
វង្វេងវិលវល់មិនដឹងទៅណា វន្ទត់ឱរាផ្សាខ្លោចអារម្មណ៍ ។
៤. តើនៅព្រឹកស្អែកថ្ងៃរះវិញទេ តូចតន់មាសមេបៀមទុក្ខក្រៀមក្រំ
តើនរណាខ្លះយល់ជីវិតមុំ ឱព្រះឥន្ទព្រហ្មយាងបំភ្លឺផង!

យូរៗម្ដងរថយន្តឈប់ដាក់អ្នកដំណើរចុះរពុយៗតាមខែត្រ ។ ទំរាំមកដល់ផ្សារ ណាត់ក្រុងបាត់ដំបង ម៉ោងប្រហែលជិត១១យប់ទៅហើយ ។ លុះអ្នកដំណើរចុះអស់ រលើងនៅសល់តែអ្នកដំណើរពីរនាក់ គឺធិតាយើងនិងអ្នកបើកបរ ។ ដោយឃើញមាន អ្នកដំណើរតែម្នាក់ តៃកុងឡានមានឫកពារហាក់ដូចជាខ្ជិល :

- នាង! យើងនៅដេកម៉ាសន្ទុះសិនទេដឹង? ពូដូចជាអស់កំលាំងហើយវិលមុខយ៉ាង ណាមិនដឹងទេនេះ ?

ក្រពុំចិត្តភ្ញាក់ព្រើត នឹកក្នុងចិត្តតែម្នាក់ឯងថា :

- តើពូនេះលេងស្មៀតអីហ្នឹង? ឫ ក៏គាត់មិនស្រួលខ្លួនពិតមែន?

មាណវីក្រលេកមើលជុំវិញខ្លួន ឃើញអ្នកលក់បង្អែមចំណីសៀម រុះរើតូបលក់ ម្ដងមួយៗចេញទៅរកដេកពួនអស់ ។ វិថរាចរតាមផ្លូវវិញក៏ស្ងាត់ជ្រៀបដូចចោរ លួចសេះ ។ តើអោយនាងទៅស្នាក់នៅឯណាទៅកាលបើនាងមិនស្គាល់នរណាម្នាក់ សោះយ៉ាងនេះ? ពុទ្ធោអើយ! ហេតុអ្វីក៏ជីវិតនាងងងិតបែបនេះ? ពូតៃកុងឡាន ឃើញនាងនៅរារែកក៏ស្រដីថា :

- មីនាងឯងទៅដេកនៅបាំងក្រោយទៅ ហើយពូដេកបាំងមុខ ។ ចាំដល់ពូភ្ញាក់ជិត ភ្លឺ ចាំបន្តដំណើរទៀត? នែវើយ! កុំមើលមុខអញ្ចឹង! គ្នាមិនស្រួលខ្លួនពិតមែនណា.. អញគ្មានបំណងអាក្រក់អីលើឯងទេ វើយ ។

ថាហើយគាត់ក៏បើកទ្វារឡានចូលទៅដេក ។ ក្រពុំចិត្តឈរវេរានៅខាងក្រៅ មួយស្របក់ មើលទិសតំបន់ចុះឡើងឃើញទីក្រុងមានភាពស្ងាត់ជ្រងំ ក៏នឹកខ្លាច ហើយក៏បើកទ្វារឡានចូលសំងំនៅបាំងខាងក្រោយដែរ ។ តាមពិតធិតាយើងគេង មិនលក់ទេ ហើយក៏មិនងងុយដែរ ។ នាងគេងពិនិត្យគ្រប់សកម្មភាពរបស់ពូតៃកុង រហូតមិនហ៊ានធ្មេចមួយស្របក់សោះ ។ ក្រោយមក នាងឃើញគាត់ទាញប្រេងខ្យល់ មកហិតហើយឈ្លីក្បាលធ្វើអាការៈហាក់ដូចជាវិលមុខពិតមែន ។ បន្តិចមក ឃើញ គាត់ក្រោកដើរត្រេះត្រុះហាក់ដូចជានៅមិនសុខក្នុងខ្លួន ។ នាងក៏ងើបសួរ :

- ពូមិនស្រួលខ្លួនមែនហើយ! នៅម្ដុំនេះ ពូមានស្គាល់ពេទ្យឯណាទេ? ចាំខ្ញុំជូនទៅ!

- ស្គាល់ដែរ...តែពូរកប្រាក់ទិញបាយអោយកូនស៊ីមិនគ្រប់ផង តើធ្វើម៉េចនឹងមាន លុយទៅបង់ថ្លៃពេទ្យបាននោះ?

CHANBOKEO.COM

ឃើញកិរិយារបស់ពូតៃកុងឡានហាក់ដូចជាគ្មានពិសពុលអ្វី ធិតាយើងក៏ស្ងប់ អារម្មណ៍មកវិញ ហើយក៏បិទភ្នែកសំងំយកកំលាំង។ ប៉ុន្តែទោះជានាងប្រឹងធ្វេច យ៉ាងណាក៏មិនលក់សោះ ចេះតែមានអារម្មណ៍ពីភាល់ក្នុងចិត្តយ៉ាងណាមិនដឹង ។ លុះនាងក៏អើតទៅមើលពូនោះម្តងទៀត ឃើញគាត់កំពុងកោសខ្យល់អោយខ្លួន
គាត់ ។ នាងក៏សួរថា :

- ពូ! ពីនេះទៅសេរីសោភណ័ បើកឡានយូរប៉ុណ្ណាដែរ?
- គឺប្រហែលមួយម៉ោងប៉ុណ្ណឹងឯង ។
- អញ្ចឹង ពូអោយខ្ញុំបើកឡានជូនពូទៅទេ ខ្ញុំចេះបើក
- អូហ៍ មិនអីទេ មីនាង ! ចង់ប្រញាប់អោយឆាប់ដល់ផ្ទះឬអ្វីបានតឿនពូម្ល៉េះ?
- អត់ទេ ! ការពិតខ្ញុំចង់អោយពូឆាប់បានដល់ផ្ទះសំរាកទេតើ ។ ខ្ញុំអាណិតពូណាស់ ដែលត្រូវមកឈឺតាមផ្លូវហើយកោសខ្យល់ម្នាក់ឯង ។
- អឺ! មីនាងនិយាយដូច្នេះ ក៏ត្រូវដែរ ។ តោះយើង! ចេញទៅទៀតក្រែងឆាប់ដល់
អាលបានសំរាកផង!

ថាហើយពូនោះក៏ដើរចូលឡានបញ្ឆេះម៉ាស៊ីនបរចេញទៅ ទុកអោយក្រពុំចិត្ត អង្គុយនៅចាំងខាងក្រោយដដែល។ តាមផ្លូវក្រពុំចិត្តអង្គុយអោបថង់ខ្មៅជាប់ ជានិច្ច។ លុះរថយន្តបរមកដល់ជិតភូមិក្បាលខ្មោច ស្រាប់តែមានភ្លៀងធ្លាក់ខ្មោក១មកយ៉ាងខ្លាំងស្ទើរតែមើលផ្លូវមិនឃើញ ទោះបីពូយើងខំបើកភ្លើងហ្វាធំ ភ្លឺ ចិញ្ចាចយ៉ាងណាក៏ដោយ។
ខ្យល់ក៏បក់វូ១យ៉ាងខ្លាំងធ្វើអោយពូយើងរេចង្កូតឡាន ជាញឹកញាប់។ ឯមាណវីយើងភ័យស្រែកភ្លាត់សំលេងជាច្រើនដងដែរ ។ លុះបរមកដល់ជិតអូរតាគី ស្រាប់តែពូតៃកុងស្រែកឡើង :

- មីនាងអើយ... ពូឡើងឈាមទៀតហើយ ឈឺក្បាលហើយងងិតមុខណាស់ ...

ពេលនោះស្រាប់តែគាត់រេចង្កូតឡានពេញផ្លូវគ្រវីគ្រវាត់ ម្តងទៅឆ្វេង ម្តង ទៅស្តាំ។ ធិតាយើងឃើញគាត់ងើយ កផ្ងាកក្រោយហើយស្រែកវ៉ាសយ៉ាងខ្លាំង រួចក៏ទន់ខ្លួនទ្រោបលើចង្កូតរថយន្តវិញ ស្រាប់តែរថយន្តក៏វិលកងធ្លាក់ផ្លូវចុះស្មោម ភ្លោះមួយរំពេច។ ធិតាយើងភ័យណាស់លែងគិតអ្វីឃើញហើយ ក្រៅពីរំដោះជីវិត ផ្ទាល់ខ្លួនរបស់នាងអោយរួចគ្រោះថ្នាក់តែប៉ុណ្ណោះ។ នាងក៏ស្ទុះបើកទ្វារឡានលោត ចេញមកវឹង ធ្លាក់រមៀលចុះទៅក្នុងព្រៃគុម្ពោតក្បែរងថ្នាល់ជាតិនោះ រួចហើយក៏ សន្លប់បាត់ស្មារតីទៅ។

00 00
00

# វគ្គទី៨
# ព្យុះព្យោមា

សព្វថ្ងៃ នាងតូចសុធាចំរើនបានវ័យជាងពីរឆ្នាំហើយ ។ នាងចេះនិយាយតិច១ ថៃដន្យនាងឈឺច្រើនណាស់ មិនសូវជានាមានសុខភាពល្អដូចឈ្លូកម្តាយរបស់នាង ឡើយ ។ សព្វថ្ងៃសុជាតិនៅតែរត់ឡានឈ្នួលដដែល តែជីវភាពក្នុងគ្រួសារមានសភាពធូរធារជាងមុនច្រើនណាស់ ត្បិតឈ្លូកបានជួយដៃជើងសុជាតិពីមុខពីក្រោយ មិនទំនេរ ។ នាងបានទទូចសុំអោយសុជាតិសង់រោងចិញ្ចឹមជ្រូកមួយ និងរោងមាន់ មួយហើយបានទៅទិញកូនជ្រូកកូនមាន់មកបន្ថែមសំរាប់ចិញ្ចឹមទុកជួញដូររួច បន្ថយផ្នែកដំណាំថ្នាំជក់វិញ ព្រោះឈ្លូកឃើញសុជាតិនឿយហត់លំបាករែកទឹក ស្រោចរាល់ល្ងាចពេកណាមួយលក់មិនសូវបានកំរៃដូចមាន់ទាផង ។ ពិតមែនតែ ជីវភាពជាអ្នកជនបទនឿយហត់ផ្លូវកាយបន្តិចក៏ដោយ ក៏ឈ្លូកមានអារម្មណ៍ថានាងមានសេចក្តីសុខយ៉ាងពេញលេញបំផុត មិនដូចជីវិតទីក្រុងដ៏អាប់អួររបស់នាង កាលពីអតិតឡើយ ។ មានពេលខ្លះនាងលួចសំរក់ទឹកភ្នែកនឹករលឹកដល់ឪពុកម្តាយ និង ក្រុមគ្រួសារ តែមីងសោមក្តី សុជាតិឬសុខាក្តី តែងតែផ្តល់នូវភាពរីករាយរមនាក្នុងគ្រួសារចំពោះនាងជានិច្ច ។ សេចក្តីស្រលាញ់ដ៏ធំធេងរវាងសមាជិកក្រុមគ្រួសារ មីងសោមបានធ្វើអោយឈ្លូកមានអារម្មណ៍ថាជីវិតកក់ក្តៅក្នុងក្រុមគ្រសារជា ប្រភពនៃសេចក្តីសុខនៅក្នុងចិត្តរបស់មនុស្សយើង  មិនមែនលុយ មិនមែនអំណាច មិនមែន ទ្រព្យសម្បត្តិ មិនមែនវណ្ណៈ ឬ រូបសម្ផស្សឡើយ  ។ មើលចុះ! សុជាតិ មានមាឌធំសំបុរខ្មៅសក់រួញ បើមើលមួយក្រលេក សមតែជាមនុស្សទុចរិតកាចយង់ឃ្នង ផ្ទុយទៅវិញ នាយប្រែទៅជាមនុស្សដែលមានសន្តានចិត្តប្រពៃ គួរគោរព បំផុត ។ ចំណែកមីងសោមជាមនុស្សពិការភ្នែកមែនតែគាត់មានចិត្តគំនិតភ្លឺថ្លា ស្រលាញ់កូនថ្នមចៅដោយយកធមិព្រះជាធរមាន ទូន្មានកូន១យ៉ាងប្រពៃ ។ ចំពោះសុខាដែលជាក្មេងស្រីពិការជើងដើរបុំងញៀចមិនរឹងប៉ឹងដូចអ្នកផងទូទៅទាំងឡាយ តែនាងមិនដែលខ្ជិលច្រអូលមិនដែលតូចចិត្តនឹងវាសនារបស់នាងឡើយ ។ ថ្ងៃណា ក៏ដូចថ្ងៃណាដែរ នាងតែងតែមានអារម្មណ៏រីករាយជានិច្ច ហើយចូលចិត្តច្រៀងលេងទៀតផង ។ មានកាលខ្លះ សុជាតិជាអ្នកនិពន្ធបទអោយច្រៀង ប៉ុន្តែ មានកាល ខ្លះទៀតដែលសុជាតិរវល់ឈ្លូកក៏និពន្ធទំនុកអោយសុខាច្រៀងជំនួស ។ រីឯបទ ចំរៀងដែលសុខាចូលចិត្តច្រៀងជាងគេនោះគឺបទ" ចំរៀងគ្រួសារយើង" ដែលឈ្លូកបាននិពន្ធអោយនាងកាលពីបីឆ្នាំមុន ។ សព្វថ្ងៃសុខាធំពេញវ័យជាស្រីក្រមុំស្មាវម្នាក់ យ៉ាងស្រស់ប្រិមប្រិយ ។ ឈ្លូកលួចនឹកគិតក្នុងចិត្តថាបើសុខាមានរូបកាយល្អប្រក្រតី ដូចគេដូចឯង ម៉្លេះសមឈ្លូកនាំប្អូនទៅប្រកួតបវរកញ្ញានឹងគេហើយ ។

រសៀលនេះ ឈ្លូកកំពុងឈររាប់កូនមាន់ដែលទើបនឹងញាស់ ហើយនិងរាប់ជ្រូកដែលនាងត្រូវអោយសុជាតិដឹកទៅលើកអោយអ្នកទទួលកាប់នៅផ្សារនាវេលា ស្អែកព្រហាម  ស្រាប់តែនាងឮសំលេងម៉ូតូមួយមកដល់ ។ ភ្លាមនេះសុធាក៏រត់ត្រេ ចេញទៅទទួល ព្រមទាំងស្រែកថា :

- ប៉ា!

សុជាតិចតម៉ូតូហើយក៏ស្ទុះទៅលើកពសុធាឡើង ហើយថើបខ្សឹតដោយ សេចក្តីស្រលាញ់ :

- ធា! មានទឹកដែរប៉ាទេកូន?

CHANBOKEO.COM

សុជាតិនិយាយផង លួចដៀងភ្នែកដាក់ទៅឈូក ដែលកំពុងអោយបាយជ្រូក នោះផង។ ឈូកឮហើយតែមិនឆ្លើយទេ សុខចិត្តនៅឈរចោលកន្ទុយភ្នែក ធ្វើមុខ ញញឹមដាក់សុជាតិមកវិញ ធ្វើពើដូចមិនបានយល់អីអញ្ចឹង ។ សុខាឃើញហើយ យល់អត្ថន័យភ្លាម ក៏ឆ្លើយជំនួស :

- មានគេនឹកបងរាល់តែថ្ងៃហ្នឹង បងជាតិមិនដឹងទេហ៎?
- អ្នកណាគេហ៎ទៅហ្ន៎?
- គឺសុខានោះអី... ហ៉ែស១!

សុខាសើចក្អឹក១ លលេងនឹងបងប្រុសយ៉ាងសប្បាយ ។ សុជាតិខ្នាញ់ពេកក៏ចាប់ ច្របាច់ច្រមុះសុខាលេង ធ្វើអោយសុធាសើចទះដៃក្អាកក្អាយដែរ ។ ព្រលប់នោះ ក្រោយពេលបាយរួច អ្នកទាំងអស់គ្នាអង្គុយដំកង់ជុំវិញសុធា ដែលកំពុងរត់ទៅ រត់មកប្រលែងលេងនឹងគ្រប់ៗគ្នា ។ រំពេចនោះសុខាក៏ចាប់ច្រៀងឡើង ដោយមាន សុធាជាតួសំដែងរបាំបន្ទរផង :

មេអំបៅ

| | | | |
|---|---|---|---|
| ១. | ក្នុងសួនឧទ្យាន | ស្អាតដូចវិមាន | ស្ថានសួគ៌ាល័យ |
| | សត្វមេអំបៅ | ហិចហើរសប្បាយ | ត្រអាលមិនណាយ |
| | | លំអងបុប្ផា ។ | |
| ២. | រេរាំរវិច | ពីកើតដល់លិច | ភ្លន់ភ្លេចអាត្មា |
| | វង្វេងស្មារតី | នឹងក្លិនគន្ធា | ស្រោចស្រពទ័យា |
| | | រំភើបដួងចៃ ។ | |
| ៣. | ឱ! មេអំបៅ | ស្លាបលឿងឆ្នូតខៅ | រេរាំសប្បាយ |
| | អ្នកមានសេរី | ពុំមានខ្វល់ខ្វាយ | គិតតែរីករាយ |
| | | ក្អាកក្អាយគ្មានភ័យ ។ | |
| ៤. | ឱ! សត្វវរនាថ | លំអធម្មជាតិ | ឧទ្យានព្រឹក្សព្រៃ |
| | ចិត្តអើយប្រាថ្នា | សូមមានសេរី | មង្គលសួស្តី |
| | | ដូចមេអំបៅ ។ | |

បរិយាកាសក្នុងគ្រួសារនាគ្រានេះ មានសភាពសប្បាយមនោរម្យក្រៃលែង ។ គ្រានេះរឿងអតីតកាលអាក្រក់១បានរលប់ស្រមោល ពីដួងចិត្តនិងអារម្មណ៍របស់ ឈូកស្ទើរអស់រលីងទៅហើយ នៅសល់តែសៀវសុភមង្គល និងសួរសំណើចនៃ សេចក្តីស្រលាញ់ក្នុងគ្រួសារថ្មីរបស់នាងតែប៉ុណ្ណោះ ។ រំពេចនោះ សុជាតិបាននាំនាំ ដំណឹងមួយយ៉ាងសប្បាយដល់គ្រួសាររបស់នាយ :

- ម៉ែ! នៅថ្ងៃស្អែកនេះ គេមានធ្វើបុណ្យធំមួយនៅទីរួមខេត្តបាត់ដំបង ហើយមាន ការសំដែងសិល្បៈនិងការប្រកួតចំរៀងទៀតផង។ ខ្ញុំគិតថាគ្រួសារយើងមិនដែល បានទៅដើរលេងឯណាជុំគ្នាទេ បើយើងទៅលេងបុណ្យជាមួយគ្នាម្តង មិនដឹងជា សប្បាយយ៉ាងណាទេ? តើម៉ែអញ្ជើញទៅជាមួយពួកយើងទេហ៎?

ការពិតទៅ សុជាតិឃើញឈូកលាក់ខ្លួនពួនកាយយូរឆ្នាំមកហើយ មិនដែល ចេញទៅណាម្តងឡើយ ក្រៅពីទៅធ្វើបុណ្យនៅវត្តគ្រាំង ។ សូម្បីតែត្រឹមមាត់ថ្នល់ ជាតិភូមិអូរតាគីក៏មិនងាយទៅដល់ផង ។ មាណពចង់អោយនាងចេញដើរក្រៅខ្លះ១ អោយស្រលះមុខមាត់បន្តិច ណាចង់ផ្លាស់ប្តូរបរិយាកាសផង ។ ស្រាប់តែមីងសោម មានប្រសាសន៍ថា :

- ល្អើយកូនអើយ! ម៉ែមើលមិនឃើញដូច្នេះ ទោះជាទៅក៏ម៉ែមើលអ្វីមិនកើតដែរ ទុកឱ្យម៉ែនៅចាំយាមជ្រូកយាមមាន់នៅផ្ទះទៅចុះ ។

CHANBOKEO.COM

លុះឈ្លូកឮមីងសោមពោលដូច្នោះ នាងក៏ស្រដីឡើងដែរ :

- យើងទុកអោយម៉ែយាមផ្ទះម្នាក់ឯងមិនបានទេ បើម៉ែមិនទៅ ខ្ញុំសុខចិត្តនៅផ្ទះ ជួយមើលផ្ទះជាមួយម៉ែចុះ ។

- អុំញនោះ អស់ពីរនាក់ស្រេចហើយ បងជាតិ ។

សុខាសំដែងទឹកមុខហាក់ដូចជាខកចិត្តណាស់ ត្បិតនាងកំពុងតែនឹងចង់ទៅ លេងបុណ្យសឹងស្លាប់ទៅហើយ ។ សុជាតិឃើញដូច្នោះក៏ទទូចសុំម្តាយថា :

- យើងទៅទាំងអស់គ្នាណាំម៉ែ ពិតមែនតែម៉ែមើលមិនឃើញ តែម៉ែអាចស្តាប់បាន តើហ៏ ។ ម្យ៉ាងទៀត ខ្ញុំចង់យកសុខាអោយទៅចូលប្រលងចំរៀងនឹងគេផង ។

- អូហ៍ មែនហ្មែសកូន? អញ្ជើងម៉ែទៅដែរ ។

មែនហើយ លុះដល់មីងសោមគាត់ព្រមទៅដែរ ឈ្លូករកពាក្យដោះសាររក ចៀសមិនព្រមទៅមិនបានសោះ ។ មួយសន្ទុះមក នាងក៏មានវាចាថា :

- បងជាតិនាំសុខានិងម៉ែទៅចុះ ។ ឈ្លូកគិតថា នៅផ្ទះដាំបាយទុកជូនអ្នកទាំងអស់ បរិភោគវិញ ណាមួយសុធានៅតូចពិបាក ពចុះពឡើងណាស់ ។

តែសុជាតិនៅតែទទូច :

- ឈ្លូក! ទៅដែរទៅណាំអូនណាំ! ចាំបងជួយមើលកូនធា មិនឱ្យអូនពិបាកទេ!

ឈ្លូកនៅស្ងៀមមិនហ៊ានប្រកែក ខ្លាចខូចទឹកចិត្តសុជាតិក៏ញញឹមហើយនៅ ស្ងៀម តែក្នុងចិត្តហាក់ដូចជាមានពិភាល់យ៉ាងម៉េចមិនដឹង ហាក់ដូចជាមិនចង់ ចេញទៅណាសោះឡើយ ក្រៅតែពីចង់នៅផ្ទះអត្តខាត់មួយនេះ ព្រោះនៅទីនេះ នាងបានទទួលសេចក្តីសុខបំផុត ។

ព្រឹកស្អែកឡើង....

សុជាតិកំពុងតែរៀបចំក្រាលកន្ទេលក្នុងរ៉ឺម៉កទ្រុងដែលភ្ជាប់ពីក្រោយម៉ូតូរបស់ នាយ ស្រាប់តែសុខា ពនាងតូចមកដល់ :

- ស្លាប់ហើយ បងជាតិ! ថ្ងៃនេះ ពាក់អាវថ្មីឡូយណាស់!

សុជាតិឈ្ងោកមើលខ្លួនឯងហើយញញឹមឡើង :

- គឺ បងពាក់អាវដែលប្រពន្ធបងគេខំដេរអោយណាំ ជាអាវដែលបង្កប់ដោយក្តី ស្រលាញ់នោះអី! ពាក់វាកាលណា សប្បាយចិត្តកាលហ្នឹង!

សុខាមើលម្តងទៀតហើយក៏សើចលាន់ខឹក១ :

-គួរអាណិតបងឯងណាស់... បងឈ្លូកគាត់ខំដេរអោយពីម្សិល តែនៅខ្វះឡេវពីរ ទៀត គិតថាចាំទៅទិញដេរដាក់ថែមថ្ងៃក្រោយ ។ ឥលូវមិនទាន់ដេរដាក់ឡេវគ្រប់ ផង បងយកវាពាក់បាត់...

- អឺ១! បងដាក់ម្ជុលខ្ទាស់ពីក្នុងហើយ ហើយបងក៏យកក្រមារុំចងចង្កេះលប់វាពីលើ ហើយ... រួចការស្រេច នែ៎! សុខា! បងថាមិនអីទេណាំ! ប្អូនកុំឈរមើលមុខបង សើចកខឹកយ៉ាងហ្នឹងអញ្ជើងមើល៍...!

សុខានៅតែសើចដាក់បងប្រុសខឹក១អត់ឈប់ ។ លុះក្រលេកឃើញរ៉ឺម៉កទ្រុង របស់សុជាតិ ស្រាប់តែនាងបើកភ្នែកធំ១ លាន់មាត់ឡើង !

- ពុទ្ធោបងជាតិ! ពួកយើងខំស្លៀកពាក់យ៉ាងស្អាតទៅលេងបុណ្យនៅឯក្រុង បាត់ដំបង ហើយម៉េចក៏បងអោយពួកយើងជិះរ៉ឺម៉កដឹកជ្រូករបស់បងនេះទៅវិញ? ពុទ្ធោអើយ! តិចគេគ្រប់គ្នាឃើញហើយច្រលំថាពួកយើងជាជ្រូកដែរទៅ?

សុជាតិឮហើយសើចខឹក១ឡើងដែរ :

- ហ៉ស១... ជិះអានេះហើយវាមិនអស់លុយថ្លៃសោហ៊ុយឡានផង ។

CHANBOKEO.COM

រំពេចនោះ ឈូកនាំមីងសោមមកដល់មានកាន់ចានស្រាក់បាយមកតាមផង ។

សុជាតិឃើញហើយក៏លាន់មាត់ថា :

- អូហ៎! ម៉ែចង់ទៅវត្តដែរ?

- អត់ទេ! ម៉ែដាក់បាយដាក់ម្ហូបទៅតាម ពេលឃ្លានកុំអោយពិបាកទិញគេនោះអី ។

- យកទៅធ្វើអីនាំតែសំពីងសំពោងទេម៉ែ ! យើងចាំទិញចំណីនៅកន្លែងបុណ្យ ទទួលទានក៏បានដែរ ។

ឈូកឮដូច្នោះក៏និយាយលើកទឹកចិត្តមីងសោមថា :

- ម៉ែគាត់ចង់ជួយសន្សំប្រាក់ឱ្យយើងណាំបង! ម្យ៉ាងទៀតម្ហូបផ្ទះយើងឆ្ងាញ់ផង កុំទៅទិញរបស់គេអី ខ្លាចទទួលទានមិនត្រូវមាត់ ។

ឮឈូកពោលសមហេតុផល សុជាតិក៏នៅស្ងៀមហើយញញឹម :

- អញ្ចឹង យើងប្រញាប់ចេញទៅ ។

សុជាតិក៏ឡើងម៉ូតូអូស៊ីម៉ាកទ្រុង ដឹកស្រី៧បួននាក់នៅពីក្រោយចេញដំណើរទៅ។ តាមផ្លូវ ឈូកមានអារម្មណ៍ប្លែកណាស់ ។ តាំងតែពីនាងបានមករស់នៅ ជាមួយក្រុមគ្រួសាររបស់សុជាតិមក នេះជាលើកដំបូងហើយដែលនាងបានស្គាល់ ថ្ពល់ជាតិសាជាថ្មី ។ តែពេលនេះ នាងមិនដូចរូបនាងពីមុនទេ ។ នាងគឺជាមនុស្សថ្មី លក្ខណៈជានារីជនបទ ស្លៀកពាក់ខ្មៅៗរុំក្រមាជិះរ៉ឺម៉កទ្រុង ដូចជាយ៉ាងណាមិន ដឹងសោះ ប៉ុន្តែនាងក៏សប្បាយចិត្តបំផុតដែរព្រោះពេលនេះនាងមិនមែនជាមនុស្សរស់នៅកណ្តោចកណ្តែងតទៅទៀត ។ ឥលូវ នាងមានកូនស្រីមួយដ៏ស្រស់ស្អាត មានម្តាយដែលប្រកបដោយព្រហ្មវិហារធម៌ មានបុរសដែលយល់ចិត្ត យល់ទុក្ខធុរៈ របស់នាងហើយនិងប្អូនស្រីដែលស្រលាញ់នាងបំផុត ។ ថ្វីបើពេលនេះ នាងមានការខ្វះខាតក្នុងជីវិតខ្លះៗដែលនាងត្រូវសំរបសំរួលតាមបែបជីវិតអ្នកក្រីក្រ ក៏មាណវី យើងមានអារម្មណ៍រំភើបសប្បាយជាងពេលណាទាំងអស់ក្នុងជីវិត ។

តាមផ្លូវ នាងឃើញអ្នកស្រុករាំដៃដាក់សុជាតិ ស្រែកហៅសួរសុខទុក្ខ ។ ខ្លះទៀតក៏ដឹកកូនចៅក្រុមគ្រួសារទៅលេងបុណ្យដែរ មើលទៅគេម្នាក់ៗរាក់ទាក់នឹង គ្នាណាស់ មិនដូចអ្នកទីក្រុងទេ ដែលសូម្បីតែមនុស្សរស់នៅជាប់ជញ្ជាំងគ្នាក៏មិន ដែលស្គាល់គ្នា ឬនិយាយរកគ្នាផង ។ មួយស្របក់ធំក្រោយមក សុជាតិក៏បាននាំសមាជិកក្រុមគ្រួសាររបស់នាយមកដល់ក្រុងបាត់ដំបង ។ ថ្ងៃនេះ នៅទីក្រុងមាន មនុស្សណែនណាន់ខ្ពាន់ខ្ពាប់ មានចរាចរអ៊ូអរ មានអ្នកលក់នំចំណីព្រោងព្រាត ។ ឈូកសំលឹងមើលមនុស្សម្នាដែលធ្វើដំណើរទៅមកអោយរចល់ ស្រាប់តែឃើញមានរថយន្តមួយដាក់មេក្រូប្រកាសថា :

- ថ្ងៃនេះយើងមានកម្មវិធីប្រលងចំរៀងពិសេស សំរាប់បុរសនារីទាំងឡាយ អ្នក ដែលបានជាប់រង្វាន់លេខមួយ នឹងបានទទួលប្រាក់ ១០០ដុល្លារ អ្នកដែលជាប់...

ឈូកឮដូច្នេះក៏បបួលសុខា :

- បើសិនសុខាឡើងប្រលង បងថា ប្អូនច្បាស់ជាទទួលពានមាសហើយ!!

សុខាឮហើយញញឹម រួចស្រែកប្រាប់បងប្រុសថា :

- បងជាតិ កន្លែងប្រលងចំរៀងនៅខាងណា? សុខាចង់ទៅចុះឈ្មោះ ។

- អឺ! ចាំបងនាំទៅ តែបើអូនបានរង្វាន់ កុំភ្លេចចែកបងពាក់កណ្តាលណាំ

- ចាស១! យកទាំងអស់ក៏យកទៅ! (សុខាសើចខឹក១ដោយក្តីរីករាយ)

CHANBOKEO.COM

នៅលើវេទិកាប្រលងចំរៀង....

សុខាក៏បានទទួលនាទីឡើងមកប្រកួតជាលើកដំបូង ។ ប៉ុន្តែគួរអោយស្ងើចនាង ណាស់ នាងឡើងវេទិកាជាលើកដំបូងក្នុងសំលៀកនិងការតុបតែងខ្លួន តាមរបៀប អ្នកជនបទសុទ្ធសាធ តែនាងបែរជាគ្មានឬកពារភ័យញាប់ញ័ររន្ធត់អ្វីឡើយ ។ នាង ងើយមុខសំលឹងទៅទស្សនិកជន និងគណៈមេប្រយោគដោយភាពរឹងប៉ឹងក្លាហាន ហើយញញឹមរហូត  ព្រមទាំងបន្លឺសំនៀងដូចតទៅ :

- នាងខ្ញុំសុខា សូមឧទ្ទិសបទចំរៀងនេះជូនម្តាយរបស់ខ្ញុំនិងជូនស្ត្រីទាំងឡាយដែល ជាម្តាយរបស់គេ....

ម៉ែអើយ...

១. រំយំរយពាន់សាយណ្ហ៍សុរិយេ ដូចសំនៀងម៉ែបំពេរបូកូន
វាតារំភើយរាត្រីស្ងាត់សូន្យ ទឹកដៃម៉ែស្ងួនថ្នមកូនអោយគេង ។

២. ទ្រូងម៉ែកក់ក្តៅបំបៅកូនក្សាន្ត រក្សាកុំផានធូនថើបប្រលែង
ទឹកហូររអឺករណ្តំគ្រាំគ្រេង បំភ្លេហាក់ភ្លេងសំណើចអ្នកម្តាយ ។

៣. ទោះម៉ែកំសត់ក៏ប្រឹងញញឹម ផ្តល់ក្តីសង្ឃឹមដល់កូនប្រុសស្រី
វាចាទូន្មានពិរោះមានន័យ ម៉ែអើយបុត្រថ្លៃអាល័យព្រះគុណ ។

៤. ឃ្លាតពីអ្នកម្តាយកាយកូនឯកា នៅក្នុងចិន្តាកូនប្រណម្យបន់
សូមកំលាំងចិត្តពីម៉ែមានបុណ្យ គ្រោះភ័យអាសន្នបន់រកម៉ែស្ងួន ។

៥. ម៉ែឃ្លាតទៅចោលស្រមោលម៉ែនៅ ក្នុងបេះដូងជ្រៅនៃគ្រប់ផងកូន
ទោះឈានទីណាវិញ្ញាណម៉ែពូន ក្នុងឱរាកូនលុះសង្ខាររលត់.... ។

ស្នូរទះដៃក៏លាន់រំពងឡើងម្តងហើយម្តងទៀត ទាំងទស្សនិកជន ទាំងគណៈ មេប្រយោគ ទាំងគណកម្មការទាំងឡាយ នាំគ្នាក្រោកឈរទះដៃយ៉ាងទ្រហឹងអឹង អាប់ត្បិតពេញចិត្តនឹងសំនៀងដ៏សែនពិរោះរបស់នាង ថែមទាំងរំភើបចិត្តចំពោះ អត្ថន័យរបស់ទំនុកចំរៀងដ៏មានខ្លឹមសារជ្រាលជ្រៅនោះទៀតផង ។ មីងសោម អង្គុយស្តាប់កូនបណ្តើរជូតទឹកភ្នែកបណ្តើរ ហាក់ដូចជាកំពុងស្រណោះខ្លួនដែលជា ម្តាយមួយរូប ។ សុជាតិឃើញឈូកអង្គុយអោបកូនស្រី មានទឹកភ្នែករលីងរលោង ក៏លូកដៃមកកាន់ដៃរបស់ឈូកយ៉ាងណែន ដើម្បីផ្តល់នូវភាពកក់ក្តៅរឹងប៉ឹងក្នុងចិត្ត ដល់នាង ។ នៅដៃម្ខាងទៀតក៏ស្រវាអោបម្តាយសំដែងនូវសេចក្តីស្រលាញ់យ៉ាង ជ្រាលជ្រៅចំពោះគាត់ ។ ភ្លាមនោះ គណៈមេប្រយោគមួយរូបក៏សម្ភាសសុខាថា :

- សូមសួរអ្នកនាងសុខា   ថាតើអ្នកនាងជាអ្នកនិពន្ធបទនេះ    ឬក៏អ្នកនាងមានគ្រូ ជួយណែនាំតែងបទនេះឡើងដើម្បីយកមកប្រលងថ្ងៃនេះ?

សុខាក៏ឆ្លើយឡើងយ៉ាងក្លាហានថា :

- ចាស ! បទចំរៀងមួយបទនេះ បាននិពន្ធឡើងដោយមនុស្សបីនាក់ ទីមួយគឺ ម្តាយខ្ញុំដែលផ្តល់សេចក្តីកក់ក្តៅអោយកូនជានិច្ច ទីពីរគឺបងប្រុសដែលជាអ្នកនិពន្ធ បទភ្លេង ហើយទីបីគឺបងស្រីដែលជាអ្នកនិពន្ធទំនុកដ៏អត្ថន័យ ។

ស្នូរទះដៃបានរណ្តំឡើងសាជាថ្មី ។ រសៀលនោះ សុខាបានទទួលជ័យលាភីជា តារាឯកប្រចាំការប្រកួតនៅថ្ងៃនោះ ថែមទាំងបានប្រាក់រង្វាន់យ៉ាងច្រើនលើសពី ការប្រកាសរបស់ក្រុមគណកម្មការទៅទៀតដោយហេតុថា នាងបានទទួលរង្វាន់ពី សំណាក់ភ្ញៀវដែលមកចូលទស្សនាយ៉ាងកុះករនោះបន្ថែមពីលើ ។ សុខាត្រេកអរ រំភើបរហូតរលីងរលោងទឹកភ្នែក ។ នៅមុនបញ្ចប់

CHANBOKEO.COM

គណៈកម្មការបានស្នើសុំ ស្គាល់ក្រុមគ្រួសាររបស់សុខាដើម្បីថតរូបទុកជាឯកសារ ។ ដំបូងទាំងអស់គ្នាប្រកែក ជាពិសេសគឺឈ្យូកតែម្តង ។ តែលុះដល់គណកម្មការចេះតែទទូច ហើយសន្យាថែម រង្វាន់អោយសុខាដល់ទៅ៥០ដុល្លារទៀត ធ្វើអោយសុខានឹកស្តាយប្រាក់ដែលគេបន្ថែមអោយនោះណាស់ ។ នាងក៏ទទូចអោយទាំងអស់គ្នា ក្រោកឈរឡើងមក បង្ហាញខ្លួនជាមួយនាងលុះត្រាតែបាន ។ ស្រាប់តែរន្ទះភ្លើងកាម៉ារ៉ាក៏ប្រកួតគ្នាចាំង ភ្លែត១ដេញតាមវត្តមានរបស់អ្នកទាំងប្រាំរូប ។ ឈ្យូកញាប់ញ័រក្នុងចិត្តដោយការភិតភ័យក្រៃលែងដែលនាងត្រូវចេញមុខនៅក្រោមពន្លឺកាមារ៉ាព្រោងព្រាតដូច្នោះ ។ កំពុងតែទាញក្រមាយកបាំងមុខស្រាប់តែឈ្យូកឮសូរសំលេងបុរសស្ត្រីពីរបីនាក់ ឧទានឡើងព្រម១គ្នាថា :

- ក្រពុំចិត្ត! នោះគឺក្រពុំចិត្តតើហ៎! នែហ៎! ឈប់សិន!! ឈប់!

គេក៏ប្រវេប្រវាវែកហ្វូងការីកាមារ៉ាស្ទុះទៅរកឈ្យូក តែនាងបែរជាស្ទុះលើក សុធាពឡើងហើយរត់គេចយ៉ាងលឿន ។ ថៃដន្យនៅទីណាទិសណាក៏ដោយ ក៏មានសុទ្ធតែមនុស្សកកកុញស្អេកស្កះមិនអាចឈានទៅណារួចឡើយ ។ នាងក៏ត្រូវបុរសម្នាក់អូសនាងថយក្រោយហើយស្រវាបោចក្រមាចេញពីក្បាលនាងទៀត ថែមទាំង ឧទានយ៉ាងភ្ញាក់ផ្អើល ថា :

- នាងចិត្ត! គឺឯងទេតើ!! ហេតុអ្វីក៏ស្រមេកស្រមកមើលមិនយល់យ៉ាងនេះ?

ឈ្យូកនៅឈ្ងោកមុខភ័យញ័រដៃញ័រជើងនិយាយមិនចេញទេ ។ សុជាតិឃើញហេតុការណ៍ដូច្នោះភ្លាមក៏ស្ទុះយកខ្លួនទៅពាំងការពារឈ្យូកថែមទាំងស្រដីសួរថា :

- លោកជានរណា? ហេតុអ្វីចាំបាច់ប្រើកំលាំងបាយធ្វើបាបមនុស្សស្រីទន់ខ្សោយ ដូច្នេះផង?

បុរសនោះក៏ឆ្លើយវិញថា :

- យើងជាឳពុកវា មានសិទ្ធិជេរស្តីវ៉ៃកូនជានិច្ច ហើយចុះឯងជានរណាដែរ ដែល ហ៊ានមាត់ធំមាត់តូចដាក់យើង?

សុជាតិភ្ញាក់ស្រលាំង ហើយមានអារម្មណ៍ហាក់ដូចត្រូវខ្សែភ្លើងឆក់អញ្ចឹង ។ ព្រះ អើយ! បុរសចំណាស់ដែលពាក់ចិញ្ចៀនពេជ្រយ៉ាងធំហើយចាំងសឹងខ្វាក់ភ្នែក មានផ្កាយពាក់នៅលើស្មាមានអង្គរក្សហែហមជុំជិតនោះឬជាឳពុករបស់ឈ្យូក? សុជាតិសឹងមិនជឿភ្នែកខ្លួនឯងឡើយ ។ នាយស្រវាកាន់ដៃឈ្យូកក្តាប់យ៉ាងណែនមិន ឱ្យរបេះហើយពោលទាំងរន្ធត់ចិត្តទៅកាន់ឈ្យូកថា :

- ឈ្យូក! ប្រាប់បងមក៏ ថា អ្វីដែលបុរសនេះនិយាយជាការពិត មែនទេអូន?

តែឈ្យូកនៅតែមិនស្រដី ឃើញតែស្រក់ទឹកភ្នែកហើយនៅឈរធ្មឹងស្ញៀមស្ងាត់ ដដែល ។ មីងសោមកាន់ដៃសុខាជាប់រង់ចាំស្តាប់ស្ថានការណ៍ទាំងភិតភ័យតក្កមា ។ ម្នាក់១ឈរធ្វើភ្នែកឡឹងឡង់១ ។ រំពេចនោះនារីស្រស់ក្មេងរូបសោភាម្នាក់ក៏ចេញវាចាឡើងថា :

- ក្រពុំចិត្ត ! ឃើញប៉ាម៉ាក់ ឃើញបងស្រីហើយ មិនជំរាបសួទេហ៎?

ឈ្យូកងើបមុខឡើង ឃើញស្ត្រីពីររូបឈរទន្ទឹមគ្នានៅចំពោះមុខនាង ម្នាក់ ចាស់ ម្នាក់ក្មេង ហើយក៏ឧទានខ្សិប១ :

- ម៉ាក់! បងដារិយ៉ា!

មែនហើយ នោះគឺអ្នកស្រីជំទាវដានីដែលកំពុងមានទឹកភ្នែករលីងរលោងពេញ រង្វង់កែវនេត្រា ។ ឯម្នាក់ទៀតគឺដារិយ៉ាបងស្រីរបស់នាងតែម្តង ។ តើខ្យល់អ្វីទៅ ហ្ន៎ ដែលបក់គេទាំងបីអោយមកជួបនាងថ្ងៃនេះ កាលបើនាងប្រាថ្នារត់គេចពី

CHANBOKEO.COM

អ្នកទាំងបីរស់មួយជីវិតរបស់នាង? តែពេលនេះ ទោះនាងចង់ប្រឹងរត់គេច ក៏រត់ លែងរួចដែរ ។ លុះប្រទះឪពុករបស់ខ្លួនហើយ ឈូកក៏មិនព្រមស្តីរកលោកទេ សូម្បីតែសំលឹងមុខលោក ក៏មិនធ្វើផង ។ ភ្លាមនោះ លោកសម្បត្តិដែលជាឪពុក ក៏មានប្រសាសន៍ឡើង :

- ដារិយ៉ា! នាំនាងចិត្តទៅផ្ទះអីលូវនេះភ្លាម ! យើងមានការនិយាយគ្នាបន្តិច ។

ដារិយ៉ាក៏ស្ទុះទាញដៃប្អូន :

- តោះ! ទៅផ្ទះ!

តែឈូកនៅឈរទ្រឹងមិនព្រមដើរទៅមុខឡើយ ។ សុជាតិឃើញដូច្នោះក៏យក ដៃនាយទៅពាំងពីមុខឈូកភ្លាម :

- ឈូកមិនអាចទៅជាមួយលោកបានទេ! ព្រោះអីឈូកបានក្លាយជាសមាជិក របស់គ្រួសារខ្ញុំហើយ !

លោកសម្បត្តិបែរក្រោយ សំលឹងសុជាតិ :

- ហើយចុះឯងជាស្អីដែរ ដែលហ៊ានហៃហៃដាក់យើងយ៉ាងនេះ.?

សុជាតិព្រួហើយភ័យបែកញើស តែខំប្រឹងតាំងចិត្តក្លាហានការពារឈូកដែល កំពុងភិតភ័យញ័រដៃញ័រជើង :

- គឺ....គឺខ្ញុំ... ជាប្តីរបស់នាង ! យើងជាប្តីប្រពន្ធនឹងគ្នា លោកបំបែកយើងទាំងពីរ នាក់មិនបានទេ ។ ម្យ៉ាងទៀតយើងមានកូនជាមួយគ្នាហើយ... មេត្តាកុំបំបែកយើង

អី... អោយខ្ញុំសូមអង្វរ... (សុជាតិលើកដៃសំពះលោកសម្បត្តិ)

ឈូកព្រួដូច្នោះក៏លាន់មាត់ខ្សិប១ :

- បងជាតិ...

លោកសម្បត្តិបើកភ្នែកធំ១ :

- យ៉ាងម៉េច? ឯងកំពុងតែចង់ប្រាប់យើងថា ឯងជាមនុស្សដែលចាប់ជំរត់នាងចិត្ត កូនស្រីរបស់យើងនោះពីភ្នំពេញមកមែនទេហ៎? ថ្លើមធំ!! ដឹងខ្លួនទេ ថាតើនឹងត្រូវ ទទួលទោសបែបណាខ្លះដែលហ៊ានលួកថ្លើមរបស់យើង ?

រំពេចនោះ នាងតូចសុធាក៏យំវ៉ាឡើងដោយការភិតភ័យចំពោះសំដីខ្លាំង១ របស់លោកសម្បត្តិ ។ លុះក្រលេកឃើញនាងតូច អ្នកស្រីដានីក៏ពោលឡើង :

- ចិត្ត! នាងតូចជាកូនរបស់ឯងទាំងពីរនាក់មែនទេហ៎?

ឈូកលើកដៃបបោសលួងកូនតែក៏នៅស្ងៀម មិនឆ្លើយអ្វីដដែល ។ ពេលនោះ លោកសម្បត្តិមានការធុញថប់ណាស់ដែល កូនស្រីរបស់លោកឈរឪមិនឆ្លើយតប មកលោកវិញ ហាក់ដូចជាចង់បំបាក់មុខលោកនៅចំពោះមុខមនុស្សម្នាដែលកំពុង ចោមរោមឈរមើលយ៉ាងកុះករ រួមទាំងអ្នកកាសែត វាគ្មិនទូរទស្សន៍និងវិទ្យុប្រចាំ ប្រទេសទៀតផង ។ ពេលនោះផ្ទៃមុខលោកឡើងពណ៌ក្រហមដោយពិរោធ រួច លោកក៏ចេញបញ្ជាយ៉ាងដាច់ណាត់ :

- ឆាប់នាំនាងក្រពុំចិត្តកូនស្រីយើងត្រលប់ទៅផ្ទះវិញភ្លាម ។ អ្នកណាធ្វើអោយទើស មុខទើសមាត់ ចាប់ដាក់គុក ! ព្រួហើយនៅ?

មានប្រសាសន៍ចប់ លោកក៏បោះជំហានចេញទៅដោយមិនបានសំលឹងមើល នរណាឡើយ ក្រៅពីបញ្ចេញឬកពារយ៉ាងក្រអឺតក្រទមថា" ក្នុងលោកនេះ មានតែ អញ!" តែប៉ុណ្ណោះ ។ អង្គរក្សពីររូបក៏ស្រវាចាប់អូសនាងតូចសុធាបេះចេញពីដៃ ឈូកភ្លាម ហើយពីរនាក់ទៀតក៏ស្រវាអូសទាញឈូកសំដៅទៅរថយន្ត ។ នាងតូច សុធាក៏ស្រែកយំវ៉ា បោយដៃហៅរកម្តាយយ៉ាងខ្លោចផ្សា :

- ម៉ាក់! ម៉ាក់! កុំទៅ...... ម៉ាក់...............!!!!!

CHANBOKEO.COM

រីឯឈ្យូកក៏ទធាក់ជើងរើបំរះរត់មករកកូនរបស់នាងវិញ តែអនិច្ចា គ្មាននរណា គេមានក្តីស្រណោះមេត្តារូបនាងនិងកូនរបស់នាងឡើយ !

- សុធា! កូនស្រីម្តាយ... សុធា!!... បងជាតិ.. (ឈ្យូកស្រែកដង្ហោយ)

សូម្បីតែអ្នកស្រីជានី ម្តាយបង្កើតរបស់នាងដែលនៅក្បែរនោះ ក៏មិនឃើញ ចេញមុខធ្វើអន្តរាគមន៍អ្វីបន្តិចសោះ ដើម្បីជួយនាងតូចសាច់ឈាមរបស់អ្នកស្រី ផ្ទុយទៅវិញអ្នកស្រីបែរជាបញ្ឆេវភ្នែកមើលអោយគេបំបែកម្តាយនឹងកូនដោយគ្មាន រំជួលចិត្តអ្វីដែរ ។ បែរទៅសុជាតិវិញ ស្ទុះប្រវេប្រវាឆក់យកនាងតូចសុធាពីដៃ អង្គរក្សចិត្តប្រេតហើយហុចទៅអោយសុខា រួចស្ទុះរត់តាមទៅប្រវាយប្រតប់ទាញអូសយកឈ្យូកចុះពីរថយន្តមកវិញ ។ គួរឱ្យអាសូរណាស់! ពេលនោះសុជាតិ បានត្រូវអង្គរក្សចិត្តឫស្សាជាច្រើនរូបវាយផងទាត់ផងផ្ទារពោះរមៀលពេញដី ហូរ ឈាមពីមាត់ ពីច្រមុះសស្រាក់ ។ ភ្លាមនោះ សុជាតិក៏ស្រែកដង្ហោយអង្វរថា :

- សូមមេត្តាដោះលែងឈ្យូកវិញមក៏... ខ្ញុំសូមអង្វរ...កុំបំបែកពួកយើងអី... ខ្ញុំសូម អង្វរ... សូមដោះលែងឈ្យូកវិញមក៏..... ឈ្យូក! កុំទៅចោលបង.. ឈ្យូកអើយ!!

- បងជាតិ!!!!.. កូនធា!!!!!!!!!.... បងជាតិ!!!!!!!!!

ឈ្យូកស្ទុះអើតតាមបង្អួចរថយន្តដែលកំពុងមានល្បឿនទៅមុខ ស្រែកដង្ហោយ ហៅកូនរបស់នាង ហៅសុជាតិ មឹងសោម និងសុខាមិនដាច់ពីមាត់ ។ នាងស្រវា តោងបង្អួចបំរុងនឹងលោតចេញមកតែត្រូវដៃរិយ៉ានិងអ្នកស្រីជានីចាប់ជាប់ ។ សុជាតិ ប្រឹងស្ទុះរត់តាមពីក្រោយរថយន្ត ប៉ុន្តែ ឥតប្រយោជន៍ទេ រថយន្តបរចេញទៅយ៉ាង លឿនស្ទើរកាន់តែឆ្ងាយទៅៗ ហើយហាក់បីដូចជាកំពុងទាញហូតយកដួងព្រលឹង របស់សុជាតិអោយរលាយបាត់ពីរូបកាយរបស់នាយដូច្នោះឯង....

ម្តេចដាច់មេត្តា

១. ឱលោកមានគុណម្តេចដាច់មេត្តា លើកដៃប្រហារដួងចិត្តកូនស្រី
ពង្រាត់រូបនាងចាកឆ្ងាយបុត្រី មិនទាន់ដឹងក្តីអោយយំខ្លោចផ្សា ។

២. អាសូរជីវិតតូចកុមារី ថ្ងៃនេះចរណៃព្រាត់ដៃមាតា
និរាសទៅហើយមិនដឹងពេលណា មុំទារិកាជួបមាតាវិញ?

៣. អនិច្ចាគូគាប់ធ្លាប់រស់នឹងគ្នា ឥលូវគ្រាំគ្រាចិន្តាទោម្នេញ
វណ្ណៈបំបែកអោយឃ្លាឃ្លាតចេញ ភូមិគ្រោងភ្នំពេញពិតឆ្ងាយសែនឆ្ងាយ ។

៤. ស្រមោលអូនបាត់ប្រមាត់បងឃ្លាត ឱរាចង្កៀតនឹកកែវនោមឆាយ
គេកាត់បេះដួងសំលាប់បងហើយ ឱមុំព្រាណត្រើយបងរស់យ៉ាងណា?

៥. តំណក់ទឹកភ្នែកជ្រែកទងបេះដូង មិនខុសអន្លូងទូងដំចិន្តា
បងត្រូវតស៊ូលុះក្ស័យសង្ខារ តាមរកស្នេហាម្ចាស់ចិត្តបងមួយ ។

៦. ចាំបងណាំអូន! ចាំបងណាំពៅ! វៀមពិតរកផ្លូវដោះក្តីព្រួយ
ទោះមេឃរលំផែនដីរញ្ជួយ បងស្នេហ៍អូនមួយគ្មានថ្ងៃប្រែអើយ ។

លុះអស់ចិត្តហើយ សុជាតិក៏ងាកក្រោយដើរទៅរកម្តាយវិញ ស្រាប់តែប្រទះ នឹងតម្រួតពីរនាក់មកស្រវាដៃនាយទាំងគូដាក់ខ្នោះព្រិប១តែម្តង ។ សុខាភ័យ ណាស់ ក៏ស្ទុះទៅឃាត់ :

- ម៉េចក៏លោកចាប់បងប្រុសខ្ញុំយកទៅអីចឹង? តើគាត់មានកំហុសអី?

- នាយមានទោសចាប់ជំរត់កូនស្រីរបស់លោកឧត្តមសេនិយ.. នាងមិនឮទេហ៎?

- តែបងសុជាតិមិនបានចាប់បងឈ្យូកជំរត់ទេ...

CHANBOKEO.COM

- នែ៎ កុំសួរអាញ៉ីអាញ៉ៅច្រើន ! តិចជាប់ខ្នោះមួយទៀតដែរអាល្ងង់!!

មីងសោមភ័យញ័រខ្លួន ក៏ស្ទុះមកសំពះអង្វរ :

- សូមលោកមេត្តាលែងកូនប្រុសខ្ញុំទៅ ។ វាមិនបាន...

- យើងថាកុំអាញ៉ីអាញ៉ៅ... ឮហើយនៅ? យីអើ មិនចេះស្តាប់ខ្មែរទេហ្អី?

នាយតម្រួតទាំងប៉ុន្មានរូបនិយាយសំលុត ដោយគ្មានចិត្តចង់ស្តាប់ការពន្យល់អ្វី របស់អ្នកទាំងបីឡើយ ។ នៅពេលនោះ សុជាតិមានអារម្មណ៍ខ្លោចផ្សាក្នុងចិត្តគិតអ្វី មិនឃើញទេ ក្រៅតែពីការរើបំរះប្រាថ្នារត់ទៅតាមឈ្លូកយកមកវិញតែប៉ុណ្ណោះ ។ នាយតម្រួតនាំសុជាតិចេញទៅហើយនិយាយប្រាប់សុខានិងម្តាយថា :

- បងប្រុសនាងនឹងត្រូវចូលមន្ទីរឃុំឃាំងសិន ទំរាំមានបញ្ជាពីលោកឧត្តមសេនិយ សាជាថ្មី តែបើចង់លោះខ្លួនបងនាង ទៅរកម៉ាពាន់ដុល្លារមកបង់ពន្ធទើបបាន ។

ថាហើយ ពួកគេក៏នាំខ្លួនសុជាតិចេញទៅ ទុកអោយសុខានិងមីងសោមស្រវ៉ា គ្នាអោបយំយ៉ាងខ្លោចផ្សាក្រៃលែង ។

00 00

00

CHANBOKEO.COM

# វគ្គទី៩
# ផ្កាយវង្វេងមេឃ

នៅភ្នំពេញ....

ឈូកបានត្រូវឪពុកម្តាយនាងចាប់ឃុំឱ្យនៅតែក្នុងបន្ទប់ជាយូរថ្ងៃយូរខែហើយ ហើយថែមទាំងបញ្ជាឱ្យអង្គរក្សប្លែកៗ បណ្តាក់វេនគ្នាយាមរូបនាងទាំងយប់ទាំង ថ្ងៃមិនអោយនាងចេញទៅណា ។ម្យ៉ាងទៀត លោកសម្បត្តិក៏នៅក្រេវក្រោធនឹង ឈូកណាស់ដែលមិនព្រមស្រដីរកលោក ឬ និយាយការពិតអ្វីក្នុងជីវិតរបស់នាង អោយលោកបានជ្រាប ។ ឪពុកម្តាយរបស់ឈូកទាំងពីរនាក់ មានបំណងឃុំឃាំង ឈូកក្នុងករណីផ្សេងគ្នាទេ តែលោកទាំងពីរក៏មិនដែលពិគ្រោះគ្នាដែរថា តើត្រូវធ្វើ យ៉ាងណាចំពោះជីវិតរបស់កូនស្រីពៅរបស់លោក ត្បិតពេលណាលោកទាំងពីរ ចាប់ផ្តើមជជែកគ្នាភ្លាម ក៏ចាប់ផ្តើមមានវន្ទះមានផ្គរដាក់គ្នាភ្លាមដែរ ។រីឯដារិយ៉ា វិញ ក៏មិនសូវជាខ្វល់អើពើនឹងរឿងអ្វីជុំវិញខ្លួនប៉ុន្មាន ។ អ្វីដែលចំលែកបំផុត គឺ ដារិយ៉ាសព្វថ្ងៃបានផ្លាស់ប្តូរច្រើន មិនសូវដើរលេងពាសវាលពាសកាលរហេតរហូត ដូចកាលពីមុនឡើយ ។ តើព្រោះហេតុអ្វីទៅហ្ន៎?

ច្រើនដងហើយ ដែលឈូកខំលួចរត់ចេញពីផ្ទះ ដើម្បីត្រលប់ទៅរកកូនរបស់ នាង តែក៏ត្រូវគេចាប់ខ្លួនបានយកទៅវិញរាល់តែដងដែរ ដោយសារតែការយាម ល្បាតយ៉ាងតឹងរឹង ។ ពេលនេះឈូកក៏បានក្លាយជានាងក្រពុំចិត្តដ៏អស់សង្ឃឹមនោះ សាជាថ្មីម្តងទៀត ។ នាងលែងបរិភោគបាយទឹក លែងនិយាយរកនរណាទាំងអស់ ក្រៅតែពីអង្គុយយំរហូតទឹកភ្នែកស្ទើរតែក្លាយជាឈាមអស់ទៅហើយ ។ រូបនាង នៅភ្នំពេញក៏ពិតមែនតែចិត្តនាង អារម្មណ៍របស់នាងស្ថិតនៅឯភូមិត្រាងឯណោះ ។ ម្ងៃៗនាងអង្គុយបន់ព្រះ សូមប្រាថ្នាសូមអោយនាងមានសេរីភាពនឹងអាលវិលៈ ទៅជួបកូនស្រីរបស់នាងតែម្យ៉ាងប៉ុណ្ណោះ ។ នាងលែងស្រលាញ់ជីវិតទីក្រុងដ៏សែន អាប់អួរនោះហើយ ពិតមែនតែភ្នំពេញជាដែនដីកំណើតរបស់នាងក៏ដោយ សូម្បី តែសេចក្តីស្រលាញ់របស់នាងចំពោះឪពុកម្តាយ ក៏ហាក់ដូចជាស្រកស្រុតទៅវិញ ដោយឯកឯងដែរ ។ នាងនឹកគិតមិនយល់សោះថា ហេតុអ្វីបានជាលោកប៉ា របស់នាង ដែលខំដាក់មនុស្សយាមនាងទាំងយប់ទាំងថ្ងៃ មើលទៅ ហាក់ដូចជា ខ្វល់ខ្វាយចង់អោយនាងមានសេចក្តីសុខ មានសុវត្ថិភាពណាស់ តែចុះហេតុអ្វីបានជា លោកមិនដែលគិតខ្វល់សាកសួរសុខទុក្ខ ថាតើការពិតរូបកូនស្រីរបស់លោក មានសេចក្តីសុខដែរឬអ្វី តាំងពីត្រលប់មកដល់ភ្នំពេញវិញ ។ ពិតមែនហើយ លោកមិនដែលហៅរកកូនសួរសុខទុក្ខអ្វីទាំងអស់ ក្រៅពីឈរសំលឹងមុខនាងដោយ ក្រសែភ្នែកពិរោធតែម្យ៉ាង ។ តើមានកូនមួយណាទៅចង់និយាយសាសងជាមួយ ឪពុកដែលចូលចិត្តបង្ហាញទឹកមុខរបស់គាត់ជាសត្រូវចំពោះកូនបែបនេះ? ចំណែក អ្នកស្រីដានីវិញឃើញមកអើតសួរនាងប៉ុន្មានដងដែរ តែលុះឃើញកូនស្រីមាន ទឹកភ្នែកទឹកសំបោរច្រើនពេក អ្នកស្រីក៏គេចខ្លួនទៅវិញ ហើយក៏លែងមកអើត អស់រយៈពេលជាយូរ ...

ពីរឆ្នាំកន្លងទៅ...

ក្រពុំចិត្តអង្គុយត្រមង់ត្រមោចតែម្នាក់ឯងក្នុងបន្ទប់ ស្រាប់តែឮសូរគោះទ្វារ ។ នាងមិនមានកំលាំងចិត្តនឹងនិយាយជាមួយនរណាទេ ក៏ប្រាសខ្លួនគេងទៅលើគ្រែនៅ ស្ងៀមស្ងាត់ ។ ស្រាប់តែនាងធឿនបើកទ្វារចូលមក :

CHANBOKEO.COM

- អ្នកនាង! ពិសាអីខ្លះទៅ! មើលហ្ន៎! អ្នកនាងស្គាំងស្គមស្លេកស្លាំងណាស់!

- ធឿនអើយ! ខ្ញុំលេបមិនចូលទេ... ខ្ញុំនឹកកូនស្រីរបស់ខ្ញុំណាស់ ។

- អ្នកនាង! បើអ្នកនាងស្រលាញ់កូនពិតមែន អ្នកនាងត្រូវតែពិសាអោយមាន កំលាំង ទើបរក្សាសុខភាពសំរាប់រកឱកាសដើម្បីទៅរកកូនអ្នកនាងវិញនោះអី ។

មែនហើយ! ធឿននិយាយត្រូវណាស់ ។ មាណវីត្រូវតែរក្សាខ្លួនរក្សាកំលាំង ដើម្បីស្វែងរកមធ្យោបាយទៅជួបសុធាកូនរបស់នាងទៀត ។ តាំងពីមកដល់ភ្នំពេញ វិញ ធឿនជាមនុស្សទីមួយហើយយកចិត្តទុកដាក់ចំពោះសុខទុក្ខផ្លូវចិត្តរបស់នាង ។ មុននឹងត្រលប់ចេញទៅវិញ នាងធឿនលួចខ្សិបប្រាប់ឈូកថា :

- ព្រឹកមិញ លោកវិសាលទូរសព្ទ័មកថា លោកនឹងមកលេងអ្នកនាងនៅម៉ោង៩ ព្រឹកនេះ ។

រួចហើយ ធឿនក៏ត្រលប់ទៅវិញបាត់ ។ មែនហើយ! លោកវិសាលតែងតែមក លេងនាងជារឿយៗ តែឈូកចេះតែគេចមុខមិនព្រមជួបលោកឡើយ ។ រីឯដារិយ៉ា ក៏ចូលចិត្តចេញមុខជំនួសនាងជានិច្ច ទោះបីជាដឹងហើយថា លោកវិសាលប្រាថ្នាចង់ជួបតែក្រពុំចិត្តក៏ដោយ ។ សព្វថ្ងៃដារិយ៉ាមិនហ៊ានចេញដើរទេ ខ្លាចជ្រួសគ្នាមិនបាន ជួបលោកវិសាល ។ ការពិត ដារិយ៉ាចាប់ចិត្តចាប់អារម្មណ៍នឹងលោកវិសាលណាស់ ទោះបីជាលោកពុំមានបង្ហាញទឹកចិត្ត ឬអារម្មណ៍ស្និទ្ធស្នាលត្រលប់មកនាងវិញក៏ ដោយ ។ ពីរឆ្នាំហើយដែលលោកវិសាលព្យាយាមភ្ជាប់សំដីមានមេត្រីជាមួយនឹង ក្រពុំចិត្តអតីតគូកំណាន់សាជាថ្មី តែមិនបានការសោះឡើយ មិនខុសពីដារិយ៉ាដែលព្យាយាមមានមេត្រីជាមួយលោកតែរកពន្លឺមិនឃើញដូចគ្នាដែរ ។ ប៉ុន្តែយ៉ាងណាក៏ លោកវិសាលនៅតែមិនបោះបង់សេចក្តីសង្ឃឹមរបស់លោកឡើយ ទោះបីជាដារិយ៉ា ខិតខំខារខាំងពីមុខពីក្រោយក៏ដោយ ។

ក្រពុំចិត្តសំលឹងទៅអាហារដែលនៅក្នុងស្តុករួចហើយក៏ស្រវារកស្លាបព្រា បំរុងនឹងបរិភោគស្រាប់តែនាងឮសូរស្នូរគោះទ្វារសាជាថ្មីម្តងទៀត ។ តែមាណវីយើងមិន ខ្វល់នឹងឆ្លើយទេ មិនថានរណាគោះទ្វាររកនាងក៏ដោយ ។ រំពេចនោះ នាងក៏ឮសូរ សំលេងមាត់អ្នកស្រីដានីដែលមានប្រសាសន៍ហៅនាងថា :

- ចិត្ត! អោយម៉ាក់ចូលនិយាយជាមួយកូនម៉ាភ្លែតបានទេ?

ក្រពុំចិត្តអង្គុយធ្ងឹងមិនស្តីតបអ្វីទាំងអស់ តែក្នុងចិត្តគិតថា :

- បើម៉ាក់ស្រលាញ់កូនមែន ម៉ាក់ត្រូវតែយល់ចិត្តខ្ញុំដែលស្រលាញ់សុធាកូនស្រីរបស់ ខ្ញុំដែរ ។ មិនគួរម៉ាក់មានគំនិតអគតិហើយឃុំឃាំងពង្រាត់បំបែកខ្ញុំពីកូនស្រីខ្ញុំទេ....

អ្នកស្រីដានីមិនឮនាងឆ្លើយតប ក៏បើកទ្វារដើរចូលមក រួចក៏ដាក់ខ្លួនអង្គុយ ជិតកូន :

- ប្រាប់ម៉ាក់អោយត្រង់មក! តើកូនពិតជាមានគ្រួសារ មានកូនចៅពិតមែន ឬក៏ គ្រាន់តែភូតភរម្តាយឪពុក ដើម្បីយកលេសនឹងអាលគេចចេញពីផ្ទះរបស់យើងតែ ប៉ុណ្ណោះទេហ្ន៎ស កូន?

ក្រពុំចិត្តងើបមុខឡើងសំលឹងម្តាយមួយស្របក់ទើបតបវិញថា :

- សុធាជាសាច់ជាឈាមរបស់ខ្ញុំពិតៗណាំម៉ាក់!

- អញ្ចឹងកូនប្រាប់ម៉ាក់បានទេថា បុរសដែលចេញមកការពារកូនថ្ងៃមុនជាឪពុក របស់ក្មេងនោះមែនទេ ហើយហេតុអីបានជាកូនទៅស្គាល់គេកើត? បើគេជាអ្នក ស្រុកស្រែចំការមិនដែលចូលក្រុងភ្នំពេញម្តងផងនោះ?

ក្រពុំឈូកឈ្ងោកមុខ ហើយឆ្លើយថា :

CHANBOKEO.COM

- គេមិនមែនជាឪពុករបស់កូនសុធាទេ តែគេជាអ្នកមានគុណចំពោះខ្ញុំនិងកូន...

- បើគេមិនមែនជាឪពុករបស់សុធា តើនរណាគេទៅជាឪពុករបស់ក្មេង ឬក៏បុរស នោះជាលោកវិសាល? បើដូច្នោះមែន ម៉ាក់នឹងនិយាយជាមួយគេ អោយគេមក ទទួលខុសត្រូវជីវិតរបស់កូនវិញ ។

- អត់ទេ ម៉ាក់! លោកវិសាលក៏មិនមែន.... (ឈូកទុចង់ក់មិនហ៊ាននិយាយតទៅ ទៀត)

- អញ្ចឹងតើជានរណា? ចិត្ត... កូននិយាយប្រាប់ម៉ាក់មោ៉ហ៏!

ចៃដន្យ នារីយើងឈប់ចង់និយាយអ្វីតទៅទៀតហើយ ក្រៅពីឈ្ងោកមុខ សំរក់ទឹកភ្នែកសាជាថ្មី ។ អ្នកស្រីជានីឃើញដូច្នោះ ក៏លែងមានអារម្មណ៍ល្អចំពោះ កូនតទៅទៀតដែរ :

- ពេលនេះ ម៉ាក់ហួសចិត្តណាស់ដែលម៉ាក់ធ្លាប់គិតថា កូនឯងជាក្មេងដ៏ល្អម្នាក់ មិន គួរណាបែរជាមានកូនស្រីមួយដោយរកមុខឪពុកមិនឃើញដូច្នេះសោះ ហ៊ឺ!

ក្រពុំចិត្តឮដូច្នោះក៏កើតមានអារម្មណ៍ធុញថប់សាជាថ្មី ។ តើអោយនាងជំរាប ម្តាយរបស់នាងយ៉ាងណាទៅ? បើមិនជំរាបទៅ លោករិតតែយល់ច្រលំលើនាងកាន់ តែខ្លាំងឡើង១ តែបើជំរាបវិញ តើលោកនឹងជឿសំដីរបស់នាងថាជាការពិតឬទេ? ចំពោះសុជាតិវិញ ក្រពុំចិត្តមានការគោរពស្រលាញ់ទឹកចិត្តរបស់នាយណាស់ ។ នាងពិតជាមិនអាចឆ្លើយដាក់នាយបានឡើយថា សុធាជាកូនរបស់នាយបានឡើយ ទោះបីជានាយមានសមានចិត្តទូលំទូលាយ ស្ម័គ្រចិត្តទទួលយកនាងតូចជាកូនពេញ មុខពេញមាត់ក៏ដោយ ។

រំពេចនោះ អ្នកស្រីជានីមានប្រសាសន៍បន្តទៅទៀតថា :

- បើកូនមិនប្រាប់ម៉ាក់ទេ នោះម៉ាក់ក៏មិនអោយកូនត្រលប់ទៅរកក្រុមគ្រួសារ ស្រមែកស្រមកនៅបាត់ដំបងនោះវិញដែរ ចាំទុក.... !

អ្នកស្រីជានីមានប្រសាសន៍ដាច់ណាត់ រួចហើយពោលថែមទៀតថា :

-ថ្ងៃនេះលោកវិសាលគេមកលេងជាមួយយើង ចូរកូនតុបតែងខ្លួនអោយសមរម្យ ហើយចេញទៅទទួលភ្ញៀវផង ឮហើយនៅ?

ថាហើយអ្នកស្រីក៏ងើបចេញទៅវិញ ។ មាណវីងើបមុខឡើងបែរមើលតាម ម្តាយពីក្រោយ ស្រាប់តែ ប្រទាក់គ្នានឹងខ្សែភ្នែករបស់លោកសម្បត្តិដែលឈរនៅ មាត់ទ្វារបន្ទប់របស់នាងតាំងពីអង្កាល់ ។ លោកធ្វើទឹកមុខយ៉ាងចំលែកដាក់នាង ប៉ុន្តែតាំងពីនាងត្រលប់មកផ្ទះវិញ លោកមិនដែលមានប្រសាសន៍និយាយអ្វីជាមួយ នាងម្តងណាឡើយ ក្រៅតែពីសំលឹងសំលក់ដាក់នាងពីចំងាយតែប៉ុណ្ណោះ ។

មួយស្របក់ធំ ក្រោយមក ស្នូររថយន្តមួយ បានបរចូលមកដល់នៅមុខផ្ទះ ។ ក្រពុំចិត្តនឹកក្នុងចិត្តថាច្បាស់ជាលោកវិសាលហើយ ។ នាងអស់កំលាំងចិត្តសាជាថ្មី រួចស្រវាភួយរកដណ្តប់រកគេងទៅវិញ ស្រាប់តែនាងធឿនអ្នកបំរើចូលមកដល់ :

- អ្នកនាង! លោកវិសាលមកដល់ហើយ! អ្នកស្រីមានប្រសាសន៍ដាច់ណាត់ថាឱ្យ អ្នកនាងចុះទៅទទួលភ្ញៀវ!

តែក្រពុំចិត្តយកដៃចុកត្រចៀកធ្វើមិនឮ ។ នាងធឿនមិនអស់ចិត្ត ក៏ឈ្ងោក មុខមកជិតមាណវីយើង ហើយនិយាយខ្សិប១បន្ថែមទៀតថា :

- អ្នកនាង! មានតែលោកវិសាលទេ ដែលលោកប្រុសលោកស្រីមានការទុកចិត្ត ជាងគេ ។ បើសិនជាអ្នកនាងសុំចេញទៅដើរលេងនៅក្រៅ ជាមួយលោកវិសាល ប្រហែលជាលោកប្រុសលោកស្រីអនុញ្ញាតិហើយ ។

ក្រពុំចិត្តក៏ប្រែខ្លួនបែរមករកនាងធឿនហើយតបវិញថា :

- ធឿនអើយ! ខ្ញុំនឹកកូនស្រីតូចរបស់ខ្ញុំណាស់ ម្ល៉ោះហើយគ្មានអារម្មណ៍ចង់ទៅដើរ សប្បាយឯណាទេ ។

CHANBOKEO.COM

- នោះហើយដែលចឿនចង់ប្រាប់អ្នកនាង ។ កាលបើអ្នកនាងបានចេញទៅក្រៅ បានហើយ
នោះអ្នកនាងពិតជាអាចមានឱកាសលួចធ្វើដំណើរទៅរកកូនស្រីរបស់ អ្នកនាងបានវិញមិនខាន ។

ប្រយោគនោះបានធ្វើអោយក្រពុំចិត្តភ្ញាក់ស្មារតីស្វាងផេងតែម្តង រួចហើយ ក៏ស្ទុះទៅអោបនាងចឿនយ៉ាងណែន :

- ចឿន! ឯងប្រៀបដូចជាព្រះមួយអង្គដែលមកប្រោសជីវិតរបស់ខ្ញុំអោយរស់សា ជាថ្មីម្តងទៀតដូច្នេះដែរ ។ ខ្ញុំអរគុណចឿនឯងណាស់ !

ស្រាប់តែនាងដាក់ទឹកមុខជ្រប់ទៅវិញហើយស្រដីបន្ថែមថា :

- ប៉ុន្តែ... ខ្ញុំគ្មានប្រាក់ជាប់នឹងខ្លួនទេ ។ ប៉ាម៉ាក់ដកហូតអ្វីៗ អស់រលីងពីខ្ញុំហើយ ។
តើអោយខ្ញុំធ្វើដំណើរយ៉ាងដូចម្តេចទៅ?

ភ្លាមនោះ ចឿនលូកយកប្រាក់មួយរមូរពីហោប៉ៅរបស់នាងហុចមកអោយ ក្រពុំចិត្ត ហើយស្រដីថា :

- នេះជាប្រាក់ខែរបស់ខ្ញុំដែលសន្សំទុកពីរបីខែហើយ ។ ខ្ញុំអោយអ្នកនាងខ្ចីប្រើសិន ថ្ងៃក្រោយមានឱកាស ចាំអ្នកនាងសងខ្ញុំវិញចុះ ។

ពេលនោះ ក្រពុំចិត្តស្រវាអោបចឿនយំហ៊ូតែម្តង ។ ចឿនទទះខ្នងឈូកបន្តើរៗ ហើយពោលតទៅទៀតថា :

- តាំងចិត្តអោយក្លាហានឡើងអ្នកនាង! បើបណ្តោយអោយខ្លួនមានចិត្តទន់ខ្សោយ យ៉ាងនេះ
អ្នកនាងមិនអាចជួយខ្លួនឯងអោយទៅជួបកូនអ្នកនាងបានទេ ហើយអ្នក នាងក៏នឹងបែកពីកូនស្រីរបស់អ្នកនាងរហូតទៅដែរ ។ ហ្នឹក!
លោកវិសាលកំពុង ចាំជួបអ្នកនាងនៅខាងក្រោម... នោះជាឱកាសល្អរបស់អ្នកនាងហើយ ។

ក្រពុំចិត្តជូតទឹកភ្នែកភ្លាម ហើយឆ្លើយជាប្រញាប់ថា :

- អរគុណណាស់ចឿន ដែលជួយដាស់សតិអោយខ្ញុំមានភាពរឹងប៉ឹងក្នុងចិត្តមកវិញ ។ បើមានឱកាស ខ្ញុំនឹងវិលមកសងគុណចឿនមិនខាន!

មាណវីយើងស្រដីហើយក៏ស្ទុះរៀបចំខ្លួនយ៉ាងស្អាតបាត ហើយស្ទុះចុះទៅរក
លោកវិសាលដែលអង្គុយរង់ចាំនៅក្នុងសាលុងដោយមានអ្នកស្រីដានីនៅជជែកកំដរ ជាមួយ ។ កាលបើឃើញក្រពុំចិត្តចុះពីលើផ្ទះមក
ទាំងអ្នកស្រីដានី ទាំងលោក វិសាល មានការសប្បាយចិត្តតែម្តង ។ មែនហើយ! ដូចគ្រោងទុកឥចឹង! កាលបើ
បានលោកវិសាលបបួលចេញទៅក្រៅ ម្តាយនាងក៏អនុញ្ញាតភ្លាម គាប់ជួនពេល នោះ លោកសម្បត្តិនិងដារិយ៉ាក៏មិននៅផ្ទះ
ម្ល៉ោះហើយគ្មាននរណារារាំងគេទាំង ពីរដែរ ។ ឃើញក្រពុំចិត្តសំដែងទឹកមុខញញឹមហើយយល់ព្រមចេញទៅក្រៅជាមួយ
លោកវិសាលរីកមុខប៉ុនចង្អេរតែម្តង ។

គ្រាន់តែចេញផុតរបងផ្ទះ លោកវិសាលសួរទៅធិតាកំពូលដួងចិត្តរបស់លោក
ភ្លាមដែរថា:

- ចិត្ត! បងនឹកអូនណាស់ណាំអូនដឹងទេហ៎?

តែក្រពុំចិត្តមិនបានឮប្រយោគរបស់លោកទេ បែរជាពោលត្រលប់ទៅរក លោកវិញថា :

- បើខ្ញុំចង់ពឹងបងរឿងមួយ បងជួយខ្ញុំទេហ៎?

- តើជារឿងអ្វីទៅ? បើអាចជួយបាន បងនឹងជួយអូនភ្លាម!

- គឺ... បងត្រូវតែសន្យាសិនថា បងមិនជំរាបប៉ាម៉ាក់ខ្ញុំឱ្យគាត់ជ្រាបទេ..

- ព្រះអើយ! តើអូនមានរឿងអ្វីធំដុំរហូតដល់ទៅលាក់បាំងនឹងឪពុកម្តាយអញ្ចឹង?

ឈូកក៏ឈ្ងោកមុខ រួចវាចាខ្សិបៗ :

- មើលទៅ ប្រហែលជាបងជួយខ្ញុំមិនបានទេ ។

CHANBOKEO.COM

ឃើញនាងសំដែងកិរិយាតូចចិត្តអស់សង្ឃឹម លោកវិសាលក៏និយាយកម្លាទឹក ចិត្តនាងឡើង :

- ណ្ហើយចុះ! បងយល់ព្រមថាមិនជំរាបប៉ាម៉ាក់អូនទេណា៎ ហើយអូននិយាយប្រាប់ បងមក តើអូនចង់អោយបងជួយរឿងអ្វីទៅ?

- ប៉ុន្តែ... បើខ្ញុំនិយាយជំរាបបងហើយ សូមបងស្តាប់ខ្ញុំអោយចប់រឿងសិន ហើយ តាំងចិត្តកុំខឹង កុំខក កុំច្រលោតនឹងក្រពុំចិត្តណា៎! ខ្ញុំសូមតែប៉ុណ្ណឹងទេ...

- ពុទ្ធោ! ក្រពុំចិត្តតែមួយរបស់បង! បងមិនដែលនឹកខឹងនឹងអូនដោយប្រការ

មួយណាទេ តាំងពីយើងស្គាល់គ្នាមក សូម្បីតែពេលអូនឃ្លាតពីបងទៅ នាគ្រាមួយ

នោះ ក៏បងមិនដែលនឹកខឹងនឹងអូនដែរ....

- ប៉ុន្តែ រឿងរ៉ាវរបស់ខ្ញុំវែងឆ្ងាយជាងការគិតរបស់បងណាស់! សូមបងសន្យាសិន មក៏

ថាបងមិនខឹងនឹងខ្ញុំឡើយកាលបើបានដឹងការពិតរួចហើយ...

- បាទ៌! បងសន្យាថាបងមិនខឹង មិនអាក់អន់ស្រពន់ចិត្តនឹងអូនឡើយ មិនថាការ

ពិតនោះវាយ៉ាងណាក្តី...

ក្រពុំចិត្តក៏ញញឹមភ្លាមយ៉ាងស្រស់បំព្រង...

នៅលើផ្លូវជាតិលេខ៥....

រថយន្តដ៏ស្អាតមួយបោះពួយយ៉ាងលឿនផ្ទុកលោកវិសាលនិងធិតាយើងសំដៅ ខេត្របាត់ដំបង ។ ពេលនោះយើងសង្កេតឃើញឈូកមានកិរិយារីករាយណាស់គ្រាន់ តែអង្គុយរសាប់រសល់បន់អោយឆាប់ដល់តែប៉ុណ្ណោះ តែលោកវិសាលវិញ... ទោះបី ជាលោកប្រឹងញញឹមយ៉ាងណា ក៏មិនអាចលាក់ជិតនៅភាពសោកសៅនៅលើផ្ទៃ មុខរបស់លោកបានដែរ ។ តើព្រោះអ្វីទៅហ្ន៎?

ភ្លាមនោះ លោកវិសាលពោលទៅកាន់នារីយើងថា :

- យប់នេះ បងមានកម្មវិធីត្រូវផ្សាយបន្តផ្ទាល់ម៉ោង៧កន្លះយប់ ។ តើយើងអាច ត្រលប់មកវិញទាន់ពេលដែរទេ អូន?

ក្រពុំចិត្តញញឹមហើយឆ្លើយភ្លាម :

- ពិតជាទាន់ហើយ ព្រោះអីពេលនេះ ទើបតែម៉ោង៩កន្លះព្រឹក ។ ធ្វើដំណើរទៅ មកពីភ្នំពេញទៅបាត់ដំបងអស់ប្រហែល៧ម៉ោងទេ ។ ខ្ញុំជឿថាបងប្រាកដជាមកវិញ ទាន់មិនខាន ។ ប៉ុន្តែដើម្បីកុំឱ្យពិបាក បងដាក់ខ្ញុំចុះនៅចំណតឡានក្រុងក៏បានដែរ ចាំខ្ញុំជិះបន្តទៅទៀតចុះ ។

- អត់ទេហ៎! បងត្រូវតែរក្សាសុវត្ថិភាពអោយអូន! ឈប់បារម្ភទៅ! ចាំបងជូនអូន

អោយទៅដល់ភូមិត្រាងតែម្តង ។

- អរគុណណាស់ បងវិសាលដែលមានចិត្តមេត្តានាំឈូកអោយមកជួបកូនវិញ...

លោកវិសាលញញឹមទ្រង់ស្ងួត១ហើយទើសទាល់ តែដោយទឹកចិត្តអាណិតនារី យើងដែលបានរងគ្រោះក្នុងជីវិតជាច្រើនដងមកហើយ លោកនឹករកពាក្យប្រកែក ថាមិនជួយនាងមិនបានសោះ ។ ពុទ្ធោអើយ! បើពេលនេះ ក្រពុំចិត្តគេមានម្ចាស់ បេះដូងរួចទៅហើយ តើលោកវិញត្រូវក្លាយជាអ្វីទៅចំពោះនាង? គិតទៅគិតមក លោកនៅតែគិតមិនចេញដដែល...

បួនម៉ោងក្រោយមករថយន្តក៏បានមកដល់ភូមិត្រាង ។ លោកវិសាលក៏បត់រថ យន្តឆ្ពោះទៅផ្ទះកញ្ចាស់មួយដែលឈូកចង្អុលប្រាប់ ។ ពេលនោះ លោកសឹងតែមិន ជឿភ្នែកខ្លួនឯងថា ផ្ទះដ៏កញ្ចាស់នោះមានអនុភាពខ្លាំងក្លាអាចទាក់ទាញទឹកចិត្តនារី ដែលមានវណ្ណៈខ្ពស់ដូចផ្កាយអោយឃ្លាតចាកពីមេឃាភ្នំពេញដ៏សែនធំហើយត្រលប់ មករកជំរំបូលកញ្ចាស់ដោយក្តីពេញចិត្តដូច្នេះសោះ ។ កាលបើមកដល់មុខផ្ទះហើយ ឈូកឈានចុះពីរថយន្តដោយក្តីត្រេកអររំភើប ស្រាប់តែ...សេចក្តីសប្បាយរីករាយ

CHANBOKEO.COM

របស់នាងរលាយបាត់សូន្យអស់ទៅវិញព្រមជាមួយគ្នាដែរ ត្បិតផ្ទះមួយនោះត្រូវ បិទទ្វារចោលគ្មានមនុស្សរស់នៅឡើយ មានតែស្មៅដុះស៊ុបទ្រុបទំនងត្រូវគេបោះ បង់យូរហើយ... ឈូករត់ចុះរត់ឡើងកូកហៅរកមីងសោម រកសុជាតិនិងសុខា តែឥតប្រយោជន៏ទេ នាងមិនបានទទួលចំលើយតបវិញសោះឡើយ ។ ភ្លាមនោះ ធិតាក៏ខ្ទប់មុខទ្រហោរយំហ៊ូ ដោយការខកចិត្តមិនបានជួបកូននិងមនុស្សជាទីស្រលាញ់ ។ បេះដូងរបស់នាងរណ្តំញាប់ញ័រដោយក្តីបារម្ភចំពោះសុធា ដៃជើងក៏ រសេះរសោះស្ទើររបេះអស់ពីខ្លួន ។ ពេលនេះ នាងមានអារម្មណ៏ថាខ្លួនកំពុងតែ ធ្លាក់នរកសាជាថ្មីម្តងទៀតហើយ ។ លោកវិសាលឈរក្បែរនោះសំលឹងទៅនាង ដោយក្តីអាណិតអាណោចក្នុងចិត្ត
តែលោកក៏មិនដឹងដែរថា ត្រូវធ្វើយ៉ាងណាដើម្បី
ជួយសំរាលទុក្ខរបស់នាងបាន ។

ផ្កាយវង្វេងមេឃ

១. មេឃខ្មៅងងិតត្បិតព្យុះព្យោមា អោយស្រីរងា រណ្តំកាយអង្គ
សង្ឃរាសាហាវគំរាមឆោមយង់ កាត់ទងបេះដូងប្រល័យដួងចិត្ត ។
២. ភពខ្មៅគួរស្លុតរលត់ពន្លឺ ឱរាវែងឈឺព្រោះនឹកវរមិត្ត
និរាសបុត្រស្ងួនខ្លួនអើយវិបរិត ស្រណោះអាណិតផ្កាយវង្វេងមេឃ ។
៣. មេឃរាំងរួចភ្លៀងស្រោចស្រពរងា រណ្តំឱរាចិន្តាសង្វេគ
ព្យុះអើយឈប់បក់បំបាក់បំបែក ដើម្បីថ្ងៃស្អែកថ្ងៃរះជាថ្មី ។
៤. ហត្ថាទាំងទ្វេប្រណម្យបន់ផ្សង សូមឱ្យទងវងជួបស្នេហាថ្លៃ
រស់សុខសប្បាយផុតទុក្ខព្រួយភ័យ ជុំគ្រួសារថ្មី រស្មីនិរន្តន៏ ។

ធិតាយើងយំអស់ចិត្តហើយក៏ជូតទឹកភ្នែកដើរចេញមកក្រៅរបងផ្ទះ គិតថា នឹងទៅសួរដំណឹងពីអ្នកភូមិជិតខាងស្រាប់តែឃើញពេទ្យអេងបរម៉ូតូកាត់តាម ផ្លូវមុខផ្ទះរបស់សុជាតិ ។ នាងក៏រត់កូកហៅភ្លាម ។ ពេទ្យអេងឮហើយក៏ បកម៉ូតូត្រលប់ថយក្រោយមករកនាងវិញ :

- សួស្តីឈូក! មករកសុជាតិមែនទេហ៏?
- ចាំស! ចុះលោកគ្រូពេទ្យមានដឹងថាគាត់នាំក្រុមគ្រួសារទៅរស់នៅទីណាដែរទេ?
- បាទ! ឮថាទៅនៅភ្នំពេញតាំងពីយូរហើយ គឺតាំងតែ ក្រុមហ៊ុនចំរៀងគេមកសុំ
កុងត្រាយកសុខាទៅច្រៀងអោយក្រុមហ៊ុនរបស់គេកាលពីពីរឆ្នាំមុនមកម្លេះ ។

ក្រពុំចិត្តឈរធ្វើភាំង ខកចិត្តផង សប្បាយចិត្តផង ខកចិត្តត្បិតមិនបានជួបមុខ
កូនតែសប្បាយចិត្តវិញព្រោះអីនៅមានសល់រស្មីសង្ឃឹមខ្លះដែរក្នុងការស្វែងរកនាយ សុជាតិនិងក្រុមគ្រួសារ ។ បន្តិចមក ពេទ្យអេងក៏លាចេញទៅទុកអោយឈូកនៅ ឈរទ្រឹងសំលឹងទៅផ្ទះឈើកញ្ចាស់នោះជាចុងក្រោយ ។ តែពេលនេះ នាងឈប់ ស្រក់ទឹកភ្នែកដូចគ្រាមុនៗទៀតហើយ ។ នាងបានសច្ចានៅក្នុងចិត្តថានឹងស្វែងរក កូនស្រីនាងនិងមនុស្សដែលនាងស្រលាញ់បំផុតក្នុងជីវិតអោយឃើញជាក់ជាមិនខាន មិនថាជីវិតរបស់នាងនឹងត្រូវប្រទះឧបសគ្គយ៉ាងណាក៏ដោយ ក៏នាងនឹងខំពុះពារ មិនអោយនរណាមកបំបាក់ទឹកចិត្តរបស់នាង អោយធ្លាក់ចុះដុនដាបតទៅទៀតឡើយ ។ ឈូកឈរសំលឹងមើលភូមិដ្ឋានដែលនាងធ្លាប់រស់នៅជាចុងក្រោយហើយក៏ ដើរត្រលប់ចូលរថយន្តវិញដោយក្តីស្ងៀមស្ងាត់ ។ លោកវិសាលក៏បញ្ឆេះរថយន្តនាំ មាណវីចេញទៅ ។ ថៃដន្យ តាមផ្លូវត្រលប់មកភ្នំពេញវិញ មានរន្ទះព្យុះភ្លៀងធ្លាក់

CHANBOKEO.COM

ជាខ្លាំងធ្វើឱ្យយឺតដំណើររបស់អ្នកទាំងពីរ ។ ពេលនោះ  លោកវិសាលក៏សំរេចចិត្ត នាំក្រពុំចិត្តទៅតំរង់កន្លែងធ្វើការរបស់លោកតែម្តង ត្បិតពេលវេលាវាកាន់តែកៀក កម្មវិធីដែលលោកត្រូវឡើងទៅសម្ភាសន៍ ផ្សាយបន្តផ្ទាល់ជាមួយតារាជើងឯកដ៏ ល្បីដល់ទៅបីរូប ។ លុះបររថយន្តជិតដល់ភ្នំពេញវិញ លោកក៏ទូរសព្ទ័ទៅលោក សម្បត្តិ អ្នកស្រីដានី និងដារិយ៉ា រំលឹកសុំអោយមកចូលរួមទស្សនាកម្មវិធីផង ហើយមកទទួលយកក្រពុំចិត្តទៅវិញផង ត្បិតពេលនោះលោកគ្មានឱកាសនាំនាង អោយដល់លំនៅវិញទាន់ពេលវេលាណាត់របស់លោក ។

00 00

00

CHANBOKEO . COM

# វគ្គទី១០
# អំបែងអណ្តែត

និយាយពីក្រុមគ្រួសារសុជាតិម្តង...

តាំងពីបែកពីឈូកនឹងសុជាតិមក នាងតូចសុធាយំរកម្តាយរកឪពុក មិនព្រម ដេកពួនសោះ ធ្វើឱ្យមីងសោមនិងសុខាកាន់តែពិបាកចិត្តឡើងរាល់ថ្ងៃ ។ ម្យ៉ាង ទៀត ប៉ុន្មានថ្ងៃកន្លងមកនេះ សុខាក៏ប្រមូល ជ្រួកប្រមូលមាន់ព្រមទាំងយកម៉ូតូចាស់របស់សុជាតិទៅលក់អស់រលីងដែរដើម្បី សន្សំមួយពាន់ដុល្លារទៅលោះយក សុជាតិមកវិញ ។ ប៉ុន្តែ... ទោះជាខំប្រឹងយ៉ាងណាក៏ដោយក៏សុខាមិនអាចប្រមូល ប្រាក់មួយពាន់ដុល្លារបានដែរ ។ រៀងរាល់ថ្ងៃ នាងប្រឹងធាក់កង់រហូតដល់បាត់ដំបង ដើម្បីទៅមើលសុជាតិដែលត្រូវក្រុមអង្គរក្សរបស់លោកសម្បត្តិឃុំខ្លួន ។ ការពិត ទី នោះមិនមែនជាពន្ធនាគានោះទេ តែជាលំនៅធម្មតា។ គ្រាន់តែមានការយាមល្បាត ច្រើនប៉ុណ្ណោះធ្វើអោយសុខារិតតែសង្ស័យឡើងថា អ្វីដែលគេកំពុងធ្វើមកលើបង ប្រុសនាងមិនមែនជាអំពើស្របច្បាប់ ។ ប៉ុន្តែ ចំពោះស្រីក្មេងពិការដូចនាង ហើយ ក្រីក្រទីទ័លយ៉ាងនេះ តើនាងត្រូវទៅរក ពឹងអ្នកណា ប្តឹងអ្នកណា ដើម្បីរកយុត្តិធម៌ អោយបងប្រុសនាងបានទៅ?

ថ្ងៃនេះនាងបានយកអាហារទៅផ្ញើសុជាតិនៅឯបាត់ដំបង ដោយឱបយកសុធា ទៅជាមួយផង ត្បិតនាងតូចយំរកឪពុករកម្តាយខ្លាំងពេក ។ រីឯសុជាតិស្គមស្រក សាច់ច្រើនណាស់ ស្លេកស្លាំងហើយមានទឹកមុខស្រពាប់ស្រពោនអនេក ។ កាលបើ បានឃើញប្អូនស្រីនាំសុធាមកដល់ មាណពយើងមានសេចក្តីរីករាយក្រៃលែងប្រៀប ដូចជាកូនដំណាំដែលកំពុងត្រូវតំណក់ភ្លៀងដូច្នោះដែរ ។ នាយយើងស្ទុះទៅទទួល យកសុធាពីដៃសុខាយកមកពទាំងទឹកភ្នែករលីងរលោងដោយក្តីនឹករលឹក :

- ធា! ប៉ានឹកកូនអ្វីម្ល៉េះទេ! ហើយក៏នឹកម៉ាក់របស់កូនជាអនេកដូចគ្នាដែរ..

សុជាតិអោបកូនសំរក់ទឹកភ្នែក... ជាលើកដំបូងបង្អស់ក្នុងជីវិតរបស់នាយ តាំង តែពីធំពេញវ័យមក ។ នៅគ្រាដែលបែកពីនីម នាយគ្រាន់តែពិបាកចិត្តបន្តិចបន្តួច ហើយក៏អាចកាត់ចិត្តបន្លប់បានវិញដោយងាយ ។ ប៉ុន្តែចំពោះឈូកវិញ នាយទប់ចិត្ត ថា មិននឹក មិនអាណិត មិនស្រលាញ់ឈូកមិនបានទេ ។ នោះគឺជាតំណក់ទឹកភ្នែក នៃសេចក្តីសោកស្តាយ ដែលនាយយើងគ្មានសមត្ថភាពនឹងជួយឈូកបានហើយក៏ជាសេចក្តីអាណិតយ៉ាងធំធេងចំពោះសុធាជាកុមារីតូចមួយដែលត្រូវព្រាត់ពីម្តាយធ្លាប់ រស់នៅនៃបនិត្យបីបមរាល់ថ្ងៃ ។ ហើយពេលនេះទៀតក៏គ្មាននរណាដឹងដែរថា នាង តូចមានវាសនាបានជួបម្តាយនាងវិញរឺ ឬក៏យ៉ាងណា ។ កាលដើមឡើយសុជាតិមិនដែលដឹងទេថា នាយលង់ខ្លួនលង់ចិត្តស្រលាញ់អាណិតឈូកក៏រិតណា... តែពេលនេះ នាយយល់ហើយនូវជំរៅចិត្តរបស់នាយថាស្រលាញ់ឈូកធំធេងរបៀបណា ។ ជីវិត របស់នាយពិតជាគ្មានន័យអ្វីតទៅទៀតឡើយ កាលបើឈូកត្រូវឃ្លាតចាកពីរង្វង់ ដៃរបស់នាយទៅ...

បើលោកនេះគ្មានរូបអូន

១. បើសិនលោកនេះគ្មានរូបអូន រៀមបងស្រពោនស្រពាប់ចិត្ត

CHANBOKEO.COM

រស់នៅខ្វះន័យឆាកជីវិត បេះដូងវិបរិតឥតឧបមា ។

២. បើសិនលោកនេះគ្មានរូបពៅ ហឫទ័យហ្មងសៅស្មើរមរណា
រស់នៅធ្វើអ្វីបាត់ស្នេហា ម្ចាស់ដួងចិន្ដាបងតែមួយ ។

៣. បើសិនលោកនេះបាត់រូបស្រី ទ្រូងញាប់ញ័រភ័យវែងវិតព្រួយ
បន់ព្រះរមណីសូមលោកជួយ ប្រណីស្នេហ៍មួយដ៏ស្មោះស្មគ្រ័ ។

៤. បើសិនលោកនេះព្រាត់លែងវិល បងសូមកាន់សីលបួសជូនអ្នក
បេះដូងបងមួយជូនវរលក្ខណ៍ លុះជាតិថ្មីជាក់ជួបរៀងអើយ ។

វីឯនាងតូចសុធាវិញក៏គួរអោយអាសូរណាស់! គ្រាន់តែបានដល់ដៃសុជាតិ កាលណា ស្រាប់បាត់យំឈឺងភ្លាម ហើយក៏ប្រលែងសើចលេងជាមួយសុជាតិយ៉ាង រអើក ដូចដែលនាងធ្លាប់ប្រលែងលេងជាមួយរាល់ថ្ងៃតាំងពីដើមមក ។ បន្ដិចក្រោយ មក សុជាតិក៏សួរទៅសុខាថា :

- ម៉ែគាត់សុខសប្បាយទេអូន?
- គាត់មិនអីទេ គ្រាន់តែពិបាកចិត្តព្រោះរកលុយមកលោះបងមិនបាន...
- ហ៊ឹ! បើដូច្នេះ តើយើងត្រូវធ្វើដូចម្ដេចទៅ?
- ម៉ែថាបើទាល់ច្រក គាត់នឹងលក់ដីចំការចេករបស់យើងហើយ
- កុំអី! បើលក់អស់ តើយើងមានអ្វីនៅសល់ជាដើមទុនទឹងរស់តទៅទៀត? ប្រាប់ ម៉ែទៅកុំលក់អី! យើងគួរទៅទទួចអង្វរគេសាកមើល ក្រែងគេចុះថ្លៃពន្ធអោយខ្លះ
- ចាំស! ចាំខ្ញុំសាកល្បងមើលចុះណាំបង ។

មុននឹងសុខាបែកទៅផ្ទះវិញ សុជាតិក៏ផ្ដាំជាចុងក្រោយថា :

- សុខា! បើអូនមានដំណឹងពីឈ្នួក ប្រាប់បងផងណាំ! បងពិតជានឹកគេណាស់!....

សុខាអាណិតបងប្រុសខ្លោចចិត្ត ហើយក៏លានាយចេញមកវិញទាំងបេះដូង សោកសៅ ។ តាមផ្លូវ នាងជិះកង់ឆ្លងស្ពានថ្មទៅទិសខាងលិច កាត់ហាងលក់ទំនិញ នានា ស្រាប់តែឮសំលេងចំរៀងយ៉ាងពិរោះគួរជាទីចាប់អារម្មណ៍ចេញពីហាងស៊ីឌី មួយ ។ ដោយហេតុនាងជាអ្នកចូលចិត្តចំរៀងតាំងពីកំណើតស្រាប់ផង ក៏ឈប់កង់ ឈរស្ដាប់នៅមុខហាង ស្រាប់តែមានបុរសម្នាក់ក្រលេកមក មើលមុខនាងមិនលែង សោះ ។ មួយស្របក់ក្រោយមក បុរសនោះក៏ដើរចេញពីហាង សំដៅមករកសុខា ព្រមទាំងពោលថា :

- នាង! អោយពូសូមសួរមួយបានទេ ? តើនាងឈ្មោះសុខាដែលប្រលងចំរៀងបាន រង្វាន់លេខមួយ កាលពីថ្ងៃមុននោះមែនទេហ៎?

សុខាភ្ញាក់ព្រើត មិនដឹងថាត្រូវឆ្លើយថាយ៉ាងម៉េច ក៏នៅរេរា ស្រាប់តែបុរស ចំណាស់នោះមានប្រសាសន៍បន្តថា :

- ដឹងទេហ៎ ថាពូកំពុងស្រាវជ្រាវរកនាងប៉ុន្មានថ្ងៃហើយ ត្បិតមានទស្សនិកជនជា ច្រើនគេពេញចិត្តនឹងសំលេងរបស់នាង ហើយគេបានទូរសព្ទ័ទទូចសុំអោយពូស្វែង រកនាងមកច្រៀងឡង់សេបទថ្មី១ ខ្លះដាក់ស៊ីឌី និងឌីវីឌីរបស់ក្រុមហ៊ុនយើង ។

ពុទ្ធោអើយ! សុខាឮហើយអរហើបជើងពីដីតែម្ដង តែខំធ្វើឫកហាក់ដូចជា មិនសូវជាចាប់អារម្មណ៍សោះឡើយ ។ នាងក៏ឆ្លើយវិញថា :

CHANBOKEO.COM

- ខ្ញុំឈ្មោះសុខាមែន តែចំពោះការហាត់ច្រៀងយ៉ាងពិរោះរបស់ខ្ញុំត្រូវពឹងមនុស្ស ពីររូបទៀត បើមិនដូច្នោះ ខ្ញុំមិនអាចជួយលោកពូបានទេ ។ អីលូវខ្ញុំមានធុរៈមាន ទុក្ខក្នុងគ្រួសារ ពុំមានអារម្មណ៍មូលសំរាប់ច្រៀងចំរៀងអ្វីទេ។

តែចំលើយនោះមិនបានធ្វើអោយបុរសចំណាស់អាក់ទឹកចិត្តទេ ផ្ទុយទៅវិញ លោកបែរជានិយាយថា :

- ពូនេះឈ្មោះសមបុណ្យ ជាម្ចាស់ផលិតកម្មការ៉ាអូខេផលិតស៊ីឌីនិងឌីវីឌី ។ តើនាង អាចទុកចិត្តបានហើយនៅថាពូមិននិយាយលេងទេ ហើយសូមនាងនិយាយប្រាប់ ពូមកមើលពីធុរៈរបស់នាងក្រែងលោពូជួយនាងដោះស្រាយបាន។

- អញ្ចឹងលោកពូអញ្ជើញទៅជួបម្ដាយខ្ញុំនៅឯផ្ទះបានទេហ៎?

នៅភូមិត្រាង ថ្ងៃដដែល....

- ម៉ែ! លោកសមបុណ្យម្ចាស់ផលិតកម្មការ៉ាអូខេ មកលេងនឹងម៉ែហ្នែក៎!!

- អើៗ កូនអើយ! តើ.. លោកសមបុណ្យមានការអ្វីជាមួយម៉ែទៅកូន?

- ម៉ែមើលនេះ!.... លោកនាំអ្នកណាគេមកជាមួយដែរហ្នែក៎!!

- ឱ្យម៉ែទៅដឹងកើត បើម៉ែមើលមិនឃើញផង...? តើជានរណាទៅកូន?

- ម៉ែទាយទៅមើល ថាម៉ែកំពុងគិតហើយបារម្ភពីនរណាជាងគេ?

- ហ្អាស់! កូនជាតិ?... អាង៉ាកូនម៉ែ.... ឯងរួចពីការឃុំឃាំងហើយឬកូន?

- បាទ! ម៉ែ... កូនរលឹកម៉ែណាស់ ។

សុជាតិស្ទុះទៅជិតក្រាបសំពះម្ដាយដល់ធរណី :

- កូនពិតជាមានសំណាងណាស់ដែលបានមកជួបម៉ែវិញថ្ងៃនេះ ។

មីងសោមស្រវាអោបកូនដោយក្ដីនឹករលឹក យំផងសើចផងលាយឡំគ្នា។ មីង យើងរំភើបរហូតដល់ទៅនិយាយស្ដីលែងរួចតែម្ដង ។ បន្ទាប់មកលោកសមបុណ្យក៏ ជំរាបទៅមីងសោមថា :

- ខ្ញុំបានជួបនាងសុខា នៅឯបាត់ដំបង ហើយកំពុងបបួលនាងទៅច្រៀងអោយក្រុម ហ៊ុនថតចំរៀងការ៉ាអូខេរបស់ខ្ញុំ។ ថ្ងៃដន្យនាងក៏សុំពឹងអោយខ្ញុំទៅជួយលោះបង ប្រុសពីមន្ទីរឃុំឃាំងដោយសុំបើកប្រាក់កំរៃមុន។ ដំបូងខ្ញុំគិតថាខ្ញុំនឹងយកលុយទៅ លោះពិតមែន តែលុះដល់នាងនាំខ្ញុំទៅជួបបងប្រុសនៅកន្លែងឃុំខ្លួនទើបដឹងថា ពពួកអ្នកដែលឃាត់ខ្លួនសុជាតិទាំងនោះជាអ្នករកស៊ីគៃបន្លំខុសច្បាប់ទេ។ ការពិត សុជាតិមិនមានដីការអ្វីត្រឹមត្រូវពីតុលាការសំរាប់ចាប់ខ្លួនគេសោះឡើយ ។ ពួកគេ ទាំងនោះធ្វើបំពានដើម្បីជំរិតរកលុយចាយផ្ទាល់ខ្លួន សំរាប់ក្រុមគេដ៏តូចមួយនោះ តែប៉ុណ្ណោះ។ បន្ទាប់មកខ្ញុំទៅជួបហើយសុំពឹងអ្នកស្របច្បាប់អោយគេជួយ ទើប តុលាការធ្វើដីការចាប់ពួកទាំងនេះយកទៅផ្ដន្ទាទោស ហើយដោះលែងឱ្យសុជាតិ រួចមកវិញដោយមិនបាច់អស់ប្រាក់ថ្លៃលោះខ្លួន សូម្បីតែមួយកាក់ក៏អត់ដែរ។ រីឯ ក្រុមមនុស្សចាប់ជំរិតមួយក្រុមនោះ ក៏ត្រូវនគរបាលគេឃាត់ខ្លួនទុកបាត់អស់ ហើយ។ តាមពិតក្រុមចាប់ជំរិតទាំងនោះកំប៉ិកកំប៉ុកទេ ព្រោះគេធ្វើបាបតែអ្នកក្រ ល្ងង់ខ្លៅ។ សំណាងល្អដែរ ដែលក្រុមប៉ូលិសគេចេញប្រតិបត្តិការបោសសំអាតទាន់ ចិត្ត កុំអីក្រុមគ្រួសារមីងវេទនាធំហើយ ។

មីងសោមយកដៃរឹតទ្រូង :

CHANBOKEO.COM

- អរគុណណាស់ព្រះអើយ! អ្នកស្រុកជនបទតូចទាបដូចជាពួកយើង មិនស្គាល់ថា នរណាជាអ្នកកាន់ច្បាប់ នរណាជាជនឆ្លៀតឱកាសទេ។ អរគុណលោកណាស់ដែល មានចិត្តធម៌មេត្តាជួយដោះកូនប្រុសខ្ញុំអោយមានសុវត្ថិភាពឡើងវិញ។ ខ្ញុំមិនដឹង បានអ្វីសងគុណលោកទេ ក្រៅពីប្រមាមដៃជប់... សំពះអរគុណលោក...

មីងសោមមានប្រសាសន៍ផង ទឹកភ្នែកអួលដើមកផង លើកដៃសំពះផង។ លោកសមបុណ្យឃើញដូច្នោះក៏លើកដៃប្រណម្យតបវិញ :

- មិនមានជាគុណស្រ័យអ្វីទេមីង! យើងជាមនុស្សល្អ ព្រះលោកយាងតាមថែរក្សា គ្រប់ទីកន្លែងជានិច្ច !

បន្ទាប់មកលោកសមបុណ្យក៏មានប្រសាសន៍សុំសុខាយកទៅភ្នំពេញដើម្បីចូល ស្ទូឌីយោថតចំរៀង តែមីងសោមប្រកែកដាច់អហង្កា ។ ចំពោះសុជាតិវិញ ក្នុងបេះ ដូងក្នុងអារម្មណ៍របស់នាយ មានតែឈូកប៉ុណ្ណោះ ។ កាលបើឮថាសុខាអាចមាន លទ្ធភាពអាចទៅភ្នំពេញបាន នាយក៏ទទូចសុំម្តាយទៅភ្នំពេញជាមួយនាង ដោយ មានគោលបំណងចង់ទៅតាមរកឈូកផង។ ដោយហេតុថា សុជាតិមានទេព កោសល្យខ្ពស់ខាងផ្លុំខ្លុយនិងផ្លុំស្លឹកព្រមទាំងចេះនិពន្ធ បទភ្លេងបែបប្រពៃណីទៀត ផង លោកសមបុណ្យក៏ទទូចជួយសុំមីងសោមរហូតដល់គាត់ប្រកែកលេងបាន។ ណាមួយ មីងសោមក៏ស្រលាញ់ឈូកដែរ។ លុះឃើញកូនប្រុសរបស់គាត់ទទួលរង វិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ មីងក៏សំរេចចិត្តតាមកូនទាំងពីរទៅភ្នំពេញទាំងអស់គ្នា ដើម្បី អោយមានឱកាសតាមរកស៊ើបដំណឹងរបស់ឈូកជាទីស្រលាញ់របស់គ្រប់ៗគ្នា ។

នៅរាជធានីភ្នំពេញ...

លោកសមបុណ្យបានយកអ្នកទាំងបួនទៅផ្ញើនៅផ្ទះជួលមួយតូចនៅម្តុំទឹកល្អក់ ដែលមានគ្នីគ្នារបស់គាត់រស់នៅទីនោះជាច្រើន។ សុខានិងសុជាតិក៏ចាប់ផ្តើមធ្វើ សហការណ៍ជាមួយលោកសមបុណ្យ និងបុគ្គលិកប្រចាំក្រុមហ៊ុនជាច្រើនទៀតដើម្បី ផលិតបទចំរៀងល្បីៗជាច្រើន ថែមទាំងមានបញ្ចេញតាមខ្សែភាពយន្តដ៏ល្បីៗជា ច្រើនរឿង ធ្វើអោយកេរ្តិ៍ឈ្មោះរបស់អ្នកទាំងពីរកាន់តែល្បីរន្ទឺឡើងៗជាលំដាប់ ។ កាលវិភាគរបស់គេក៏ចេះតែរវល់ទៅៗរហូតរកពេលនឹងចេញស៊ើបដំណឹងអំពីឈូក មិនបានសោះ។ តាំងពីមកនៅភ្នំពេញ សុជាតិធ្វើការគត់មត់ក្រៃលែង តែគេក៏មិន ដែលភ្លេចនាងតូចសុធាកំព្រាម្តាយនោះដែរ។ រីឯសុខាវិញក៏បានក្លាយជាតារាដែល មានសំលេងមាសប្រចាំប្រទេសទៅហើយ ខុសតែនាងមានពិការភាពទើបមិនអាច ចេញបង្ហាញខ្លួននៅលើវេទិកាណាមួយបាន គឺបានត្រឹមតែថតសំលេងច្រៀងនិង បញ្ចូលសំលេងអោយខ្សែភាពយន្តឬការ៉ាអូខេតែប៉ុណ្ណោះ។ ទឹកដមសំនៀងរបស់ សុខាពេលនេះអាចចាត់ទុកបានថា មិនចាញ់តារាជើងចាស់នៅប្រទេសខ្មែរ នាគ្រា អតីតកាលឡើយ។ ដោយសារការប្រឹងប្រែងដ៏មោះមុតរួមផ្សំនិងទេពកោសល្យដ៏ វិសេសរបស់អ្នកទាំងពីរ និងដោយសារទឹកចិត្តសប្បុរសរបស់លោកសមបុណ្យដែល ជាចាងហ្វាងផលិតកម្ម ជីវភាពក្រុមគ្រួសាររបស់សុជាតិក៏កាន់តែមានដំណើរធូរ ស្រាលម្តងបន្តិចៗហើយ។ ទោះបីមានកាលខ្លះមីងសោមរអ៊ូចង់ធុញថប់នឹងជីវភាព អ៊ូអរនៅក្រុងភ្នំពេញក៏ដោយ ក៏មីងនៅតែខំប្រឹងសំរបសំរួលខ្លួនអោយងាយរស់ តាមរបៀបអ្នកភ្នំពេញដែរ។ នោះក៏ព្រោះតែមីងស្រលាញ់កូនទាំងពីរ ហើយមាន មោទនភាពខ្ពស់ណាស់ដែលគេទាំងពីរអាចឈានដល់កិត្តិល្បីបំផុត។

ថ្ងៃមួយ...

អ្នកទាំងបួនកំពុងតែរៀបចំបរិភោគអាហារថ្ងៃត្រង់ស្រាប់តែលោកសមបុណ្យ

CHANBOKEO.COM

នាំតារាវាំសិចស៊ីឈ្មោះម្លិះរូតនិងការីពីររូបទៀតមកដល់ ។ លោកសមបុណ្យឈាន ចុះពីឡានដើរសំដៅមករកសុជាតិនិង សុខាដោយទឹកមុខញញឹមពព្រាយ :

- សុជាតិ! ពូមានដំណឹងល្អមកប្រាប់ !

មាណពយើងភ្ញាក់ក្រញាង នឹកត្រេកអរថែមទាំងនឹកឆ្ងល់ផង :

- ព្រះអើយ! ខ្ញុំនឹងមានការធ្វើថែមទៀតហើយមែនទេហ៎បាទ?

- មែនហើយ! ម៉ោង៧កន្លះយប់នេះ ស្ថានីយទូរទស្សន៍មានបំណងចង់ជួបសម្ភាស ជាមួយអ្នកទាំងបីនាក់ដោយមានការផ្សាយបន្តផ្ទាល់ទៀតផង ។

- យើងទាំងបី? (សុជាតិលាន់មាត់) ជានរណាខ្លះទៅ?

- មានទៅនរណាទៀត? (ម្លិះរូតឆ្លើយ) គឺបងជាតិសុខាហើយនិងខ្ញុំ នោះអី!!

ទាំងសុជាតិ ទាំងសុខា ទាំងមីងសោម សុទ្ធតែបញ្ចេញអាការៈភ្ញាក់ផ្អើលបើក ភ្នែកធំ១ប៉ុនពងមាន់ទាំងអស់គ្នា ។ លុះឃើញដូច្នោះលោកសមបុណ្យក៏មាន ប្រសាសន៍ពន្យល់ថា :

- នេះជាឱកាលស្អសំរាប់អ្នកទាំងបីហើយក៏សំរាប់ក្រុមហ៊ុនរបស់យើងដែរ ។ ដឹងទេ ថាសព្វថ្ងៃ ផលិតកម្មរបស់យើងកំពុងមានប្រជាប្រិយភាពធំធេងណាស់ ។ ពូជឿ ថាលើកនេះ សុជាតិ សុខាព្រមទាំងម្លិះរូត ប្រាកដជានឹងឈានដល់កិរិតតារា កំពូលប្រចាំទសវត្សនេះមិនខានឡើយ ។

សុខាត្រេកអរហើបជើងពីដី ហើយក៏ងើបទៅសំពះលោកសមបុណ្យ :

- អរគុណលោកពូណាស់ដែលជួយជ្រោមជ្រែងពួកយើងរហូតមក ។ បើគ្មានលោក ពូទេ ជីវិតរបស់ពួកយើងក៏គ្មានថ្ងៃនេះដែរ ។

- អើ១! ពូដឹងហើយ! ឯងនិយាយអរគុណសំពះពូដូច្នោះរាល់ថ្ងៃឡើងពូចាំពាក្យ ឯងនិយាយអស់រលីងហើយ ។ នែស! បើស្រលាញ់ហើយគោរពពូមែន កុំភ្លេច សម្ភាសអោយបានល្អណា៎ ។

តែពេលនេះ សុជាតិហាក់ដូចជាមានអារម្មណ៍ពិភាល់ចំលែក យ៉ាងណាមិនដឹង ទេ ដូចជានឹកអរបន្តិច ភ័យបន្តិច ញាប់ញ័រក្នុងចិត្ត ព្រួយបន្តិច ខ្លាចខ្លួនធ្វើមិនបានល្អ នាំឱ្យខូចខាតដល់កត្តិយសផលិតកម្មទាំងមូល ។ ម្យ៉ាងទៀតនៅ ពេលរសៀល នេះជាវេនរបស់នាយដែលត្រូវសំរាក ដើម្បីមានឱកាសចេញទៅក្រៅ ស៊ើបសួររក គេហដ្ឋានរបស់លោកឧត្តមសេនីយសម្បត្តិ ។ ការពិតគោលបំណងរបស់នាយគឺ ស្វែងរកឈ្លូកម្ចាស់បេះដូងរបស់ខ្លួនតែប៉ុណ្ណោះ ។ តាំងពីឈានចូលប្រលូកក្នុង សង្គមសិល្បៈនៅក្រុងភ្នំពេញមក សុជាតិបានប្រទះនារីប្លែក១ច្រើនណាស់ តែក៏ មិនឃើញនារីណាម្នាក់ដែលអាចអង្រួនទងបេះដូងរបស់នាយឱ្យរំភើបញាប់ញ័រ សា ជាថ្មីសោះ ។ ទោះបីពេលនេះ នាយយើងបានក្លាយជាកវីនិពន្ធយ៉ាងល្បីល្បាញ ទៅហើយក្តី ក៏មាណពយើងមិនដែលទទួលភាពរីករាយក្នុងចិត្តរបស់គេបានពេញ លេញដែរត្បិតបេះដូងរបស់គេ កំពុងតែដង្ហោយហៅរកម្ចាស់ចិត្ត មកបំពេញ សំនៀងស្នេហ៍រីករាយរបស់គេអោយពេញលក្ខណៈមកវិញ ។ សូម្បីតែម្លិះរូតតារា វាំសិចស៊ីក៏មានចិត្តស្នេហ៍មកលើនាយមិនតិចដែរ ប៉ុន្តែសុជាតិមិនដែលនឹករវីរវល់ឬ បញ្ចេញកិរិយាណាអោយនាងមានក្តីសង្ឃឹមលើនាយឡើយ ។ តើហេតុអ្វីទៅហ្ន៎ ដែលចងចិត្តនាយយើងអោយជាប់ជំពាក់ចិត្តចំពោះឈ្លូកដល់ម្លឹង? ពេលនេះបំណង ដ៏ធំបំផុតរបស់សុជាតិ គឺប្រាថ្នាអោយនាងតូចសុធាបានរស់ជួបជុំនឹងម្តាយរបស់នាង វិញ ត្បិតអីទោះបីជាសុជាតិ មីងសោមឬសុខាបានផ្តល់នូវក្តី កក់ក្តៅសព្វបែបយ៉ាង ចំពោះនាងតូចយ៉ាងណា ក៏សុធានៅតែមានសេចក្តីសោកសៅជានិច្ច តាំងតែពីពេល

CHANBOKEO.COM

ដែលនាងព្រាត់ពីម្តាយមក។ សព្វថ្ងៃសុធាបានក្លាយជាក្មេងអង្គុយធ្មក់ៗស្ងៀមៗ ហើយឈ្ងោកមុខមិនសូវនិយាយស្តីឆ្លើយឆ្លងនឹងនរណា ដូចទំលាប់កាលពីតូចរបស់ នាងទេ។ មានកាលខ្លះ នាងយំរកម្តាយទាល់តែទន់ខ្លួនគេងលក់តែម្តង ទោះបី នរណាលួងក៏មិនបាត់ដែរ ។ សុជាតិអាល័យតែអង្គុយភ្លឹកពិចារណាតែម្នាក់ឯង ស្រាប់តែលោកសមបុណ្យទះស្មា ធ្វើអោយនាយភ្ញាក់ស្មារតីព្រើតមកវិញ :

- ជាតិ! រសៀលម៉ោងប្រាំពីរយប់នេះជួបគ្នានៅស្ថានីយ៍ទូរទស្សន៍ណា៎!

លោកសមបុណ្យក៏នាំតារាសិចស៊ីនិងការីរបស់លោកត្រលប់ទៅវិញ ។

នៅស្ថានិយ៏វិទ្យុទូរទស្សន៍ប្រចាំភ្នំពេញ....

សុជាតិមិនដែលបណ្តោយអោយម្តាយរបស់នាយ នៅផ្ទះតែពីរនាក់ជាមួយ សុធានោះឡើយ។ រាត្រីនេះ នាយនិងសុខាក៏នាំយកអ្នកទាំងពីរមកតាមដល់សាល វេទិកាសម្ភាសន៍តែម្តង ។ កម្មវិធីក៏ចាប់ផ្តើមឡើងដោយមានអ្នកស្រីនិសាជា អ្នកសម្ភាសន៍ ព្រមជាមួយស្នូរទះដៃយ៉ាងរំពងកក្រើកពេញសាលមណ្ឌល។

សុជាតិនិងសុខាមើលមុខគ្នាទៅវិញទៅមកទាំងចិត្តត្រេកអរផង រំភើបផង ថែមទាំងនឹកអស្ចារ្យក្នុងចិត្តដូចគ្នាថាមិនសមបើឡើយដែលគេទាំងពីរមានសំណាង ខ្ពង់ខ្ពស់បានមកអង្គុយទីនេះ ឆ្លើយឆ្លងនិងការផ្សាយបន្តផ្ទាល់តាមទូរទស្សន៍ជួប ជាមួយបងប្អូនរួមជាតិខ្មែរទាំងអស់ទូទាំងប្រទេស។ លោកសមបុណ្យអង្គុយមើល ពីកៅអីខាងក្រោមទៅដោយមានទឹកមុខញញឹមមិនដាច់សោះ ឃើញតែលោក ងក់ក្បាលដោយការពេញចិត្ត ចំពោះជោគជ័យរបស់អ្នកទាំងបី។ នៅឯខាង ក្រោយសាលសម្ភាសន៍ មីងសោមអង្គុយអោបចៅស្រីមុខទូរទស្សន៍មួយ ស្តាប់ ការសម្ភាសន៍របស់កូនគាត់ទាំងពីររូប។ គាត់នឹកត្រេកអរផងសង្វេគក្នុងចិត្តផងថា :

- ឈូកអើយ! តើពេលនេះ កូននៅឯណា? ដឹងទេថា យើងរាល់គ្នាកំពុងតែ នឹកកូនគ្រប់គ្នា ជាពិសេសគឺចៅធាតែម្តង ។ សូមបារមីព្រះអង្គសក្តិសិទ្ធិណែនាំឱ្យ កូនស្រីបានឃើញកម្មវិធីទូរទស្សន៍របស់យើង ហើយតាមមករកយើងនៅទីនេះ ឥលូវនេះផង! សាធុ!!

០០ ០០

០០!

CHANBOKEO.COM

# វគ្គទី១១
# ផ្កាយប្រលាក់ដី

ស្នូរទះដៃកក្រើកលាន់ឮសាជាថ្មីនៅក្នុងសាលសម្ភាសន៍....

ទស្សនិកជនក្រោកឈរអបអរសាជាថ្មី កាលបើបានស្តាប់សាច់រឿងរបស់តារា សុជាតិនិងនារីសោភាឈ្មោះក្រពុំចិត្តហៅឈ្លូកមកដល់ត្រឹមនេះ ជាពិសេសអបអរ ដែលគូស្នេហ៍យើងបានជួបគ្នាវិញ និងអបអរកុមារីសុធាបានជួបនឹងម្តាយរបស់នាង ក្រោយពីបែកឃ្លាតពីគ្នាអស់ជាងពីរឆ្នាំ។ សុជាតិកាន់ដៃឈ្លូកដោយទឹកមុខញញឹម បំព្រង ហាក់មិនខ្វល់នឹងទឹកមុខក្រញូវរបស់ឪពុកម្តាយរបស់នាងទៀតឡើយ។

រំពេចនោះស្រាប់តែដារិយ៉ាពោលឡើងថា :

- កុំទាន់ទះដៃអី! រឿងមិនទាន់ចប់ឯណា?

ទាំងពិធីករ ទាំងការីការងារ និងទស្សនិកជននៅទីនេះក៏ស្រាប់តែនាំគ្នាឈប់ ឈរទ្រឹងបើកភ្នែកត្រលួង។ ឃើញដូច្នោះ នារីយើងក៏ប្រែប្ញកពារអេះអុញទៅវិញ។ អ្នកស្រីនិសាហាក់ដូចជាយល់នូវអ្វីដែលដារិយ៉ាចង់សួរ ក៏មានប្រសាសន៍ជំនួសថា:

- មែនហើយ! រឿងរ៉ាវបានបកស្រាយអស់ហើយមែនតែនៅមានរឿងមួយដែល អ្នកនាងឈ្លូកនិងលោកសុជាតិមិនទាន់បកស្រាយ... នោះគឺប្រិយមិត្តចង់ដឹងថា តើ ភស្តុតាងដែលសំគាល់អត្តសញ្ញាណរបស់បុរស ដែលបំពានទៅលើឈ្លូកនោះនៅឯ ណា? តើគួរយើងទាំងអស់គ្នាដាក់ទោសគេយ៉ាងដូចម្តេច? ហើយចុះវាសនារបស់ នាងតូចសុធាតើយ៉ាងម៉េចវិញពេលដែលយើងរែកមុខបុរសទុរយសឃើញហើយ។

ភ្លាមនោះ លោកឧត្តមសេនីយសម្បត្តិក៏ឆ្លើយឃាត់ :

- ណ្ហើយចុះ! ឱ្យរឿងវាចប់ត្រឹមហ្នឹងចុះ! មិនបាច់ដោះស្រាយតទៅទៀតក៏បានដែរ

មើលទៅលោកសម្បត្តិ ហាក់ដូចជាចាប់ផ្តើមមានកិរិយាអាមាស ដែលរឿង រ៉ាវក្នុងក្រុមគ្រួសាររបស់លោកដែលកាន់តែរាលដាលវែងឆ្ងាយនោះហើយ។ តែអ្នក ស្រីដានីមិនអស់ចិត្តឡើយ។ អ្នកស្រីក៏មានប្រសាសន៍តទៅទៀតថា :

- តែខ្ញុំនៅចង់ឃើញភស្តុតាងដែលនៅសល់... រែកមុខបុរសឈ្លើងសង្គមដើម្បីចាប់ វាយកទៅដាក់ទោសអោយសមនឹងការប្រព្រឹត្តរបស់វា...

លោកសម្បត្តិលូកដៃទាញដាវអាវភរិយា ស៊ីញ៉ូអោយឈប់មាត់ក តែអ្នកស្រី មិនឈប់ទេ បែរជាដើរតាំង១ទៅរកឈ្លូក ហើយសួរថា :

- បើអ្វីដែលកូននិយាយមកនេះជាការពិត... ឱ្យម៉ាក់សុំឃើញភស្តុតាងនោះមក៏ បានទេ? ដឹងទេហ៏ថាប៉ារបស់កូនជាឧត្តមសេនីយ៏ មានអំណាចធំ១ ចាប់ពួកវា ដាក់ទោសប្រដៅវាបាន អោយវាទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរនៅក្នុងពន្ធនាគារយ៉ាង សក្តិសមបំផុត... ណាំកូន!!

កាលបើឮដូច្នោះ លោកវិសាលក៏ចូលទៅឃាត់ :

- បើប្រសិនជា លោកឧត្តមសេនីយ៏និងភរិយាសំរេចអោយលោកសុជាតិនិងអ្នក នាងក្រពុំចិត្តជួបជុំគ្នាវិញហើយ ចាំបាច់អីទៅកកាយរឿងវែងឆ្ងាយដល់ម្លឹង?

CHANBOKEO.COM

អ្នកស្រីដានីបើកភ្នែកមូលក្រលង់សំលឹងទៅលោកវិសាលៈ

- ហេតុអ្វីបានជាលោកមិនចង់ចាប់ជនដែលមានកំហុសដាក់ទោសដូច្នេះ?

- គឺ... គឺ.... (លោកវិសាលឆ្លើយមិនរួច)

អ្នកស្រីដានីក៏ពោលទៅកាន់អ្នកស្រីនិសាថា :

- បើអ្នកស្រីពិតជាចង់បានយុត្តិធម៌អោយឈូកនិងតារាមួយរូបនេះមែន សូមអ្នក ស្រីទូរសព្ទ៍ហៅប៉ូលីសមក... នឹងអាលបានវែកមុខចាប់យកបុរសនោះនៅវេលានេះ តែម្តងទៅ! នាងខ្ញុំអនុញ្ញាត្ត!

ទស្សនិកជនក៏ទះដៃប្រាវគាំទ្រភ្លាម ។ ឆ្លៀតឱកាសនោះ អ្នកស្រីនិសាក៏បែរ ក្រោយស៊ីញ៉ូទៅសហការីនៅខាងក្រោយវេទិកា ដើម្បីទាក់ទងទៅតម្រួតសន្តិសុខ ស្រាប់តែដារិយ៉ាស្ទុះទៅជិតឈូក ហើយហុចដៃទារ :

- អូនចិត្ត ! ឯណាភស្តុតាង? បងមិនចង់អោយម៉ាក់យល់ច្រលំទេ ថាបងវិសាលជា ឪពុករបស់ក្មេងស្រីមួយរូបនេះ!

មែនហើយ ពេលនេះទស្សនិកជនទាំងឡាយដកករង់ចាំមើល ស្ទើរមិនហ៊ាន ដកដង្ហើមទៅហើយថាតើចំលើយវាយ៉ាងម៉េចវិញ ។ ឈូកបែរមើលគ្រប់គ្នាទាំង អស់ក្នុងគ្រួសាររបស់នាង ហើយសំលឹងទៅលោកវិសាល រួចប៉េងឡុង រួចសុខា ហើយក៏បែរមកមីងសោមដែលនៅអង្គុយស្ងាត់ស្ងៀមឯជ្រុងជញ្ជាំង រួចក៏មានវាចា ឡើងទៅកាន់ទាំងអស់គ្នាថា :

- ឈូកត្រូវឃ្មៀបកម្មក្បៀបឈឺជាយូរមកហើយ! ដល់ពេលហើយដែលឈូកត្រូវរើ បំរះសុំសេរីភាពនិងសេចក្តីសុខពិតប្រាកដ.... សេចក្តីសុខដែលមនុស្សទាំងឡាយ គ្រប់ៗគ្នាតែងតែដង្ហោយហៅចង់បានជានិច្ច មិនថានៅក្នុងវណ្ណៈណាក៏ដោយ នោះ គឺសេចក្តីសុខ ដែលកើតឡើងពីសេចក្តីស្រលាញ់ថ្នាក់ថ្នម និងគុណធមិដែលឪពុក ម្តាយផ្តល់អោយមកកូនក្នុងគ្រួសារ... ប៉ុន្តែថៃដន្យ... ឈូកបានរស់នៅក្នុងភាពរងា កណ្តោចកណ្តែងឯកាជាយូរមកហើយ....

រួចហើយឈូកក៏បែរសំលឹងម្តាយនាងរួចស្រដីថា :

- កូនសូមអរគុណម៉ាក់ណាស់ ដែលបានអោយកំណើតកូន អោយកូនមានឱកាស បានស្គាល់ពន្លឺព្រះអាទិត្យនឹងគេ ក្រែងបានទទួលការកក់ក្តៅរូបកាយខ្លះៗ តែអនិច្ចា កូនបែរក្លាយជាមនុស្សសង្វេគចិត្ត....សង្វេគពន់ពេកទៅវិញ ដែលកូនពុំដែលបាន ទទួលពន្លឺរស្មីក្នុងជីវិតពីគ្រួសាររបស់យើង ដើម្បីអោយដួងចិត្តកូនបានទទួលការកក់ក្តៅម្តងណាឡើយ!...

រួចហើយនាងក៏បែរទៅលោកសម្បត្តិហើយវាចាឡើង បន្តថា :

- កូនក៏សូមអរគុណលោកប៉ាដែលបានផ្តល់កំណើតកូន... លោកជាមនុស្សដែលខ្ញុំ ស្រលាញ់បំផុត... ហើយ... ក៏ស្អប់បំផុតក្នុងជីវិតរបស់ខ្ញុំដែរ...

ឈូកខាំមាត់មិនសំរក់ទឹកភ្នែកទេ តែបែរជាសំលឹងតបទៅលោកសម្បត្តិវិញ ដោយលែងខ្លាចក្រសែភ្នែករបស់លោកទៀតហើយ ។ នាងឈរឈប់មួយស្របក់ មិនឮលោកប៉ារបស់នាងឆ្លើយយ៉ាងណា ក៏ញញឹមហើយសួរលោកថា :

- នៅពេលនេះ តើលោកប៉ាចង់មានប្រសាសន៍ជេរប្រដៅរូបកូនទៀតទេ? កូន ស្រីលោកប៉ាកំពុងត្រៀមខ្លួនទទួលការប្រៀនប្រដៅរបស់លោកប៉ាហើយ ។ ការពិត នៅពេលនេះ កូនមិនដែលបន់សូមអោយព្រះលោកយាងមកប្រោសកូនអកត្តញ្ញូដូច ខ្ញុំនេះម្តងណាឡើយ ។ ប៉ុន្តែ

CHANBOKEO.COM

បើសិនព្រះអង្គអាចយាងចុះមកប្រោសសត្វលោកបាន មែននោះ កូនសូមបែបទ់ប្រាថ្នាយាងព្រះមកប្រោសមនុស្សដូចលោកប៉ាជាជាង ក្រែងលោពេលដែលលោកប៉ាបានឃើញបានយល់ពន្លឺព្រះធម៌ទៅ លោកប៉ាអាចជំរុះ ចោលនូវកំរោលអវិចិយ៍ក្នុងដួងចិត្តរបស់លោកប៉ាបានខ្លះ...

- នាងចិត្ត! (ដារិយ៉ានិយាយកាត់) ហេតុអ្វីឯងនិយាយស្តីមើលងាយឪពុករបស់ខ្លួន ឯងដូចជាប្រេតអសុរកាយយ៉ាងនេះ?

តែឈ្យូកលែងខ្លាចបងស្រីនាងដូចមុនទៀតហើយ ។ នាងបែរសំលឹងដារិយ៉ា ហើយស្រដីយ៉ាងមុតតទៅទៀតថា :

- មនុស្សយើង កាលបើមិនចេះខ្មាសអៀន ចំពោះកំហុសនិងអំពើប្រព្រឹត្តដ៏មិនគួរ គប្បីរបស់ខ្លួនឯងហើយ ទោះបីមានព្រះយាងមកប្រោសរូបយើង ក៏មិនអាចជួយ រំដោះយើងអោយរួចអំពីបាបកម្មរបស់ខ្លួនយើងដែរ តើបងដារិយ៉ាយល់មួយឃ្លានេះដែរឬទេហ៎?

ពូវាចារបស់ប្អូនស្រីដូច្នោះ ដារិយ៉ាថយក្រាក មិនហ៊ានតបទៅឈ្យូកវិញទៀត ទេ ។ មែនហើយ ពេលនេះ ឈ្យូកហាក់ដូចជាមានសេចក្តីក្លាហានចំលែកណាស់ មិនដូចឈ្យូកដ៏ទន់ខ្សោយកាលពីមុននោះឡើយ ។ នាងបែរសំលឹងទៅសុជាតិរួច ហើយក៏បែរទៅ លោកសម្បត្តិ ទើបនិយាយបន្តថា :

- កាលបើបុរសម្នាក់នេះ នឹងក្រុមគ្រួសាររបស់គេ មានគុណចំពោះខ្ញុំនិងកូនយ៉ាង ធំធេងវាស់មិនបាន... ខ្ញុំត្រូវតែគោរពគេជាព្រះនៅក្នុងដួងចិត្តរបស់ខ្ញុំរៀងរហូតទៅ ក្នុងឱកាសដែលមនុស្សផ្សេងទៀតខិតខំប្រឹងសំដែងឫទ្ធិចង់អោយខ្ញុំទទួលថាជាព្រះក្នុងជីវិតរបស់ខ្ញុំ តែបែរប្រព្រឹត្តខ្លួនជាឃាតករសំលាប់ខ្ញុំនិងកូនស្រីដ៏តូចមួយនេះ អោយស្លាប់ទាំងរស់រួចទៅហើយ....

នាងស្រដីផង សំលក់ទៅឪពុកនាងផង ។ ឃើញធិតាស្រដីដៀមដាមដាក់ លោកសម្បត្តិទ្រាំមិនបាន ក៏ពោលតបទាំងកំហឹងទៅវិញថា :

- ក្រពុំចិត្ត! ឯងដូចជាមើលងាយឪពុកជ្រុលហួសហេតុពេកហើយណ៎!

- ចាំស! លោកប៉ា...? លោកប៉ាស្គាល់ពាក្យថា "ជ្រុលហួសហេតុ" ដែរមែនទេហ៎? មែនទេ លោកប៉ា?

- ឈប់មាត់! ថ្លើមនាងកាន់តែធំហើយតើហ៎...

- ដែលថ្លើមកូនធំនៅពេលនេះ តើមកពីអ្វីដែរ លោកប៉ាជ្រាបទេហ៎? នោះក៏គឺមកពី ការកៀបសង្កត់របស់ប៉ាអោយជីវិតរបស់កូនទាល់ច្រករហូតដល់ហ៊ានបែរក្រោយ ច្រានលោកប៉ាអោយដួលវិញហើយ... ឥលូវនោះលោកប៉ានៅចង់ដឹងទៀតដែរ មែនទេហ៎ ថាតើនរណាជាបុរសអវិចិយ៍បំពានរូបកូន? តើនរណាជាឪពុកដ៏អាប់ យសរបស់សុធា?... កន្លងមក លោកប៉ាធ្វើបាបកូនមិនអស់ចិត្តទេ នៅតាមធ្វើបាប នាងតូចសុធាដ៏តូចមិនដឹងក្តីនេះទៀត! តើលោកប៉ាមាននៅសល់ចិត្តជាមនុស្សខ្លះ ដែរទេហ៎? ឬក៏លោកប៉ាជាដុំថ្មចំលាក់ដែលគ្មានបេះដូង គ្មានអារម្មណ៍ អ្វីទាល់តែសោះនោះ?

លោកសម្បត្តិសង្រ្កឹតធ្មេញហើយក្តាប់ដៃយ៉ាងណែន ប៉ុន្តែចំលែកមែន! លើកនេះ លោកបែរជាមិនហ៊ានលើកដៃទះកំភ្លៀងឈ្យូកដូចគ្រាមុនៗ ដែលនាងធ្លាប់ និយាយតមាត់លោកឡើយ ។ មើលចុះ! ឈ្យូកឈរខមដាក់លោកសម្បត្តិដោយមិន ពព្រិចភ្នែកអ្វីបន្តិចសោះទំនងដូចជាមាណវីឆ្អែតចិត្តដល់កហើយ ។ បន្តិចមក នាងក៏ ដើរសំដៅទៅមីងសោមហើយលុតជង្គង់ចុះ :

- ម៉ែ! អោយកូនសូមថង់ខ្មៅរបស់កូនវិញបានទេហ៎?

- អឺៗ ម៉ែដាក់ជាប់ខ្លួនគ្រប់ពេល ដើម្បីទុកអោយកូន ពេលម៉ែបានជួបកូនវិញ នេ៎ះ នៅក្នុងកន្ត្រកម៉ែនេះនែហ៎!

មីងសោមក៏ទាញកន្ត្រកដាក់ឥវ៉ាន់របស់គាត់មកកកាយ រួចក៏យកថង់ខ្មៅមួយ មកហុចអោយឈ្យូក ។ លុះទទួលបានហើយ នាងក៏ដើរត្រលប់សំដៅទៅឪពុកនាង វិញ ។ ការីកាម៉ារ៉ាក៏រត់ព្រូឡើង ដើម្បីតាមថតមិនអោយបាត់ភស្តុតាងនិងសាច់ រឿង ។

CHANBOKEO.COM

លុះមកដល់ចំពោះមុខលោកសម្បត្តិហើយ ក្រពុំចិត្តក៏យកថង់នោះទៅគប់ ចំកណ្តាលទ្រូងរបស់ឪពុករបស់នាងផាច់ ដោយកំហឹងខ្លាំងក្លា ហើយស្រដីថា :

- កូនបានទទួលរងនូវទណ្ឌកម្មពីលោកប៉ាយូរហើយ តែគ្មានកូនណាឡើយនឹងហ៊ាន ធ្វើទណ្ឌកម្មលើលោកវិញទេ ជាពិសេសពេលដែលលោកប៉ាប្រព្រឹត្តខុសលើកូន... ខុសយ៉ាងធ្ងន់មិនគួរនឹងអភ័យទោសអោយបាន ថ្ងៃនេះ ពេលនេះ វេលានេះ! ក្រពុំចិត្តជាកូនលោកប៉ា សូមអញ្ជើញគ្រប់ៗគ្នានៅទីនេះធ្វើជាសាក្សីនិងជាចៅក្រម ដើម្បីដាក់ទោសលោកប៉ាចុះ! នេះ! សូមលោកប៉ាមើលឱ្យច្បាស់ទៅ! មើលទៅ! នេះហើយភស្តុតាង!!!!!

តែលោកសម្បត្តិបែរជាខំាធ្មេញមិនព្រមឈ្ងោករើសយកមកទេ ។ លោកនៅឈរទ្រឹងដូចរូបចំលាក់សំលឹងមុខក្រពុំចិត្តដោយមិនពព្រិចភ្នែកសោះឡើយ ។ អ្នកស្រីដានីឃើញដូច្នោះក៏អោនស្រវារើសថង់នោះឡើងយកមកស្រាយចំណងរួចក៏ដក កាបូបមនុស្សប្រុសមួយចេញមក ដោយមានភ្ជាប់ទាំងសញ្ញាផ្កាយមាសសំគាល់ ងារសំងាត់ក្នុងក្រសួងទៀតផង ។ អ្នកស្រីទាញយកអត្តសញ្ញាណនោះមកពិនិត្យរូបថតសំគាល់បុគ្គល ស្រាប់តែអ្នកស្រីបើកភ្នែកធំៗឡើងមូលក្រឡង់ ដូចពងមាន់ សំដែងកិរិយាហាក់មិនចង់ជឿភ្នែករបស់អ្នកស្រីឡើយ តែអនិច្ចា... ពេលនោះ ការីកាម៉ាវ៉ាបានថតជាប់ភស្តុតាងអស់ហើយ ទោះនឹងចង់យកលាក់ទុកវិញក៏ឥត ប្រយោជន៍ដែរ ។ ក្រោយពីប្រមូលស្មារតីបានវិញហើយ អ្នកស្រីក៏ស្រែកទ្រហោរ ឡើងយ៉ាងខ្លាំងហើយស្ទុះទៅវាយតប់លោកសម្បត្តិយ៉ាងញាប់ដៃ ព្រមទាំងឧទានឡើងភ្លាត់សំលេងថា :

- អាបិសាច! អាបិសាច! ឯងមិនត្រឹមតែរំលោភធ្វើបាបយើងទេ.. ឯងរំលោភកូនស្រីរបស់យើងទៀត... ឯងដឹងទេហ៎ថាឯងបានរំលោភកូនស្រីរបស់ខ្លួនឯង?.. យើងនឹងសំលាប់ឯងចោលអាបិសាចយង់ឃ្នង... យើងនឹងសំលាប់ឯងចោល!!

ទស្សនិកជនឮហើយក៏ស្ទុះក្រោកឈរឈ្ងេររងើឡើង សំដែងការភ្ញាក់ផ្អើល ។ ភាពជ្រួលច្របល់ក៏ចាប់កើតមានមួយរំពេចម្ល៉ោះហើយតម្រួតសន្តិសុខក៏ស្ទុះចូល មកដល់ធ្វើអន្តរាគមន៍ភ្លាមដែរ ។ គ្រានោះស្រាប់តែអធិការតម្រួតមួយរូបកាន់ដីការតុលាការមួយសន្លឹកមកដល់យ៉ាងរហ័ស ព្រមទាំងមានប្រសាសន៍ទៅកាន់ ទៅលោកសម្បត្តិថា :

- សូមទោសបាទ! ថ្ងៃនេះ ផ្កាយរបស់លោកត្រូវជ្រុះប្រលាក់ដីហើយ! នេះនែ៎! ដីការតុលាការសំរាប់ចាប់ខ្លួនលោកទៅឥលូវនេះ ដោយបុព្វហេតុធ្វើការឃុបឃិត ជាមួយមន្ត្រីពុករលួយ បន្លំឯកសារទិញបុណ្យសក្តិឧត្តមសេនិយយកមកបាំងបិទការរកស៊ីជួញដូរមនុស្សនិងរត់ពន្ធថ្នាំញៀន ។ ដីការបានចោទថាលោកគឺជាមេក្លោងម្នាក់ក្នុងចំណោមបុគ្គលដទៃទៀតដែលរដ្ឋាភិបាលកំពុងត្រូវការឃាត់ខ្លួន ដើម្បីទៅជូនចំលើយនៅសាលក្រម ។

គ្រានេះ លោកសម្បត្តិអស់អីនឹងនិយាយហើយ ក្រៅពីឈរភ្ញាក់ស្រលាំងកាំងចំពោះហេតុការណ៍ ដែលលោកត្រូវគេបកអាក្រាតរឿងសំងាត់ក្នុងជីវិតជាច្រើននៅ ចំពោះមនុស្សយ៉ាងកុះករ ។ ភ្លាមនោះស្រាប់តែអ្នកស្រីដានីទាញកាំភ្លើងខ្លីមួយ ពីក្នុងកាបូបដៃរបស់គាត់ ហើយក៏គាស់បាញ់ផាំងសំដៅប្រលោះភ្នៅរបស់លោកសម្បត្តិត្រូវពីរបីគ្រាប់ផ្ទួនៗគ្នា ។ លោកសម្បត្តិក៏ដួលប្រួសទៅដីក្នុងថ្លុកឈាមដង្ហក់ ដង្ហោយអនិច្ចារកជីវិតមួយរំពេច ។ ស្រាប់តែអ្នកស្រីដានីសើចកខឹកឡើង :

CHANBOKEO.COM

- សមមុខឯងណាស់ អាទុរយស! ថ្ងៃនេះកម្មតាមស្នងឯងវិញហើយ! ការពិត
យើងក៏បានរស់នៅវេទនាក្នុងក្រញាំដៃរបស់ឯងអស់រយៈជាយូរមកហើយ លម្មដល់ ថ្ងៃដែលយើងត្រូវស៊ីសងគ្នាម្តង មែនទេហ៎ា អាបិសាច!
ឯងមានដែលដឹងខ្លះទេហ៎ា ថាក្មេងស្រីអាយុ១៣ឆ្នាំត្រូវគេចាប់រំលោភធ្វើបាបរៀងរាល់ថ្ងៃនោះ វាវេទនាបែប ណា?  ទោះបីពេលក្រោយមក
ឯងយកយើងជាប្រពន្ធចេញមុខចេញមាត់ក៏ដោយ ក៏ឯងនៅតែបង្ខំយើងអោយទៅបំរើមនុស្សប្រុសដទៃផ្សេងៗ ដើម្បីអោយឯងឆ្លៀត
ឱកាសទាញស្រង់យកប្រយោជន៍សំរាប់មុខជំនួញជួញដូរ និងកត្តិយសបុណ្យសក្តិ មុខមាត់សំរាប់រូបឯង
សំរាប់ការសប្បាយនិងតម្រេករបស់ឯងតែម្នាក់ឯងប៉ុណ្ណោះ ។ ឯងដឹងទេថាយើងឈឺចាប់ណាស់ នឹងរកពាក្យអ្វីមករៀបរាប់ឱ្យសមស្មើ មិនបាន
ឡើយ ។ សមមុខឯងណាស់ដែលឯងចូលចិត្តបំពានធ្វើបាបស្រីក្មេងៗ!! ឥលូវ ឯងរំលោភបំពានប៉ះកូនស្រីបង្កើតរបស់ខ្លួនឯងហើយ!
សមមុខណាស់លោកអើយ! ហ៎ាសហា១ ពេលនេះតើឯងយល់ហើយនៅថាអារម្មណ៍របស់ឪពុកម្តាយវាឈឺចាប់ បែបណា
កាលបើដឹងថាកូនរបស់ខ្លួនត្រូវគេធ្វើបាបផ្លូវភេទ?....  យ៉ាងម៉េច ឆ្លើយ រួចទេហ៎ា? ឬក៏វាស្លាក់កទៅហើយ...?

លោកសម្បត្តិយកដៃអោបពោះដែលកំពុងតែឈាមសស្រាក់ រួចបែរសំលឹង
ទៅអ្នកស្រីដានី រួចសំលឹងទៅឈួក.. សំដែងទឹកមុខស្លូតស្រពោន... មែនហើយ! ពេលនេះ
លោកកំពុងតែចាប់ផ្តើមវន្ធត់តក់ស្លុតហើយមានវិប្បដិសារីក្នុងចិត្តណាស់ ចំពោះរឿងដែលលោកកំពុងតែប្រឈមមុខ ប៉ុន្តែ
ក្នុងមួយជីវិតរបស់លោកកន្លង មក លោកធ្លាប់តែមានឫកឆ្មើងឆ្មៃក្រអឺតក្រទម មានវណ្ណៈយសសក្តិឧត្តុង្គឧត្តម
ហើយក៏ចង្អុលគេប្រើមួយជីវិតទៅហើយ ពេលនេះ តើអោយលោកទៅហារមាត់សុំ ទោសគេវិញម្តេចនឹងរួចទៅ?
លោកសំលឹងទៅនាងតូចសុធា...មួយស្របក់មក ក៏លើកដៃបបោយហៅរកនាងខ្សាវៗ ប៉ុន្តែនាងតូចបាក់ស្បាតអារម្មណ៍តាំងពីឃើញ
លោកពីដំបូងមកម្ល៉េះ ។ កុមារីមិនហ៊ានចូលមកក្បែរលោកឡើយ ។ ភ្លាមនោះ ឈួកក៏រូសដៃកុមារីសុធាថយយ៉ាងឆ្ងាយពីលោកសម្បត្តិ ។
រីឯដារិយ៉ាក៏ឈរទ្រឹង ស្រលាំងកាំងភន្ត័ភាំងអស់ស្មារតី ចំពោះហេតុការណ៍ដែលនាងកំពុងឃើញអំបាញ មិញនេះ ។ មើលចុះ!
សូម្បីតែអ្នកស្រីដានីទាញកាំភ្លើងបាញ់លោកសម្បត្តិអស់បី គ្រាប់ទៅហើយ តែក៏គ្មាននរណាចេញមុខឃាត់អ្នកស្រីម្នាក់ឡើយ ។ ឯតម្រួត
សន្តិសុខដែលនៅក្បែរនោះ ក៏ឈរធ្វើមុខមឹងមាំងដូចគ្នាទាំងអស់ ។ នៅទីបំផុត លោកសម្បត្តិក៏ដាច់ចិត្តមានប្រសាសន៍ជាចុងក្រោយ ខ្សាវៗថា :
- អោយខ្ញុំសុំនិយាយជាមួយកូនរបស់ខ្ញុំបន្តិចបានទេហ៎ា?...

ទាំងអស់គ្នាឮហើយក៏ឈរស្ងៀមស្ងាត់ឈឹង រង់ចាំស្តាប់លោកសម្បត្តិពោល បន្តទៅទៀតថា :
- ក្រពុំចិត្ត! អោយប៉ាសូមទោសផង ដែលកាលណោះប៉ាស្រវឹងជាតិញៀនបាត់សតិ ទើបវង្វេងមិនដឹងថាជារូបកូន...
ក្រោយមកប៉ាក៏មានចិត្តសង្ស័យដែរ ពេលប៉ាបាន ដឹងថាឯងលោតសំលាប់ខ្លួនពីបន្ទប់សណ្ឋាគារ តែប៉ាក៏មិនដែលហ៊ានសួរកូន... ណាមួយប៉ាខ្មាស
ណាមួយប៉ាក្រអឺតក្រទម មិនព្រមចុះចាញ់ការពិត ទើបប៉ាចេះតែ បំពានវៀងរហូតមក ។ នោះគឺដើម្បីលាក់មុខលាក់មាត់ដ៏អាស្រូវរបស់ប៉ា... ចិត្ត!
កូននិយាយត្រូវហើយ! ទោះបីជាព្រះចុះយាងប្រោស ក៏ប៉ាមិនអាចរួចពីបាបកម្មនេះ ដែរ ត្បិតអំពើរបស់ប៉ាវាធ្ងន់ធ្ងរនឹងលើកលែងអោយណាស់ ។
ពេលនេះ ប៉ាយល់ ហើយថាកូនមានអារម្មណ៍ឈឺចាប់ប៉ុណ្ណា! អហោសិកម្មអោយប៉ាផងណាំកូនណាំ! អហោសិកម្មផង.... ! ស្តាយណាស់...
ដែលប៉ាគ្មានឱកាសកែខ្លួនឡើងវិញ...!!
- ហួសពេលនឹងកែខ្លួនហើយលោកសម្បត្តិ ( អ្នកស្រីដានីស្រដីកាត់)  អាពាក្យត្រឹម
តែសុំទោសមួយម៉ាត់ វាមិនអាចលប់លាងបំបាត់ស្នាមដំបៅឈឺចាប់មួយជីវិតរួច មកហើយនោះបានទេ ។  ពេលនេះ យើងក៏មិនសំលាប់ឯងដែរ
គឺសំលាប់ត្រឹមតែ អវៈយវៈរបស់ឯងចោលអស់ នោះយើងក៏អស់ចិត្តហើយ ហ៎ាស១... អាបីសាចឯង លម្មទៅដេកស្លាប់នៅក្នុងគុកទៅ!!

លុះឃើញ អ្នកស្រីដានីកាន់តែវង្វេងស្មារតីធ្ងន់ធ្ងរឡើង ក្រពុំចិត្តក៏ស្ទុះទៅជិត ម្តាយហើយស្រវាអោបភ្លាម :

CHANBOKEO.COM

- ម៉ាក់! កូនដឹងណាស់ថាម៉ាក់មានការឈឺចាប់ថ្លែងមិនបាន ក៏ប៉ុន្តែសូមម៉ាក់កុំសង សឹកលោកប៉ាហើយបំផ្លាញដួងចិត្តរបស់ខ្លួនឯងធ្វើអ្វី។ កូនស្រលាញ់ម៉ាក់! មិនថា ម៉ាក់មានអតីតកាលយ៉ាងណាទេ កូននៅតែស្រលាញ់ម៉ាក់រៀងរហូតទៅ!!

អ្នកស្រីដានីញដូច្នោះ ក៏ស្រវាអោបកូនវិញហើយយំខ្សឹកខ្សួលឡើង បន្ធូរនូវ ភាពតានតឹងក្នុងចិត្តទាំងប៉ុន្មានចេញមកតាមតំណក់ទឹកភ្នែកយ៉ាងជោគជាំ។ ឃើញ ដូច្នោះ ដារិយ៉ាក៏ដើរមកជិតម្តាយហើយស្រវាអោបគាត់ដូចគ្នា :

- ម៉ាក់! ដារិយ៉ាក៏ស្រលាញ់ម៉ាក់ជានិច្ច! បើអត់ពីលោកប៉ាទៅ មានតែម៉ាក់ទេដែល ជាម្លប់ដល់កូន! សូមម៉ាក់រឹងប៉ឹងឡើង... កូនទាំងពីរពិតជាត្រូវការម៉ាក់ណាស់!!

អ្នកស្រីដានីក៏អោបកូនទាំងពីរញញឹមទាំងទឹកភ្នែក :

- អរគុណកូនណាស់! កូនសំលាញ់ម្តាយ! អរគុណណាស់!

ទាំងបីនាក់ស្រវាអោបគ្នាយ៉ាងណែន។ បន្ទាប់មកអ្នកស្រីដានីក៏លើកនាងតូច សុធាមកពហើយមានវាចាថា:

- ចៅស្រីរបស់ជីដូន! អោយជីដូនសូមទោសផងដែលជីដូនគិតមិនបានវែងឆ្ងាយ ធ្វើបាបចៅអោយរងទុក្ខជាយូរឆ្នាំ... ជីដូនពិតជាសោកស្តាយខ្លាំងណាស់។

តែសុធាមិនឆ្លើយថាម៉េចទេ គ្រាន់តែសំលឹងមុខអ្នកស្រីដានីដោយងឿងឆ្ងល់។ ភ្លាមនោះ ក្រុមតម្រួតសន្តិសុខក៏នាំខ្លួនលោកសម្បត្តិចេញទៅ។ ប៉ុន្តែមុននឹងអោយ គេនាំខ្លួនលោកទៅ លោកសម្បត្តិក៏បែរមកសុជាតិ ហើយនិយាយទៅកាន់នាយជា ចុងក្រោយថា :

- សុជាតិ! រូបកូនសក្តិសមជាតារាគំរូដល់ប្អូនៗជំនាន់ក្រោយ ពិតមែនហើយ។ ប៉ាសូមសរសើរហើយមានមោទនភាពបំផុតចំពោះសន្តានចិត្តរបស់កូន។ ពេលនេះ ប៉ាសូមផ្ញើក្រពុំចិត្តនិងនាងតូចសុធាជាមួយនឹងកូនផងណា!... ប៉ាសង្ឃឹមថាកូន ប្រាកដជាបំពេញនាទីនេះបានល្អប្រសើរជាងប៉ាឆ្ងាយណាស់! អភ័យទោសអោយប៉ា ផង...!..... អហោសិកម្មណាកូនណា !

លោកសម្បត្តិមានប្រសាសន៍ទាំងទឹកភ្នែករលីងរលោង។ បន្ទាប់មកនាយតំរួត សន្តិសុខពីររូបក៏ជួយគ្រាហ៏លើកយកលោកសម្បត្តិចាកចេញពីទីនោះទៅទុកអោយ អ្នកទាំងឡាយឈរមើលពីក្រោយស្ងាត់ស្ងៀមក្រៀមចិត្ត មិនដឹងថាគួរតែទះដៃ អបអរសាទរចំពោះគូស្នេហ៏ដែលបានជួបគ្នាវិញ ឬក៏ត្រូវចូលរួមការសោកសង្រេង របស់ក្រុមគ្រួសារមួយនេះទេ។ ទោះបីជាយ៉ាងណា ក៏ម្នាក់ៗនៅទីនេះមានអារម្មណ៏ ថា ល្ខោនជីវិតរបស់សុជាតិនិងក្រពុំចិត្ត នៅពេលនេះ កំពុងតែបោះជំហើរឆ្ពោះទៅ រកពន្លឺសុភមង្គលថ្មីមួយទៀតហើយ។

ភ្លាមនោះ ស្រាប់តែលោកសុជាតិដឹកដៃឈ្លូកនិងកូនដើរចុះពីវេទិកាសំដៅទៅ លោកសមបុណ្យ ដែលកំពុងអង្គុយស្ងៀមស្ងាត់មើលស្ថានការណ៏មកជាយូរហើយ។ សុជាតិក៏នាំឈ្លូកលុតជង្គង់ចុះ ហើយក្រាបក្បាលសំពះលោកដល់កំរាលឥដ្ឋតែម្តង :

- នែ៎! អ្នកទាំងពីរកំពុងធ្វើស្អីហ្នឹង? (លោកសមបុណ្យភ្ញាក់ដូចគេចាប់គ្រវែង)

សុជាតិងើបមុខឡើង ហើយឆ្លើយថា :

- លោកពូគឺជាព្រះដែលមកប្រោសជីវិតគ្រួសារខ្ញុំ និងនាំផ្លូវអោយខ្ញុំទទួលជោគជ័យ

CHANBOKEO.COM

សព្វបែបយ៉ាងក្នុងជីវិតរួមទាំងបុព្វហេតុដែលនាំអោយយើងទាំងពីរជួបគ្នានៅពេល នេះវិញដែរ ។ យើងទាំងពីរអ្នកសូមចូលខ្លួនមកសំដែងសេចក្តីកតញ្ញូចំពោះលោក...

លោកសមបុណ្យយកដៃទទួលការសំពះរបស់សុជាតិ ហើយមានប្រសាសន៍ កាត់សំដីរបស់សុជាតិទៅវិញថា :

- អឺៗ ដឹងហើយៗ! តែមិនបាច់អរគុណថ្វីទេ! ឯងជាមនុស្សល្អ មានសម្បទា មាន សន្តានចិត្តប្រពៃស្រាប់ ។ អំពើល្អទាំងនេះហើយដែលបាននាំផ្លូវអោយឯងបានទទួល នូវជោគជ័យក្នុងជីវិតរបស់ឯងណា៎! បើឯងគោរពស្រលាញ់ពូពិតប្រាកដមែន ចូរខំធ្វើអំពើល្អអោយច្រើនទៅ នោះជីវិតរបស់ឯងនឹងភ្លឺស្វាងជានិច្ច!!

00 00

00

CHANBOKEO . COM

# វគ្គទី១២
# ផ្កាយរះក្នុងមេឃថ្មី

នៅវត្តទឹកល្អក់....

សុជាតិនិងឈ្យូកដើរដឹកដៃនាងតូចសុធាសំដៅទៅកុដិតូចមួយ ដែលមានដូនជី មួយរូបគង់នៅទីនោះរង់ចាំ។ លុះទៅដល់ហើយ គេទាំងបីក៏នាំគ្នាក្រាបបង្គំដូនជី នោះភ្លាម។ ដូនជីឃើញហើយក៏ញញឹមយ៉ាងបំព្រង :

- អរគុណកូនទាំងពីរណាស់ដែលនាំចៅមកលេងជីដូនរាល់អាទិត្យ។ មើលទៅចៅ ធាហាក់ដូចជាមានសុខភាពមិនសូវប្រក្រតីសោះ ជីដូនមានចិត្តបារម្ភពីចៅណាស់។ សុជាតិ! ម្ដាយសូមផ្ញើសុធានិងកូនចិត្តផង ហើយម្ដាយក៏សូមអរគុណកូនប្រុសជា អតិបរមា ដែលម្ដាយបានឃើញកូនផ្ដល់សេចក្ដីសុខយ៉ាងពេញលេញបំផុតចំពោះគេ ទាំងពីរ....

សុជាតិងើបមុខឡើងនិយាយទៅកាន់ដូនជីវិញថា :

- បាទ! អ្នកម្ដាយ! អ្នកទាំងពីរជាបេះដូង ជាជីវិតរបស់កូនទៅហើយ! កូនត្រូវតែ ថែរក្សាឱ្យបានល្អរហូតតរៀងទៅ។

ការពិតនោះគឺជាអ្នកស្រីដានីដែលបានមករក្សាធមិជាដូនជីប៉ុន្មានខែមកហើយ គឺតាំងពីថ្ងៃដែលលោកសម្បត្តិចាកចេញពីជីវិតរបស់ពួកគេគ្រប់ៗគ្នាទៅ។ បន្តិច មក ដូនជីក៏មានវាចាទៅកាន់កូនស្រីថា :

- ថៃខ្លួនណាកូនចិត្ត! ពេលសំរាលកូនទីពីរហើយ កុំភ្លេចនាំគេមកលេងនឹងជីដូន របស់គេផង!

- ចាស! អ្នកម្ដាយ!

- ហើយចុះកូនមានដឹងហើយនៅថាជាកូនស្រីឬជាកូនប្រុស?

ឈ្យូកយកដៃស្ទាបផ្ទៃពោះរបស់នាង ហើយញញឹមឆ្លើយវិញថា :

- ចាស! លោកគ្រូពេទ្យប្រាប់ថាជាកូនប្រុស។

- អឺៗ ! សូមអោយគេប្រសូត្រមកក្លាយជាមនុស្សល្អដូចប៉ារបស់គេផងចុះ!

ឈ្យូកបែរសំលឹងទៅសុជាតិដោយសេចក្ដីរីករាយ :

- កូនក៏សង្ឃឹមថាអញ្ចឹងដែរ អ្នកម្ដាយ!

សុជាតិអង្គុយអោបសុធា លួចដៀងភ្នែកមើលទៅភរិយាដោយទឹកមុខញញឹម ហើយរំភើបចិត្តបំផុត កាលបើបានឮនាងវាចាដូច្នោះ។

រសៀលថ្ងៃដដែល....

- បងវិសាល! អោយដារិយ៉ាសុំនិយាយអ្វីជាមួយបងបានទេហ៎?

- តែបងគ្មានរឿងអ្វីត្រូវនិយាយជាមួយដារិយ៉ាទេ..

- បងវិសាល! ដារិយ៉ាពិតជាស្រលាញ់បង... ស្រលាញ់ណាស់! តែហេតុអ្វីក៏បងមិន បើកឱកាសអោយអូនបន្តិចសោះអញ្ចឹង?

CHANBOKEO.COM

- ដារិយ៉ា! បងប្រាប់ហើយតើហ៏ ថាបងពុំមានដួងចិត្តនៅសល់សំរាប់នារីណាទេ...

- បង! ហេតុអ្វីក៏បងបិទទ្វារបេះដូងជិតយ៉ាងនេះ? បងដឹងទេហ៏ថាដារិយ៉ាបាន ព្យាយាមកែចិត្តកែគំនិត ក៏គឺដើម្បីតែបងម្នាក់

តែ...ហេតុអ្វីក៏បងទទួលអូនមិន បាន? មែនហើយ! អតីតកាលរបស់ដារិយ៉ាពិតជាមានភាពល្អក់កករខ្លះ! ប៉ុន្តែតាំង ពីអូនបានជួបបងមក៏

ដារិយ៉ាក៏បានផ្លាស់ប្តូរខ្លួន កែជីវិតបច្ចុប្បន្នអោយបានល្អឡើង វិញ ដើម្បីសាងអនាគតល្អ ព្រោះអូនតែងតែសង្ឃឹមថា ថ្ងៃណាមួយបងនឹងយល់

អំពីចិត្តអូន... ប៉ុន្តែ យូរឆ្នាំមកហើយ បងនៅតែមិនយកភ្នែកមើលអូនដដែល...

- ដារិយ៉ា!.. អូនយល់ពាក្យថា "និស្ស័យ" ទេហ៏? ពេលនេះ និស្ស័យរបស់បង អាចទទួលអូនបានត្រឹមតែជាមិត្តប៉ុណ្ណោះ!

មិនអាចទៅរួចលើសពីនោះទៀតទេ....

ឮដូច្នោះ ដារិយ៉ាក៏ឈ្ងោកមុខស្រក់ទឹកភ្នែកច្រោក និយាយលែងរួចតែម្តង។

លោកវិសាលក៏បោះជំហានដើរចេញទៅ... ស្រាប់តែឈ្យូកនិងសុជាតិនាំកូនស្រីមក ដល់ល្មម។ ឈ្យូកចុះពីរថយន្តហើយញញឹមដាក់លោកវិសាល :

- បងវិសាលសុខសប្បាយជាទេហ៏?

- បាទ! ធម្មតាទេ! ជំរាបសួរសុជាតិ!

- បាទ! ជំរាបសួរលោកវិសាល! ចុះលោកសុខទុក្ខយ៉ាងណាដែរ?

លោកវិសាលមិនទាន់ឆ្លើយផង ស្រាប់តែឈ្យូកក្រលេកឃើញបងស្រីឈរ នៅក្បែរមាត់ទ្វារល្ងចជូតទឹក ភ្នែក ក៏សួរកាត់ភ្លាម :

- បងដារិយ៉ា! បងវិសាល! មានរឿងអ្វីនឹងគ្នាមែនទេ?

តែគេទាំងពីរនៅស្ងៀមមិនព្រមឆ្លើយទាំងអស់គ្នា។ ឈ្យូកក៏ស្ទុះទៅទាញដៃ លោកវិសាលអោយមកចាប់ដៃគ្នាជាមួយដារិយ៉ា :

- បងវិសាលចាំទេហ៏ ថាបងបានសន្យាជាមួយខ្ញុំ នៅពេលដែលបងជូនខ្ញុំទៅឯ បាត់ដំបងនាថ្ងៃមួយនោះ

ថាបងសុខចិត្តទទួលខ្លួនជាបងប្រុសរបស់ឈ្យូកម្នាក់?

លោកវិសាលងក់ក្បាល ។ ឈ្យូកក៏និយាយបន្តថា :

- បងដារិយ៉ាក៏ជាបងស្រីតែមួយរបស់ខ្ញុំដែរ ។ បើខ្ញុំសូមផ្ញើបងដារិយ៉ាជាមួយបង តើបងទទួលសំណូមពររបស់ប្អូនដែរឬទេ?

ពុទ្ធោអើយ! ម្តងនេះ លោកវិសាលនិយាយលែងរួចតែម្តង ត្បិតអីលោក ស្រលាញ់ឈ្យូកណាស់ ទោះបីជាពេលនេះ

នាងមានគូស្រកររួចហើយក៏ដោយ។

លោកអាចលះបង់អ្វីសព្វបែប ក៏គឺដើម្បីនាងដែរ។ លោកក៏ឆ្លើយវិញថា :

- អោយបងសុំឱកាសខ្លះបានទេហ៏ សំរាប់រំងាប់អារម្មណ៏ចាស់ៗ មុននឹងបងអាច

ចាប់ផ្តើមសាជីវិតស្នេហាជាថ្មីម្តងទៀត?

- បាន ចាំស! ពេលនេះបងសន្យាហើយណាំ ! ដូច្នេះ បងដារិយ៉ាត្រូវតែជានារី ទីមួយនៅក្នុងបញ្ជីឈ្មោះកំពូលធិតាប្រចាំដួងចិត្តរបស់បងដែរ...

ណាំ ណាំ!!

ថាហើយនាងក៏ចាប់ដៃអ្នកទាំងពីរលើកឡើង :

- បងទាំងពីរជាមនុស្សដែលខ្ញុំស្រលាញ់បំផុត! សូមកុំបែកគ្នាទៅណាអី.. អោយខ្ញុំ បានទទួលដឹងឮនូវសុភមង្គលក្នុងជីវិតរបស់បងទាំងពីរនាក់ផង

ណាំបងណាំ!

អ្នកទាំងពីរលួចមើលមុខគ្នាទៅវិញទៅមក... ហាក់ដូចជាកំពុងស្ទង់ទឹកចិត្ត រៀងៗខ្លួន តែក៏មិនឮនរណានិយាយអ្វី ប្រកែកអ្វីតទៅទៀតដែរ

ប្រហែលជាលោក

CHANBOKEO.COM

វិសាលកំពុងត្រិះរិះសំណូមពររបស់ឈូកហើយមើលទៅ...

នៅព្រះលានយន្តហោះពោធិចិនតុង....

នាងចឿនដើរដឹកដៃនាងតូចសុធាត្រឹក១ តាមក្រោយសុជាតិនិងឈូកដែល កំពុងទៅជូនដំណើរសុខានិងម្តាយឡើងយន្តហោះ។ នៅទីនោះ លោកសមបុណ្យ និងសហការីពីររូបទៀត កំពុងរៀបចំពិនិត្យក្រដាសស្នាមនិងសំបុត្រយន្តហោះ។ ឱ! តើសុខានិងមីងសោមកំពុងចេញដំណើរទៅណាហ្នឹង?

ភ្លាមនោះ សុជាតិនិយាយទៅកាន់ប្អូនស្រីថា:

- សុខា! អូនពិតជាមានសំណាងខ្ពស់ណាស់ដែលបានទទួលការអញ្ជើញពីប្រិយមិត្ត អ្នកស្តាប់អោយទៅសំដែងជាតារាចំរៀងកត្តិយសនៅរដ្ឋមិនីសូតា សហរដ្ឋអាមេរិក កុំភ្លេចទូរសព្ទ័មកប្រាប់ពីសុខទុក្ខរបស់ប្អូននិងម៉ែអោយបងបានដឹងផងណាំពេលអូន បានទៅដល់ស្រុកគេ! ម្យ៉ាងទៀត ចូរកុំសប្បាយភ្លេចខ្លួនអោយសោះ! សូមរក្សា កត្តិយសជាតារាគំរូជានិច្ចណាំប្អូនសំលាញ់តែមួយរបស់បង!

សុខាញញឹមពព្រាយ ហើយឆ្លើយឡើងថា :

- ចាំស! ប្អូននឹងធ្វើតាមពាក្យណែនាំរបស់បងជានិច្ច។

ឈូកដែលនៅឈរក្បែរនោះ ក៏កាន់ដៃមីងសោមហើយនិយាយផ្តែផ្តាំថា :

- ម៉ែ! ម៉ែមានដំណើរទៅអាមេរិក ក្នុងឋានៈជាអ្នកអាណាព្យាបាលរបស់សុខា ត្បិតនាងនៅក្មេងមិនទាន់ពេញអាយុ។ ពេលនេះ ទោះបីជាម៉ែសំលឹង មើលពិភព លោកមិនឃើញយ៉ាងណាក្តី តែកូនទាំងពីរទុកចិត្តម៉ែណាស់ថា ម៉ែពិតជាមាន ស្មារតីភ្លឺថ្លា រក្សាសុខាបានសុខជានិច្ច!

ឈូកស្រវាអោបម្តាយហើយ ក៏បែរមកសុខាស្រវាអោបប្អូនយ៉ាងណែនពេញ ដៃ រួចផ្តែផ្តាំថា:

- សុខា! បងធ្លាប់ឮថា មេឃនៅអាមេរិកខ្ពស់ហើយធំធេងណាស់។ កាលបើ អូនបានក្លាយជាតារារះនៅលើផ្ទៃមេឃនៃប្រទេសគេហើយ សូមប្អូនថៃរក្សាផ្កាយ របស់ប្អូនអោយនៅរៀងរះត្រចះលើមេឃរៀងរហូតទៅ... កុំអោយផ្កាយវិលធ្លាក់ ប្រលាក់ដីវិញអោយសោះ... ណាំអូនណាំ!

- ចាំសបង! សុខាពិតជាធ្វើបាន មិនអោយបងទាំងពីរខកចិត្តទេ! បងវិញក៏សូមថៃ រក្សាខ្លួនផង។ ខ្ញុំនិងម៉ែច្បាស់ជាត្រលប់មកវិញទាន់ពេលបងសំរាលកូនមិនខាន។

សុខាស្រដីផង ស្រវាអោបចង្កេះបងស្រីហើយដាក់ត្រចៀកផ្ទិបនឹងពោះរបស់ ឈូករួចស្រដីថា :

- សុខសប្បាយណាំក្មួយប្រុសសំលាញ់!

សុខានិងមីងសោមលើកសុធាថើបជាចុងក្រោយ ហើយក៏បែរដើរតាមក្រោយ លោកសមបុណ្យនិងសហការីឡើងយន្តហោះទៅ ទាំងដួងចិត្តសប្បាយផងព្រួយផង សប្បាយដោយមានសំណាងបានទៅឃើញស្រុកគេ តែក៏ព្រួយព្រោះត្រូវឃ្លាតស្រុក និងឃ្លាតសុជាតិ ឈូក និងនាងតូចសុធាដែលគេស្រលាញ់បំផុត។ សុជាតិក៏ស្រែក ក្ចកផ្តាំទៅលោកសមបុណ្យជាចុងក្រោយថា :

- លោកពូ! សុជាតិសូមផ្ញើសុខានិងម៉ែផង!

លោកសមបុណ្យញញឹមហើយលើកដៃវា :

- អឺ១ មិនអីទេ! ត្រៀមខ្លួនទៅ... ដើងក្រោយ ប្រហែលជាសុជាតិនិងបានចេញ ទៅតាមប្អូនពីក្រោយដែរហើយ...

CHANBOKEO.COM

ថាហើយ លោកក៏លើកដៃវា លាចេញទៅ ។

បន្តិចក្រោយមក... យន្តហោះក៏ផ្ទុកនាំរូបអ្នកទាំងអស់ឡើងទៅលើវេហាស៍ បាត់ស្រមោលទៅ ទុកអោយសុជាតិនិងឈ្យូកនៅឈរមើលទាំងចិត្តញាប់ញ័រ...

មួយអាទិត្យកន្លងទៅ...

នៅខេត្តបាត់ដំបង....

សុជាតិកាន់ដៃឈ្យូកចុះពីរថយន្តហើយកាន់ផ្កាមួយបាច់យ៉ាងស្អាតដើរតំរង់ទៅ កាន់ស្ថានអូរតាគី ។ នៅពីក្រោយអ្នកទាំងពីរ ច្រឿននិងសុធាដើរប្រលែងគ្នា សើច លាន់រអឺក ។ ឱ! តើគេកំពុងតែធ្វើអ្វីទៅ? ភ្លាមនោះ ឈ្យូកបានយកបាច់ផ្កា ទៅដាក់ផ្តេកលើក្បាលស្តានហើយអុជធូបបីសរសៃ រួចមកក៏លើកដៃប្រណម្យទាំង គូឡើង ។ សុជាតិ សុធា និងច្រឿនឃើញហើយ ក៏ប្រណម្យតាមទាំងអស់គ្នា ដែរ ។ ឈ្យូកបែរមើលទៅសុជាតិនិងកុមារីសុធាដែលជាកូនស្រី រួចក៏អោនក្រាបសំពះ ក្បាលស្តានបីដង ទើបបន្លឺវាចាថា :

- ពូសូហ្វ៍ឡានអើយ! ខ្ញុំពិតជាមិនស្គាល់ថាពូជានរណាទេ គ្រាន់តែខ្ញុំដឹងថាពូជា មនុស្សល្អមួយរូប ។ ពេលនេះ ខ្ញុំនឹងស្វាមីសូមចូលខ្លួនមកសំពះវិញ្ញាណក្ខន្ធ័របស់ពូ ដើម្បីឧទ្ទិសសូមអោយដួងវិញ្ញាណរបស់ពូបានទៅកាន់សុគតិភពផង ។ ក្មួយសូមអរ គុណពូណាស់ដែលនាំផ្លូវខ្ញុំហួតមកដល់ទីនេះ... អោយខ្ញុំបានជួបបុរសដ៏ល្អមួយ រូបទៀត ដែលបាននាំរូបខ្ញុំអោយទៅជួបពន្លឺរស្មីជីវិតសាជាថ្មី! បើជាតិក្រោយមាន

ពិតមែន សូមអោយខ្ញុំមានឱកាសបានសងគុណពូវិញកុំបីខាន!

ក្រោយពីអធិដ្ឋានរួចហើយ សុជាតិក៏នាំក្រុមគ្រួសារវិលមកដល់ភូមិត្រាង ដែលជាចំណុចចាប់ផ្តើមនៃជីវិតស្នេហារវាងគេទាំងពីររូប ។

នៅទីនោះ សុជាតិបានប្រទះឃើញមានជាងឈើបីបួននាក់ កំពុងតែចាប់ផ្តើម ជួសជុលផ្ទះចាស់របស់សុជាតិឡើងវិញ ។ សុជាតិឃើញហើយក៏ញញឹមឡើងហើយ

សួរទៅភរិយាថា :

- ឈ្យូក! អូនជួលជាងបីបួននាក់នេះអោយមកជួសជុលផ្ទះរបស់យើង មែនទេ?

ឈ្យូកឮហើយក៏ញញឹមពព្រាយ ហើយក៏តបវិញ :

- ផ្ទះយើងចាស់ទ្រុឌទ្រោមពេកហើយ ម្ល៉ោះហើយ អូនចង់ជួសជុលវាទុកទទួល ម៉ែនិងប្អូនរបស់យើង ពេលគេវិលពីអាមេរិកវិញណាំបង...!

- មែនហ្អេស? តើអូនមានបំណងត្រឹមប៉ុណ្ណឹងមែន? តែបងគិតថា... អូនត្រៀម លើសពីហ្នឹងទៅទៀតឯណោះ!

- ម៉េចក៏បងដឹងកើត ថាអូនមានគំនិតអ្វីពីលើហ្នឹងទៀត?

- ចឹក៏មិនដឹង... បងដឹងចិត្តប្រពន្ធរបស់បងជានិច្ច តែរហូតមក៏....

- ឥចឹង បើដឹងចិត្តប្រពន្ធរបស់បងពិតមែន ឥលូវប្រាប់អូនមក៏ថាអូនមានបំណង ជួលជុលផ្ទះនេះដើម្បីអ្វី...?

- អញ្ចឹងអូនមកតាមបងមក....

សុជាតិនាំឈ្យូកទៅដល់ស្តានឈើមួយ ដែលអ្នកទាំងពីរធ្លាប់ទៅអង្គុយសំយុង ជើង ទទះទឹកលេងក្នុងត្រពាំង សំលឹងមើលថ្ងៃលិចតែពីរនាក់ហើយ ហើយធ្លាប់បាន លួចសាសងពាក្យពេចន៍ស្នេហា តាមរយៈក្រសែភ្នែកផ្អែមល្ហែមទៅវិញទៅមកជា ញយដងថែមទៀតផង ។ មាណពយើងកាន់ដៃភរិយាសំលឹងទៅគង្គាថ្លាខ្យងហើយ

ក៏បន្លឺវាចាឡើងថា :

CHANBOKEO.COM

- ឈូក! អូនដឹងទេហ៏? នៅពេលណាដែលបងនឹកអូនម្តង១... បងតែងតែមកទី នេះ ឈរសំលឹងផ្កាឈូកហើយបែបន់ព្រះ សូមអោយផ្កាដែលកំពុងរីកនៅក្នុង ត្រពាំងនេះ ក្លាយជារូបអូន... ដើម្បីអោយបងបានឃើញភក្រ្ត័អូនសាជាថ្មី....

- ចំណែកឈូកក៏ដូចគ្នាដែរ.... ផ្ទះឯណា ក៏ពុំមានផ្តល់មួប់សុខដល់ឈូកអោយបាន ស្មើនឹងផ្ទះដ៏ចាស់ទ្រុដទ្រោមមួយនេះទេ... នៅទីនេះ ជីវិតរបស់អូនមានសុភមង្គល ភ្លឺថ្លាបំផុត ។

- ទើបអូនជួសជុលទីនេះ ត្បិតអូនមានបំណង ថែរក្សាអនុស្សាវរីយ៏ទាំងឡាយ ដ៏ ល្អ១ រវាងអូននិងបង...

ឈូកញ្ញដូច្នោះក៏ញញឹមឡើង :

- ចាស! ពិតហើយបង! ទីនេះ ជាកន្លែងដែលមានបុរសចិត្តធមិមួយរូបមក ស្មគ្រ័ទទួលដើមឈូកស្វិតស្រពោនមួយទង យកទៅដាំក្នុងទឹកត្រពាំងថ្មីអោយគេ មានជីវិតរីកស្រស់ល្អត្រកាលមកវិញម្តងទៀត យ៉ាងបំព្រង...

មាណវីក៏បែរភក្រ្ត័សំលឹងទៅគូម្ចាស់ចិត្តហើយពោលបន្តថា :

- ហើយបុរសនោះ គឺជាព្រះនៅក្នុងដួងចិត្តរបស់អូន ដែលបានមកប្រស់រូបអូន អោយមានទឹកចិត្តចង់រស់ ដើម្បីទទួលពន្លឺនៃសេចក្តីសុខ និងសេចក្តីសង្ឃឹមសាជាថ្មី ម្តងទៀត...

- បើសិនរូបគេជាព្រះនៅក្នុងចិត្តរបស់អូន... រូបអូនក៏គឺជាផ្កាឈូកដ៏បរិសុទ្ធមួយ ទងនៅក្នុងចិត្តរបស់បង ដែលរង់ចាំបំរើព្រះធមិ សាងអំពើល្អ និងរក្សាជីវិតអោយ មានសង្ឃឹមនិងមានសេចក្តីសុខភ្លឺថ្លាជានិច្ច.... រហូតតរៀងទៅ...

ពេលនោះ មាណវីយើងក៏មានវាចាចុងក្រោយទៅកាន់គូជីវិតរបស់នាងថា :

- ផ្កាយជីវិតរបស់អូន បានវង្វេងមេឃ មកធ្លាក់នៅក្នុងត្រពាំងភក់ឯភូមិត្រាង ក៏ពិតមែនហើយ តែអូនក៏មិនដែលនឹកសោកស្តាយម្តងណាដែរ ដែលបានមកកសាង ជីវិតថ្មីនៅទីនេះ ត្បិតអីត្រពាំងភក់នៅទីនេះ ពោរពេញទៅដោយអាកាសបរិសុទ្ធ មិនដូចជាមេឃាចាស់របស់អូន ដែលពោរពេញទៅដោយព្យុះភ្លៀងនិងឧស្មន័បំពុល ឥតឈប់ឈរនោះឡើយ...

គូស្នេហ៍ទាំងទ្វេហាឈរកាន់ដៃគ្នាសំលឹងទៅវេហាស៏ដ៏សែនខ្ពស់ឆ្ងាយ ហើយ ញញឹមទទួលនូវសេចក្តីសុខយ៉ាងល្អត្រកាល... ក្នុងជីវិតរបស់គេ...

ផ្កាយអម្រឹតផ្ចិតមេឃស្នេហ៍

| | | |
|---|---|---|
| ស. | ផ្កាយអូនវង្វេងបាត់ផ្ទៃមេឃ | ឱភាសង្វេគអស់សង្ឃឹម |
| | ចរគ្មានទីដៅលង់សន្លឹម | ចាកភាពញញឹមក្នុងជីវិត ។ |
| ប. | មេឃបងតូចទាបត្រឹមដំបូល | រហែករចល់ឥតបើគិត |
| | ជូនផ្កាយបានត្រឹមតែទឹកចិត្ត | អត្តខាត់ទ្រព្យពិតចិត្តបងមាន ។ |
| ស. | តែផ្កាយអូនស៊ូប្តូរកាយា | ក្លាយមកជាផ្កាឈូកក្រោមស្ពាន |
| | ដើម្បីទទួលភាពសុខសាន្ត | ដែនវារីស្ថានក្សេមក្សាន្តអង្គ ។ |
| ប. | យ៉ាងណាក៏ផ្កាយនៅភ្លឺផ្លេក | ស្រស់ថ្លាជានិច្ចយ៉ាងត្រចង់ |
| | ក្រោមដំបូលចាស់ខ្វះទ្រាយទ្រង់ | រះក្នុងចិត្តបងត្រកាលអើយ ។ |
| ស. | អរគុណមេឃស្នេហ៍ថៃផ្កាយស្រី | ឱ្យផុតអវិចិយ៏ទុក្ខឥតស្បើយ |
| | បានយល់នូវមួប់មេឃបងហើយ | ផ្កាយពៅត្រាណត្រើយរះជាថ្មី ។ |
| ប. | ទោះមេឃបងតូចទាបមិនសមសួន | ក៏ប្តូរថៃជូនផ្កាយចរណៃ |
| | មិនអោយវង្វេងសាជាថ្មី | មេឃថៃផ្កាយស្រីសុខរៀងទៅ ។ |

CHANBOKEO.COM

# ចប់

CHANBOKEO.COM